# កច្ចាយនូបត្ថម្ភកៈ

# ២

## Kaccāyanūpatthambhaka II

បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៥៨ គ.ស. ២០១៥

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# អក្សរសង្ខេប

## ប្រើក្នុងកច្ចាយនរូបត្ថម្ភកៈ

## ពីសមាសនិទ្ទេសរៀងដល់ឧណាទិនិទ្ទេស

| | | |
|---|---|---|
| ឯក. | គឺ | ឯកវចនៈ |
| ឧ. | គឺ | ឧត្តមបុរិសៈ |
| ឧ. | គឺ | ឧទាហរណ៍ |
| ក. អធិ. | គឺ | កត្តុរូបអធិករណសាធនៈ |
| ក. អបា. | គឺ | កត្តុរូបអបាទានសាធនៈ |
| ក. ក. | គឺ | កត្តុរូបកត្តុសាធនៈ |
| ក. កម្ម. | គឺ | កត្តុរូបកម្មសាធនៈ |
| ក. ករ. | គឺ | កត្តុរូបករណសាធនៈ |
| ក. ត. | គឺ | កត្តុរូបតស្សីលសាធនៈ |
| ក. សម្ប. | គឺ | កត្តុរូបសម្បទានសាធនៈ |
| កម្ម. អធិ. | គឺ | កម្មរូបអធិករណសាធនៈ |

| | | |
|---|---|---|
| កម្ម. កម្ម. | គឺ | កម្មរូបកម្មសាធនៈ |
| កម្ម. ករ. | គឺ | កម្មរូបករណសាធនៈ |
| កម្ម. សម្ប. | គឺ | កម្មរូបសម្បទានសាធនៈ |
| ប. | គឺ | បឋមបុរិសៈ |
| ពហុ. | គឺ | ពហុវចនៈ |
| ភា. ភា. | គឺ | ភាវរូបភាវសាធនៈ |
| ម. | គឺ | មជ្ឈិមបុរិសៈ |
| ស. ត. | គឺ | សមាសរូបតស្សីលសាធនៈ ។ |

ឯគ្រឿងសម្គាល់ មានន័យដូចបានពន្យល់ក្នុងនិទ្ទេសខាងដើមរួចហើយ ។

# បញ្ជីមាតិកា
## សមាសនិទ្ទេស ទី ៣

មាតិកានុក្រម ទំព័រ


កិច្ចនៃសមាស ២ យ៉ាង ........ ២៥៧
ឈ្មោះសមាស ៦ យ៉ាង ........ ២៥៧
កម្មធារយសមាស ........ ២៥៨
វិសេសនបុព្វបទ ........ ២៥៨
វិសេសនុត្តរបទ ........ ២៥៩
វិសេសនោភយបទ ........ ២៥៩
វិសេសនោបមបទ ........ ៣០០
សម្ភាវនបុព្វបទ ........ ៣០១
អវធារណបុព្វបទ ........ ៣០២
ទិគុសមាស ........ ៣០៣
សមាហារទិគុ ........ ៣០៤
អសមាហារទិគុ ........ ៣០៤
តប្បុរិសសមាស ........ ៣០៥
ទុតិយាតប្បុរិសៈ ........ ៣០៥
តតិយាតប្បុរិសៈ ........ ៣០៦
ចតុត្ថីតប្បុរិសៈ ........ ៣០៦
បញ្ចមីតប្បុរិសៈ ........ ៣០៧
ឆដ្ឋីតប្បុរិសៈ ........ ៣០៧
សត្តមីតប្បុរិសៈ ........ ៣០៧
ឧភយតប្បុរិសៈ ........ ៣០៨
ទ្វន្ទសមាស ........ ៣០៩
សមាហារទ្វន្ទៈ ........ ៣១០

ទំព័រ

អសមាហារទ្វន្ទ ........................................................ ៣១០
អព្យយីភាវសមាស........................................................ ៣១១
ឧបសគ្គបុព្វកៈ........................................................ ៣១២
និបាតបុព្វកៈ........................................................ ៣១២
ពហុព្វីហិសមាស........................................................ ៣១៣
ទុតិយាពហុព្វីហិ........................................................ ៣១៣
តតិយាពហុព្វីហិ........................................................ ៣១៤
ចតុត្ថីពហុព្វីហិ........................................................ ៣១៤
បញ្ចមីពហុព្វីហិ........................................................ ៣១៥
ឆដ្ឋីពហុព្វីហិ........................................................ ៣១៦
ឧបមាពហុព្វីហិ........................................................ ៣១៦
នបុព្វបទឆដ្ឋីពហុព្វីហិ........................................................ ៣១៧
ឆដ្ឋីភិន្នាធិករណពហុព្វីហិ........................................................ ៣១៨
សត្តមីពហុព្វីហិ........................................................ ៣១៩
សហបុព្វបទពហុព្វីហិ........................................................ ៣២១
ឯកសេសសមាស........................................................ ៣២២
វិគ្គហៈនៃសមាស (ក្នុងត្រៃលិង្គទាំង ២ វចនៈ).................. ៣២៤
ប្រធាននៃសមាស........................................................ ៣២៦

## តទ្ធិតនិទ្ទេស ទី ៤

ឈ្មោះតទ្ធិត ៣ យ៉ាង........................................................ ៣៣១
សាមញ្ញតទ្ធិត ១៥ យ៉ាង........................................................ ៣៣២
គោត្តតទ្ធិត ........................................................ ៣៣២
តរត្យាទិតទ្ធិត........................................................ ៣៣៥
រាគាទិតទ្ធិត........................................................ ៣៤១

ទំព័រ
ជាតាទិតទ្ធិត .................................................................. ៣៤៣
សម្ហូហាតទ្ធិត.................................................................. ៣៤៥
ឋានតទ្ធិត ...................................................................... ៣៤៦
ឧបមាតទ្ធិត .................................................................... ៣៤៨
និស្សិតតទ្ធិត................................................................... ៣៤៨
ពហុលតទ្ធិត.................................................................... ៣៤៩
សេដ្ឋតទ្ធិត..................................................................... ៣៥០
តទស្សត្ថិតទ្ធិត................................................................ ៣៥៣
បកតិតទ្ធិត..................................................................... ៣៥៧
បូរណាតទ្ធិត.................................................................... ៣៥៩
សំខ្យាតទ្ធិត.................................................................... ៣៦៤
វិភាគតទ្ធិត..................................................................... ៣៦៤
ភាវតទ្ធិត........................................................................ ៣៦៥
អព្យយតទ្ធិត.................................................................... ៣៦៥
ដំណើរលិង្គរបស់តទ្ធិត....................................................... ៣៧០
អាខ្យាតនិទ្ទេស ទី ៤
អាខ្យាត........................................................................... ៣៧៥
វិភត្តិ................................................................................ ៣៧៥
កាល................................................................................ ៣៨០
បទ .................................................................................. ៣៨៥
វចនៈ............................................................................... ៣៩១
បុរិសៈ.............................................................................. ៣៩១
ធាតុ................................................................................. ៣៩៣
វាចកៈ ............................................................................... ៤០០
បច្ច័យ............................................................................... ៤០៤
បែបបំបែកធាតុ .................................................................. ៤២១

## កិតកនិទ្ទេស ទី ៦

ទំព័រ

កិតក: ........................................................ ៤៩៩
នាមកិតក: .................................................. ៤៩៩
សាធន: ....................................................... ៥០០
បច្ច័យនៃនាមកិតក: ...................................... ៥១១
ឧទាហរណ៍ក្នុងកិត-បច្ច័យ ................................. ៥១២
ឧទាហរណ៍ក្នុងកិច្ច-បច្ច័យ ................................ ៥២៧
ឧទាហរណ៍ក្នុងកិតកិច្ច-បច្ច័យ ........................... ៥៣៤
កិរិយាកិតក: ................................................ ៥៦៦
វិភត្តិនិងវចន: .............................................. ៥៦៧
កាល ........................................................... ៥៦៨
ធាតុនិងវាចក: .............................................. ៥៧១
បច្ច័យនៃកិរិយាកិតក: .................................... ៥៧៣
ឧទាហរណ៍ក្នុងកិត-បច្ច័យ ................................. ៥៧៤
ឧទាហរណ៍ក្នុងកិច្ច-បច្ច័យ ................................ ៥៨០
ឧទាហរណ៍ក្នុងកិតកិច្ច-បច្ច័យ ........................... ៥៩០
កាល ៧ យ៉ាង .................................................. ៦១៥

## ឧណាទិនិទ្ទេស ទី ៧

ឧណាទិ ........................................................ ៦២១
បច្ចេកបច្ច័យ ................................................ ៦២១
ឧទាហរណ៍ដោយសង្ខេប .................................... ៦២២
បែបចងវិគ្គហ: (៤ យ៉ាង) .................................. ៦៣៨
សេចក្តីពន្យល់ដោយឡែក ................................. ៦៤០

# ក្បួនរូបសិទ្ធិវិធាន

ទំព័រ


រូបសិទ្ធិក្នុងសន្ធិ .......................................................... ខ

រូបសិទ្ធិក្នុងនាម.............................................................. ង

រូបសិទ្ធិក្នុងសមាស.......................................................... ជ

រូបសិទ្ធិក្នុងតទ្ធិត .......................................................... ដ

រូបសិទ្ធិក្នុងអាខ្យាត.......................................................... ណ

រូបសិទ្ធិក្នុងអាខ្យាត បែបអញ្ញាស.......................................... ត

រូបសិទ្ធិក្នុងកិតកៈ.............................................................. ទ

# សមាសធាតុទី ៣

# សមាសនិទ្ទេស ទី ៣

## សមាស

[១២៨] នាមសព្ទតាំងពី ២ បទឡើងទៅដែលបំប្រួញរួមចូលគ្នាជាបទមួយ ហៅថា "សមាស" ។ សមាសនោះ សម្ដែងដោយកិច្ចមាន ២ យ៉ាង គឺ លុត្តសមាស ១ អលុត្តសមាស ១ ។ សមាសដែលលុបវិភត្តិចេញ ហៅថា លុត្តសមាស ឧ.រាជបុត្តោ "កូននៃស្ដេច", មរណភយំ "ភ័យអំពីមរណៈ", វដ្ដទុក្ខំ "សេចក្ដីទុក្ខក្នុងវដ្ដៈ" ។

សមាសដែលមិនលុបវិភត្តិ ហៅថា អលុត្តសមាស ឧ. ឧរសិលោមោ "(បុរស) មានរោមត្រង់ទ្រូង" ទេវានមិន្ទោ "(ទេវរាជ) ជាធំជាងទេវតាទាំងឡាយ = (ព្រះឥន្ទ)", គវម្បតិ "ម្ចាស់នៃគោទាំងឡាយ" ។

សមាសបើសម្ដែងដោយឈ្មោះមាន ៦ យ៉ាង គឺ កម្មធារយៈ ១ ទិគុ ១ តប្បុរិសៈ ១ ទ្វន្ទ្វៈ ១ អព្យយីភាវៈ ១ ពហុព្វីហិ ១ ។

## កម្មធារយសមាស

[១២៩] នាមសព្ទពីរបទ ដែលមានវិភត្តិនិងវចនៈស្មើគ្នា បទ ១ ជានាមនាម ជាតួប្រធាន, បទ ១ ជាគុណនាម ឬ ជានាមនាម ជាតួវិសេសនៈ ឬក៏ជាគុណនាមទាំងពីរបទ មានបទឯទៀតជាប្រធាន, ដែលបំប្រួញចូលជាបទមួយ ហៅថា កម្មធារយសមាស, មាន ៦ យ៉ាង គឺ វិសេសនបុព្វបទ ១ វិសេសនុត្តរបទ ១ វិសេសនោភយបទ ១ វិសេសនោបមបទ ១ សម្ភាវនបុព្វបទ ១ អវធារណបុព្វបទ ១ ។

## វិសេសនបុព្វបទ

កម្មធារយសមាស ដែលមានបទវិសេសនៈនៅខាងដើម, មានបទខាងចុងជាប្រធាន ហៅថា វិសេសនបុព្វបទ ឧ. មហន្តោ - បុរិសោ > មហាបុរិសោ "បុរសធំ"(ផ្លាស់មហន្តជាមហា) ឧត្តមោ - បុរិសោ > ឧត្តមបុរិសោ "បុរសខ្ពង់ខ្ពស់", មហន្តំ-ផលំ > មហប្ផលំ "ផលធំ" (ផ្លាស់ មហន្ត ជា មហ), មហន្តំ-ទុក្ខំ > មហាទុក្ខំ "ទុក្ខធំ" ។

សមាសនេះ ជួនណាលោកលុបអក្ខរៈរបស់បទវិសេសនៈចេញខ្លះ ទុកឲ្យសល់នៅតែមួយតួខាងដើមក៏មាន ឧ. កុច្ឆិតា-ទិដ្ឋិ > កុទិដ្ឋិ "ទិដ្ឋិដែលបណ្ឌិតគួរខ្ពើម" បធានំ-វចនំ > បាវចនំ "ពាក្យជាប្រធាន = (ធម្មវិន័យ = ពុទ្ធសាសនៈ)" (ទីឃៈ ប ជា បា), សន្តោ-បុរិសោ > សប្បុរិសោ "បុរសរម្ងាប់ហើយ" ។

## វិសេសនុត្តរបទ

កម្មធារយសមាសដែលមានបទវិសេសនៈនៅខាងចុង,មានបទខាងដើមជាប្រធាន ហៅថា វិសេសនុត្តរបទ ឧ. បុរិសោ-ឧត្ត-មោ > បុរិសុត្តមោ "បុរសខ្ពង់ខ្ពស់", បុរិសោ-លាមកោ > បុរិស-លាមកោ "បុរសលាមក", នរោ-វរោ > នរវរោ "នរៈប្រសើរ" មនុស្សោ-ទលិទ្ទោ > មនុស្សទលិទ្ទោ "មនុស្សកម្សត់" ។

## វិសេសនោភយបទ

កម្មធារយសមាសដែលមានបទទាំងពីរជាវិសេសនៈ មានបទឯទៀតជាប្រធាន[១] ហៅថា វិសេសនោភយបទ ឧ. សីតញ្ច-ឧណ្ហញ្ច > សីតុណ្ហំ (ឋានំ) "(ទី) ត្រជាក់ផងក្តៅផង = (ទាំង

---

១ អញ្ញបទ ។

ត្រជាក់ទាំងក្តៅ)″, អន្ធោ ច-ពធិរោ ច > អន្ធពធិរោ (បុរិសោ) ‷(បុរស) ខ្វាក់ផងថ្លង់ផង = (ទាំងខ្វាក់ទាំងថ្លង់)″, ខញ្ជោ ច-ខុជ្ជោ ច > ខញ្ជខុជ្ជោ (បុរិសោ) ‷(បុរស) ខ្វកផងគមផង = (ទាំងខ្វកទាំងគម)″, កីសោ ច-ខុទ្ទកោ ច > កីសខុទ្ទកោ (បុរិសោ) ‷(បុរស) ស្គមផងតូចផង = (ទាំងស្គមទាំងតូច)″ ។

## វិសេសនោបមបទ

កម្មធារយសមាសដែលមានបទវិសេសនៈជាឧបមា ហៅថា វិសេសនោបមបទ, មាន ២ យ៉ាង តាមបទវិសេសនៈនៅខាងដើមនិងខាងចុង, ដែលមានបទឧបមានៅខាងដើម ហៅថា ឧបមាបុព្វបទ, ដែលមានបទឧបមានៅខាងចុង ហៅថា ឧបមានុត្តរបទ ។

## ឧបមាបុព្វបទ

សង្ខំ ឥវ-បណ្ឌរំ > សង្ខបណ្ឌរំ (ខីរំ) ‷(ទឹកដោះស្រស់) សដូចជាស័ង្ខ″, កាកោ ឥវ-សូរោ > កាកសូរោ ‷(បុរស) ក្លៀវក្លាដូចជាក្អែក″, ទិព្វំ ឥវ-ចក្ខុ > ទិព្វចក្ខុ ‷ចក្ខុដូចជាទិព្វ″ បេតោ ឥវ-មនុស្សោ > បេតមនុស្សោ ‷មនុស្សដូចជាប្រេត″ ។

## ឧបមានុត្តរបទ

នរោ-សីហោ ឥវ > នរសីហោ ‟នរៈដូចជាសត្វសីហៈ″, មនុស្សោ-បេតោ ឥវ > មនុស្សប្បេតោ ‟មនុស្សដូចជាប្រេត″, ញាណំ-ចក្ខុ ឥវ > ញាណចក្ខុ ‟ញាណដូចជាចក្ខុ″, បញ្ញា-បាសាទោ ឥវ > បញ្ញាបាសាទោ ‟ប្រាជ្ញាដូចជាប្រាសាទ″ ។

## សម្ភាវនបុព្វបទ

កម្មធារយសមាសដែល ក្នុងវិគ្គហៈ មានបទប្រកបដោយ ឥតិ-សព្ទ ជាសម្ភាវនៈ (គ្រឿងលើក, សរសើរ ឬ ស្មាន) នៅខាងដើម, មានបទខាងចុងជាប្រធាន ហៅថា សម្ភាវនបុព្វបទ ឧ. ខត្តិយោ (អហំ) ឥតិ មានោ > ខត្តិយមានោ ‟មានះថា (អញ) ជាក្សត្រិយ៍″, សមណោ-(អហំ)-ឥតិ-បដិញ្ញា > សមណប្បដិញ្ញា ‟សេចក្តីប្តេជ្ញាថា (អញ) ជាសមណៈ″, សត្តោ-ឥតិ-សញ្ញា > សត្តសញ្ញា ‟សេចក្តីសម្គាល់ថាសត្វ″, មំសំ-ឥតិ-សញ្ញា > មំសសញ្ញា ‟សេចក្តីសម្គាល់ថាសាច់″ ។

## អវធារណបុព្វបទ

កម្មធារយសមាសដែល ក្នុងវិគ្គហៈ មានបទប្រកបដោយ ឯវ-សព្ទ "សព្ទជាគ្រឿងឃាត់នូវសេចក្ដីឯទៀត" នៅខាងដើម, មានបទខាងចុងជាប្រធាន ហៅថា អវធារណបុព្វបទ ឧ. ពុទ្ធោ-ឯវ-រតនំ > ពុទ្ធរតនំ "កែវគឺព្រះពុទ្ធ", សទ្ធា-ឯវ-ធនំ > សទ្ធា-ធនំ "ទ្រព្យគឺសទ្ធា", បញ្ញា-ឯវ-បាសាទោ > បញ្ញាបាសាទោ(១) "ប្រាសាទគឺបញ្ញា", បញ្ញា-ឯវ-ចក្ខុ > បញ្ញាចក្ខុ "ចក្ខុគឺ-ប្រាជ្ញា" ។ (ឯវ ក្នុងវិគ្គហៈនៃសមាសនេះ មានន័យឲ្យប្រែថា "គឺ") ។

## សេចក្ដីរួបរួមបែបតាំងវិគ្គហៈ

ក្នុងកម្មធារយសមាសខ្លះ តាមបែបដែលលោកតាំងច្រើនយ៉ាង ដូចខាងក្រោមនេះ ៖

## វិសេសនបុព្វបទ

មហន្តោ-បុរិសោ > មហាបុរិសោ ។ មហន្តោ ច-បុរិ-សោ ច > មហាបុរិសោ ។ មហន្តោ ច សោ-បុរិសោ ច >

---

១ ការន្តក្នុងឥត្ថីលិង្គ ៣ តួគឺ អា, ឦ, ឩ នេះត្រូវទុកឲ្យនៅជាទីឃ-សរៈ តាមរូបដើម ។

មហាបុរិសោ ។ មហន្តោ ច-សោ-បុរិសោ ចា´តិ[១] > មហាបុរិសោ ។

## វិសេសនុត្តរបទ

បុរិសោ-ឧត្តមោ > បុរិសុត្តមោ ។ បុរិសោ ច-ឧត្តមោ ច > បុរិសុត្តមោ ។ បុរិសោ ច-សោ ឧត្តមោ ច > បុរិសុត្តមោ ។ បុរិសោ ច-សោ-ឧត្តមោ ចា´តិ > បុរិសុត្តមោ ។

## វិសេសនោភយបទ

សីតំ-ឧណ្ហំ > សីតុណ្ហំ ។ សីតញ្ច-ឧណ្ហញ្ច > សីតុណ្ហំ ។ សីតញ្ច-តំ-ឧណ្ហញ្ច > សីតុណ្ហំ ។ សីតញ្ច-តំ-ឧណ្ហញ្ចា´តិ > សីតុណ្ហំ (ឋានំ) ។

(អាចារ្យអ្នកបង្រៀន គួរនាំសិស្សប្រែវិគ្គហៈ ទាំងនេះផងចុះ) ។

## ទិគុសមាស

[១៣០] វិសេសនបុព្វបទកម្មធារយសមាសនុ៎ះឯង កាលបើមានសំខ្យាសព្ទជាបទវិសេសនៈនៅខាងដើម ក៏ត្រឡប់ឲ្យ

---

១ ច-សព្ទនិងឥតិ-សព្ទនេះ ដាក់មកយ៉ាងនេះក៏បាន មិនបាច់ដាក់មកដូចវិគ្គហៈខាងលើក៏បាន, ដែលដាក់មក ក៏គ្រាន់តែជានិបាតសព្ទរាំងឃ្លារបស់បទបុណ្ណោះ នឹងមានសេចក្ដីពិសេសអ្វីជាងដែលមិនដាក់មកនោះក៏ទេ ។

ឈ្មោះថា "ទិគុសមាស" វិញ ។ ទិគុសមាសនោះ មាន ២ យ៉ាង គឺ សមាហារទិគុ ១ អសមាហារទិគុ ១ ។

## សមាហារទិគុ

ទិគុសមាសដែលបំប្រួញនាមសព្ទមានសេចក្តីជា ពហុវចនៈ ធ្វើឲ្យជាឯកវចនៈនបុំសកលិង្គវិញ ហៅថា សមាហារទិគុ ឧ. តយោ-លោកា > តិលោកំ "លោកបី", ចតស្សោ-ទិសា > ចតុទ្ទិសំ "ទិសបួន", បញ្ច-ឥន្ទ្រិយានិ > បញ្ចិន្ទ្រិយំ "ឥន្ទ្រិយប្រាំ", ឆ-ទ្វារានិ > ឆទ្វារំ "ទ្វារប្រាំមួយ" ។

## អសមាហារទិគុ

ទិគុសមាសដែលមិនបំប្រួញនាមសព្ទឲ្យជាឯកវចនៈ នបុំ-សកលិង្គ ហៅថា អសមាហារទិគុ ឧ. ឯកោ-បុគ្គលោ > ឯក-បុគ្គលោ "បុគ្គលម្នាក់", ចតស្សោ-ទិសា > ចតុទ្ទិសា "ទិសបួនទាំងឡាយ", បញ្ច-ពលានិ > បញ្ចពលានិ "កម្លាំងប្រាំទាំង-ឡាយ", សត្ត-រតនានិ > សត្តរតនានិ "រតនៈ ៧ ទាំងឡាយ" ។

# តប្បុរិសសមាស

[១៣១] នាមសព្ទដែលផ្សំនឹងវិភត្តិនាមមានទុតិយាវិភត្តិជាដើម ហើយបំប្រួញរួមចូលជាមួយនឹងបទខាងចុងដែលមានវិភត្តិផ្សេងគ្នា ហៅថា តប្បុរិសសមាស, មាន ៦ យ៉ាង គឺ ទុតិយាតប្បុរិសៈ ១ តតិយាតប្បុរិសៈ ១ ចតុត្ថីតប្បុរិសៈ ១ បញ្ចមី-តប្បុរិសៈ ១ ឆដ្ឋីតប្បុរិសៈ សត្តមីតប្បុរិសៈ ១ ។ រាប់ឧភ-យតប្បុរិសៈ ១ ដែលមានដំណើរផ្សេងពីតប្បុរិសៈទាំង ៦ នោះបញ្ចូលមកផង ជា ៧ យ៉ាង ។

## ទុតិយាតប្បុរិសៈ

សុខំ-បត្តោ > សុខប្បត្តោ (ជនោ) "(ជន) ដល់ហើយនូវសេចក្ដីសុខ", គាមំ-គតោ > គាមគតោ (បុរិសោ) "(បុរស) ទៅហើយកាន់ស្រុក", អរញ្ញំ-គតោ > អរញ្ញគតោ (បុរិសោ) "(បុរស) ទៅហើយកាន់ព្រៃ", សព្វរត្តឹ-សោភនោ > សព្វរត្តិ-សោភនោ (ចន្ទោ) "(ព្រះចន្ទ) ល្អអស់រាត្រីទាំងមូល" ។

## តតិយាតប្បុរិសៈ

សល្លេន-វិទ្ធោ > សល្លវិទ្ធោ (មិគោ) "ម្រឹគ) ដែលសរមុត ហើយ" ឬ "(ម្រឹគ) ដែលព្រានបាញ់ហើយដោយសរ", អស្សេ-ន (យុត្តោ)-រថោ > អស្សរថោ "រថ (ដែលជនទឹមហើយ) ដោយសេះ", អសិនា - កលហោ > អសិកលហោ "ជម្លោះដោយដាវ" ឬ "ជម្លោះព្រោះដាវ", មគ្គេន - (សម្បយុត្តំ)-ចិត្តំ > មគ្គចិត្តំ "ចិត្ត (ប្រកបព្រមហើយ) ដោយមគ្គ" ។

## ចតុត្ថីតប្បុរិសៈ

កឋិនស្ស-ទុស្សំ > កឋិនទុស្សំ "សំពត់ដើម្បីកឋិន" ឬ "សំពត់ (ដែលជននាំមកហើយ) ដើម្បីកឋិន", អាគន្តុកស្ស-ភត្តំ > អាគន្តុកភត្តំ "ភត្តដើម្បីអាគន្តុកៈ", គមិកស្ស-ភត្តំ > គមិកភត្តំ "ភត្តដើម្បីភិក្ខុអ្នកគួរដើម្បីទៅ", សង្ឃស្ស-ភត្តំ > សង្ឃភត្តំ "ភត្តដើម្បីសង្ឃ" ។

## បញ្ចមីតប្បុរិសៈ

រញ្ញោ-ភយំ > រាជភយំ "ភ័យអំពីស្តេច", ចោរម្ហា-ភយំ > ចោរភយំ "ភ័យអំពីចោរ", ពន្ធនា-មុត្តោ > ពន្ធនមុត្តោ (សត្តោ) "(សត្វ) រួចហើយចាកចំណង", មេថុនស្មា-អបេតោ > មេថុ-នាបេតោ (បព្វជិតោ) "(បព្វជិត) វៀរហើយចាកមេថុន" ។

## ឆដ្ឋីតប្បុរិសៈ

រញ្ញោ-បុត្តោ > រាជបុត្តោ "កូននៃស្តេច", នទិយា-តីរំ > នទីតីរំ "ត្រើយនៃស្ទឹង", សារិយា-បុត្តោ > សារីបុត្តោ[១] "កូននៃនាងព្រាហ្មណីឈ្មោះសារី = (ព្រះសារីបុត្ត)", រុក្ខស្ស-សាខា > រុក្ខសាខា "មែកនៃឈើ" ។

## សត្តមីតប្បុរិសៈ

រូបេ-សញ្ញា > រូបសញ្ញា "សេចក្តីសម្គាល់ក្នុងរូប", សំ-សារេ-ទុក្ខំ > សំសារទុក្ខំ "សេចក្តីទុក្ខក្នុងសំសារ", វនេ-បុប្ផំ >

---

១ នទី និងសារី ជាឦការន្តឥត្ថីលិង្គ, កាលបើរួមចូលជាបទសមាសយ៉ាងនេះ ត្រូវទុកឲ្យគង់នៅតាមរូបដើម, កុំរស្សៈ ឦ ជា ឥ ដូចឦការន្តបុំលិង្គយ៉ាង សេដ្ឋិបុត្តោ, ហត្ថិទន្តា ជាដើម នោះឡើយ ។

នៃបុប្ផំ "ផ្កាក្នុងព្រៃ", នទិយំ-មច្ឆា > នទីមច្ឆា "ត្រីក្នុងស្ទឹងទាំងឡាយ", ឧក្ខលិយំ-ភត្តំ > ឧក្ខលិភត្តំ "បាយក្នុងឆ្នាំង" ។

ឧភយតប្បុរិសៈ

កម្មធារយសមាសក្តី ទិគុសមាសក្តី បើមាន "ន" និបាតសព្ទ នៅខាងដើម ដែលផ្លាស់ធ្វើជា "អ" ឬជា "អ័ន" នោះបែរជាឲ្យឈ្មោះថា ឧភយតប្បុរិសសមាស ទៅវិញ ឧ. ន-ព្រាហ្មណោ > អព្រាហ្មណោ "ព្រាហ្មណ៍មិនមែន គឺមិនមែនព្រាហ្មណ៍", ន-បញ្ចគវំ > អបញ្ចគវំ "គោប្រាំមិនមែន គឺមិនមែនគោប្រាំ", ន-អរិយោ > អនរិយោ "ព្រះអរិយៈមិនមែន គឺមិនមែនព្រះអរិយៈ" , ន-អស្សោ > អនស្សោ "សេះមិនមែន គឺមិនមែនសេះ" ។

សមាសនេះ បើមិនហៅ ឧភយតប្បុរិសៈ នឹងហៅថា "នបុព្វបទកម្មធារយសមាស" ដូច្នេះវិញក៏បាន ។ បើព្យញ្ជនៈនៅខាងចុង "ន", ត្រូវផ្លាស់ "ន" ជា "អ" ដោយមេសូត្រ

អត្តន្នស្សតប្បុរិសេ ដូច អព្រាហ្មណោ ជាដើម, បើស្រះនៅខាងចុង "ន", ត្រូវផ្លាស់ "ន" ជា "អ័ន" ដោយមេសូត្រ សរេអ័ន ដូច អនស្សោ ជាដើម ។

តប្បុរិសសមាសទាំង ៦ តាំងពីទុតិយាតប្បុរិសៈដល់សត្តមីតប្បុរិសៈ ដូចបាននិយាយមកហើយនោះ ប្លែកគ្នាពីកម្មធារយសមាសដូច្នេះគឺ កម្មធារយសមាសមានវិភត្តិនិងវចនៈ ស្មើគ្នា បទ ១ ជាប្រធាន បទ ១ ជាវិសេសនៈ ឬជាវិសេសនៈទាំងពីរបទ មានបទឯទៀតជាប្រធាន, ឯតប្បុរិសសមាសនេះ មានវិភត្តិនិងវចនៈមិនស្មើគ្នាដូច្នោះទេ ។

## ទ្វន្ទ្វសមាស

[១៣២] នាមសព្ទតាំងពីពីរបទឡើងទៅដែលមានវិភត្តិស្មើគ្នា បំប្រួញចូលជាបទ ១ ហៅថា ទ្វន្ទ្វសមាស ៗ នោះពោលដោយសង្ខេប ដើម្បីឲ្យអ្នកសិក្សាសង្កេតបានដោយងាយ កំណត់ឲ្យឈ្មោះត្រឹមតែ ២ យ៉ាង គឺ សមាហារៈ ១ អសមាហារៈ ១ (ដូចទិគុសមាសដែរ) ។

## សមាហារទ្វន្ទៈ

ទ្វន្ទសមាសដែលបំប្រួញនាមសព្ទបទខាងចុងបំផុត, ទោះជាបុំលិង្គក្តី ឥត្ថីលិង្គក្តី, ឲ្យជានបុំសកលិង្គឯកវចនៈ ឬសព្ទខាងចុងបំផុតដែលជានបុំសកលិង្គស្រាប់ ក៏ឲ្យនៅជានបុំសក-លិង្គឯកវចនៈដូចដែល ហៅថា សមាហារទ្វន្ទៈ ឧ. សមថោ ច-វិបស្សនា ច > សមថវិបស្សនំ "សមថៈនិង[១] វិបស្សនា", កាកោ ច-ឧលូកោ ច > កាកោលូកំ "ក្អែកនិងមៀម", បណ្ណំ ច-បុប្ផំ ច-ផលំ ច > បណ្ណបុប្ផផលំ "ស្លឹកនិងផ្កានិងផ្លែ", ហត្ថី ច-អស្សោ ច-រថោ ច-បត្តិកោ ច > ហត្ថិអស្សរថបត្តិកំ ឬ ហត្ថ្យស្សរថបត្តិកំ "ដំរីនិងសេះនិងរថនិងពលថ្មើរជើង" ។

## អសមាហារទ្វន្ទៈ

ទ្វន្ទសមាស ដែលបំប្រួញនាមសព្ទបទខាងចុងបំផុតឲ្យជាពហុវចនៈ តាមដំណើរលិង្គ ហៅថា អសមាហារៈ ឧ. សមណោ ច-ព្រាហ្មណោ ច > សមណព្រាហ្មណា "សមណៈនិងព្រាហ្មណ៍ទាំងឡាយ", ភិក្ខុ ច-សាមណេរោ ច >

១ ពាក្យថា "និង" នេះ ជាជំនួសពាក្យថា "វី" (ផង) ដែលប្រែចេញមកពី ច-សព្ទក្នុងវិគ្គហៈ។ ២ ជា ហត្ថស្សរថបត្តិកំ ក៏បាន ។

ភិក្ខុសាមណេរា "ភិក្ខុនិងសាមណេរទាំងឡាយ", បណ្ណំ ច-បុប្ផំ ច-ផលំ ច > បណ្ណបុប្ផផលានិ "ស្លឹកនិងផ្កានិងផ្លែទាំងឡាយ", ទេវោ ច-មនុស្សោ ច-នាគោ ច-អសុរោ ច-គន្ធព្វោ ច > ទេវមនុស្សនាគាសុរគន្ធព្វា "ទេវតានិងមនុស្សនិងនាគនិងអសុរនិងគន្ធព្វទាំងឡាយ" ។

## អព្យយីភាវសមាស

[១៣៣] សមាសដែលមានឧបសគ្គ ឬនិបាតនៅខាងដើមហើយជានបុំសកលិង្គ, បើទុកជាពហុវចនៈក៏មានអាការជានបុំសកលិង្គឯកវចនៈ ហៅថា អព្យយីភាវសមាស ។ នោះពោលដោយសង្ខេប ដើម្បីឲ្យកុលបុត្រអ្នកសិក្សាសង្កេតបានដោយងាយ កំណត់ឲ្យឈ្មោះត្រឹមតែ ២ យ៉ាង គឺ ឧបសគ្គបុព្វកៈ ១ និបាតបុព្វកៈ ១ ។ ដែលមានឧបសគ្គនៅខាងដើម ហៅថា ឧប-សគ្គបុព្វកៈ ឬ ឧបសគ្គបុព្វកាព្យយីភាវៈ, ដែលមាននិបាតនៅខាងដើម ហៅថា និបាតបុព្វកៈ ឬ និបាតបុព្វកាព្យយីភាវៈ[១] ។

១ ហៅថា ឧបសគ្គបុព្វបទ, និបាតបុព្វបទ ឬ ឧបសគ្គបុព្វបទាព្យ-យីភាវៈ, និបាតបុព្វបទាព្យយីភាវៈ ដូច្នេះក៏បាន ។

## ឧបសគ្គបុព្វកៈ

នគរស្ស-សមីបំ > ឧបនគរំ "ទីជិតនៃនគរ", នគរស្ស-សមីបេ-វត្តតី' តិ-វា> ឧបនគរំ "ម្យ៉ាងទៀតថា (កថា) ប្រព្រឹត្តទៅក្នុងទីជិតនៃនគរ" (ផ្លាស់ "សមីប" ជា "ឧប" ដោយនិបាតសូត្រ), ទរថស្ស-អភាវោ > និទ្ទរថំ "កិរិយាមិនមាននៃសេចក្តីក្រវល់ក្រវាយ" (ផ្លាស់ "អភាវ" ជា "និ" ដោយនិបាតសូត្រ), សោតស្ស-បតិវត្តតី' តិ > បតិសោតំ (នាវា) "(ទូក) ប្រព្រឹត្តច្រាសនូវខ្សែទឹក", អត្តានំ-អធិវត្តតី តិ > អជ្ឈត្តំ (ធម្មជាតំ) "(ធម្មជាត) ប្រព្រឹត្តសង្កត់នូវខ្លួន" (ផ្លាស់ "អធិ" ជា "អជ្ឈ" ដោយព្យញ្ជនាទេសសន្ធិ ត្រង់លេខបព្វៈ ២៤) ។

## និបាតបុព្វកៈ

វុឌ្ឍានំ-បដិបាដិ > យថាវុឌ្ឍំ "លំដាប់នៃជនចម្រើន = (លំដាប់នៃជនចាស់), វុឌ្ឍានំ-បដិបាដិយា-យេ-យេ-វុឌ្ឍា-ព្រាហ្មណា-និសីទន្តិ-វា > យថាវុឌ្ឍំ (ព្រាហ្មណា) "ម្យ៉ាងទៀតថា (ព្រាហ្មណ៍ចាស់ទាំងឡាយ) អង្គុយតាមលំដាប់នៃជនចាស់" (ផ្លាស់ "បដិបាដិ" ជា "យថា" ដោយនិបាតសូត្រ), បព្វតស្ស-

តិរោ > តិរោបព្វតំ "ខាងក្រៅនៃភ្នំ", បាសាទស្ស-អន្តោ > អន្តោ-បាសាទំ "ខាងក្នុងនៃប្រាសាទ", ភត្តស្ស-បច្ឆា > បច្ឆាភត្តំ "កាលជាខាងក្រោយនៃភត្ត" ។

## ពហុព្វីហិសមាស

[១៣៤] សមាសដែលមានបទឯទៀត (អញ្ញបទ) ស្ទុះពីក្នុងវិគ្គហៈចេញមកជាប្រធាន ហៅថា ពហុព្វីហិសមាស ៗ នោះពោលតាមអំណាចវិភត្តិ មាន ៦ យ៉ាង គឺ ទុតិយាពហុព្វីហិ ១ តតិយាពហុព្វីហិ ១ ចតុត្ថីពហុព្វីហិ ១ បញ្ចមីពហុព្វីហិ ១ ឆដ្ឋីពហុព្វីហិ ១ សត្តមីពហុព្វីហិ ១ ។

## ទុតិយាពហុព្វីហិ

កំណត់យកបទជាទុតិយាវិភត្តិក្នុងវិគ្គហៈ ដែលស្ទុះចេញជាប្រធាននៃបទសមាសជាគ្រឿងសម្គាល់ ដូច្នេះ ៖

អាគតា-សមណា-យំ-សោ > អាគតសមណោ (អារា-មោ) "(អារាម) មានសមណៈមកហើយ", រុឡ្ហា-លតា-យំ-សោ > រុឡ្ហលតោ (រុក្ខោ) (ឈើ) មានវល្លិឡើងហើយ",

សម្បត្តា-ភិក្ខូ-យំ-សោ > សម្បត្តភិក្ខុ (អាវាសោ) ‟(អាវាស) មានភិក្ខុដល់ព្រមហើយ″, អភិរុឡ្ហា-វានរោ-យំ-សោ > អភិរុឡ្ហ-វានរោ (រុក្ខោ) ‟(ឈើ) មានស្វាឡើងហើយ″ ។

## តតិយាពហុព្វីហិ

កំណត់យកបទជាតតិយាវិភត្តិក្នុងវិគ្គហៈ ដែលស្ទុះចេញជាប្រធាននៃបទសមាសជាគ្រឿងសម្គាល់ ដូច្នេះ ៖

ជិតានិ-ឥន្ទ្រិយានិ-យេន-សោ > ជិតិន្ទ្រិយោ (សមណោ) ‟(សមណៈ) មានឥន្ទ្រិយឈ្នះហើយ″, កតំ-បុញ្ញំ-យេន-សោ) កតបុញ្ញោ (ជនោ) ‟(ជន) មានបុណ្យធ្វើហើយ″, អាហិតោ-អគ្គិ-យេន-សោ > អាហិតគ្គិ (ព្រាហ្មណោ) ‟(ព្រាហ្មណ៍) មានភ្លើងបូជាហើយ″។ នឹងរៀងបាឡីឲ្យមានបទវិសេសនៈនៅខាងចុងវិញក៏បាន ឧ. អគ្គិ-អាហិតោ-យេន-សោ > អគ្យាហិតោ (ព្រាហ្មណោ) ‟(ព្រាហ្មណ៍) មានភ្លើងបូជាហើយ″ ។

## ចតុត្ថីពហុព្វីហិ

កំណត់យកបទជាចតុត្ថីវិភត្តិក្នុងវិគ្គហៈ ដែលស្ទុះចេញជាប្រធាននៃបទសមាសជាគ្រឿងសម្គាល់ ដូច្នេះ ៖

ទិន្នា-សុង្កា-យស្ស-សោ > ទិន្នសុង្កោ (រាជា) "(ស្តេច) មានសួយគឺអ្នកនគរថ្វាយហើយ", កតំ-ទណ្ឌកម្មំ-យស្ស-សោ > កតទណ្ឌកម្មោ (សិស្សោ) "(សិស្ស) មានទណ្ឌកម្មគឺអាចារ្យធ្វើហើយ", សញ្ជាតោ-សំវេគោ-យស្ស-សោ > សញ្ជាតសំវេគោ (ភិក្ខុ) "(ភិក្ខុ) មានសេចក្តីសំវេគកើតព្រមហើយ", ទិន្នា-យសោ-យស្សា-សា > ទិន្នយសា (ទេវី) "(នាងទេវី) មានយសគឺស្តេចព្រះរាជទានហើយ" ។

## បញ្ចមីពហុព្វីហិ

កំណត់យកបទជាបញ្ចមីវិភត្តិក្នុងវិគ្គហៈ ដែលស្ទុះចេញជាប្រធាននៃបទសមាសជាគ្រឿងសម្គាល់ ដូច្នេះ ៖

និគ្គតា-ជនា-យស្មា-សោ > និគ្គតជនោ (គាមោ) "(ស្រុក) មានជនចេញហើយ", បតិតានិ-ផលានិ-យស្មា-សោ > បតិតប្ផលោ (រុក្ខោ) "(ឈើ) មានផ្លែជ្រុះហើយ", វីតោ-រាគោ-យស្មា-សោ > វីតរាគោ (ភិក្ខុ) "(ភិក្ខុ) មានរាគៈទៅប្រាសហើយ", អបគតា-សិរី-យស្មា-សោ > អបគតសិរី (ជនោ) "(ជន) មានសិរីទៅប្រាសហើយ" ។

## ឆដ្ឋីពហុព្វីហិ

កំណត់យកបទជាឆដ្ឋីវិភត្តិក្នុងវិគ្គហៈ ដែលស្មុះចេញជាប្រធាននៃបទសមាសជាគ្រឿងសម្គាល់ ដូច្នេះ ៖

ខីណា-អាសវា-យស្ស-សោ > ខីណាសវោ (ភិក្ខុ) "(ភិក្ខុ) មានអាសវៈអស់ហើយ", សន្តំ-ចិត្តំ-យស្ស-សោ > សន្តចិត្តោ (ជនោ) "(ជន) មានចិត្តរម្ងាប់ហើយ", ឆិន្នា-ហត្ថា-យស្ស-សោ > ឆិន្នហត្ថោ (បុរិសោ) "(បុរស) មានដៃដាច់ហើយ" នឹងរៀងបាឡីឲ្យមានបទវិសេសនៈនៅខាងចុងវិញក៏បាន ឧ. ហត្ថា-ឆិន្នា-យស្ស-សោ > ហត្ថច្ឆិន្នោ (បុរិសោ) "(បុរស) មានដៃដាច់ហើយ" ។

## ឧបមាពហុព្វីហិ

សមាសដែលមានបទបឋមាវិភត្តិជាឧបមា មានបទឆដ្ឋីវិភត្តិក្នុងវិគ្គហៈស្មុះចេញជាប្រធាន ហៅថា ឆដ្ឋីឧបមាពហុព្វីហិ ឧ. សុវណ្ណវណ្ណោ ឥវ-វណ្ណោ-យស្ស-សោ > សុវណ្ណវណ្ណោ (តថាគតោ) (ព្រះតថាគត) មានសម្បុរដូចជាសម្បុរនៃមាស",

ព្រហ្មស្សរោ ឥវ-សរោ-យស្ស-សោ > ព្រហ្មស្សរោ (តថាគតោ) "(ព្រះតថាគត) មានសំឡេងដូចជាសំឡេងនៃព្រហ្ម", និគ្រោ-ធបរិមណ្ឌលោ ឥវ-បរិមណ្ឌលោ-យស្ស-សោ > និគ្រោធបរិ-មណ្ឌលោ (រាជកុមារោ) "(រាជកុមារ) មានបរិមណ្ឌលដូចជាបរិមណ្ឌលនៃដើមជ្រៃ" ។

## នបុព្វបទឆដ្ឋីពហុព្វីហិ

ឆដ្ឋីពហុព្វីហិសមាសដែលមានសេចក្ដីជាបដិសេធ, លោកឲ្យឈ្មោះថា នបុព្វបទឆដ្ឋីពហុព្វីហិ ឧ. នត្ថិ-តស្ស-សមោ' តិ > អសមោ (តថាគតោ) "(ព្រះតថាគត) មានបុគ្គលស្មើមិនមាន = (ឥតមានបុគ្គលស្មើ)", នត្ថិ-តស្ស-បដិបុគ្គលោ'តិ > អប្បដិបុគ្គលោ (តថាគតោ) "(ព្រះតថាគត) មានបុគ្គលប្រៀបមិនមាន = (ឥតមានបុគ្គលប្រៀប), នត្ថិ-ឯតស្ស-សទ្ធា' តិ > អស្សទ្ធោ (ជនោ) "(ជន) មានសទ្ធាមិនមាន = (ជន គ្មានសទ្ធា ឬ ឥតសទ្ធា)", នត្ថិ-ឯតស្ស-បុត្តោ'តិ > អបុត្តកោ (ជនោ) "(ជន) មានកូនមិនមាន = (ជនគ្មានកូន ឬ ឥតកូន)" (ចុះ "ក" បច្ច័យដោយមេសូត្រ សព្វតោកោ) ។

## ឆដ្ឋីភិន្នាធិករណពហុព្វីហិ

ពហុព្វីហិសមាសដែលមានវិគ្គហៈ កំណត់ដោយបទមានវិភត្តិផ្សេងគ្នា គឺមានបទជាទុតិយា ឬតតិយា ឬសត្តមីវិភត្តិសម្ពន្ធចូល នឹងបទជាបឋមាវិភត្តិហើយមានបទជាឆដ្ឋីវិភត្តិស្ទុះចេញមកជាប្រធាន ហៅថា ឆដ្ឋីភិន្នាធិករណពហុព្វីហិ[១] ឧ. ក) ឯករត្តឹ-វាសោ-អស្សាតិ > ឯករត្តិវាសោ (ជនោ) "(ជន) មានកិរិយានៅអស់យប់មួយ" ។ ខ) ឧរសិ-លោមានិ-យស្ស-សោ > ឧរសិ-លោមោ (បុរិសោ) "(បុរស) មានរោមឰដ៏ទ្រូង", អសិ-ហត្ថេ-យស្ស-សោ > អសិហត្ថោ (យោធោ) "(ទាហាន) មានដាវក្នុងដៃ", គ) សមានេន-សំវាសោ-អស្សាតិ > សមានសំវាសោ (ជនោ) "(ជន) មានកិរិយានៅរួមដោយជនស្មើគ្នា" ។

---

១ សមាសនេះ បើហៅតាមដំណើរវិគ្គហៈដើម្បីឲ្យអ្នករៀនងាយយល់នោះត្រង់ ក)គួរហៅថាទុតិយាភិន្នាធិករណឆដ្ឋីពហុព្វីហិ, ត្រង់ ខ) គួរហៅថា សត្តមីភិន្នាធិករណឆដ្ឋីពហុព្វីហិ, ត្រង់ គ) គួរហៅ ថា តតិយាភិន្នាធិករណឆដ្ឋីពហុព្វីហិ, ប៉ុន្តែក្នុងបករណៈទាំង ពួង ប្រាប់ឈ្មោះត្រឹមតែថាភិន្នាធិករណពហុព្វីហិ ឬ ឆដ្ឋីភិន្នាធិករណពហុ-ព្វីហិ ប៉ុណ្ណោះព្រោះហេតុដូច្នោះយើងត្រូវហៅតាមតែន័យក្នុងបករណៈទាំងពួងបានហើយ ។

## សត្តមីពហុព្វីហិ

កំណត់យកបទជាសត្តមីវិភត្តិក្នុងវិគ្គហៈ ដែលស្មុះចេញជាប្រធាននៃបទសមាសជាគ្រឿងសម្គាល់ ដូច្នេះ ៖

សម្បន្នានិ-សស្សានិ-យស្មឹ-សោ > សម្បន្នសស្សោ (ជនបទោ) "(ជនបទ) មានសំទូងដល់ព្រមហើយ", ពហវោ-នទិយោ-យស្មឹ-សោ > ពហុនទិកោ (ជនបទោ) "(ជនបទ) មានស្ទឹងច្រើន" (ចុះ "ក" បច្ច័យដោយមេសូត្រ នទិម្ហាច), បិតា-សិរី-យស្មឹ-សោ > បិតសិរី (ជនោ) "(ជន) មានសិរីបិតនៅ", បិតំ-បេមំ-យស្មឹ-សោ > បិតបេ្បមោ[១] (ជនោ) "(ជន) មានសេចក្តីស្រឡាញ់បិតនៅ" ។

## សមាសមានផ្ទៃ

ពហុព្វីហិសមាសដែលសម្តែងមកហើយនេះ ជាបែបតែមួយជាន់ មិនមានសមាសឯទៀតនៅលាយខាងក្នុងផងឡើយ,

---

១ ពហុព្វីហិសមាសទាំង ៦ បើចងវិគ្គហៈឲ្យមានឥតិ-សព្ទរាំងថាៈ អាគតា-សមណា-យន្តិ > អាគតសមណោ ឬ អាគតា-សមណា-ឥមន្តិ > អាគតសមណោ (អារាមោ) ។ បេ ។ បិតំ-បេមំ-យស្មិន្តិ > បិតបេ្បមោ ឬ បិតំ-បេមំ-អស្មិន្តិ > បិតបេ្បមោ (ជនោ) ដូច្នេះក៏បាន។ វិគ្គហៈ ប្លែកពីបែបនេះទៅទៀតក៏មាន, ប៉ុន្តែគង់អាចកំណត់ដឹងថាជាពហុព្វីហិសមាសបានដូចគ្នាពីព្រោះមានគ្រឿងចំណាំដោយសព្ទ ២ បទដែលមានបទទុតិយាវិភត្តិជាដើម ស្មុះចេញពីក្នុងវិគ្គហៈមកជាបទប្រធាននៃសមាស ចេញដំណើរសេចក្តីថា "មាន" ។

ពហុព្វីហិដែលមានសមាសឯទៀត នៅលាយខាងក្នុងផងនោះ ហៅដោយសន្មតិថា "សមាសមានផ្ទៃ" ឬ "សមាសផើម" ព្រោះសមាសនេះប្រៀបដូចស្ត្រីមានផ្ទៃពោះ ដូចឧទាហរណ៍តទៅនេះ

ធម្មោ ឯវ-ចក្កំ > ធម្មចក្កំ "ចក្រគឺធម៌" (អវធារណបុព្វបទ-កម្មធារយៈ), បវរំ-ធម្មចក្កំ > បវរធម្មចក្កំ "ចក្រគឺធម៌ដ៏ប្រសើរ" (វិសេសនបុព្វបទកម្មធារយៈ, បវត្តិតំ-បវរធម្មចក្កំ-យេន-សោ > បវត្តិតបវរធម្មចក្កោ (ភគវា) "ព្រះមានជោគ) មានធម៌ដ៏ប្រសើរឲ្យប្រព្រឹត្តទៅហើយ" (ឈ្មោះតតិយាពហុព្វីហិ, មានកម្មធារយ-សមាស ២ នៅខាងក្នុង) ។ គន្ធោ ច-មាលា ច > គន្ធមាលា "គ្រឿងក្រអូបនិងផ្កាកម្រងទាំងឡាយ" (អសមាហារទ្វន្ទៈ), គន្ធមាលា-អាទយោ-យេសំ-តានិ > គន្ធមាលាទីនិ (វត្ថូនិ) "(វត្ថុទាំងឡាយ) មានគ្រឿងក្រអូបនិងផ្កាកម្រងជាដើម" (ឈ្មោះឆដ្ឋីតុល្យាធិករណពហុព្វីហិ[១] មានទ្វន្ទសមាស ១ នៅខាងក្នុង), គន្ធមាលាទីនិ-ហត្ថេសុ-យេសំ-តេ > គន្ធមាលាទិហត្ថា (មនុស្សា) "(មនុស្សទាំងឡាយ) មានវត្ថុ មានគ្រឿងក្រអូប

១ ហៅឲ្យងាយយល់ថា: បឋមាតុល្យាធិករណឆដ្ឋីពហុព្វីហិ ។

និងផ្កាកម្រងជាដើមក្នុងដៃ″ (ឈ្មោះឆដ្ឋីភិន្នាធិករណពហុព្វីហិ មានទ្វន្ទសមាស ១ និងពហុព្វីហិសមាស ១ នៅខាងក្នុង) ។

## សហាបុព្វបទពហុព្វីហិសមាស

មានសមាសម្យ៉ាងទៀត មានដំណើរវិគ្គហៈជា កត្តុសាធនៈ (ក្រិត) ប៉ុន្តែដោយសារមានសហ-សព្ទ នៅខាងដើម ជាគ្រឿងសម្គាល់ ក៏កំណត់ឲ្យឈ្មោះថា សហបុព្វបទពហុព្វីហិ ទៅវិញ ឱ. សហ-បុត្តេន-យោ-វត្តតី´តិ > សបុត្តោ (បិតា) ‶(បិតា) ប្រព្រឹត្តទៅមួយអន្លើដោយកូន = (បិតាព្រមទាំងកូន)″, សហ-មច្ឆេរេន-យំ-វត្តតី´តិ > សមច្ឆេរំ (ចិត្តំ) ‶(ចិត្ត) ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីកំណាញ់″, សហ-បរិវារេន-យោ-វត្តតី´តិ > សបរិវារោ (ថេរោ) ‶ព្រះថេរៈ) ប្រព្រឹត្តទៅមួយអន្លើដោយបរិវារ = (ព្រះថេរៈព្រមទាំងបរិវារ)″, សហ-រញ្ញា-យា-វត្តតី´តិ > សរាជិកា (បរិសា) ‶(បរិស័ទ) ប្រព្រឹត្តទៅមួយអន្លើដោយស្ដេច = (បរិស័ទព្រមទាំងស្ដេច គឺបរិស័ទ ដែលមានស្ដេចគង់ជាប្រធាននៅនោះផង) ។

---

១ ហៅឲ្យងាយយល់ថា សត្តមីភិន្នាធិករណ-ឆដ្ឋីពហុព្វីហិ ។

## ឯកសេសសមាស

[១៣៥] អសមាហារទ្វន្ទសមាសដែលលុបបទឯទៀតចេញ ទុកឲ្យនៅសល់តែ ១ បទ ហៅថា ឯកសេសសមាស ប្រែថា "សមាសសល់នៅតែសព្ទមួយ" ឬថា សមាសមានសព្ទមួយជាចំណែកសល់នៅ" ។ សមាសនេះ ក្នុងកច្ចាយនបករណ៍ លោកសម្ដែងទៅខាងប៉ែកតទ្ធិត ត្រង់មេសូត្រ សរូបានមេកសេ-ស្វសកឹ, ជាសមាសមានឈ្មោះដោយឡែក មិនរាប់បញ្ចូលក្នុងពួកសមាសទាំង ៦ ឈ្មោះ ដែលបាននិយាយមកហើយក្នុងខាងដើមនោះទេ ។ សមាសនេះ សម្ដែងតាមប្រភេទនៃវិធីលុបមាន ២ យ៉ាង គឺ បុព្វេកសេសៈ ១ បរេកសេសៈ ១ ។ សមាសដែលលុបបទខាងចុងទុកឲ្យសល់បទខាងដើម ហៅថា បុព្វេកសេសៈ ឧ. ឧបាសកោ ច-ឧបាសិកា ច > ឧបាសកា "ឧបាសកនិងឧបាសិកាទាំងឡាយ", មាតា ច-បិតា ច > មាតរោ "មាតានិងបិតាទាំងឡាយ", ទហរោ ច-សាមណេរោ ច > ទហរា "ភិក្ខុកំលោះនិងសាមណេរទាំងឡាយ", សីតំ ច-ឧណ្ហំ ច > សីតានិ "រដូវត្រជាក់និងរដូវក្ដៅទាំងឡាយ" ។ សមាសដែល

លុបបទខាងដើម ទុកឲ្យសល់បទខាងចុង ហៅថា បរេកសេសៈ ឧ. ឧបាសកោ ច-ឧបាសិកា ច > ឧបាសិកា "ឧបាសកនិងឧបាសិកាទាំងឡាយ", មាតា ច-បិតា ច > បិតរោ "មាតានិងបិតាទាំងឡាយ", ទហរោ ច-សាមណេរោ ច > សាមណេរា "ភិក្ខុកំលោះនិងសាមណេរទាំងឡាយ", សីតំ ច-ឧណ្ហំ ច > ឧណ្ហានិ "រដូវត្រជាក់និងរដូវក្តៅទាំងឡាយ" ។

សមាសនេះ សម្តែងតាមប្រភេទនៃរូបសព្ទដែលទុកឲ្យសល់, មាន ២ យ៉ាង គឺ សរូបេកសេសៈ ១ វិរូបេកសេសៈ ១ ។ សមាសដែលមានរូបសព្ទស្មើគ្នា គឺទាំង ២ បទជាសព្ទមានរូបតែមួយ ហៅថា សរូបេកសេសៈ ឧ. បុរិសោ ច-បុរិសោ ច > បុរិសា "បុរសនិងបុរសទាំងឡាយ", យុគា ច-យុគា ច > យុគា "គូនិងគូទាំងឡាយ" ។ សមាសដែលមានរូបសព្ទខុសគ្នា គឺសព្ទទាំង ២ មានរូបផ្សេងគ្នា ប៉ុន្តែមានសេចក្តីជាគូនឹងគ្នាហៅថា វិរូបេកសេសៈ ឧ. មាតា ច-បិតា ច > មាតរោ ឬ បិតរោ "មាតានិងបិតាទាំងឡាយ", សារីបុត្តោ ច-មោគ្គល្លានោ ច > សារីបុត្តា ឬ មោគ្គល្លានា "ព្រះសារីបុត្រនិងព្រះមោគ្គល្លានទាំងឡាយ" ។

ឬ សព្ទដែលទុកឲ្យសល់នោះជាសព្ទ ផ្លាស់រូបឲ្យខុសចាករូបដើមរបស់សព្ទទាំង ២ ក្នុងវិគ្គហៈ ក៏ហៅថា វិរូបេកសេសៈដែរ ឧ. ទស ច-ទស ច > វីស "ដប់និងដប់" គឺ "២០", ទស ច-ទស ច-ទស ច > តឹស "ដប់និងដប់និងដប់" គឺ "៣០" ... ។

## វិគ្គហៈនៃសមាសក្នុងលិង្គទាំង ៣

[១៣៦] សមាសខ្លះដែលមានវិគ្គហៈប្រើបានទាំង ៣ លិង្គ ដូច្នេះ ៖

### តប្បុរិសសមាស

ឯកវចនៈ

(បុំ.) គាមំ - គតោ > គាមគតោ (បុរិសោ),

(ឥ.) គាមំ - គតា > គាមគតា (ឥត្ថី),

(នបុំ.) គាមំ - គតំ > គាមគតំ (កុលំ) ។

ពហុវចនៈ

(បុំ.) គាមំ - គតា > គាមគតា (បុរិសា),

(ឥ.) គាមំ - គតា > គាមគតា (ឥត្ថិយោ),

(នបុំ.) គាមំ - គតានិ > គាមគតានិ (កុលានិ) ។

-៣២៥-

## កម្មធារយសមាស

ឯកវចនៈ

(បុំ.) សីតោ ច - សោ - ឧណ្ហោ ចា´តិ > សីតុណ្ហោ (បទេសោ),

(ឥ.) សីតា ច - សា - ឧណ្ហា ចា´តិ > សីតុណ្ហា (ភូមិ),

(នបុំ.) សីតំ ច - តំ - ឧណ្ហាញ្ចា´តិ > សីតុណ្ហំ (ឋានំ) ។

ពហុវចនៈ

(បុំ.) សីតា ច - តេ - ឧណ្ហា ចា´តិ > សីតុណ្ហា (បទេសា),

(ឥ.) សីតា ច - តា - ឧណ្ហា ចា´តិ > សីតុណ្ហា (ភូមិយោ),

(នបុំ) សីតានិ ច-តានិ-ឧណ្ហានិ ចា´តិ > សីតុណ្ហានិ (ឋានានិ) ។

## ពហុព្វីហិសមាស

ឯកវចនៈ

(បុំ.) រុឡ្ហា - លតា - យំ - សោ > រុឡ្ហលតោ (រុក្ខោ),

(ឥ.) រុឡ្ហា - លតា - យំ - សា > រុឡ្ហលតា (សាលា),

(នបុំ.) រុឡ្ហា - លតា - យំ - តំ > រុឡ្ហលតំ (ឃរំ), ។

ពហុវចនៈ

(បុំ.) រុឡ្ហា - លតា - យេ - តេ > រុឡ្ហលតា (រុក្ខា),

(ឥ.) រុឡ្ហា - លតា - យា - តា > រុឡ្ហលតា (សាលាយោ),

(នបុំ.) រុឡ្ហា-លតា-យានិ - តានិ > រុឡ្ហលតានិ (ឃរានិ) ។

## ប្រធាននៃសមាស

[១៣៧] សមាសទាំងអស់សម្តែងដោយប្រធានមាន ៤ យ៉ាង គឺ ៖

១- បុព្វបទត្ថប្បធានោ សមាសមានអត្ថនៃបទខាងដើមជាប្រធាន គឺមានប្រធាននៅខាងដើម,

២- ឧត្តរបទត្ថប្បធានោ សមាសមានអត្ថនៃបទខាងចុងជាប្រធាន គឺមានប្រធាននៅខាងចុង,

៣- ឧភយបទត្ថប្បធានោ សមាសមានអត្ថនៃបទទាំងពីរជាប្រធាន គឺមានបទតាំងពីពីរបទឡើងទៅសុទ្ធតែជាប្រធានទាំងអស់,

៤- អញ្ញបទត្ថប្បធានោ សមាសមានអត្ថនៃបទដទៃជាប្រធាន គឺមានបទឯទៀតជាប្រធាន ។

វិសេសនុត្តរបទកម្មធារយៈ, ឧបមានុត្តរបទកម្មធារយៈ, អព្យយីភាវៈ ៣ នេះជាបុព្វបទត្ថប្បធាន ត្រូវប្រែចាប់យកបទខាងដើមមកថាមុន ។ វិសេសនបុព្វបទកម្មធារយៈ, ឧបមាបុព្វបទកម្មធារយៈ, សម្ភាវនបុព្វបទកម្មធារយៈ, អវធារណបុព្វបទកម្មធារយៈ, ទិគុ, តប្បុរិសៈ ៦ នេះជាឧត្តរបទត្ថប្បធាន ត្រូវប្រែចាប់យកបទខាងចុងមកថាមុន ។ ទ្វន្ទៈ ជាឧភយបទត្ថប្បធាន ត្រូវប្រែរាយជម្រាលពីខាងដើមចុះមក ។ វិសេសនោភយបទកម្មធារយៈ, ពហុព្វីហិ ២ នេះជាអញ្ញបទត្ថប្បធាន ត្រូវប្រែដាក់បញ្ចូលបទឯទៀតមកនាំមុខជាមុន ។

សមាសនិទ្ទេសទី ៣ ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

# តទ្ធិតនិទ្ទេស ទី ៤

# តទ្ធិតនិទ្ទេស ទី ៤

## តទ្ធិត

[១៣៨] សព្ទមានចំនួន ២, ចុះបច្ច័យជាជំនួសមកហើយលុបសព្ទមួយខាងចុងចេញ ទុកតែមួយខាងដើម, ផ្សំជាមួយនឹងបច្ច័យ ដើម្បីឲ្យខ្លីស្រួលថា, ស្រួលហៅ ដូចជា "រាជគហជាត" ផ្សំនឹងវិភត្តិនាមជា "រាជគហេ ជាតោ", ថែមសព្ទថា "ជនោ" ដែលជាតួប្រធានមកជា "រាជគហេ ជាតោ" (ជនោ) ប្រែថា (ជន) "កើតហើយក្នុងនគររាជគហៈ", ចុះ "ណិក" បច្ច័យ ជាជំនួសសព្ទថា "ជាត" ហើយលុប "ជាត" ចេញ ទុកតែ "រាជគហ", លុប "ណ" ចេញ ទុកតែ "ឥក" ផ្សំជា "រាជគហិក" ក៏គង់នៅប្រែថា (ជន) "កើតហើយក្នុងនគររាជគហៈ" ដូចដើម, សព្ទយ៉ាងនេះ ហៅថា "តទ្ធិត" ។ តទ្ធិតនោះ និយាយដោយសង្ខេប មាន ៣ យ៉ាង គឺ សាមញ្ញ-តទ្ធិត ១ ភាវតទ្ធិត ១ អព្យយតទ្ធិត ១ ។

## សាមញ្ញតទ្ធិត

[១៣៩] សាមញ្ញតទ្ធិតបែកចេញជា ១៥ យ៉ាង គឺ គោត្ត-តទ្ធិត ១ តរត្យាទិតទ្ធិត ១ រាគាទិតទ្ធិត ១ ជាតាទិតទ្ធិត ១ សមូហតទ្ធិត ១ ឋានតទ្ធិត ១ ឧបមាតទ្ធិត ១ និស្សិតតទ្ធិត ១ ពហុលតទ្ធិត ១ សេដ្ឋតទ្ធិត ១ តទស្សត្ថិតទ្ធិត ១ បកតិតទ្ធិត ១ បូរណតទ្ធិត ១ សំខ្យាតទ្ធិត ១ វិភាគតទ្ធិត ១ ។

## គោត្តតទ្ធិត

[១៤០] ក្នុងគោត្តតទ្ធិតមានបច្ច័យ ៨ គឺ ណ, ណាយន, ណាន, ណេយ្យ, ណិ, ណិក, ណវ, ណេរ, ។ "ណ" បច្ច័យ ឬបច្ច័យដែលមានអក្សរ "ណ" ជាប់ជាមួយផង ហៅថា "ណានុពន្ធៈ" ដូចយ៉ាង ណាយន, ណាន, ណេយ្យ ជាដើម បើមានសព្ទដែលជាប់ដោយស្រៈ ៣ តួគឺ អ, ឥ, ឧ, ជាស្រៈសុទ្ធក្តី មានព្យញ្ជនៈអាស្រ័យផងក្តី ជាលហុ គឺឥតមានព្យញ្ជនសំ-យោគនៅខាងចុងបន្ទាប់ស្រៈនោះទេ, ត្រូវព្រឹទ្ធិស្រៈនោះឲ្យជាស្រៈមានសំឡេងវែង គឺទីឃៈអជាអា, ឥជាឰ, ឧជាឱ ឬវិការៈឥជាឯ, ឧជាឱ, ជាដើម, តែបើមានព្យញ្ជនសំយោគនៅខាងចុង ឬស្រៈ

ជាទីយៈស្រាប់ នោះមិនមានវិធីកែប្រែអ្វីឡើយ, ឯអក្សរ "ណ" នោះត្រូវលុបចេញ ទុកឲ្យសល់នៅតែស្រះដែលណអាស្រ័យ, ព្យញ្ជនៈដែលជា ណានុពន្ធៈក៏ត្រូវទុកដែរ ។ ឧទាហរណ៍សង្ខេបក្នុងគោត្តតទ្ធិត ដូចមានខាងក្រោយនេះ ៖

ណៈ វសិដ្ឋស្ស-អបច្ចំ[១] > វាសិដ្ឋោ (ជនោ) "(ជន) ជាកូននៃវសិដ្ឋៈ = (ជន ជាពូជពង្សនៃវសិដ្ឋៈ = វសិដ្ឋគោត្ត)", វសិដ្ឋស្ស-អបច្ចំ > វាសិដ្ឋី (ឥត្ថី) "(ស្រី) ជាកូននៃវសិដ្ឋៈ" (ចុះ ឦ-បច្ច័យសម្រាប់ឥត្ថីលិង្គផ្សំមកផង), វសិដ្ឋស្ស-អបច្ចំ > វាសិដ្ឋំ[២] (កុលំ) "(ត្រកូល) ជាពូជវង្សនៃវសិដ្ឋៈ" ។

ណាយនៈ វច្ឆស្ស-អបច្ចំ > វច្ឆាយនោ (ជនោ) "(ជន) ជាកូននៃវច្ឆៈ", សកជស្ស-អបច្ចំ > សាកជាយនោ (ជនោ) "(ជន) ជាពូជវង្សនៃសកជៈ" ។

ណានៈ កច្ចស្ស-អបច្ចំ > កច្ចានោ (ជនោ) "(ជន) ជាពូជវង្សនៃកច្ចៈ" វច្ឆស្ស-អបច្ចំ > វច្ឆានោ (ដូចវច្ឆាយនោ) ។

---

អបច្ច "កូន, កូនចៅ, ពូជវង្ស ឬ ពូជពង្ស" ជាសាធារណនាមនាមនបុំ. តែក្នុងទីនេះ ប្រើជាបទវិសេសនៈ ដូចជាគុណនាម ហៅថា "នាមនាមប្រើដូចគុណនាម" ប៉ុន្តែត្រូវនៅជានបុំ. តាមភាពដើមរបស់ខ្លួន ។ ២ សព្ទឯទៀតក្រៅពីនេះក៏ជា តិលិង្គិកៈដូចគ្នាដែរ ។

ណេយ្យៈ កត្តិកាយ-អបច្ចំ > កត្តិកេយ្យោ (ជនោ) "(ជន) ជាកូននៃស្រីឈ្មោះកត្តិកា" ភគិនិយា-អបច្ចំ > ភាគិនេយ្យោ (ជនោ) "(ជន) ជាកូននៃបង-ប្អូនស្រី" ។

ណិៈ ទក្ខស្ស-អបច្ចំ > ទក្ខិ (ជនោ) "(ជន) ជាពូជពង្ស នៃទក្ខៈ, វសវស្ស-អបច្ចំ > វាសវិ (ជនោ) "(ជន) ជាពូជវង្សនៃ វសវៈ" (ឥ. ចុះឥនី-បច្ច័យផ្សំមកផងជា ទក្ខិនី, វាសវិនី ។

ណិកៈ សក្យបុត្តស្ស-អបច្ចំ > សក្យបុត្តិកោ (ជនោ) "(ជន) ជាកូននៃសក្យៈ", ជិនទត្តស្ស-អបច្ចំ > ជេនទត្តិកោ (ជនោ) "(ជន) ជាពូជវង្សនៃជិនទត្តៈ" ។

ណវៈ ឧបកុស្ស-អបច្ចំ > ឱបកវោ (ជនោ) "(ជន) ជាពូជវង្សនៃឧបកុ," មនុនោ-អបច្ចំ > មាណវោ (ជនោ) "(ជន) ជាពូជវង្សនៃមនុ" (ផ្លាស់ "ន" ជា "ណ") ។

ណេរៈ វិធវាយ-អបច្ចំ > វេធវេរោ (ជនោ) "(ជន) ជាពូជវង្សនៃស្រីវិធវា = (ស្រីមេម៉ាយ)" (ឥ. វេធវេរី), សមណស្ស-អបច្ចំ > សាមណេរោ (ជនោ) "(ជន) ជាកូនចៅនៃសមណៈ" (ឥ. សាមណេរី) ។

# តរត្យាទិតទ្ធិត

[១៤១] តរត្យាទិតទ្ធិតនេះបែកចេញជាឈ្មោះមាន ២៧ យ៉ាងគឺ តរតិតទ្ធិត ១ សំសដ្ឋតទ្ធិត ១ ចរតិតទ្ធិត ១ វេហ-តិតទ្ធិត ១ វេសតិតទ្ធិត ១ ជាតតទ្ធិត ១ អធិគេតទ្ធិត ១ កតតទ្ធិត ១ វត្តតិតទ្ធិត ១ សន្និធានតទ្ធិត ១ និយុត្តតទ្ធិត ១ សិប្បតទ្ធិត ១ ភណ្ឌតទ្ធិត ១ ជីវតិតទ្ធិត ១ ហតតទ្ធិត ១ ពន្ធតទ្ធិត ១ អាវុធតទ្ធិត ១ អាពាធតទ្ធិត ១ បសន្នតទ្ធិត ១ សន្តកតទ្ធិត ១ កីតតទ្ធិត ១ បរិមាណតទ្ធិត ១ រាសិតទ្ធិត ១ អរហតិតទ្ធិត ១ ទិព្វតិតទ្ធិត ១ វិទិតតទ្ធិត ១ សំវត្តតិតទ្ធិត ១ ។

តទ្ធិតទាំង ២៧ នេះមានបច្ច័យតែ ១ គឺ "ណិក", ចុះតែបច្ច័យ ១ នេះដូចគ្នាទាំងអស់ ដូច្នេះ ៖

តរតិតទ្ធិតៈ នាវាយ-តរតី'តិ > នាវិកោ (ជនោ) "(ជន) ឆ្លង...ដោយទូក" ។

សំសដ្ឋតទ្ធិតៈ តិលេន-សំសដ្ឋំ-(ភោជនំ) > តេលិកំ[១] "ភោ-ជន (ដែលជនលាយហើយដោយល្ង = (ភោជនលាយល្ង)" ។

---

១ បើតាមដំណើរវិគ្គហៈ គួរចងថា តិលេន-សំសដ្ឋំ > តេលិកំ (ភោជនំ) ។

ចរតិតទ្ធិតៈ សកដេន - ចរតី´តិ > សាកដិកោ (ជនោ) ‟(ជន) ដើរដោយរទេះ″, ធម្មេន-ចរតី´តិ > ធម្មិកោ (ជនោ) (ជន) ប្រព្រឹត្តតាមធម៌″ ។

វហតិតទ្ធិតៈ សីសេន-វហតី´តិ> > សីសិកោ (ជនោ) ‟(ជន) នាំទៅ...ដោយក្បាល″ ។

វសតិតទ្ធិតៈ មគធេ-វសតី´តិ > មាគធិកោ (ជនោ) ‟(ជន) នៅក្នុងដែនមគធៈ″ ។

ជាតតទ្ធិតៈ ឥន្ទបត្ថេ-ជាតោ > ឥន្ទបត្ថិកោ (ជនោ) ‟(ជន) កើតហើយក្នុងនគរឥន្ទបត្ថ″ ។

អធិតេតទ្ធិតៈ វិនយំ-អធិតេ´តិ > វេនយិកោ (ភិក្ខុ) ‟(ភិក្ខុ) រៀននូវវិន័យ = អ្នករៀនវិន័យ″ ។

កតតទ្ធិតៈ កាយេន-កតំ-(កម្មំ) > កាយិកំ[១] ‟(អំពើ) ដែលបុគ្គលធ្វើហើយដោយកាយ″, វចសា-កតំ-(កម្មំ) > វាចសិកំ

១ តាមដំណើរវិគ្គហៈ ថា កាយេន-កតំ> កាយិកំ (កម្មំ) ។

"(អំពើ) ដែលបុគ្គលធ្វើហើយដោយសម្តី", មនសា-កតំ-(កម្មំ) > មានសិកំ "(អំពើ) ដែលបុគ្គលធ្វើហើយដោយចិត្ត" (ចុះស-អាគម) ។

វត្តិតទ្ធិតៈ កាយេ-វត្តតី'តិ > កាយិកំ (កម្មំ) "(កម្ម) ប្រព្រឹត្តទៅក្នុងកាយ", មនសិ-វត្តតី'តិ > មានសិកំ (កម្មំ) "(កម្ម) ប្រព្រឹត្តទៅក្នុងចិត្ត" ។

សន្និធានតទ្ធិតៈ សរីរេ-សន្និធានា-(វេទនា) > សារីរិកា(១) "(វេទនា) អាស្រ័យនៅក្នុងសរីរៈ" ។

និយុត្តតទ្ធិតៈ ទ្វារេ-និយុត្តោ > ទោវារិកោ (ជនោ) "(ជន) ប្រកបក្នុងទ្វារ", ភណ្ឌាគារេ-និយុត្តោ > ភណ្ឌាគារិកោ (ជនោ) "(ជន) ប្រកបក្នុងឃ្លាំង" ។

សិប្បតទ្ធិតៈ វីណា-អស្ស-សិប្បន្តិ(២) > វេណិកោ (ជនោ) "(ជន) មានពិណជាសិល្បៈ" ។

ភណ្ឌតទ្ធិតៈ គន្ធោ-អស្ស-ភណ្ឌំ(៣) > គន្ធិកោ (ជនោ) "(ជន) មានគ្រឿងក្រអូបជាទ្រព្យ" ។

---

១ សរីរេ-សន្និធានា > សារីរិកា (វេទនា) ។ ២-៣ សិប្ប និង ភណ្ឌ នេះជាសាធារណនាមនាម នបុំ. តែក្នុងទីនេះប្រើដូចគុណនាម ។

ជីវិតិតទ្ធិតៈ ឧរម្ភំ(១)-ហន្ត្វា-ជីវតី'តិ > ឱរម្ភិកោ (ជនោ) "(ជន) សម្លាប់នូវចៀមហើយចិញ្ចឹមជីវិត" ។

ហតតទ្ធិតៈ ជាលេន(២)-ហតោ > ជាលិកោ (សត្តោ) "(សត្វ) ដែលជនសម្លាប់ហើយដោយសំណាញ់" ។

ពន្ធតទ្ធិតៈ សុត្តេន-ពន្ធោ > សុត្តិកោ (សត្តោ) "(សត្វ) ដែលជនចងហើយដោយចេស" ។

អាវុធតទ្ធិតៈ មុសលោ-អស្ស-អាវុធោ > មោសលិកោ (ជនោ) "(ជន) មានអង្រែជាអាវុធ" ។

អាពាធតទ្ធិតៈ វាតោ-អស្ស-អាពាធោ > វាតិកោ (ជនោ) "(ជន) មានខ្យល់ជាអាពាធ" ។

បសន្នតទ្ធិតៈ ពុទ្ធេ-បសន្នោ > ពុទ្ធិកោ (ជនោ) "(ជន) ជ្រះថ្លាក្នុងព្រះពុទ្ធ = (ជ្រះថ្លាចំពោះព្រះពុទ្ធ)" ។

សន្តកតទ្ធិតៈ សង្ឃស្ស-សន្តកំ > សង្ឃិកំ (ភណ្ឌំ) "(ភណ្ឌៈ) ជារបស់នៃសង្ឃ" ។

---

១ ក្នុងអភិធានប្បទីបិកាថា "ឧរព្ភ" ដូចគ្នានឹងសព្ទថា "ឯឡក" ប្រែថា "ចៀម ឱរព្ភេ ហន្ត្វា-ជីវតី'តិ > ឱរព្ភិកោ (ជនោ), មានក្នុងបិដកច្រើនអន្លើក៏ជា ឧរព្ភ ឱរព្ភិក យ៉ាងនេះ ។

២ ជាល-សព្ទនេះប្រែថា "បណ្ដាញ, សំណាញ់, បង្កាត់, បន្ទឹង" ។

កីតតទ្ធិតៈ សុវណ្ណេន-កីតំ-(ភណ្ឌំ) > សោវណ្ណិកំ[១] "(ភណ្ឌៈ) ដែលជនទិញហើយដោយមាស" ។

បរិមាណតទ្ធិតៈ កុម្ភោ-អស្ស-បរិមាណំ[២] > កុម្ភិកំ (វត្ថុ) "(វត្ថុ) មានផ្ទាំងជាប្រមាណ = (ប្រមាណមួយផ្ទាំង ឬ ប្រមាណប៉ុនផ្ទាំង) " ។

រាសិតទ្ធិតៈ កុម្ភស្ស[៣]-រាសិ > កុម្ភិកោ "គំនរនៃផ្ទាំង" កដ្ឋស្ស-រាសិ > កដ្ឋិកោ "គំនរនៃឈើ" ។

អរហតិតទ្ធិតៈ កុម្ភំ-អរហតី'តិ > កុម្ភិកោ (ជនោ) "(ជន) គួរ (ដើម្បីនាំទៅ) នូវទ្រព្យមួយកុម្ភៈ" ឬ (មណិ) (កែវមណី) គួរនូវទ្រព្យមួយកុម្ភៈ" ។

ទិព្វតិតទ្ធិតៈ អក្ខេន-ទិព្វតី'តិ > អក្ខិកោ (ជនោ) "(ជន) លេងដោយខ្នាច់-ដោយស្កា" ។

វិទិតតទ្ធិតៈ លោកេ-វិទិតោ > លោកិកោ (ធម្មោ) "(ធម៌) ប្រាកដហើយក្នុងលោក" ។

---

១ តាមដំណើរវិគ្គហៈថា សុវណ្ណេន-កីតំ > សោវណ្ណិកំ (ភណ្ឌំ) ។

២ ជាសាធារណនាមនាម នបុំ. ក្នុងទីនេះប្រើដូចគុណនាម ។

៣ កុម្ភានំ-រាសិ > កុម្ភិកោ ក៏បាន ។

សំវត្តតិតទ្ធិតៈ[១] លោកាយ-សំវត្តតី´តិ > លោកិកោ (ធម្មោ) "(ធម៌) ប្រព្រឹត្តទៅព្រមដើម្បីសត្វលោក" ។

ក្នុងបករណៈឯទៀតក្រៅពីកច្ចាយនៈ ថាចុះបច្ច័យ ៣ គឺ "ឯយ្យ, ឯយ្យក, ណក" ក្នុងវសតិតទ្ធិតនិងជាតតទ្ធិតក៏បានខ្លះ ។ ឯយ្យ និង ឯយ្យក, ចម្បាយនគរេ-វសតី´តិ > ចម្បេយ្យោ ចម្បេយ្យកោ (ជនោ) "(ជន) នៅក្នុងនគរចម្បា", ចម្បាយំ-ជាតោ > ចម្បេយ្យោ, ចម្បេយ្យកោ (ជនោ) "(ជន) កើតហើយក្នុងនគរចម្បា" ពារាណសី "នគរពារាណសី", ពារាណសេយ្យោ, ពារាណសេយ្យកោ "(ជន) នៅ ឬ កើតហើយក្នុងនរគពារាណសី" ។ ណកៈ កុសិនារាយំ-វសតី´តិ > កោសីនារកោ (ជនោ) "(ជន) នៅក្នុងនគរកុសិនារា" មគធេ-ជាតោ > មាគធកោ (ជនោ) (ជន) កើតហើយក្នុងដែនមគធៈ ។

---

១ បណ្ដាតទ្ធិតទាំង ២៧ ឈ្មោះនេះ តទ្ធិតណាដែលហៅលាយដោយអាខ្យាតបទដូចយ៉ាង តរតិ-តទ្ធិត ចរតិ-តទ្ធិត ជាដើមនោះ គឺហៅឲ្យជាប់ដោយសព្ទក្នុងវិគ្គហៈ តែបើនឹងហៅឈ្មោះឲ្យលាយដោយសព្ទត្រឹមតែធាតុដើម ឬលាយដោយសព្ទនាមនាមថា តរ-តទ្ធិត, ចរ-តទ្ធិត ឬ តរណ-តទ្ធិត, ចរណ-តទ្ធិត, ។ល។ ដូច្នេះក៏បាន ។

## រាគាទិតទ្ធិត

[១៤២] រាគាទិតទ្ធិតនេះចែកចេញជាឈ្មោះមាន ១៣ យ៉ាងគឺ រាគតទ្ធិត ១ ឥទំតទ្ធិត ១ ភវតទ្ធិត ១ ជាតតទ្ធិត ១ អាគតតទ្ធិត ១ និយុត្តតទ្ធិត ១ ទេវតាតទ្ធិត ១ អវេច្ចធិតេតទ្ធិត ១ វិសយតទ្ធិត ១ សន្តិតទ្ធិត ១ និព្វត្តតទ្ធិត ១ និវាសតទ្ធិត ១ ឥស្សរតទ្ធិត ១ ។

តទ្ធិតទាំង ១៣ នេះមានបច្ច័យតែ ១ គឺ "ណ" ចុះតែបច្ច័យ ១ នេះដូចគ្នាទាំងអស់ ដូច្នេះ ៖

រាគតទ្ធិតៈ កសាវេន-រត្តំ-(វត្ថំ) > កាសាវំ[១] "(សំពត់) ដែលជនជ្រលក់ហើយដោយទឹកចត់" ។

ឥទំតទ្ធិត សូករស្ស-ឥទំ-មំសំ > សោករំ "សាច់នេះនៃជ្រូក" ឬ (សាច់) "នេះជាសាច់នៃជ្រូក" ។

ភវតទ្ធិតៈ ឧទុម្ពរស្ស-អវិទូរេ-ភវំ-វិមានំ > ឱទុម្ពរំ "វិមានកើតក្នុងទីជិតនៃដើមល្វា" ។

១ តាមដំណើរវិគ្គហៈ ថា កសាវេន-រត្តំ > កាសាវំ (វត្ថំ) ។

ជាតតទ្ធិតៈ មគធេ-ជាតោ > មាគធោ (ជនោ) "(ជន) កើតហើយក្នុងដែនមគធៈ" ។

អាគតតទ្ធិតៈ មគធស្មា-អាគតោ > មាគធោ (ជនោ) "(ជន) មកហើយអំពីដែនមគធៈ"

និយុត្តតទ្ធិតៈ កត្តិកាយ-និយុត្តោ-(មាសោ) > កត្តិកោ[១] "(ខែ) ប្រកបដោយកត្តិកាឫក្ស" = (ខែកត្តិក)" ។

ទេវតាតទ្ធិតៈ ពុទ្ធោ-អស្ស-ទេវតា'តិ > ពុទ្ធោ (ជនោ) "(ជន) មានព្រះពុទ្ធជាទេវតា" ។

អវេច្ចធិតេតទ្ធិតៈ សំវច្ឆរំ-អវេច្ច-អធិតេ > សំវច្ឆរោ (ជនោ) "(ជន) ពិចារណាហើយរៀននូវឆ្នាំ" ។

វិសយតទ្ធិតៈ កុន្តានំ-វិសយោ-(ទេសោ) > កុន្តោ[៣] "(ប្រទេស) ជាទីនៅនៃសត្វក្រៀល ។

សន្និតទ្ធិតៈ ឧទុម្ពរា-អស្មឹ-(បទេសេ)-សន្តិ > ឱទុម្ពរោ[៤] "(ប្រទេស) មានដើមល្វា" ។

---

១ តាមដំណើរវិគ្គហៈថា កត្តិកាយ-និយុត្តោ > កត្តិកោ (មាសោ) ។ ២ នាមនាមប្រើដូចគុណនាម ។ ៣ កុន្តានំ-វិសយោ > កុន្តោ (ទេសោ) ។ ៤ ឧទុម្ពរា-អស្មឹ-សន្តី'តិ > ឱទុម្ពរោ (បទេសោ) ។

និព្វត្តតទ្ធិតៈ សាគរេហិ - (រាជកុមារេហិ) - និព្វត្តោ´តិ > សាគរោ (សមុទ្ទោ) "(សមុទ្ទ) កើតហើយដោយសារ (ព្រះរាជ-កុមារ) ជាបុត្រនៃស្តេចសគរៈ(១)" ។

និវាសតទ្ធិតៈ មគធោ-អស្ស-និវាសោ´តិ > មាគធោ (ជនោ) "(ជន) មានដែនមគធៈជាទីនៅអាស្រ័យ" ។

ឥស្សរតទ្ធិតៈ មថុរាយ-ឥស្សរោ > មាថុរោ (ជនោ) "(ជន) ជាឥស្សរៈ ក្នុងនគរមថុរា" ។

## ជាតាទិតទ្ធិត

[១៤៣] បច្ច័យសម្រាប់ចុះក្នុងជាតាទិតទ្ធិតមាន ៤ គឺ ឥម, ឥយ, ឥក, កិយ ។ ពាក្យថា "ជាតាទិតទ្ធិត" នេះ គ្រាន់តែជាឈ្មោះដើមនៃប្រភេទរបស់សាមញ្ញតទ្ធិតប៉ុណ្ណោះ មិនមែនជាឈ្មោះតទ្ធិតមួយយ៉ាងដោយដាច់ខាតតែម្នាក់ឯងទេ, ដល់ញែកឈ្មោះចេញដោយឡែកទៅ, តទ្ធិតនេះចេញទៅជាឈ្មោះមាន ៣ យ៉ាង គឺ ជាតតទ្ធិត ១ និយុត្តតទ្ធិត ១ អត្ថិតទ្ធិត ១ ។

---

១ ក្នុងរឿងរាមាយណៈ (ជារឿងព្រេង យូរអង្វែងណាស់ទៅហើយ) ថា សមុទ្ទបានជាហៅថា "សាគរ" ពីព្រោះកើតដោយសារពួកព្រះរាជកុមារជាបុត្រនៃស្តេចសគរៈកេណ្ឌាពលឲ្យជីក ។

ជាតតទ្ធិតចុះបានបច្ច័យ ២ គឺ ឥម ឥយ ។ ឥមៈ បុរេ-ជាតោ > បុរិមោ (ជនោ) "(ជន) កើតហើយក្នុងកាលមុន", មជ្ឈេ-ជាតា > មជ្ឈិមា (ឥត្ថី) "(ស្រី) កើតហើយក្នុងកណ្ដាល", បច្ឆា-ជាតំ > បច្ឆិមំ (ធនំ) "(ទ្រព្យ) កើតហើយក្នុងខាងក្រោយ", គោប្ផេ-ជាតោ > គោប្ផិមោ (រោគោ) "(រោគ) កើតត្រង់កជើង" ។ ឥយៈ មនុស្សជាតិយា[១]-ជាតោ > មនុស្សជាតិយោ (សត្តោ) "(សត្វ) កើតហើយដោយជាតិនៃមនុស្ស", ហត្ថិជាតិយា-ជាតោ > ហត្ថិជាតិយោ (សត្តោ) "(សត្វ) កើតហើយដោយជាតិនៃដំរី" ។

និយុត្តតទ្ធិតចុះបានគ្រប់ទាំង ៤ បច្ច័យ ។ ឥមៈ អន្តេ-និយុត្តោ > អន្តិមោ (ជនោ) "(ជន) ប្រកបហើយក្នុងទីបំផុត" ។ ឥយៈ អន្តេ-និយុត្តោ > អន្តិយោ (ជនោ) ។ ឥកៈ អន្តេ-និយុត្តោ > អន្តិកោ (ជនោ) ។ កិយៈ អន្ធេ - និយុត្តោ > អន្ធ-

---

១ សព្ទប្រកបដោយបទសមាសយ៉ាងនេះ, បើចង់ញែកឲ្យឃើញដោយឡែក, ត្រូវចងវិគ្គហៈសមាសសិន, ដូចបទនេះ ចងថា មនុស្សានំ-ជាតិ > មនុស្សជាតិ (ឆដ្ឋីតប្បុរិស) ។

កិយោ (ជនោ) "(ជន) ប្រកបក្នុងងងឹត", ជច្ចន្ធោ[១]-និយុត្តោ > ជច្ចន្ធកិយោ (ជនោ) "(ជន) (ប្រកបក្នុងងងឹតអំពីកំណើត = (ខ្វាក់អំពីកំណើត) ។

អត្ថិតទ្ធិតចុះបានបច្ច័យ ៣ គឺ ឥម, ឥយ, ឥក ។ ឥមៈ បុត្តោ - យស្ស - អត្ថិ´តិ > បុត្តិមោ (បុរិសោ) " (បុរស) មានកូន" ។ ឥយៈ បុត្តោ - យស្សា - អត្ថិ´តិ > បុត្តិយា (ឥត្ថី) "(ស្រ្តី មានកូន" ចុះអា-បច្ច័យផង) ។ ឥកៈ បុត្តោ - យស្ស-អត្ថិ´តិ > បុត្តិកំ (កុលំ) "(ត្រកូល) មានកូន" ។

## សមូហតទ្ធិត

[១៤៤] ក្នុងសមូហតទ្ធិតមានបច្ច័យ ៣ គឺ កណ[២],ណ,តា ។

កណៈ រាជបុត្តានំ[២] - សមូហោ > រាជបុត្តកោ "ប្រជុំនៃរាជ-បុត្រ" ឬ "ពួកនៃរាជបុត្រ", មនុស្សានំ - សមូហោ > មានុស្សកោ "ប្រជុំនៃមនុស្ស" ឬ "ពួកនៃមនុស្ស", មយូរានំ - សមូហោ > មាយូរកោ "ហ្វូងនៃក្ងោក" ។

---

១ ចងវិគ្គហៈបញ្ចមីតប្បុរិសសមាសថា ជាតិយា-អន្ធោ > ជច្ចន្ធោ "ងងឹតពីកំណើត" រូបសិទ្ធិ, ជាតិ+អន្ធ, តិ > ច, ច > ច្ច, ជា > ជ, ជច្ច + អន្ធ > ជច្ចន្ធ ។ ២ ក្នុងកច្ចាយនបករណ៍អក្សរភូមាថា ក័ណ ។ ៣ ចងវិគ្គហៈឆដ្ឋីតប្បុរិសសមាសថា រញ្ញោ-បុត្តា > រាជបុត្តា ។

ណៈ រាជបុត្តានំ - សមូហោ > រាជបុត្តោ, មនុស្សានំ-សមូហោ > មានុស្សោ, មយូរានំ - សមូហោ > មាយូរោ (ប្រែដូចខាង កណ-បច្ច័យដែរ) ។

តា[១] គាមានំ - សមូហោ > គាមតា "ប្រជុំនៃស្រុក", ជនានំ - សមូហោ > ជនតា "ប្រជុំនៃជន", ពន្ធូនំ - សមូហោ ពន្ធុតា "ប្រជុំនៃផៅពង្ស", សហាយានំ - សមូហោ > សហាយតា "ប្រជុំនៃសំឡាញ់" (ជាឥត្ថីលិង្គ) ។

### ឋានតទ្ធិត

[១៤៥] ក្នុងឋានតទ្ធិតមានបច្ច័យតែ ១ គឺ "ឦយ" ឧ. មទនស្ស - ឋានំ > មទនីយំ "ហេតុជាទីតាំងនៃសេចក្ដីស្រវឹង",

---

១ ក្នុងបករណៈជាច្រើន ប្រាប់ថា សព្ទថា ទេវតា, ធម្មតា, បារមីតា ក៏ចុះតា-បច្ច័យនេះដែរ,ប៉ុន្តែចុះក្នុង សកត្ថៈ "អត្ថរបស់ខ្លួន" គឺគ្រាន់តែចុះមកដើម្បីបំបែរសព្ទដែលជាបុំលិង្គ ឬ នបុំ.សកលិង្គ ឲ្យក្លាយមកជាឥត្ថីលិង្គ ឬក៏សព្ទដែលជាឥត្ថីលិង្គស្រាប់ ចុះបច្ច័យនេះមកដើម្បីឲ្យប្លែកជាងលំនាំដើមប៉ុណ្ណោះ ។ លោកប្រាប់ដំណើរសកត្ថៈនោះដូច្នេះថា "ទេវោ ឯវ ទេវតា, ធម្មោ ឯវ ធម្មតា, បារមី ឯវ បារមីតា" សេចក្ដីថា "សព្ទថា ទេវតា, ធម្មតា, បារមីតា ក៏ដូចគ្នានឹងសព្ទថា ទេវោ, ធម្មោ, បារមី ដែរ" ។ ឲ្យចុះ "និ" បច្ច័យក្នុងសកត្ថៈថែមមកទៀតជា "ទេវតានិ" ដើម្បីឲ្យក្លាយជានបុំសកលិង្គក៏មាន, លោកប្រាប់សកត្ថៈ របស់និ-បច្ច័យថា "ទេវតា ឯវ ទេវតានិ", សព្ទថា ទេវតានិ ក៏ដូចគ្នានឹងសព្ទថា ទេវតា ដែរ ឬថា សព្ទថា ទេវតានិ ក៏គឺសព្ទថា ទេវតា ហ្នឹងឯង ។

ពន្ធនស្ស - ឋានំ > ពន្ធនីយំ "ហេតុជាទីតាំងនៃកិរិយាចង", ទុស្ស-នស្ស - ឋានំ > ទុស្សនីយំ "ហេតុជាទីតាំងនៃសេចក្ដីប្រទូស្ត" ។

ក្នុងបករណៈឯទៀតក្រៅពីកច្ចាយនៈ មានសទ្ទនីតិបករណ៍ជាដើមប្រាប់ថាបច្ច័យ ២ គឺ "ណីយ, ឯយ្យ" ចុះក្នុងអត្ថ ៣ យ៉ាងគឺ "ហិត, ភវ, អរហ" ។ ណីយ ចុះក្នុងហិតៈ ឧបាទានានំ-ហិតំ > ឧបាទានីយំ " ធម្មជាតជាគ្រឿងទំនុកបម្រុងដល់ឧបាទាន ឬ "សេចក្ដីទំនុកបម្រុងដល់ឧបាទាន" (ឈ្មោះហិតតទ្ធិត) ។ ណីយ ចុះក្នុងភវៈ ឧទរេ - ភវំ > ឧទរិយំ (ភោជនំ) "(ភោជន) មានក្នុងពោះ = (អាហារថ្មី)" (ឈ្មោះភវតទ្ធិត) ។ ណីយ និងឯយ្យ ចុះក្នុងអរហៈ បូជនំ - អរហតី'តិ > បូជនីយោ, បូជនេយ្យោ (ជនោ) "(ជន) គួរនូវកិរិយាបូជា" ឬ "(ជន) គួរ (ដើម្បីទទួល) នូវកិរិយាបូជា", បូជនស្ស - អរហតី'តិ - វា > បូជនីយោ, បូជ-នេយ្យោ (ជនោ) "ម្យ៉ាងទៀតថា (ជន) គួរដល់កិរិយាបូជា" (ឈ្មោះអរហតិតទ្ធិត ឬ ហៅត្រឹមតែ អរហតទ្ធិតក៏បាន) ។

## ឧបមាតទ្ធិត

[១៤៦] ក្នុងឧបមាតទ្ធិតមានបច្ច័យតែ ១ គឺ "អាយិតត្ត" ឧ. ធូមោ វិយ -ទិស្សតិ - អទុំ - វត្ថុ - តទិទំ > ធូមាយិតត្តំ[១] "(វត្ថុ) ប្រាកដដូចជាផ្សែង", តិមិរំ វិយ - ទិស្សតិ - អទុំ - វត្ថុ - តទិទំ > តិមិរាយិតត្តំ[១] (វត្ថុ) ប្រាកដដូចជាអ័ព្ទ ។

## និស្សិតតទ្ធិត

[១៤៧] ក្នុងនិស្សិតតទ្ធិតមានបច្ច័យតែ ១ គឺ "ល" ចុះក្នុងអត្ថ ២ យ៉ាង គឺ និស្សិត និង ឋានៈ ។

ល ចុះក្នុង និស្សិតៈ ទុដ្ឋុំ-និស្សិតំ > ទុដ្ឋុល្លំ (កម្មំ) "(កម្ម) អាស្រ័យហើយនូវសេចក្តីអាក្រក់" (ចុះល - អាគម), វេទំ - និស្សិតំ > វេទល្លំ (ធម្មជាតំ) "(ធម្មជាត) អាស្រ័យហើយនូវប្រាជ្ញា" (ឈ្មោះនិស្សិតតទ្ធិត) ។

---

១ ចងវិគ្គហៈថាៈ ធូមោ-វិយ-ទិស្សតី'តិ > ធូមាយិតត្តំ (វត្ថុ), តិមិរំ-វិយ-ទិស្សតី'តិ > តិមិរាយិតត្តំ (វត្ថុ) តែត្រឹមប៉ុណ្ណោះក៏បាន ។

ល ចុះក្នុងឋានៈ ទុដ្ឋស្ស - ឋានំ > ទុដ្ឋុល្លំ "ហេតុជាទីតាំងនៃសេចក្ដីអាក្រក់", វេទស្ស - ឋានំ > វេទល្លំ "ហេតុជាទីតាំងនៃប្រាជ្ញា" (ឈ្មោះឋានតទ្ធិត) ។

## ពហុលតទ្ធិត

[១៤៨] ក្នុងពហុលតទ្ធិតមានបច្ច័យតែ ១ គឺ "អាលុ" ចុះក្នុងអត្ថ ២ យ៉ាង គឺ បកតិ និង ពហុល ។

អាលុ ចុះក្នុងបកតិៈ អភិជ្ឈា - អស្ស - បកតិ > អភិជ្ឈាលុ (ជនោ) "(ជន) មានអភិជ្ឈាជាប្រក្រតី", សីតំ - ឯត្ថ - បកតិ > សីតាលុ (បទេសោ) "(ប្រទេស) មានត្រជាក់ជាប្រក្រតី", ធជោ - ឯត្ថ- បកតិ[១] > ធជាលុ (បាសាទោ) "(ប្រាសាទ) មានទង់ជាប្រក្រតី" (ឈ្មោះបកតិតទ្ធិត) ។

អាលុ ចុះក្នុងពហុលៈ អភិជ្ឈា - អស្ស - ពហុលា > អភិជ្ឈាលុ (ជនោ) "(ជន) មានអភិជ្ឈាច្រើន", សីតំ - ឯត្ថ - ពហុលំ > សីតាលុ (បទេសោ) "(ប្រទេស) មានត្រជាក់ច្រើន"

---

១ សាធារណនាមនាម ឥ. ប្រើដូចគុណនាម ។

ធជោ - ឯត្ត - ពហុលោ > ធជាលុ (បាសាទោ) "(ប្រាសាទ) មានទង់ច្រើន" (ឈ្មោះពហុលតទ្ធិត) ។

## សេដ្ឋតទ្ធិត

[១៤៩] ក្នុងសេដ្ឋតទ្ធិតមានបច្ច័យ ៥ គឺ តរ, តម, ឥយិស្សក, ឥយ, ឥដ្ឋ ។

តរៈ បាបតរោ "(ជន) លាមកដោយវិសេស = លាមកជាង, លាមកយ៉ាងល្មម", បណ្ឌិតតរោ "(ជន) ជាបណ្ឌិតដោយវិសេស = (ជាបណ្ឌិតយ៉ាងល្មម", នីចតរំ "... ទាបជាង", បណីតតរំ "...ថ្លៃថ្លាជាង", ខុទ្ទកតរោ "... តូចជាង" ។

តមៈ បាបតមោ "... លាមកបំផុត, អាក្រក់ផុត...", មហន្តតមោ "... ធំបំផុត ...", ឧច្ចតមំ "...ខ្ពស់បំផុត...", បណីតតមោ "... ថ្លៃថ្លាបំផុត ..." ។

ឥយិស្សកៈ បាបិយិស្សកោ "(ជន) លាមកដោយវិសេស = (លាមកយ៉ាងល្មម)" ។ ឥយិស្សកនេះ[៣] មិនសូវប្រើទេ ។

១ ក្នុងកច្ចាយនបករណ៍អក្សរភូមាថា "ឥសិក" ឧ. បាបិសិកោ ។

ឥយៈ បាបិយោ "... លាមកដោយវិសេស = (លាមកយ៉ាងល្មម)", កនិយោ "... តូចជាង" (តាំង អប្ប "តូច" ហើយផ្លាស់ អប្ប ជា ក័ណ, ផ្លាស់ ណ របស់ ក័ណ ជា "ន", ក័ន + ឥយ > កនិយ), សេយ្យោ "...ប្រសើរជាង" (តាំង បសដ្ឋ "ប្រសើរ" ហើយផ្លាស់ បសដ្ឋ ជា "ស" វិការៈ ឥ របស់ ឥយ ជា "ឯ" តម្រួត យ ជា "យ្យ", ស + ឯយ្យ > សេយ្យ), ជេយ្យោ "... ចម្រើនជាង" ឬ "...ប្រសើរជាង" (តាំង វុឌ្ឍ "ចម្រើន" ឬតាំង បសដ្ឋ "ប្រសើរ" ក៏បាន, ផ្លាស់វុឌ្ឍ ឬ បសដ្ឋ ជា "ជ", ផ្លាស់ ឥ របស់ ឥយ ជា "ឯ", តម្រួត យ ជា "យ្យ", ជ + ឯយ្យ > ជេយ្យ) ។

ឥដ្ឋៈ បាបិដ្ឋោ "...លាមកបំផុត...", កនិដ្ឋោ "...តូចបំផុត...", សេដ្ឋោ "...ប្រសើរបំផុត...", ជេដ្ឋោ "...ចម្រើនបំផុត...", ឬ "...ប្រសើរបំផុត...", (បែបរូបសិទ្ធិ មើលខាងឥយ-បច្ច័យ) ។

តរ, ឥយិស្សក, ឥយ ៣ នេះសម្រាប់ចុះក្នុងវិសេសគុណសព្ទ, តម, ឥដ្ឋ ២ នេះសម្រាប់ចុះក្នុងអតិវិសេសគុណសព្ទ,

តាមន័យដែលបាននិយាយក្នុងនាមនិទ្ទេស ត្រង់លេខ ៤១ និង ៤២ រួចហើយ ។

បែបតាំងវិគ្គហៈខាង តរ, តយិស្សក, តយ ដូច្នេះ សព្វេ-តមេ-បាបា-អយ-មិមេសំ វិសេសេន-បាបោ´ តិ > បាបតរោ, បា-បិយិស្សកោ, បាបិយោ (ជនោ) "ជនទាំងឡាយនេះ ទាំងអស់គ្នាលាមក, ជននេះ លាមក ដោយវិសេស (ប្លែក) ជាងជនទាំង-ឡាយនេះ, ព្រោះហេតុនោះ (សោ - ជនោ ជននោះ) ឈ្មោះបា-បតរោ ឈ្មោះបាបិយិស្សកោ, ឈ្មោះបាបិយោ" (ជន) "លាមកប្លែកជាងជនទាំងនេះ = (អាក្រក់ជាងគេ)" ។

បែបតាំងវិគ្គហៈខាង តម, តដ្ឋ ដូច្នេះ អយញ្ច - បាបោ-អយញ្ច -បាបោ- សព្វេ - តមេ - បាបា - អយ - មិមេសំ វិសេសេន-បាបោ[១] តិ > បាបតមោ, បាបិដ្ឋោ (ជនោ) "ជននេះ ក៏លា-

១ វិគ្គហៈទាំង ២ បែបនេះ ចងផ្សេងពីគ្នា ដើម្បីឲ្យឃើញដំណើរសេចក្តីរបស់វិសេសគុណនាម និងអតិវិសេសគុណនាម ដែលប្លែកគ្នា ប៉ុន្តែក្នុងបករណៈទាំងពួង ជួនណាលោកប្រើវិគ្គហៈតែបែបមួយដូចគ្នា គឺបណ្តាវិគ្គហៈទាំង ២ បែបនុ៎ះ តាមតែយកបែបណាប្រើក៏បាន(ច្រើនឃើញប្រើតែបែបវិគ្គហៈខាងលើ) ។

មក ជននេះ ក៏លាមក, ជនទាំងឡាយនេះ ទាំងអស់គ្នា លាមក, ជននេះ លាមក ដោយប្លែក ជាងជនទាំងឡាយនេះ ព្រោះហេតុដូច្នោះ (សោ - ជនោ ជននោះ) ឈ្មោះបាបតមោ, ឈ្មោះបាបិដ្ឋោ "(ជន) លាមកបំផុតជាងជនទាំងអស់នេះ = (លាមកបំផុត, អាក្រក់ផ្តាច់)" ។

## តទស្សត្ថិតទ្ធិត

[១៥០] ក្នុងតទស្សត្ថិតទ្ធិតមានបច្ច័យ ៩ គឺ វី, ស[១], សី, ឥក, ល្ល, រ, វន្តុ, មន្តុ, ណ ។ តទស្សត្ថិតទ្ធិតនេះ មានបែបចងវិគ្គហៈពីរយ៉ាង គឺ ចងដោយប្រើអាខ្យាតបទក្នុងវិគ្គហៈជា "អត្ថិ" ម្យ៉ាង, ជា "វិជ្ជតិ" ម្យ៉ាង, បើចងដោយ អត្ថិ ហៅថា អត្ថិតទ្ធិត, ចងដោយ វិជ្ជតិ ហៅថា វិជ្ជតិតទ្ធិត, ប្រែថា "មាន" ដូចគ្នា[២] ។

---

១ ក្នុងកច្ចាយនបករណ៍ថាៈ សោ បច្ចយោ, ពាក្យមេសូត្រសម្រាយច្រើនតែថា "ចុះសោ-បច្ច័យ..." ពាក្យមេសូត្រនោះច្រឡំទេ, កុំប្រែថា "បច្ច័យ គឺ សោ" ប្រែថា "បច្ច័យ គឺ ស" ដូច្នេះទើបត្រូវ, ពីព្រោះបច្ច័យនេះជា តិលិង្គិកៈ ហៅសោ-បច្ច័យ ដូចម្ដេចបាន ។ ២ បើមានដំណើរសេចក្ដីជាសម្ពន្ធឆដ្ឋីត្រូវចងវិគ្គហៈជាអត្ថិតទ្ធិត, បើមានលំនាំសេចក្ដីប្រាប់ទី ត្រូវចងវិគ្គហៈជាវិជ្ជតិតទ្ធិត, តែបើសព្ទមានទំនងសេចក្ដីដែលគួរប្រើបានទាំង ២ យ៉ាង នោះតាមតែចងវិគ្គហៈខាងណាក៏បាន, ឯវិគ្គហៈដែលចងក្នុងទីនេះ គ្រាន់តែជាបែបឲ្យយល់ក្នុងដំណើរនៃការសិក្សាប៉ុណ្ណោះ ។

នឹងចងវិគ្គហៈខាង វិដ្ឋតិ តែបីឧទាហរណ៍ឲ្យឃើញជាបែប, ក្រៅពីនោះចងជា អត្ថិ ទាំងអស់ ។

វីៈ មេធា - យស្ស - អត្ថី៍តិ > មេធាវី (ជនោ) "(ជន) មានប្រាជ្ញា", មេធា - យស្សា - អត្ថី៍តិ > មេធាវិនី (ឥត្ថី) "ស្ត្រី) មានប្រាជ្ញា " (ចុះឥនី បច្ច័យមកផង), មេធា - យស្ស[១] - អត្ថី៍ តិ > មេធាវិ (កុលំ) "(ត្រកូល) មានប្រាជ្ញា" (រស្សៈល្អជាឥ) ។ មេធា - តស្មឹ-វិជ្ជតី៍តិ > មេធាវី (ជនោ) "(ជន) មានប្រាជ្ញា", មេធា - តស្សំ-វិជ្ជតី៍តិ > មេធាវិនី (ឥត្ថី) "ស្ត្រី)" មានប្រាជ្ញា", មេធា - តស្មឹ-វិជ្ជតី៍តិ > មេធាវិ (កុលំ) "(ត្រកូល) មានប្រាជ្ញា", ។ មាយា-យស្ស - អត្ថី៍តិ > មាយាវី (ជនោ) "(ជន) មានមាយា" ។

សៈ សុមេធា - យស្ស - អត្ថី៍តិ > សុមេធសោ (ជនោ) "(ជន) មានប្រាជ្ញាល្អ", (ឥ. ចុះអា-បច្ច័យមកផងជា សុមេ-ធសា, នបុំ, សុមេធសំ) ។

សីៈ តបោ - យស្ស - អត្ថី៍តិ > តបសី (ជនោ) "(ជន) មានតបៈ", តេជោ - យស្ស - អត្ថី៍តិ > តេជសី (ជនោ) "(ជន) មាន

---

១ ត្រង់កន្លែងនេះ ប្រើសព្វនាម ៤ សព្វគឺ "យ, ត, ឯត, ឥម," តាមត្រូវការ ។

តេជះ″, យសោ - យស្ស - អត្ថី´តិ > យសសី (ជនោ) ‶(ជន) មានយស″ (ឥ. តបសិនី, តេជសិនី យសសិនី, នបុំ. តបសិ-តេជសិ, យសសិ) ។

ឥកៈ ទណ្ឌោ - យស្ស - អត្ថី´តិ > ទណ្ឌិកោ (ជនោ) ‶(ជន) មានឈើច្រត់″, មាលា - យស្ស - អត្ថី´តិ > មាលិកោ (ជនោ) ‶(ជន) មានផ្កាកម្រង″ (ឥ. ទណ្ឌិកា, មាលិកា, នបុំ-ទណ្ឌិកំ, មាលិកំ) ។

ឦៈ ទណ្ឌោ - យស្ស - អត្ថី´តិ > ទណ្ឌី (ជនោ), មាលា-យស្ស - អត្ថី´តិ > មាលី (ជនោ) ។ សុខំ - យស្ស - អត្ថី´តិ > សុខី (ជនោ) ‶(ជន) មានសេចក្តីសុខ″ (ឥ. ទណ្ឌិនី, មាលិនី, សុខិនី, នបុំ. ទណ្ឌិ, មាលិ, សុខិ) ។

រៈ មធុ - យស្ស - អត្ថី´ តិ > មធុរោ (បូរោ) ‶ (នំ) មានទឹកឃ្មុំ = (នំមានរសផ្អែម)″, កុញ្ជោ - យស្ស - អត្ថី´តិ > កុញ្ជរោ (សត្តោ) ‶(សត្វ) មានប្រមោយ = (កុញ្ជរ, ដំរី)″, សុសិ[១] - យស្ស - អត្ថី´តិ

១ ឥត្ថីលិង្គ ក្នុងអភិធានប្បទីបិកា ថា សុសី ‶ប្រហោង, រន្ធ, ព្រង់ចន្លោះ″ គឺលោកទីយៈ ឥ-បច្ច័យ (ក្រិត) ជា ឦ ។

សុសិរោ (រុក្ខោ) "(ឈើ) មានប្រហោង", (ឥ, មធុរា, ..., នបុំ. មធុរំ,...) ។

វន្តុៈ គុណោ - យស្ស - អត្ថី´តិ > គុណវា (ជនោ) "(ជន) មានគុណ", បញ្ញា - យស្ស - អត្ថី´តិ > បញ្ញវា (ជនោ) "(ជន) មានប្រាជ្ញា", (រស្សៈ អា របស់បញ្ញាជា អ), សីលំ - យស្ស - អត្ថី´តិ > សីលវា (ជនោ) "(ជន) មានសីល", (ឥ - គុណវន្តី, គុណវតី, ..., នបុំ. គុណវន្តំ, គុណវំ,...) ។

មន្តុៈ សតិ - យស្ស - អត្ថី´តិ > សតិមា (ជនោ) "(ជន) មានស្មារតី",ពន្ធុ - យស្ស - អត្ថី´តិ > ពន្ធុមា (ជនោ) "(ជន) មានផៅពង្ស", អាយុ - យស្ស - អត្ថី´តិ > អាយស្មា (ភិក្ខុ) "(ភិក្ខុ) មានអាយុ" (ផ្លាស់ ឧ របស់អាយុជា អស, អាយ + អស > អាយស,អាយស + មន្តុ > អាយស្មន្តុ) ។ (ឥ. សតិមន្តី, សតិមតី,...,នបុំ. សតិមន្តំ, សតិមំ, ...) ។

សព្ទដែលមានទីបំផុតជា អ ឬ អា ដូច គុណ, សីល, បញ្ញា ជាដើម ត្រូវចុះវន្តុ - បច្ច័យ, សព្ទដែលមានទីបំផុត

ជា ឥ ឬ ឱ ដូច សតិ, ពន្ធុ ជាដើម ត្រូវចុះមន្តុ - បច្ច័យ (មើលក្នុងនាមនិទ្ទេស ត្រង់លេខ ៨០) ។ ក្នុងបករណៈឯទៀតក្រៅពីកច្ចាយនៈ មានសទ្ទនីតិបករណ៍ជាដើមថាសព្ទ គឺ បុត្តិមា "(ជន) មានកូន" បាបិមា "(ជន) មានបាប" ចន្ទិមា[១] "(ចន្ទទេវបុត្រ) មានចន្ទវិមាន" ចុះឥមន្តុ - បច្ច័យ ។

ណៈ សទ្ធា - យស្ស - អត្ថី´តិ > សទ្ធោ (ជនោ) "(ជន) មានសទ្ធា", បញ្ញា - យស្ស - អត្ថី´តិ > បញ្ញោ (ជនោ) "(ជន) មានប្រាជ្ញា", អមច្ឆរំ - យស្ស - អត្ថី´តិ > អមច្ឆរោ[២] (ជនោ) "(ជន) មានសេចក្តីមិនកំណាញ់", (ឥ. សទ្ធា, បញ្ញា,..., នបុំ-សទ្ធំ, បញ្ញំ,...) ។

## បកតិតទ្ធិត

[១៥១] ក្នុងបកតិតទ្ធិតមានបច្ច័យតែ ១ គឺ "ម" ចុះក្នុងអត្ថ ២ យ៉ាង គឺ បកតិ និង វិការ ។

---

១ វិគ្គហៈថាៈ ចន្ទវិមានំ - អស្ស - អត្ថី´តិ > ចន្ទិមា (ចន្ទទេវបុត្តោ),ម្យ៉ាងទៀតថា ចន្ទសំខាតោ ចន្ទោ - អស្ស - អត្ថី´តិ > ចន្ទិមា (ចន្ទ-ទេវបុត្តោ) ។ សព្ទនេះជួនប្រើចំពោះចន្ទវិមានតែម្តងវិគ្គហៈថាៈ ចន្ទោ - អស្មឹ - វិជ្ជតី´តិ > ចន្ទិមំ (វិមានំ) "(វិមាន) មានព្រះចន្ទ" ។

២ មិនព្រឹទ្ធិ ។

មយ ចុះក្នុងបកតិៈ សុវណ្ណេន - បកតំ > សោវណ្ណមយំ (ភាជនំ) "(ភាជន៍) ដែលជនធ្វើហើយដោយមាស = (ភាជន៍មាស)", មត្តិកាយ - បកតំ > មត្តិកាមយំ (ភាជនំ) "(ភាជន៍) ដែលជនធ្វើហើយដោយដីស្អិត=(ភាជន៍ដី)", រជតេន - បកតោ> រជតមយោ (សរកោ) "(ផ្តិល) ដែលជនធ្វើហើយដោយប្រាក់ = (ផ្តិលប្រាក់)", អយសា - បកតោ > អយមយោ[១] "(បត្តោ) (បាត្រ) ដែលជនធ្វើហើយដោយដែក = (បាត្រដែក)", ទារុនា- បកតា > ទារុមយា (សាលា) "(សាលា) ដែលជនធ្វើហើយដោយឈើ = (សាលាឈើ)", គាវេន - បកតំ > គោមយំ (ករីសំ) "(ករីស) ដែលគោធ្វើហើយ = (អាចម៍គោ)" ។

មយ ចុះក្នុងវិការៈ សុវណ្ណស្ស - វិការោ[២] > សោវណ្ណមយំ (ភាជនំ) "(ភាជន៍) ជាវិការៈនៃមាស = (ភាជន៍មាស)", កន- កស្ស - វិការោ > កនកមយំ (ទេវតាវិមានំ) "(វិមាននៃទេវតា)

---

១ ផ្លាស់ អ របស់ យ នៃ អយ ជា ឱ តាមដំណើរមនោគណសព្ទ (មើលនាមនិទ្ទេសត្រង់លេខ ៨៦) ។ ២ វិការោ ប្រែថា "កិរិយាធ្វើប្លែក ជាសាធារណនាមនាម ប៉ុ. តែក្នុងទីនេះប្រើដូចគុណនាម ។

ជាវិការៈនៃមាស″, ឥដ្ឋកាយ - វិការោ > ឥដ្ឋកាមយោ[១] (ថូបោ) "(ស្តូប) ជាវិការៈនៃឥដ្ឋ = (ស្តូបឥដ្ឋ, ចេតិយឥដ្ឋ) ។

សព្ទដែលចុះមយ - បច្ច័យនេះ កាលបើរួមចូលជាបទសមាស ជាមួយនឹងនាមសព្ទឯទៀត ត្រូវលុបបំបាត់ មយ ចេញក៏មាន ឧ. កនកមយំ - វិមានំ > កនកវិមានំ "វិមានដែលបុញ្ញកម្មធ្វើហើយដោយមាស″ ឬ "វិមានជាវិការៈនៃមាស = (វិមានមាស)″ (វិសេសនបុព្វបទកម្មធារយសមាស ជា មជ្ឈេលោប) ។

## បូរណតទ្ធិត

[១៥១] ក្នុងបូរណតទ្ធិតមានបច្ច័យ ៥ គឺ តិយ, ថ, ឋ, ម, អ[២] ហៅថា បូរណបច្ច័យ ។ បច្ច័យទាំង ៥ នេះ សម្រាប់ចុះផ្សំជាមួយនឹងបកតិសំខ្យាតាំងពីទ្វិ[៣] ជាដើមរៀងទៅ បំបែរបកតិ-សំខ្យាឲ្យក្លាយជាបូរណសំខ្យា ដូចបាននិយាយក្នុងនាមនិទ្ទេស

---

១ ក្នុងបករណៈខ្លះប្រាប់ថា មយ - បច្ច័យចុះក្នុងអត្ថឯទៀត មាន និព្វត្ត ជាដើម ក៏បាន ឧ. គោតោ - និព្វត្តំ > គោមយំ (ករីសំ) "(ករីស) កើតហើយអំពីគោ = (អាចម៍គោ)″ ឈ្មោះ និព្វត្តតទ្ធិត ។ ២ មើលលេខយោងក្នុងនាមនិទ្ទេស ត្រង់បូរណសំខ្យា ។ ៣ ត្រង់ ឯក "១″, បើតាមដំណើរសំខ្យា, គួតែផ្សំ ឯក និង ម - បច្ច័យ ជា "ឯកម″ ដូច្នេះ ប៉ុន្តែក្នុងបាឡីភាសាមិនប្រើយ៉ាងនេះទេ ត្រង់កន្លែង ឯក លោកយក បឋ - សព្ទផ្សំនឹង ម - បច្ច័យជា "បឋម″ ប្រែថា "ជាដំបូង″ ឬថា "ទី១″ មកប្រើជំនួសវិញ (មើលនាមនិទ្ទេសត្រង់លេខ ១០៧) ។

តាំងពីលេខ ១០៧ ដល់លេខ ១១០ នោះហើយ, ក្នុងនិទ្ទេសនេះ បូរណសំខ្យាន៎ុះឯង ហៅថា បូរណតទ្ធិត ។ ប៉ុន្តែ, បណ្ដាបច្ច័យទាំង ៥ ន៎ុះ បច្ច័យមួយ ៗ មិនមែនសុទ្ធតែត្រូវចុះបានរាល់សព្ទបកតិសំខ្យានោះទេ, ចុះបានដោយឡែកតាមគួរដល់ការប្រកប, ដូចមានសេចក្ដីសង្ខេបតទៅនេះ ៖

តិយៈ ទ្វិន្នំ - បូរណោ > ទុតិយោ (ជនោ) "(ជន) ជាទីពេញនៃជន ២ នាក់ =(ជនជាគម្រប់ ២ ឬ ជនទី ២)", ទ្វិន្នំ-បូរណី > ទុតិយា (ឥត្ថី) "(ស្រី) ជាទីពេញនៃស្រី ២ នាក់ =(ស្រីជាគម្រប់ ២ ឬ ស្រីទី ២)", ទ្វិន្នំ-បូរណំ > ទុតិយំ (ភាជនំ) "ភាជន៍) ជាទីពេញនៃភាជន៍ ២=(ភាជន៍ជាគម្រប់ ២ ឬ ភាជន៍ទី ២)", (ផ្លាស់ ទ្វិ ជា ទុ, ឥ. ចុះ អា - បច្ច័យមកផង) ។ តិណ្ណំ - បូរណោ > តតិយោ (ជនោ) "(ជន) ជាទីពេញនៃជន ៣ នាក់ = (ជនជាគម្រប់ ៣ ឬ ជនទី ៣), ឥ. តតិយា[១], នបុំ. តតិយំ (ផ្លាស់ តិ ជា ត, ឥ, ចុះ អា - បច្ច័យមកផង ។

១ ឥ. តិស្សន្នំ - បូរណី > តតិយា (ឥត្ថី) ។

ថៈ ចតុន្នំ - បូរណោ > ចតុត្ថោ (ជនោ) "(ជន) ជាទីពេញនៃជន ៤ នាក់ = (ជនជាគម្រប់ ៤ ឬ ជនទី ៤)", ឥ. ចតុត្ថី,[១] (ចតុត្ថា), នបុំ. ចតុត្ថំ (តម្រួត ត លើ ថ ជា ត្ថ, ឥ, ចតុត្ថ + ឦ > ចតុត្ថី, ចតុត្ថ + អា > ចតុត្ថា) ។

ឋៈ ឆន្នំ - បូរណោ > ឆដ្ឋោ[២] (ជនោ) "(ជន) ជាទីពេញនៃជន ៦ នាក់ = ជនជាគម្រប់ ៦ ឬ ជនទី ៦)", ឥ. ឆដ្ឋី, (ឆដ្ឋា),
នបុំ. ឆដ្ឋំ (តម្រួត ដ លើ ឋ ជា ដ្ឋ) ។ ចុះ ម - បច្ច័យថែមមកទៀតជា ឆដ្ឋម ក៏បានខ្លះ ។

មៈ បញ្ចន្នំ - បូរណោ > បញ្ចមោ (ជនោ) "(ជន) ជាទីពេញនៃជន ៥ នាក់ = (ជនជាគម្រប់ ៥ ឬជនទី ៥)", ឥ. បញ្ចមី, បញ្ចមា, នបុំ. បញ្ចមំ ។ សត្តន្នំ - បូរណោ > សត្តមោ, ឥ. សត្តមី, សត្តមា, នបុំ. សត្តមំ ។ ល ។ អសំខេយ្យមោ, អសំ-ខេយ្យមា, អសំខេយ្យមំ ។

---

១ ឥ. ចតស្សន្នំ - បូរណី > ចតុត្ថី (ឥត្ថី) ។ ២ ផ្លាស់ ឆ ជា ស ជា សដ្ឋោ ក៏បានខ្លះប៉ុន្តែត្រង់ ឥ. នឹងប្រើជា សដ្ឋី ដូច្នេះពុំបានឡើយ, ព្រោះកុំឲ្យច្រឡំនឹង សដ្ឋី "៦០" ។

អៈ បុំ ឯកាទសន្នំ - បូរណោ > ឯកាទសោ (បុរិសោ) "(បុរស) ជាទីពេញនៃបុរស ១១ នាក់ = (បុរសគម្រប់ ១១ ឬ បុរសទី ១១)", ឥត្ថី. ឯកាទសន្នំ-បូរណី > ឯកាទសី )ឥត្ថី) "(ស្រី) ជាទីពេញនៃស្រី ១១ នាក់ = (ស្រីគម្រប់១១ ឬ ស្រីទី ១១)", នបុំ. ឯកាទសន្នំ - បូរណំ > ឯកាទសំ (កុលំ) "(ត្រកូល) ជាទីពេញនៃត្រកូល ១១ = (ត្រកូលគម្រប់១១ ឬ ត្រកូលទី ១១)" ។

បណ្តាបូរណបច្ច័យទាំង ៥ នេះ, តិយ ចុះបានចំពោះសំខ្យា ២ សព្ទគឺ ទ្វិ, តិ ជា តិលិង្គិកៈ, ថ ចុះបានចំពោះតែសំខ្យា ១ សព្ទគឺ ចតុ ជា តិលិង្គិកៈ, ឋ ចុះបានចំពោះតែសំខ្យា ១ សព្ទគឺ ឆ ជា តិលិង្គិកៈ, ម ចុះបានតាំងពីត្រឹម បញ្ច រៀងដល់ អសំខេយ្យ, អ ចុះបានចំពោះសំខ្យា ដែលមាន ស ជាទីបំផុតតាំងពី ឯកាទស ជាដើមរៀងទៅ រហូតដល់ បញ្ញាស ជា តិលិង្គិកៈ, ដែលមាន តិ ជាទីបំផុត តាំងពី ឯនវីសតិ ជាដើមរៀងទៅ ត្រូវចុះ ម - បច្ច័យវិញ ។ សំខ្យា

តាំងពីត្រឹម ចតុ ដល់ ទស នោះ ចុះ ថ, ឋ, ម - បច្ច័យ និងសំខ្យា តាំងពី ឯកាទស ជាដើមទៅ ដែលចុះ អ - បច្ច័យរួចហើយ ត្រូវចុះ ឦ (សាធារណបច្ច័យ សម្រាប់ឥត្ថីលិង្គ) ថែមមកទៀត, បូរណសំខ្យាប៉ែកខាងឥត្ថីលិង្គដែលសល់ពីនោះទាំងប៉ុន្មាន ត្រូវចុះ អា (សាធារណបច្ច័យ សម្រាប់ឥត្ថីលិង្គ) ថែមមក ។

អឌ្ឍ-សព្ទ

បូរណសំខ្យាត្រង់ ទុតិយ, តតិយ ចតុត្ថ បើរួមចូលជាមួយនឹង អឌ្ឍ ដែលប្រែថា "កន្លះ" នេះ ត្រូវផ្លាស់សំខ្យាព្រមទាំងអឌ្ឍជារូបសព្ទផ្សេង ដូច្នេះ ក) ផ្លាស់ ទុតិយ និង អឌ្ឍ ជា ទិវឌ្ឍ ឬជា ទិយឌ្ឍ ឧ. អឌ្ឍេន - ទុតិយោ > ទិវឌ្ឍោ ឬ ទិយឌ្ឍោ (សភាវោ) "(សភាវៈ) ជាគម្រប់២ ដោយកន្លះ" គឺ "មួយកន្លះ", ឥ, ទិវឌ្ឍា, ទិយឌ្ឍា, នបុំ. ទិវឌ្ឍំ, ទិយឌ្ឍំ ។ ខ) ផ្លាស់ តតិយ និង អឌ្ឍ ជាអឌ្ឍតិយ ឬជា អឌ្ឍតេយ្យ ឧ. អឌ្ឍេន-តតិយោ > អឌ្ឍ-តិយោ ឬ អឌ្ឍតេយ្យោ (សភាវោ) "(សភាវៈ) ជាគម្រប់៣ ដោយកន្លះ" គឺ "ពីរកន្លះ", ឥ. អឌ្ឍតិយា, អឌ្ឍតេយ្យា, នបុំ. អឌ្ឍតិយំ, អឌ្ឍតេយ្យំ ។ គ) ផ្លាស់ ចតុត្ថ និង អឌ្ឍ ជា អឌ្ឍុឌ្ឍ ឧ.

អឌ្ឍេន - ចតុត្ថោ > អឌ្ឍុឌ្ឍោ (សភាវោ) "(សភាវៈ) ជាគម្រប់៤ ដោយកន្លះ" គឺ "បីកន្លះ", ឥ. អឌ្ឍុឌ្ឍា, នបុំ. អឌ្ឍុឌ្ឍំ ។

## សំខ្យាតទ្ធិត

[១៥៣] ក្នុងសំខ្យាតទ្ធិតមានបច្ច័យតែ ១ គឺ "ក" ចុះក្នុងសេចក្តីថា "-មានប្រមាណ-" គឺ "-មានចំនួន-" ឧ. ទ្វេ-បរិមាណានិ - អស្ស្វា´តិ > ទ្វិកោ (ធម្មោ) "(ធម៌) មានប្រមាណពីរ = (មានចំនួនពីរ)",ទ្វេ - បរិមាណានិ - អស្ស្វា´តិ > ទ្វិកា (ចេតនា) "(ចេតនា) មានប្រមាណពីរ = (មានចំនួនពីរ)", ទ្វេ-បរិមាណានិ - អស្ស្វា´តិ > ទ្វិកំ (វត្ថុ) "(វត្ថុ) មានប្រមាណពីរ = មានចំនួនពីរ" ។ តិកោ, តិកា, តិកំ, "មានប្រមាណបី = (មានចំនួនបី)" ។ល។

## វិភាគតទ្ធិត

[១៥៤] ក្នុងវិភាគតទ្ធិតមានបច្ច័យ ២ គឺ ធា, សោ ។

ធាៈ ឯកេន - វិភាគេន > ឯកធា "ដោយចំណែក ១", ទ្វីហិ - វិភាគេហិ > ទ្វិធា "ដោយចំណែក ២, តីហិ - វិភាគេហិ >

តិធា "ដោយចំណែក ៣" ។ ចតុធា "ដោយចំណែក៤", បញ្ចធា "ដោយចំណែក ៥" ។ ល ។

សោៈ បទេន - វិភាគេន > បទសោ "ដោយចំណែកដោយបទ", សុត្តេន -វិភាគេន > សុត្តសោ "ដោយចំណែកដោយសូត្រ" ។

## ភាវតទ្ធិត

[១៥៥] ក្នុងភាវតទ្ធិតមានបច្ច័យ ៦ គឺ ណ្យ, ត្ត, ត្តន, តា, ណ, កណ ។

ណ្យៈ (លុប ណ ទុកតែ យ ហើយផ្លាស់ផ្សេងទៅទៀត) ឧ. បណ្ឌិតស្ស - ភាវោ > បណ្ឌិច្ចំ "ភាវៈនៃបណ្ឌិត" (ត្យ > ច្ច), កុសលស្ស - ភាវោ > កោសល្លំ "ភាវៈនៃជនឈ្លាស" (កុ > កោ, ល្យ > ល្ល), សមណស្ស - ភាវោ > សាមញ្ញំ "ភាវៈនៃសមណៈ" (ស > សា, ណ្យ > ញ្ញ), សុហទស្ស - ភាវោ > សោហជ្ជំ "ភាវៈនៃជនមានដួងចិត្តល្អ = (ភាវៈនៃសំឡាញ់)" (សុ > សោ, ទ្យ > ជ្ជ), បុរិសស្ស - ភាវោ > បោរិស្សំ "ភាវៈនៃបុរស" (បុ > បោ, ស្យ >

ស្ស), ឧបមាយ - ភាវោ > ឱបម្មំ "ភាវៈនៃសេចក្តីឧបមា" (ឧ>ឱ, ម្យ > ម្ម, និបកស្ស - ភាវោ > នេបក្កំ "ភាវៈនៃជនមានប្រាជ្ញារក្សានូវខ្លួន" (និ > នេ, ក្យ > ក្ក > ។ (លុប ណ ទុក យ ហើយគ្រាន់តែផ្សំ យ ជាមួយនឹងព្យញ្ជនៈទីបំផុតសព្ទ) ឧ. អរោគស្ស-ភាវោ > អារោគ្យំ "ភាវៈនៃបុគ្គលឥតរោគ" (អ > អា, យ + គ > គ្យ), អលសស្ស - ភាវោ > អាលស្យំ "ភាវៈនៃបុគ្គលខ្ជិល" (អ > អា, ស + យ > ស្យ), ឥណស្ស - ភាវោ > អាណ្យំ "ភាវៈនៃបំណុល" (ឥ > អា, ណ + យ > ណ្យ), ទុស្សីលស្ស[១] - ភាវោ > ទុស្សីល្យំ "ភាវៈនៃបុគ្គលមានសីលគឺទោសប្រទូស្តហើយ = (ភាពនៃបុគ្គលទ្រុស្តសីល)" (ល + យ > ល្យ) ។

ត្តៈ អនោទរិកស្ស - ភាវោ > អនោទរិកត្តំ "ភាវៈនៃភិក្ខុមិនប្រកប (ក្នុងការព្យាយាម) ដើម្បីពោះ", សមចិត្តស្ស[២] - ភាវោ > សមចិត្តត្តំ "ភាវៈនៃបុគ្គលមានចិត្តស្មើ", មនុស្សស្ស - ភាវោ > មនុស្សត្តំ "ភាវៈនៃមនុស្ស = (ភាពរបស់មនុស្ស), នបុំសកស្ស-

---

១ ទុដ្ឋំ - សីលំ យស្ស - សោ > ទុស្សីលោ (បុគ្គលោ) ។ ២ សមំ - ចិត្តំ - យស្ស - សោ > សមចិត្តោ (បុគ្គលោ) ។

ភាវោ > នបុំសកត្តំ "ភាវៈនៃខ្ទើយ", ទីឃស្ស - ភាវោ > ទីឃត្តំ "ភាវៈនៃ (កាល) វែង", ឯកស្ស - ភាវោ > ឯកត្តំ "ភាវៈនៃ (វត្ថុ) មួយ", ទ្វិន្នំ - ភាវោ > ទ្វិត្តំ "ភាវៈនៃ (វត្ថុ) ពីរ" ។

ត្តនៈ បុថុជ្ជនស្ស - ភាវោ > បុថុជ្ជនត្តនំ "ភាវៈនៃបុថុជ្ជន", វេទនស្ស[១] - ភាវោ > វេទនត្តនំ "ភាវៈនៃបុគ្គលមានវេទនា" ។

តាៈ មុទុនោ - ភាវោ > មុទុតា "ភាវៈនៃ (ចិត្ត) ទន់ "ឬ" ភាវៈនៃ (បុគ្គល) ទន់", និទ្ទារាមស្ស - ភាវោ > និទ្ទារាមតា "ភាវៈនៃបុគ្គលអ្នកត្រេកអរទ្វេទៅក្នុងកិរិយាដេកលក់ = (ភាពនៃបុគ្គលល្មោភដេក", បច្ចវេក្ខណស្ស - ភាវោ > បច្ចវេក្ខណតា "ភាវៈនៃកិរិយាពិចារណា", សហាយស្ស - ភាវោ > សហាយតា "ភាវៈនៃសំឡាញ់" ឬ "ភាវៈនៃជនជាគ្នា" ។

ណៈ វិសមស្ស - ភាវោ > វេសមំ "ភាវៈនៃ(ផ្លូវ)ស្មើប្រាស = (ភាពនៃផ្លូវមិនរាបស្មើ)" (វិ>វេ), សុចិនោ - ភាវោ > សោចំ "ភាវៈនៃ (វត្ថុ) ស្អាត" (សុ>សោ), ឧជុនោ - ភាវោ > អាជ្ជវំ "ភាវៈនៃ (ចិត្ត) ត្រង់ "ឬ" ភាវៈនៃ(បុគ្គល)ត្រង់" (ឧជុៈ ឧ > អា, ជុ > ជវ, អា +

១ វេទនា-យស្ស-អត្ថិ៍តិ > វេទនោ (ណ បច្ច័យ ចុះក្នុងតទស្សត្ថិតទ្ធិត) ។

ជរ+អ[១] > អាជរ, មុទុនោ-ភាវោ > មទ្ទវំ "ភាវៈនៃ (ចិត្ត)ទន់" ឬ "ភាវៈនៃ(បុគ្គល)ទន់" (មុៈទុមុ>ម,ទុ>ទវ, ម+ទវ + អ>មទ្ទវ ។

កណ[២] រមណីយស្ស-ភាវោ > រាមណីយកំ "ភាវៈនៃ(វត្ថុ) ដែលជនគួររីករាយ" (រ > រា), មនុញ្ញស្ស - ភាវោ > មានុញ្ញកំ "ភាវៈនៃវត្ថុជាទីគាប់ចិត្ត" (ម > មា), អគ្គិហោមស្ស-ភាវោ > អគ្គិ-ហោមកំ "ភាវៈនៃព្រាហ្មណ៍អ្នកបូជានូវភ្លើង" ។

ក្នុងសទ្ទនីតិបករណ៍ ថាសព្ទគឺ វីរិយំ[៣] "ភាវៈនៃសេចក្ដីអង់អាច" ឬ "ភាវៈនៃសេចក្ដីខ្មីឃ្មាត=(ការព្យាយាម)", អាលសិយំ[៤] "ភាវៈនៃបុគ្គលខ្ជិល" ចុះ "ណិយ" បច្ច័យ ។ សោចេយ្យំ[៥] "ភាវៈនៃ (វត្ថុ) ស្អាត" ចុះ "ណេយ្យ" បច្ច័យ ។ ទាសព្យំ[៦] "ភាវៈនៃទាសៈ = (ភាវៈនៃជនជាខ្ញុំ)" ចុះ "ព្យ" បច្ច័យ ។

---

១ វិការៈ ឧ ខាងដើមជា អា ហើយផ្លាស់ឧរបស់ ជុ ជា ឱ ហើយផ្លាស់ ឱ ជា អវ រួចតម្រួតជ ជា ជ្ជ ផ្សំ វ ជាមួយនឹង អ របស់ ណ បច្ច័យ សម្រេចរូបជា អជ្ជវ ។ ២ ក្នុងបករណៈទាំងពួងច្រើនហៅ ក័ណ-បច្ច័យ ។ ៣ វីរស្ស-ភាវោ>វីរិយំ ។ ៤ អលសស្ស-ភាវោ> អាលសិយំ ។ ៥ សុចិនោ-ភាវោ>សោចេយ្យំ ។ ៦ ទាសស្ស-ភាវោ> ទាសព្យំ ។ ក្នុងកច្ចាយនភេទថាសព្ទ គឺ បុថុជ្ជនត្តំ ចុះ ត្ត បច្ច័យ, បុថុជ្ជនត្តំ ចុះ ត្វ-បច្ច័យ, បោថុជ្ជនិកោ ចុះ ណិក-បច្ច័យ, បោថុជ្ជនិយោ ចុះ ណិយ-បច្ច័យ, បោថុជ្ជនិលំ ចុះ និល-បច្ច័យ, ប្រែថា "ភាវៈនៃបុថុជ្ជន" ដូចគ្នាទាំង ៥ សព្ទ, ចងវិគ្គហៈថាៈ បុថុជ្ជនស្ស-ភាវោ> បុថុជ្ជនត្តំ, បុថុជ្ជនត្វំ, បោថុជ្ជនិកោ, បោថុជ្ជនិយោ, បោថុជ្ជនិលំ ។

# អព្យយតទ្ធិត

[១៥៦] ក្នុងអព្យយតទ្ធិតមានបច្ច័យ ៣ គឺ ថា, ថត្តា, ថំ, ហៅថា "អព្យយបច្ច័យ" ។ បច្ច័យទាំង ៣ នេះ ចុះក្នុងសេចក្ដីថា "បការៈ" ចុះបានចំពោះតែខាងចុងវិសេសនសព្វនាម ដែលគួរប្រកបប៉ុណ្ណោះ ។

ថាៈ យោ-បការោ > យថា "វីប្រការៈណា", យំ-បការំ > យថា "នូវប្រការៈណា", យេន-បការេន > យថា "ដោយប្រការៈណា", យស្ស-បការស្ស > យថា "ដល់ប្រការៈណា", យស្មា-បការា > យថា "អំពីប្រការៈណា", យស្ស - បការស្ស > យថា "នៃប្រការៈណា", យស្មឹ - បការេ > យថា "ក្នុងប្រការៈណា" ។ តថា "ប្រការៈនោះ", សព្វថា "ប្រការៈទាំងពួង", អញ្ញថា "ប្រការៈដទៃ", ឥតរថា "ប្រការៈក្រៅនេះ" (ចងវិគ្គហៈដូចរបៀបយថា) ។

ថត្តាៈ យោ-បការោ > យថត្តា "វីប្រការៈណា" ។ ល ។ យស្មឹ - បការេ > យថត្តា "ក្នុងប្រការៈណា" ។ តថត្តា "ប្រការៈនោះ", សព្វថត្តា "ប្រការៈទាំងពួង" ។ល។

ចំៈ បច្ច័យនេះចុះបានចំពោះតែខាងចុង "កឹ" និង "ឥម" ពីរសព្ទប៉ុណ្ណោះ ឧ. កោ-បការោ > កថំ "រីប្រការៈដូចម្តេច", កំ-បការំ > កថំ "នូវប្រការៈដូចម្តេច" ។ ល ។ កស្មឹ-បការេ > កថំ "ក្នុងប្រការៈដូចម្តេច" ។ អយំ - បការោ > ឥត្ថំ "រីប្រការៈនេះ", ឥមំ-បការំ > ឥត្ថំ "នូវប្រការៈនេះ", អនេន - បការេន > ឥត្ថំ "ដោយប្រការៈនេះ" ។ល។ អស្មឹ-បការេ > ឥត្ថំ "ក្នុងប្រការៈនេះ"។

សព្ទដែលចុះអព្យយបច្ច័យក្នុងនាមនិទ្ទេស (ត្រង់លេខ [១២៧] លើកលែងតែអព្យយបច្ច័យ ៥ គឺ តវេ, តុំ, ត្វា, ត្វាន, តូន ចេញ, ក៏រាប់បញ្ចូលជាអព្យយតទ្ធិតដែរ[១] ។

## ដំណើរលិង្គរបស់តទ្ធិត

[១៥៧] តទ្ធិតទាំងអស់ដែលបាននិយាយមកហើយនោះ ជា ឯកលិង្គិកៈ ក៏មាន ជា តិលិង្គិកៈក៏មាន ។ តទ្ធិតដែលមាន

---

១ ក្នុងកច្ចាយនភេទថា សព្ទគឺ ឯកវិធំ "ប្រការមួយ" ទុវិធំ ឬ ទុព្វិធំ "ប្រការពីរ" តិវិធំ "ប្រការបី" ។ល។ ទសវិធំ "ប្រការ ១០" ឯកាទសវិធំ "ប្រការ ១១" ។ល។ ចុះវិធ-បច្ច័យ ចុះបានតែខាងចុង បកតិសំខ្យា ប៉ុណ្ណោះ ។ បែបតាំងវិគ្គហៈថាៈ ឯកោ-បការោ > ឯកវិធំ, ឯកំ-បការំ> ឯកវិធំ ។បេ។ ឯកស្មឹ-បការេ > ឯកវិធំ ។ ទ្វេ-បការា > ទុវិធំ ឬ ទុព្វិធំ ។ល។ ទសសុ-បការេសុ > ទសវិធំ ។ ឯកាទស-បការា > ឯកាទសវិធំ ។បេ។ ឯកាទសសុ-បការេសុ > ឯកាទសវិធំ ។បេ។

ដំណើរប្រើបានតែលិង្គមួយ ៗ ដូចយ៉ាងភាវតទ្ធិតជាដើម ហៅថា ឯកលិង្គិកៈ, ដែលប្រើបានគ្រប់ទាំង ៣ លិង្គ ដូចយ៉ាងគោត្តតទ្ធិត ជាដើម ហៅថា តិលិង្គិកៈ ។ ប៉ុន្តែ តទ្ធិតជាឯកលិង្គិកៈខ្លះមាន លំនាំសេចក្តីល្មមឲ្យបំបែរជា តិលិង្គិកៈ ដោយចុះបច្ច័យតទ្ធិតផង គ្នាថែមមកទៀត ក៏ក្លាយជា តិលិង្គិកៈ ទៅបាននោះក៏មាន, ដូច ជា សាមញ្ញំ "ភាវៈនៃសមណៈ", បើចុះ "ណ" បច្ច័យក្នុងតទ-ស្សត្ថិតទ្ធិតថែមមក, តាំងវិគ្គហៈថាៈ សាមញ្ញំ-យស្ស-អត្ថី៍តិ > សាមញ្ញោ (ជនោ) "(ជន) មានភាវៈនៃសមណៈ", ឥ. សាមញ្ញា, នបុំ. សាមញ្ញំ, យ៉ាងនេះ, ក៏បែរក្លាយជា តិលិង្គិកៈទៅបានដោយ អំណាចបច្ច័យតទ្ធិតផងគ្នា ដែលមានគតិជា តិលិង្គិកៈ, តទ្ធិត បំបែរគ្នាយ៉ាងនេះ ហៅដោយសន្មតិថា "តទ្ធិតបំបែរតទ្ធិត" ឬ "តទ្ធិតលេបតទ្ធិត" ។ ចំណែកខាងតទ្ធិតជា តិលិង្គិកៈវិញសោត បើចុះបច្ច័យតទ្ធិតផងគ្នា ដែលមានគតិជា ឯកលិង្គិកៈថែមមក, ក៏ ក្លាយជា ឯកលិង្គិកៈ បានដែរ, ដូចជា វាសិដ្ឋោ "ជនជាពូជ

វង្សនៃវសិដ្ឋៈ″, វេទនោ ‶ជនមានវេទនា″, ទណ្ឌី ‶ជនមានឈើច្រត់″, បើចុះ ‶ត្ត″ ឬ ‶ត្តន″ ឬ ‶តា″ បច្ច័យក្នុងភាវតទ្ធិតថែមមក, តាំងវិគ្គហៈថាៈ វាសិដ្ឋស្ស - ភាវោ > វាសិដ្ឋត្តំ (នបុំ.) ឬ វាសិដ្ឋតា (ឥ.) ‶ភាវៈនៃជនជាពូជវង្សនៃវសិដ្ឋៈ″, វេទនស្ស-ភាវោ > វេទនត្តនំ (នបុំ.) ‶ភាវៈនៃជនមានវេទនា″, ទណ្ឌិនោ-ភាវោ > ទណ្ឌិត្តំ (នបុំ.) ឬទណ្ឌិតា (ឥ.) ‶ភាវៈនៃជនមានឈើច្រត់″ យ៉ាងនេះ, ក៏ក្លាយជា ឯកលិង្គិកៈ ប្រើចំពោះតែលិង្គមួយ ៗ ទៅវិញ ។ ប៉ុន្តែដែលប្រើយ៉ាងនេះ មិនមែនជាសាធារណ៍បានគ្រប់តទ្ធិតទាំងអស់ទេ, លុះតែសព្ទដែលមានលំនាំសេចក្ដីល្មមផ្លាស់ប្រែបង្វែរបាននោះដែរ ទើបមានទំនងឲ្យធ្វើយ៉ាងនេះកើត ។ អ្នករៀនចូរសង្កេតដំណើរលិង្គរបស់តទ្ធិតតាមន័យនេះឲ្យត្រាតែយល់ជាក់ប្រាកដដោយច្រើន ៗ ទៅទៀតចុះ ។

តទ្ធិតនិទ្ទេសទី ៤ ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

# អាខ្យាតនិទ្ទេស ទី ៨

# អាខ្យាតនិទ្ទេស ទី ៥

## អាខ្យាត

[១៥៨] កិរិយាសព្ទ គឺសព្ទដែលប្រាប់នូវដំណើរនៃអំពើ មានពាក្យថា "ដេក, ដើរ, ឈរ, អង្គុយ, ស៊ី, ផឹក, និយាយ, ស្តាប់, គិត"ជាដើម ហៅថា អាខ្យាត ។

ក្នុងអាខ្យាតនោះ លោកកំណត់បែប ជាគ្រឿងប្រដាប់សម្រាប់សម្គាល់ មាន ៨ យ៉ាង គឺ វិភត្តិ, កាល, បទ, វចនៈ, បុរិសៈ, ធាតុ, វាចកៈ បច្ច័យ ។

## វិភត្តិ

[១៥៩] វិភត្តិសម្រាប់ប្រើក្នុងបាឡីភាសាមាន ២ យ៉ាង គឺ វិភត្តិនាម ១ វិភត្តិអាខ្យាត ១ ។ វិភត្តិទាំង ២ យ៉ាងនេះ មានដំណើរប្លែកគ្នាដូច្នេះ គឺ វិភត្តិនាមសម្រាប់បំបែកនាមសព្ទទាំង ៣ យ៉ាង ដូចបាននិយាយក្នុងនាមនិទ្ទេសរួចហើយ, ឯវិភត្តិអាខ្យាតនេះ សម្រាប់បំបែកសព្ទជាមូលដើម ដែលហៅថា "ធាតុ" ឲ្យចេញលំនាំប្រាកដមកជាកិរិយារបស់នាមសព្ទ ។ នឹងទាញ

ឧទាហរណ៍ ១ មកឲ្យឃើញ, ដូចជាសព្ទថា ឧបាសក ធម្ម សុ "ឧបាសក ធម៌ ស្តាប់", នឹងប្រើសព្ទទទេឥតវិភត្តិយ៉ាងនេះពុំបានឡើយ, ត្រូវផ្សំសព្ទទាំងនេះឲ្យមានវិភត្តិឡើងទើបប្រើបាន, ផ្សំជា: ឧបាសកោ ធម្មំ សុណាតិ "រី - ឧបាសក ស្តាប់ នូវ-ធម៌", ឧបាសក ជា ឧបាសកោ, ធម្ម ជា ធម្មំ ផ្សំដោយវិភត្តិនាម, សុ ជា សុណាតិ ផ្សំដោយវិភត្តិអាខ្យាត ។

វិភត្តិអាខ្យាតមាន ៨ ពួក គឺ វត្តមានា, បញ្ចមី, សត្តមី, បរោក្ខា, ហីយត្តនី, អជ្ជត្តនី, ភវិស្សន្តិ, កាលាតិបត្តិ ។ វិភត្តិទាំង ៨ ពួកនេះ មានដំណើរប្រាប់ឲ្យដឹងនូវគ្រឿងសម្គាល់ ៤ យ៉ាងគឺ កាល, បទ, វចនៈ, បុរិសៈ ដែលមានចំពោះខ្លួននៅនោះជាកំណត់ ។ វិភត្តិនុ៎ះ ក្នុងពួកមួយ ៗ សុទ្ធតែមាន ១២ ដូចគ្នាទាំងអស់ ដូចមានរបៀបរៀងតាមលំដាប់តទៅនេះ ៖

### ១ វត្តមានា

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិសៈ | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | តិ | អន្តិ | តេ | អន្តេ |

-៣៧៧-

| | | | | |
|---|---|---|---|---|
| ម. | សិ | ថ | សេ | វ្ហេ |
| ឧ. | មិ | ម | ឯ | ម្ហេ |

## ២ បញ្ចមី

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិសៈ | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | តុ | អន្តុ | តំ | អន្តំ |
| ម. | ហិ | ថ | ស្សុ | វ្ហោ |
| ឧ. | មិ | ម | ឯ | [១]អាមសេ |

## ៣ សត្តមី

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិសៈ | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | ឯយ្យ | ឯយ្យុំ. | ឯថ | ឯរំ |
| ម. | ឯយ្យាសិ | ឯយ្យាថ | ឯថោ | ឯយ្យវ្ហោ |
| ឧ. | ឯយ្យាមិ | ឯយ្យាម | ឯយ្យំ | ឯយ្យាម្ហេ |

---

១-អាមសេ នេះ ក្នុងគម្ពីរសព្វសាស្ត្រទាំងឡាយ មានកច្ចាយនៈ (គម្ពីរដើម), សទ្ទនីតិ, រូបសិទ្ធិ, មុខមត្តទីបនី និងពាលាវតា ជាដើម មានរូបជា អាមសេ ដូចគ្នាទាំងអស់, តែសៀវភៅនេះ ក្នុងលើក មុនៗ ជា អាម្ហសេ តាមមូលកច្ចាយនៈ ជាគម្ពីរពិសេសក្នុងប្រទេស ខ្មែរដែលមិនធ្លាប់ឃើញប្រើក្នុងគម្ពីរដទៃឡើយ ។

## ៤ បរោក្ខា

| បុរិសៈ | បរស្សបទ ឯក. | ពហុ. | អត្តនោបទ ឯក. | ពហុ. |
| --- | --- | --- | --- | --- |
| ប. | អ | ឧ | ត្ថ | រេ |
| ម. | ឯ | ត្ថ | ត្ថោ | វ្ហោ |
| ឧ. | អំ | ម្ហ | តំ | ម្ហេ |

## ៥ ហីយត្តនី

| បុរិសៈ | បរស្សបទ ឯក. | ពហុ. | អត្តនោបទ ឯក. | ពហុ. |
| --- | --- | --- | --- | --- |
| ប. | អា | ឩ | ត្ថ | ត្ថុំ |
| ម. | ឱ | ត្ថ | សេ | វ្ហំ |
| ឧ. | អំ | ម្ហ | តំ | ម្ហសេ |

## ៦ អជ្ជត្តនី

| បុរិសៈ | បរស្សបទ ឯក. | ពហុ. | អត្តនោបទ ឯក. | ពហុ. |
| --- | --- | --- | --- | --- |
| ប. | ឦ | ឧំ | អា | ឩ |

| | | | | |
|---|---|---|---|---|
| ម. | ឱ | ត្ថ | សេ | វ្ហំ |
| ឧ. | តំ | ម្ហា | អំ | ម្ហេ |

## ៧ ភវិស្សន្តិ

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិសៈ | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | ស្សតិ | ស្សន្តិ | ស្សតេ | ស្សន្តេ |
| ម. | ស្សសិ | ស្សថ | ស្សសេ | ស្សវ្ហេ |
| ឧ. | ស្សាមិ | ស្សាម | ស្សំ | ស្សាម្ហេ |

## ៨ កាលាតិបត្តិ

| | បរស្សបទ | | អត្តនោបទ | |
|---|---|---|---|---|
| បុរិសៈ | ឯក. | ពហុ. | ឯក. | ពហុ. |
| ប. | ស្សា | ស្សំសុ | ស្សថ | ស្សឹសុ |
| ម. | ស្សេ | ស្សថ | ស្សសេ | ស្សវ្ហេ |
| ឧ. | ស្សំ | ស្សាម្ហា | ស្សំ | ស្សាម្ហសេ |

# កាល

[១៦០] "ពេល" ដែលជាគ្រឿងកំណត់ក្នុងការនិយាយស្ដី ដើម្បីឲ្យដឹងថា "ឥឡូវនេះ" ឬ "ពីអង្កាល់" ឬក៏ "ដល់ទៅអង្កាល់" ហៅថា "កាល" ។ ក្នុងអាខ្យាតនេះ បើនិយាយដោយសង្ខេប, "កាល" មានត្រឹមតែ ៣ យ៉ាង គឺ ពេលដែលកំពុងតែមាននៅចំពោះមុខ គឺពេលឥឡូវនេះ ហៅថា "បច្ចុប្បន្ន-កាល" ១, ពេលដែលកន្លងហួសទៅហើយ ហៅថា "អតីត-កាល" ១, ពេលដែលមិនទាន់មកដល់ គឺពេលដែលនៅខាងមុខ ហៅថា "អនាគតកាល" ១ ។ បើនិយាយដោយពិស្ដារតាមដំណើររបស់កាល ឲ្យឃើញសេចក្ដីយ៉ាងល្អិតទៅទៀត, បច្ចុប្បន្នកាលចែកចេញជា ៣ យ៉ាង គឺ បច្ចុប្បន្នសុទ្ធ ១, បច្ចុប្បន្នជិតអតីត ១, បច្ចុប្បន្នជិតអនាគត ១, អតីតកាលចែកចេញជា ៣ យ៉ាង គឺ អតីតកាលកន្លងហើយមិនមានកំណត់ ១, អតីតកាលកន្លងហើយក្នុងថ្ងៃម្សិល ១, អតីតកាលកន្លងហើយក្នុងថ្ងៃនេះ ១, អនាគតកាលចែកចេញជា ២ យ៉ាង គឺ អនាគតរបស់បច្ចុប្បន្ន ១,

អនាគតរបស់អតីត ១, រួមត្រូវជា ៨ យ៉ាង ។ កាលទាំង ៨ យ៉ាងនេះ បើនឹងហៅដោយសន្មតិ ដើម្បីឲ្យងាយចំណាំ ថា "សាខាកាល" ប្រែថា "កាលដូចជាមែក" ឬហៅថា "កាលបន្ទាប់បន្សំ" ដូច្នេះក៏គួរ ។ មាន "កាល" ម្យ៉ាងទៀត ហៅថា "អនុត្តកាល" គឺកាលដែលមិនប្រាប់ដំណើរថាជា បច្ចុប្បន្ន ឬ អតីត ឬក៏ អនាគត ឡើយ ។ អនុត្តកាលនេះចែកចេញជា ៤ យ៉ាង គឺ អាណត្តិ "ប្រាប់សេចក្តីបង្គាប់" ១, អាសិដ្ឋៈ "ប្រាប់សេចក្តីប្រាថ្នា សេចក្តីប៉ុនប៉ង" ឬ "សេចក្តីអង្វរ" ១, អនុមតិ "ប្រាប់សេចក្តីយល់ឃើញ" គឺប្រាប់សេចក្តីណែនាំតាមគំនិតរបស់ខ្លួនដោយទំនងថា "គួរតែ-" ១, បរិកប្បៈ "ប្រាប់សេចក្តីកំណត់" គឺប្រាប់សេចក្តីគ្នេរគ្នាន់ ដោយទំនងថា "ត្រូវតែ-" ឬ "ប្រាប់សេចក្តីដញ្ជឹង, សេចក្តីត្រិះរិះ" ១ ។ កាលទាំង ៤ យ៉ាងនេះ ក៏ហៅថា "សាខាកាល" ដូចន័យមុនដែរ ពីព្រោះបែកមែកចេញមកអំពីអនុត្តកាល, បើរាប់កាល ៤ យ៉ាងនេះផ្សំ

ផង ត្រូវជាសាខាកាលមាន ១២ យ៉ាង ។ ដែលនឹងអាចដឹងនូវកាលទាំងនេះ ដោយដាក់ប្រាកដនោះ ត្រូវកំណត់ដឹងដោយអាស្រ័យវិភត្តិទាំង ៨ ពួក ដូចសេចក្ដីរៀបរៀងដោយសង្ខេបតាមលំដាប់វិភត្តិតទៅនេះ ៖

## វត្តមានា-វិភត្តិ

វត្តមានា[១] ប្រាប់បច្ចុប្បន្នកាលទាំង ៣ យ៉ាង ដូច្នេះ

បច្ចុប្បន្នសុទ្ធ ឲ្យប្រែថា "កំពុង-, កំពុងតែ-" ឧ. ឥទានិ បន សោ កឹ ករោតិ "ចុះ ឥឡូវ គាត់ កំពុងធ្វើ នូវអ្វី?", ថេរោ ធម្មំ ទេសេតិ "ព្រះថេរៈ កំពុងសម្ដែង នូវធម៌" ។ ឬប្រែទទេ ៗ គឺគ្រាន់តែប្រែចេញសព្ទរបស់កិរិយាប៉ុណ្ណោះក៏បាន ឧ. បញ្ញាយ បភា សព្វាហិ បភាហិ វិរោចតិ "ពន្លឺ នៃប្រាជ្ញារុងរឿង ជាងពន្លឺទាំងឡាយ ទាំងពួង" ។

---

១ វត្តមានា ប្រែថា "(វិភត្តិ) ប្រាប់សេចក្ដីថា កំពុងប្រព្រឹត្ត" ។

បច្ចុប្បន្នជិតអតីត ឲ្យប្រែថា "ទើប-, ទើបនឹង-" ឬថា "-ហើយ" ក៏បានខ្លះ ឧ. កុតោ នុ ត្វំ អាគច្ឆសិ "ចុះ ឯង ទើបមក ពីណា ហ្នឹង?," ឥទានេវ សោ អាគច្ឆតិ "គាត់ ទើបនឹងមក អម្បាញ់មិញនេះឯង", តទា បុញ្ញំ ករោមិហំ "ក្នុងកាលនោះ ខ្ញុំ ធ្វើហើយ[១] នូវបុណ្យ" ។

បច្ចុប្បន្នជិតអនាគត ឲ្យប្រែថា "នឹង-, រមែង-, តែង តែ-" ឬថា "គង់-, គង់តែ" ក៏បាន ឧ. ឯវំ តយា កតេ បាបេ និរយំ នូន គច្ឆសិ "កាលបើអំពើអាក្រក់ គឺឯង ធ្វើ យ៉ាងនេះ ហើយ, (ឯង) នឹងទៅ កាន់នរក ពុំខានឡើយ", កឹ បនាហំ ករោមិ "ចុះ អញ នឹងធ្វើ ដូចម្ដេច?" ឬថា "ចុះ អញ នឹងធ្វើ នូវអ្វី?", អយតោ មលំ សមុដ្ឋាយ តមេវ ខាទតិ "ច្រែះ កើតហើយ អំពីដែក រមែងស៊ី នូវដែកនោះវិញ", យោ ពាលំ សេវតិ, សោ វិនាសំ បាបុណាតិ "បុគ្គលណា សេព គប់ នូវជនពាល, បុគ្គលនោះ គង់ដល់ នូវសេចក្ដីវិនាស" ។

---

១ បានជាប្រែថា "-ហើយ" ព្រោះមានសព្ទថា "តទា" ជាអតីតកាល-សត្តមី (បច្ចុប្បន្នដែលប្រែថា "-ហើយ" យ៉ាងនេះច្រើនមានប្រើក្នុង គាថា) ។

## បញ្ចមី-វិភត្តិ

បញ្ចមី[១] ប្រាប់អនុត្តកាល ២ យ៉ាង គឺ អាណត្តិ និងអាសិដ្ឋៈ ។

អាណត្តិ "ប្រាប់សេចក្ដីបង្គាប់" ឲ្យប្រែថា "ចូរ-" ឬ "ចូរ-ចុះ" ឧ. មម វចនេន ករោហិ "ឯង ចូរធ្វើ តាមពាក្យ នៃអញ", សោយេវ ចោរោ នំ គណ្ហថ "វាហ្នឹងឯង ជាចោរ (អ្នកទាំងឡាយ) ចូរចាប់ នូវវា", ឯវំ វទេហិ "(អ្នក) ចូរថា យ៉ាងនេះ" គច្ឆាហិ (ឯង) ចូរទៅចុះ" ។

អាសិដ្ឋៈ "ប្រាប់សេចក្ដីប្រាថ្នា, សេចក្ដីប៉ុនប៉ង[២]" ឲ្យប្រែថា "ចូរ-" ឧ. សុខំ តេ ហោតុ "សេចក្ដីសុខ ចូរមាន ដល់អ្នក!", ទីឃាយុកា ហោថ[៣] "(អ្នកទាំងឡាយ) ចូរជាបុគ្គលមានអាយុ

---

១ បញ្ចមី ក្នុងទីនេះ ប្រែថា "(វិភត្តិ) មានអាសិដ្ឋៈជាគម្រប់ ៥" គឺរាប់សាខាកាលរបស់បច្ចុប្បន្ន ៣ និងអាណត្តិ ១ ជា ៤ អាសិដ្ឋៈ ១ ទៀតជា ៥, គ្រប់ ៥ ត្រឹមអាសិដ្ឋៈនោះព្រោះហេតុនោះបានជាវិភត្តិនេះមានឈ្មោះថាបញ្ចមី, មិនមែនប្រែថា "(វិភត្តិ) ទី ៥" ដូចបញ្ចមី-វិភត្តិនាមនោះទេ ។ ២ គឺសេចក្ដីប្រាថ្នា, ប៉ុនប៉ងឲ្យបានកបដូច្នោះ (សេចក្ដីសំបូងសង្រួង, សេចក្ដីលន់តួ, ដោះសា, លោមទោម) ។ ២ ហោថ ប្រែថា "ចូរមាន" ជាកិរិយារបស់ "តុម្ហេ" ក៏ពិត, ប៉ុន្តែក្នុងប្រយោគយ៉ាងនេះ, ត្រូវប្រែរួប, មិនបាច់ចេញសម្ដីថា "មាន" ទេ ត្រូវប្រែចេញត្រឹមតែពាក្យជាវិកតិកត្តា ថា "ជា-" ប៉ុណ្ណោះ ។

វែង!” ។ ឬប្រែថា “សូម-, សូមឲ្យ-ចុះ” ឧ. ភវតុ សព្វមង្គលំ... “មង្គលទាំងពួង សូមមាន = (សូមឲ្យមង្គលទាំងពួងមាន!)...”, ឯវំ ហោតុ “សូមឲ្យបានយ៉ាងហ្នឹងចុះ[១]!” ។ “ប្រាប់សេចក្ដីអង្វរ” ឲ្យប្រែថា “សូម-” ឧ...តំ មេ ខមថ. សូម-(ព្រះអង្គ)-អត់ នូវទោសនោះ ដល់ខ្ញុំព្រះអង្គ = (សូមទ្រង់អត់ទោសដល់ខ្ញុំព្រះអង្គ)”, អភយំ មេ ទេថ “សូម-(អ្នកទាំងឡាយ)-ឲ្យ នូវអភ័យ ដល់ខ្ញុំ” ។

## សត្តមី-វិភត្តិ

សត្តមី[២] ប្រាប់អនុត្តកាល ២ យ៉ាងគឺ អនុមតិ និងបរិកប្បៈ ។ អនុមតិ “ប្រាប់សេចក្ដីយល់ឃើញ” ឲ្យប្រែថា “គួរ-” ឬ “គួរតែ-” ឧ...ភជេថ មិត្តេ កល្យាណេ, ភជេថ បុរិសុត្តមេ... “(បុគ្គល) គួររាប់រក នូវមិត្តទាំងឡាយ ដែលបណ្ឌិតគួររាប់, គួររាប់រក នូវបុរសឧត្តមទាំងឡាយ” ។

---

១ ប្រែយ៉ាងនេះតាមលំនាំសេចក្ដី, បើតាមដំណើរ “បុរិស” ត្រូវដាក់នាមនាមណាមួយមកឲ្យជាបទប្រធាន របស់ហោតុ ដែលជាបឋមបុរិស ។ ២ សត្តមី ក្នុងទីនេះ ប្រែថា “(វិភត្តិ) មានបរិកប្បៈជាគម្រប់ ៧” គឺរាប់សាខាកាលរបស់បច្ចុប្បន្ន ៣ អាណត្តិ ១ អាសិដ្ឋៈ ១ អនុមតិ ១ រួមជា ៦, រាប់បរិកប្បៈ ១ ទៀតផ្សំជា ៧, គ្រប់ ៧ ត្រឹមបរិកប្បៈនេះ, ព្រោះហេតុនោះបានជាវិភត្តិនេះមានឈ្មោះថាសត្តមី, មិនមែនប្រែថា “(វិភត្តិ) ទី ៧” ដូចសត្តមី-វិភត្តិនាមនោះទេ ។

បរិកប្បៈ "ប្រាប់សេចក្ដីកំណត់" ឲ្យប្រែថា "គប្បី-" ឬ "ត្រូវ-" ឧ. បុញ្ញញ្ចេ បុរិសោ កយិរា, កយិរាថេនំ បុនប្បុនំ តម្ហិ ឆន្ទំ កយិរាថ, សុខោ បុញ្ញស្ស ឧច្ចយោ "បើ បុរស គប្បី ធ្វើ នូវបុណ្យ, គប្បីធ្វើ នូវបុណ្យនុ៎ះ ឲ្យរឿយៗ, គប្បីធ្វើ នូវសេចក្ដីពេញចិត្ត ក្នុងបុណ្យនោះ, កិរិយាសន្សំ នូវបុណ្យ នាំមក នូវសេចក្ដីសុខ" ។ "ប្រាប់សេចក្ដីជញ្ជឹង, សេចក្ដីត្រិះរិះ" ឲ្យប្រែថា "គប្បី-" ឬ "ត្រូវ-" ឧ. កឹ បនា'ហំ ករេយ្យំ "ចុះ អញ គប្បីធ្វើ នូវអ្វី?" ឬថា "ចុះ អញ ត្រូវធ្វើ ដូចម្ដេច?" យន្នូនា'ហំ បព្វជ្ជេយ្យំ "បើដូច្នោះមានតែ អញ ត្រូវបួស" ឬថា "អញ គប្បីបួស ឬអ្វីហ្ន៎?" ។

## បរោក្ខា-វិភត្តិ

បរោក្ខា[១] ជាវិភត្តិប្រាប់អតីតកាលកន្លងហើយមិនប្រាកដ ឲ្យប្រែថា "-ហើយ" ឧ. តេនា'ហ ភគវា... "ព្រោះហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយ..", សេដ្ឋី ឯវ'មាហ... "សេដ្ឋី

១ បរោក្ខា ប្រែថា "(វិភត្តិ) ពោលនូវកាលដែលមានហើយក្នុងខាងក្រោយ" ។

ពោលហើយ យ៉ាងនេះ...˝, តេនា˴ហុ[១] បោរាណា... ˝ព្រោះហេតុនោះ អាចារ្យក្នុងកាលមុនទាំងឡាយ ពោលហើយ...˝ ។

ហីយត្តនី-វិភត្តិ

ហីយត្តនី[២] ជាវិភត្តិប្រាប់អតីតកាលកន្លងហើយក្នុងថ្ងៃម្សិល ឲ្យប្រែថា "-ហើយ˝ ឧ. សោ អគមា "គេ បានទៅហើយ˝, តេ អគមូ (ជនទាំងឡាយ) នោះ បានទៅហើយ˝, ឯរំ អវចំ "(ខ្ញុំ) បាននិយាយហើយ យ៉ាងនេះ˝ ។ បើមាន "មា[៣]˝ សព្ទយោគចូលផង, ត្រង់ពាក្យថា "-ហើយ˝ ត្រូវ

---

១ អាខ្យាតកិរិយា ៤ សព្ទគឺ អាហុ, អហុ, អត្ថិ, នត្ថិ នេះ មានដំណើរប្លែកអំពីកិរិយាសព្ទឯទៀត, អាហុ និង អហុ ជាពហុវចនៈ, ប៉ុន្តែជួនណាប្រើជាឯកវចនៈក៏មាន, ដូចជា "យម្ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ សមាធិមានន្តរិកញ្ញមាហុ...˝ អាហុ ក្នុងទីនេះ ជាកិរិយារបស់ពុទ្ធសេដ្ឋោ ជាឯកវចនៈ ។ "ធម្មចក្កំ បវត្តេន្តេ កោណ្ឌញ្ញោ លោកនាយកេ កោដិសតសហស្សានំ បឋមាភិសមយោ អហុ˝ អហុ ក្នុងទីនេះ ជាកិរិយារបស់ បឋមាភិសមយោ ជាឯកវចនៈ ។ អត្ថិ និង នត្ថិ ជាឯកវចនៈ ប៉ុន្តែប្រើជាពហុវចនៈក៏បាន, ថែមទាំងប្រើរួមចូលនឹងនាមដែលមានសព្ទថា "ភាវ˝ ឬ "តា˝ បច្ច័យ នៅខាងចុងនោះបានទៀត, ដូចជាៈ ធនស្ស អត្ថិភាវោ "ភាវៈនៃទ្រព្យមាន˝, ធនស្ស នត្ថិតា "ភាវៈនៃទ្រព្យមិនមាន˝ ។ ២ ហីយត្តនីប្រែថា "(វិភត្តិ) មានក្នុងថ្ងៃម្សិល˝ គឺវិភត្តិប្រាប់នូវកាលដែលមានហើយក្នុងថ្ងៃម្សិល (ជា "ហិយ្យត្តនី˝ ដូច្នេះក៏មាន) ។ ៣ មា-សព្ទនេះ ប្រើយោគចូលបានតែនឹងវិភត្តិ ៣ ពួក គឺហិយ្យត្តនី, អជ្ជត្តនី និង បញ្ចមី, បើយោគចូលនឹងហីយត្តនី ឬអជ្ជត្តនី ឲ្យប្រែថា "កុំឡើយ˝, យោគចូលនឹងបញ្ចមី ឲ្យប្រែថា "ចូរកុំ-" ឧ. មា គច្ឆ "(ឯង) ចូរកុំទៅ˝ មា ឯរំ វទេថ "(អ្នកទាំងឡាយ) ចូរកុំនិយាយ យ៉ាងនេះ˝ ។

ផ្លាស់ថា "-ឡើយ" វិញ គឺប្រែថា "កុំ-ឡើយ" ឧ. ខណោ មា វោ ឧបច្ចគា "ខណៈ កុំ - កន្លង នូវអ្នកទាំងឡាយ - ឡើយ" ។

អជ្ជត្តនី-វិភត្តិ

អជ្ជត្តនី(១) ជាវិភត្តិប្រាប់អតីតកាលកន្លងហើយក្នុងថ្ងៃនេះ ឲ្យប្រែថា "-ហើយ" ឧ. ថេរោ អាគមិ "ព្រះថេរៈ មកហើយ", ភិក្ខូ ឯតៈទវោចុំ... "ភិក្ខុទាំងឡាយ បានពោលហើយ នូវពាក្យនេះ...", ឯវំ អកាសឹ "(ខ្ញុំ) បានធ្វើហើយ យ៉ាងនេះ" ។

ភវិស្សន្តិ-វិភត្តិ

ភវិស្សន្តិ(២) ជាវិភត្តិប្រាប់អនាគតរបស់បច្ចុប្បន្ន ឲ្យប្រែថា "នឹង-" ឧ. សោ គច្ឆិស្សតិ "គេ នឹងទៅ", ស្វេ ថេរោ អាគមិស្សតិ មយំ តស្ស ភិក្ខំ ទស្សាម ធម្មញ្ច សុណិស្សាម "ព្រះថេរៈ នឹងនិមន្តមក ក្នុងថ្ងៃស្អែក, យើងទាំងឡាយ នឹងប្រគេន នូវចង្ហាន់ ដល់លោកផង នឹងស្តាប់ នូវធម៌ផង" ។

---

១ អជ្ជត្តនី ប្រែថា "(វិភត្តិ) មានក្នុងថ្ងៃនេះ" គឺវិភត្តិប្រាប់នូវកាលដែលមានហើយក្នុងថ្ងៃនេះ ។ ២ ភវិស្សន្តិ ប្រែថា "...នឹងមាន" ជាវិភត្តិប្រាប់អនាគតរបស់បច្ចុប្បន្ន ។

# កាលាតិបត្តិ-វិភត្តិ

កាលាតិបត្តិ[១] ជាវិភត្តិប្រាប់អនាគតរបស់អតីត ឲ្យប្រែថា "នឹង-ហើយ", បើមាន "អ" អាគមនៅខាងដើម ឲ្យប្រែថា "នឹងបាន-ហើយ" ឧ. សោ ចេ យានំ លភិស្សា អគច្ឆិស្សា[២] "បើ គេ នឹងបានហើយ នូវយាន, (គេ) នឹងបានទៅហើយ" ។

បទ

[១៦១] វិភត្តិមួយពួក ៗ ចែកចេញជា ២ ផ្នែក ដូចគ្នាទាំងអស់ គឺខាងដើម ៦ បទ, ខាងចុង ៦ បទ, ផ្នែកខាងដើមហៅថា បរស្សបទ "បទដើម្បីបុគ្គលដទៃ", ផ្នែកខាងចុងហៅថា អត្តនោ-បទ "បទដើម្បីខ្លួន", ត្រូវជាបទមាន ២ យ៉ាង ។ បរស្សបទ

១ កាលាតិបត្តិ ប្រែថា "(វិភត្តិ) កន្លងនូវកាល" គឺប្រាប់ដំណើររបស់កាលដែលកន្លងទៅហើយ តែប្រាប់ប្រយោលសេចក្ដីបែរទៅខាងចំណែកអនាគត ។ វិភត្តិនេះ រមែងតែមាននិបាតសព្ទថា "បើ, ប្រសិនបើ, ប្រសិនបើជា" នេះ ប្រែនាំមុខមុនជាដរាប ។ ២ ត្រង់ "ស្សា" នេះ ច្រើនតែរស្សៈឲ្យទៅជា "ស្ស" ដូច្នេះ អភវិស្ស "នឹងបានមានហើយ", អករិស្ស "នឹងបាធ្វើហើយ", អលភិស្ស "នឹងបានបានហើយ", អសក្ខិស្ស "នឹងបានអាចហើយ", បព្វជិស្ស "នឹងបួសហើយ", បយោជិស្ស "នឹងប្រកបហើយ", បាបុណិស្ស "នឹងដល់ហើយ", បតិដ្ឋហិស្ស "នឹងឋិតនៅស៊ប់ហើយ..." ។

សម្រាប់សម្គាល់ឲ្យដឹង នូវកិរិយាសព្ទដែលជាកត្តុវាចកៈ ឧ. សូទោ ឱទនំ បចតិ "អ្នកគ្រួ[១] កំពុងចម្អិន នូវបាយ" ។ អត្តនោបទ សម្រាប់សម្គាល់នូវកិរិយាសព្ទដែលជាកម្មវាចកៈនិង ភាវវាចកៈ ឧ. សូទេន ឱទនោ បច្ចតេ "បាយ គឺអ្នកគ្រួ កំពុង ចម្អិន", ន តយា លព្ភតេ គន្តុំ "គឺអ្នក មិនបាន ដើម្បីទៅ-ទេ" (មើលទៅក្នុងខាងមុខត្រង់លេខ ១៦៥) ។ បទទាំង ២ យ៉ាង ដែលកំណត់យ៉ាងនេះ គឺកំណត់តាមដំណើរ ដែលប្រើដោយ ច្រើន, បើនិយាយឲ្យឃើញផ្សេងដោយឡែក, មិនមែនសុទ្ធតែ ទៀងទាត់ដូច្នោះដោយដាច់ខាតទេ ពីព្រោះជួនណាបរស្សបទ ប្រើជាកម្មវាចកៈ ឬភាវវាចកៈក៏មាន ឧ. ...កស្មា ឯសោ ន វុច្ចតិ "...ព្រោះហេតុអ្វីបានជា ជននុ៎ះ (គឺអ្នក) មិនថា?" (កម្មវាចកៈ) ...ន ច លព្ភតិ រូបេ..." ...ម្យ៉ាងទៀត (គឺអ្នកណាមួយ) មិនបាន ក្នុងរូប..." (ភាវវាចកៈ) ។ ជួនណាអត្តនោបទប្រើ ជាកត្តុវាចកៈក៏មាន ឧ. បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ... "សេចក្តីសោក កើត ព្រោះសេចក្តីស្រឡាញ់

---

១ អ្នកដាំស្ល ។

ភ័យ កើត ព្រោះសេចក្តីស្រឡាញ់...", សោកតេ វត មេ សខា "សំឡាញ់ នៃអញ ល្អ ហ្ន៎ ។

វចនៈ

[១៦២] វិភត្តិទាំងនោះមានវចនៈ ២ យ៉ាងគឺ ឯកវចនៈ ១ ពហុវចនៈ ១ ដូចវិភត្តិនាមដែរ ។ បើនាមសព្ទជាវចនៈណា កិរិយាសព្ទក៏ត្រូវប្រកបដោយវចនៈនោះដែរ (ឲ្យត្រូវគ្នា) ឧ. សោ គច្ឆតិ "គេ កំពុងទៅ", តេ គច្ឆន្តិ "គេទាំងឡាយ កំពុងទៅ," បុរិសោ កម្មំ ករោតិ "បុរស ធ្វើ នូវអំពើ", ឥត្ថិយោ កម្មំ ករោន្តិ "ស្ត្រីទាំងឡាយ ធ្វើ នូវអំពើ" ។ ប៉ុន្តែបើនាមសព្ទច្រើនបទតាំងពី ២ បទជាដើមទៅ, ជាឯកវចនៈ ប្រកបចូលដោយនិបាតសព្ទមាន "ច" ជាដើម (ដែលគួរប្រកប) ត្រូវប្រើកិរិយាសព្ទជាពហុវចនៈ ឧ. សេដ្ឋី ច សេដ្ឋិភរិយា ច រាជានំ ឧបសង្កមឹសុ "សេដ្ឋីផង ភរិយានៃសេដ្ឋីផង ចូលទៅគាល់ហើយ នូវស្តេច ។

បុរិសៈ

[១៦៣] វិភត្តិទាំងនោះចែកចេញជាបុរិសៈមាន ៣ យ៉ាង គឺ បឋមបុរិសៈ ១ មជ្ឈិមបុរិសៈ ១ ឧត្តមបុរិសៈ ១ ដូចបុរិស-

សព្វនាមដែរ (មើលក្នុងនាមនិទ្ទេសត្រង់លេខ ១១១) ។ បើបុរិសសព្វនាមណាជាបទប្រធាន. ត្រូវប្រើកិរិយាសព្ទប្រកបវិភត្តិឲ្យត្រូវគ្នានឹងបុរិសសព្វនាមនោះ ឧ. (បឋមបុរិសៈ) សោ យាតិ "គេ ទៅ", តេ យន្តិ "គេទាំងឡាយ ទៅ", កុមារោ យាតិ "ក្មេងប្រុស ទៅ" កុមារិយោ យន្តិ "ក្មេងស្រីទាំងឡាយ ទៅ" ។ (មជ្ឈិមបុរិសៈ) ត្វំ យាសិ អ្នក ទៅ" តុម្ហេ យាថ "អ្នកទាំងឡាយ ទៅ" ។ (ឧត្តមបុរិសៈ) អហំ យាមិ "ខ្ញុំ ទៅ" មយំ យាម "យើងទាំងឡាយ ទៅ" ។ ប៉ុន្តែដែលនឹងសរសេរក្តីនិយាយមាត់ទទេក្តី បើមិនបាច់ដាក់បទប្រធានមក គ្រាន់តែដាក់កិរិយាសព្ទមកប៉ុណ្ណោះក៏បាន ឧ. យាហិ "(អ្នក) ចូរទៅចុះ", សីឃំ និក្ខម "(ឯង) ចូរចេញ ឲ្យឆាប់ទៅ", ទានំ ទស្សាម "(យើងទាំងឡាយ) នឹងឲ្យ នូវទាន", យាហិ និង និក្ខម ជា ម. ឯក. កិរិយាសព្ទរបស់ ត្វំ, ទស្សាម ជា. ឧ. ពហុ. កិរិយា

សព្ទរបស់ មយំ, បើទុកជាមិនសរសេរដាក់ ត្វំ, មយំ មក ក៏គង់អាចដឹងបាន ពីព្រោះ យាហិ និង និក្ខម ជាកិរិយារបស់ ត្វំ, ទស្សាម ជាកិរិយារបស់ មយំ ។

ធាតុ

[១៦៤] វិភត្តិប្រកបដោយ កាល, បទ, វចនៈ, បុរិសៈ ប៉ុណ្ណេះ សម្រាប់ផ្សំជាមួយនឹង "ធាតុ" គឺសព្ទដែលជាឫសគល់នៃពាក្យ ឲ្យចេញប្រាកដមកជា កិរិយាសព្ទ របស់ នាមដូចបាននិយាយក្នុងខាងដើមត្រង់លេខ ១៥៩ ខ្លះមកហើយ ។ ធាតុនោះ និយាយដោយសង្ខេប ចែកចេញជា ធាតុគណៈ "ពួកនៃធាតុ" មាន ៨ ពួក តាមដំណើរដែលចុះបច្ច័យត្រូវគ្នាដូចមានរបៀបរៀបរៀង ព្រមទាំងបែបផ្សំដោយវត្តមានាវិភត្តិប៉ែកខាងបរស្សបទខ្លះ ដោយសង្ខេបតទៅនេះ ៖

## ១ ឰកាភូ-ធាតុ

ភូ "កើត, មាន, ជា-" (ប.) ភវតិ, ភវន្តិ, (ម.): ភវសិ, ភវថ, (ឧ.): ភវាមិ, ភវាម ។ ហុ(១) "កើត, មាន, ជា-" ហោតិ, ហោន្តិ, ...ហោមិ, ហោម ។ សី "ដេក": សេតិ, សយតិ, សេន្តិ, សយន្តិ:... សេមិ, សយាមិ, សេម, សយាម ។ ខន "ជីក": ខនតិ, ខនន្តិ,... ។ បឋ "ពោល, និយាយ,..." បឋតិ, បឋន្តិ,... ។ បច "ចម្អិន,...": បចតិ, បចន្តិ,... ។ ឥក្ខ "ឃើញ": ឥក្ខតិ, ឥក្ខន្តិ,... ។ មរ "ស្លាប់": មរតិ, មរន្តិ,... ។ លភ "បាន": លភតិ, លភេតិ, លភន្តិ,... ។ គម "ទៅ, ដល់"

---

១ ធាតុ ៣ សព្ទគឺ "ភូ, ហុ, អស", កាលណាបើប្រើជាកិរិយាសព្ទក្នុងប្រយោគជាវិកតិកត្តា,មិនបាច់ប្រែចេញពាក្យថា "កើត" ថា "មាន" ទេ ព្រោះជាកិរិយាសព្ទគ្រាន់តែនាំដំណើរប្រយោគឲ្យមានពាក្យថា "ជា-" ប៉ុណ្ណោះ : ត្រូវប្រែថា "ជា-" ឧ. និរត្ថន្តំ ភវិស្សតិ "កម្មនោះនឹងជាអំពើឥតប្រយោជន៍" ។ មម មាតា សីលវតី ហោតិ..." មាតារបស់ខ្ញុំជាអ្នកមានសីល...", តុណ្ហី ហោហិ "(ឯង) ចូរជាមនុស្សស្ងៀមទៅ" ។ ឆេកោ'សិ ទក្ខោ កុសលោ "(អ្នក)ជាមនុស្សឈ្លាសប្រសប់វាងវៃ ពុទ្ធំ សរណំ គតោ'ស្មិ "(ខ្ញុំ) ជាបុគ្គលដល់ហើយ នូវព្រះពុទ្ធជាទីរឭក" ។ជួនណាមានទំនងឲ្យប្រែថា "នៅ" ឧ. គច្ឆថ, ឥធេវ ភវិស្សាមិ "(អ្នក ទាំងឡាយ) ចូរទៅចុះ (ខ្ញុំ) នឹងនៅ ក្នុងទីនេះឯង", មា តត្ថាតិចិរំ ហោហិ (ឯង) ចូរកុំនៅ ក្នុងទីនោះ យូរពេក" ។ ដែលចុះក្នុងប្រយោគជាវិកតិកត្តា, ទោះមានបទវិកតិកត្តា ឬ បទវិសេសនៈច្រើន ក្តី, លើកតែបទប្រធាន ចេញ,ក្រៅពីនោះ ត្រូវ ប្រែរួបទាំងអស់ចូលភ្ជាប់ទៅនឹងកិរិយាសព្ទ(បែបសម្ពន្ធគង់នៅតាមធម្មតា) ។

គច្ឆតិ, គមេតិ, គច្ឆន្តិ, គច្ឆសិ, គច្ឆថ, គច្ឆាមិ, គច្ឆាម,... ។ គុប "គ្រប់គ្រង, រក្សា" : គោបេតិ, គោបេន្តិ: គោបេសិ, គោបេថ, គោបេមិ, គោបេម, ... ។

## ២ ពួករុធ-ធាតុ

រុធ "បិទ, រាំង, ខ្ទប់,..." : រុន្ធតិ, រុន្ធេតិ, រុន្ធន្តិ, រុន្ធសិ, រុន្ធថ, រុន្ធាមិ, រុន្ធាម ។ មុច "រួច, លែង, រដោះ,..." : មុញ្ចតិ, មុញ្ចេតិ, មុញ្ចន្តិ, មុញ្ចេន្តិ,... ។ ភុជ "ស៊ី,..." : ភុញ្ជតិ, ភុញ្ជន្តិ,... ។ ឆិទ "កាត់,..." ឆិន្ទតិ, ឆិន្ទន្តិ,... ។ ភិទ "បែក, ធ្លាយ" : ភិន្ទតិ, ភិន្ទន្តិ, ភិន្ទសិ, ភិន្ទថ, ភិន្ទាមិ, ភិន្ទាម,... ។

## ៣ ពួកទិវ-ធាតុ

ទិវ "លេង" : ទិព្វតិ, ទិព្វន្តិ, ទិព្វសិ, ទិព្វថ, ទិព្វាមិ, ទិព្វាម ។ សិវ "ដេរ" : សិព្វតិ, សិព្វន្តិ,... ។ ខិ "អស់" : ខិយតិ, ខិយន្តិ?... ។ មុហ "ភ្លេច, វង្វេង, ភាន់,..." : មុយ្ហតិ, មុយ្ហន្តិ,...។ រជ "ជ្រលក់" : រជ្ជតិ, រជ្ជន្តិ,... ។ មុស "ភ្លេច,..." : មុស្សតិ,

មុស្សន្តិ,... ។ ពុធ "ដឹង, ត្រាស់ដឹង,..." : ពុជ្ឈតិ, ពុជ្ឈន្តិ,... ។ យុធ "ច្បាំង,..." : យុជ្ឈតិ, យុជ្ឈន្តិ, យុជ្ឈសិ, យុជ្ឈថ, យុជ្ឈាមិ, យុជ្ឈាម,... ។

## ៤ ពួកសុ-ធាតុ

សុ "ឮ, ស្តាប់" : សុណាតិ, សុណោតិ, សុណន្តិ, សុណសិ, សុណោសិ, សុណាថ, សុណោថ, សុណាមិ, សុណោមិ, សុណាម, សុណោម ។ វុ "ក្រង,..." : វុណាតិ, វុណោតិ, វុណន្តិ,... ។ អាប "ដល់", ប + អប "ដល់, ទាន់,..." : បាបុណាតិ, បាបុណន្តិ, បាបុណាសិ, បាបុណាថ, បាបុណាមិ, បាបុណាម ។

## ៥ ពួកកី-ធាតុ

កី "ទិញ" : កីនាតិ, កីនន្តិ, កីនាសិ, កីនសិ, កីនាថ, កីនថ, កីនាមិ, កីនាម ។ ចិ "សន្សំ, បេះ,..." : ចិនាតិ, ចិនន្តិ,... ។ ជិ "ឈ្នះ, ផ្ចាញ់" : ជិនាតិ, ជិនន្តិ,... ។ ញា "ដឹង, ស្គាល់" : ជានាតិ, ជានន្តិ,... ។ ធុ "កុំចាត់, កម្ចាត់

បង់″ : ធុនាតិ, ធុនន្តិ,... ។ ផុ "អុំ, ស្ងៃ″ : ផុនាតិ, ផុនន្តិ,... ។ លុ "កាត់″ : លុនាតិ, លុនន្តិ, លុនាសិ, លុនសិ, លុនាថ, លុនថ, លុនាមិ, លុនាម,... ។

## ៦ ពួកគហ-ធាតុ

គហ "កាន់, ចាប់, យក,...″ : (ឃេប្បតិ), គណ្ហាតិ, គណ្ហតិ, គណ្ហន្តិ, គណ្ហាសិ, គណ្ហសិ, គណ្ហាថ, គណ្ហថ, គណ្ហាមិ, គណ្ហាម ។ តាមមេសូត្រក្នុងអាខ្យាតថា គហាទិតោ ប្ប-ណ្ហា "ចុះបច្ច័យគឺ ប្ប និង ណ្ហា, ក្នុងកត្តុ អំពីមុខពួកធាតុ មាន គហ ជាដើម″, ប៉ុន្តែឧទាហរណ៍ឃើញមានតែ គហ មួយប៉ុណ្ណោះ ។

## ៧ ពួកតន-ធាតុ

តន "ផ្សាយចេញ, ត្រដាង, លាត, លា″ : តនោតិ, តនោន្តិ, តនោសិ, តនោថ, តនោមិ, តនោម ។ ករ "ធ្វើ″ : ករោតិ, កយិរតិ, ករោន្តិ, កយិរន្តិ,... ។ ជាគរ "ភ្ញាក់, រឭក″ : ជាគរោតិ, ជាគរោន្តិ,... ។ សក្ក "អាច, ហ៊ាន″ : សក្កោតិ, សក្កោន្តិ, សក្កោសិ, សក្កោថ, សក្កោមិ សក្កោម,... ។

## ៨ ឰភចុរ-ជាតុ

ចុរ "លួច" : ចោរេតិ, ចោរយតិ, ចោរេន្តិ, ចោរយន្តិ, ចោរេសិ, ចោរយសិ, ចោរេថ, ចោរយថ, ចោរេមិ, ចោរយាមិ, ចោរេម, ចោរយាម ។ ចិន្ត "គិត" : ចិន្តេតិ, ចិន្តយតិ, ចិន្តេន្តិ, ចិន្តយន្តិ,... ។ តក្ក "ត្រិះរិះ" : តក្កេតិ, តក្កយតិ, តក្កេន្តិ, តក្កយន្តិ,...។ មន្ត "ប្រឹក្សា, ពិភាក្សា, ជជែក" : មន្តេតិ, មន្តយតិ, មន្តេន្តិ, មន្តយន្តិ,... ។ លក្ខ[១] "កំណត់" : លក្ខេតិ, លក្ខយតិ, លក្ខេន្តិ, លក្ខយន្តិ, លក្ខេសិ, លក្ខយសិ, លក្ខេថ, លក្ខយថ, លក្ខេមិ, លក្ខយាមិ, លក្ខេម, លក្ខយាម,... ។

---

១ ធាតុដែលមានព្យញ្ជនៈទីបំផុតហាក់ដូចជាអាស្រ័យនឹងស្រៈ "អ" ដូចយ៉ាង គម, ខន, បឋ, បច, តន, លភ, មរ, ទិវ ជាដើមនោះ តាមន័យក្នុងកច្ចាយនៈ, ជួនណាប្រើស្រៈ "ឧ" ខ្លះក៏មាន ដូចជា គម, ខន, តន, ទិវ ជាដើម ប្រើជា គមុ, ខនុ, តនុ, ទិវុ, ជួនណាប្រើជាគម, ទិវ ដូចត្រង់មេសូត្រ "គម-ខន-ហាន-រមាទីនមន្តោ, គម-ខន-ហានាទីនន្តំតព្វាទីសុ ន" ជាដើម ។ បានសង្កេតក្នុងគម្ពីរសព្ទសាស្ត្រច្រើនអន្លើ ឃើញថាព្យញ្ជនៈទីបំផុតធាតុទាំងនោះច្រើនតែជា មូគព្យញ្ជនៈ "ព្យញ្ជនៈគ" គឺមិនមានសម្លេងស្រៈ "អ" ទេ. ឲ្យថា គ័ម, ខ័ន, ត័ន, ល័ក្ខ, ល័ភ, ច័រ, ក័រ, ត័រ ម័រ, អ័ស,... ។ ក្នុងកច្ចាយនបករណ៍, ត្រង់វិធីឯទៀតក្រៅពីធាតុ ក៏មានន័យយ៉ាងនេះខ្លះដែរ ដូចត្រង់មេសូត្រ "អប្បស្ស ក័ណ សរេ អ័ន (ឲ្យផ្លាស់អប្ប ជាក័ណ ឲ្យផ្លាស់ ន ជា អ័ន)" ជាដើម ។ ចំណែកខាងលទ្ធិរបស់វេយ្យាករណបណ្ឌិតទាំងឡាយក្នុងប្រទេសប៉ែកខាងលិច, ក៏សុទ្ធតែប្រកាន់តាមន័យខាងក្រោយនេះ ។ ត្រង់ន័យនេះសូមអស់លោកវេយ្យាករណបណ្ឌិតក្នុងប្រទេសយើង កាន់យកតាមគួរដល់ការប្រកបចុះ ។

បណ្តាធាតុទាំងឡាយក្នុងពួកទាំង ៨ នោះ, ធាតុណាដែលប្រកបដោយ "កម្ម" គឺអំពើដែលគេត្រូវធ្វើ ដូចយ៉ាង បច, ឥក្ខ ជាដើម ធាតុនោះហៅថា សកម្មធាតុ "ធាតុប្រព្រឹត្តទៅមួយអន្លើដោយកម្ម" ឬថា "ធាតុប្រកបដោយកម្ម" ពីព្រោះត្រូវការដោយពាក្យអាយតនិបាតថា "នូវ-" ឧ. ឱទនំ បចាមិ "ខ្ញុំ កំពុងចម្អិន នូវបាយ", រូបំ ឥក្ខតិ- "(គេ) ឃើញ នូវរូប-" ។ ធាតុណាដែលមិនប្រកបដោយកម្ម គឺមិនត្រូវការដោយពាក្យអាយតនិបាតថា "នូវ-" ដូច្នោះទេ ដូចយ៉ាង ភូ, ហុ, សី ជាដើម ធាតុនោះហៅថា អកម្មធាតុ "ធាតុមិនមានកម្ម" ឧ. មញ្ចេ សយតិ "(គេ) ដេក លើគ្រែ" ។

មានន័យផ្សេងទៀតថា: ធាតុទាំង ២ យ៉ាងនោះ កាលបើមានឧបសគ្គជាបុព្វបទ, ឧបសគ្គនោះ មានអំណាចបំបែរសព្ទឲ្យមានសេចក្តីផ្សេងអំពីដំណើរដើម បំបែរសកម្មធាតុឲ្យត្រឡប់ជាអកម្មធាតុ, អកម្មធាតុឲ្យត្រឡប់ជាសកម្មធាតុវិញក៏មាន, ហៅថា "ឧបសគ្គបំបែរធាតុ" ឬ "ឧបសគ្គបំបែរសព្ទ" ឧ. ភវតិ "-កើត, -មាន" ( ជាអកម្មធាតុ ), អនុភវតិ "-សោយ, -រង, ទទួល",

អភិភវតិ "-គ្របសង្កត់" (ត្រឡប់ជាសកម្មធាតុវិញ), គច្ឆតិ "-ទៅ, -ដល់" (ជាសកម្មធាតុ), អបគច្ឆតិ "-ជៀសចេញ, -គេចចេញ", អវគច្ឆតិ "-លិចចុះ, -លិបចុះ", វិគច្ឆតិ "ទៅប្រាស, -ឃ្លាត" (ត្រឡប់ជាអកម្មធាតុវិញ) ។ (មើលនាមនិទ្ទេស ត្រង់លេខ ១២៤ និង ១២៥) ។

ម្យ៉ាងទៀត, ធាតុដែលមានដំណើរសព្ទជា ២ យ៉ាង ដូចជា "ឆិទ" បើប្រែថា "កាត់" ជាសកម្មធាតុ, បើប្រែថា "ដាច់" ជាអកម្មធាតុ, "បច" បើប្រែថា "ចម្អិន" ជាសកម្មធាតុ, បើប្រែថា "ឆ្អិន, ចាស់, ទុំ,..." ជាអកម្មធាតុ, ធាតុយ៉ាងនេះហៅថា សកម្មាកម្មធាតុ "ធាតុមានកម្មផងមិនមានកម្មផង" គឺជាសកម្មធាតុក៏បាន ជាអកម្មធាតុក៏បាន ។

## វាចកៈ

[១៦៥] កិរិយាសព្ទប្រកបដោយ វិភត្តិ កាល, បទ, វចនៈ, បុរិសៈ, ធាតុ ដូចថ្លែងមកហើយនោះ ចែកចេញជា វាចកៈមាន ៥ យ៉ាង គឺ កត្តុវាចកៈ ១ កម្មវាចកៈ ១ ភាវវាចកៈ ១ ហេតុកត្តុវាចកៈ ១ ហេតុកម្មវាចកៈ ១ ។

កត្តុវាចកៈ កិរិយាសព្ទប្រាប់កត្តា ហៅថា កត្តុវាចកៈ ឧ. សូទោ ឱទនំ បចតិ "អ្នកគ្រួ កំពុងចម្អិន នូវបាយ" ។ សូទោ ជាអ្នកធ្វើ ហៅថា កត្តា[១] ជាបទប្រធានរបស់ បចតិ, ឱទនំ ជាអំពើដែលអ្នកគ្រួត្រូវធ្វើ ហៅថា កម្ម, បចតិ ជាកិរិយាសព្ទប្រាប់ដំណើរធ្វើរបស់ សូទោ ហៅថា "កត្តុវាចកៈ ។

កម្មវាចកៈ កិរិយាសព្ទប្រាប់កម្ម ហៅថា កម្មវាចកៈ ឧ. សូទេន ឱទនោ បចិយតេ "បាយ ដែលអ្នកគ្រួកំពុងចម្អិន" ។ សូទេន ជាកត្តា ព្រោះជាអ្នកចម្អិន ដូចក្នុងកត្តុវាចកៈដែរ ប៉ុន្តែក្នុងទីនេះ ត្រូវប្រកបតតិយាវិភត្តិ បែរជា ហៅថា អនភិហិតកត្តាវិញ, ឱទនោ ជាកម្ម ដូចក្នុងកត្តុវាចកៈដែរ ប៉ុន្តែក្នុងទីនេះ ត្រូវប្រកបបឋមាវិភត្តិ ព្រោះប្រើជាបទប្រធានរបស់ បចិយតេ, បចិយតេ ជា "កម្មវាចកៈ" ព្រោះជាកិរិយាសព្ទប្រាប់ដំណើររបស់ ឱទនោ ដែលជាកម្ម ។

ភាវវាចកៈ កិរិយាសព្ទប្រាប់ភាព ហៅថា ភាវវាចកៈ ឧ. តេន ភូយតេ "គឺគេ កើត" ។ តេន ជាអនភិហិតកត្តា

---

១ ហៅថាឲ្យពេញតាមដំណើរសម្ពន្ធថាៈ សយកត្តា "អ្នកធ្វើខ្លួនឯង" ។

ដូចន័យមុន, ភូយតេ ជា "ភាវវាចកៈ" ជាកិរិយាសព្ទគ្រាន់តែប្រាប់សេចក្តីថា "កើត" ប៉ុណ្ណោះមិនមែនប្រាប់កត្តាឬកម្មឡើយ កិរិយាសព្ទជាភាវវាចកៈនេះ ប្រើបានចំពោះតែត្រង់បឋមបុរិសៈឯកវចនៈម្យ៉ាង, ឯអនភិហិតកត្តា តាមតែប្រើបុរិសៈណា, វចនៈណាក៏បាន ឧ. តេន ភូយតេ, តេហិ ភូយតេ, ជនេន ភូយតេ, ជនេហិ ភូយតេ, តយា ភូយតេ, តុម្ហេហិ ភូយតេ, មយា ភូយតេ, អម្ហេហិ ភូយតេ ។

ហេតុកត្តុវាចកៈ កិរិយាសព្ទប្រាប់កត្តា ដែលជាហេតុ ហៅថា ហេតុកត្តុវាចកៈ ឧ. សេដ្ឋី សូទំ ឱទនំ បាចេតិ "សេដ្ឋីញ៉ាំងអ្នកគ្រួឲ្យចម្អិន នូវបាយ" ។ សេដ្ឋី ជា ហេតុកត្តា ព្រោះជាអ្នកធ្វើគ្រាន់តែជាហេតុ គឺមិនធ្វើខ្លួនឯង ជាអ្នកគ្រាន់តែប្រើគេឲ្យធ្វើ ជាបទប្រធានរបស់ បាចេតិ, សូទំ ជា ការិតកម្ម ព្រោះជាអ្នកទទួលបង្គាប់ ហើយសម្រេចអំពើដែលគេប្រើឲ្យធ្វើនោះ, ឱទនំ ជាកម្ម ដូចន័យមុន, បាចេតិ ជា "ហេតុកត្តុ-វាចកៈ" ព្រោះជាកិរិយាសព្ទប្រាប់ដំណើរប្រើរបស់ សេដ្ឋី ដែលជាហេតុកត្តា ។

ហេតុកម្មវាចកៈ កិរិយាសព្ទប្រាប់កម្មដែលជាហេតុ ហៅថា ហេតុកម្មវាចកៈ ឧ. សេដ្ឋិនា សូទេន ឱទនោ បាចាបិយតេ "បាយ ដែលសេដ្ឋី ញុាំងអ្នកគ្រួឲ្យចម្អិន" ។ សេដ្ឋិនា ជាអ្នកធ្វើគ្រាន់តែជាហេតុ ហៅថា ហេតុកត្តា ដូចន័យមុន ប៉ុន្តែក្នុងទីនេះ ត្រូវប្រកបតតិយាវិភត្តិ បែរជាហៅថា អនភិហិតកត្តាវិញ, សូទេន ជាការិតកម្ម ដូចន័យមុន តែក្នុងទីនេះ ប្រកបតតិយាវិភត្តិ[១] បែរជាហៅថា តតិយាការិតកម្ម វិញ, បាចាបិយតេ ជា "ហេតុកម្មវាចកៈ" ព្រោះជាកិរិយាសព្ទប្រាប់ដំណើរកម្មដែលជាហេតុ គឺប្រាប់ថាជាកិរិយារបស់ ឱទនោ ដែលជាអំពើគេប្រើឲ្យអ្នកដទៃធ្វើ ។

វាចកៈ ទាំង ៥ នេះ ជាសំខាន់បំផុត ក្នុងការរៀនបាឡីភាសា, អ្នករៀនត្រូវសង្កេតឲ្យយល់ដោយច្បាស់លាស់ទើបប្រែបាឡីមិនច្រឡំ, ទោះត្រូវការតែងសេចក្តីជាភាសាបាឡីក្តី និយាយគ្នាជាភាសាបាឡីក្តី តែមិនស្ទាត់វាចកៈហើយ ក៏មុខជានឹងភ្លាត់ខុស ប្រើការពុំកើតឡើយ ។

---
១ ប្រកបទុតិយាវិភត្តិក៏បាន ។

[១៦៦] វាចកៈទាំង ៥ យ៉ាងនោះ អ្នកសិក្សានឹងយល់ដាក់បាន ដោយអាស្រ័យបច្ច័យជាគ្រឿងចំណាំ ។ បច្ច័យក្នុងអាខ្យាត, និយាយដោយសព្វគ្រប់ តាមរបៀបក្នុងកច្ចាយនៈបករណ៍, មាន ២៥ គឺ អ, ឥ, ឦ, ឯ, យ, ណុ, ណា, ឧណា, នា, ប្ប, ណ្ហា, ឱ, យិរ, ណេ, ណយ, ណាបេ, ណាបយ, ខ, ឆ, ស, អាយ, ឦយ, អល, អារ, អាល ។

បច្ច័យសម្រាប់ចុះក្នុងកត្តុវាចកៈមាន ១៥ គឺ អ, ឥ, ឦ, ឯ, យ, ណុ, ណា, ឧណា, នា, ប្ប, ណ្ហា, ឱ, យិរ, ណេ, ណយ ។ បច្ច័យទាំង ១៥ នេះ ចុះក្នុងពួកធាតុ ទាំង ៨ (ក្នុងកត្តុវាចកៈ) ដូច្នេះ

ពួកភូ-ធាតុចុះបានបច្ច័យ ១ គឺ "អ" : ឧ. ភវតិ, ហោតិ, សេតិ, សយតិ, ខនតិ, ជយតិ, ជេតិ, នយតិ, នេតិ, លភតិ, គច្ឆតិ, ... ... កថេតិ, កិតេតិ, គោបេតិ, ជោតេតិ, លភេតិ, មានេតិ, វជ្ជេមិ, វទេមិ,... (ផ្លាស់អ-បច្ច័យជា ឯ, តែក្នុងបករណៈឯទៀតខ្លះ ថាឲ្យចុះឯ-បច្ច័យតែម្តង, ថាពួកភូ-ធាតុមានបច្ច័យ ២ គឺ អ, ឯ) ។

ពួករុធ-ធាតុចុះបានបច្ច័យ ៥ គឺ អ, ឥ, ឦ, ឯ, ឱ ។ អ : រុន្ធតិ, កុញ្ចតិ, មុញ្ចតិ, ឆិន្ទតិ, ភិន្ទតិ, ចង្កមតិ, ចញ្ចលតិ, ជង្គមតិ, ... ។ ឥ, ឦ : រុន្ធិតិ, រុន្ធីតិ ។ ឱ : សុម្ភោតិ ។ (បច្ច័យ ៣ គឺ ឥ, ឦ, ឱ នេះ ពិតជាសម្រាប់ចុះក្នុងពួករុធ-ធាតុមែន ប៉ុន្តែមិនសូវប្រើទេ)។ ឯ : រុន្ធេតិ, មុញ្ចេតិ, ... ។ ក្នុងពួករុធ-ធាតុនេះ ត្រូវចុះនិគ្គហិតអាគម[១] ត្រង់ខាងលើព្យញ្ជនៈខាងដើមធាតុ ហើយផ្លាស់និគ្គហិតនោះជាវគ្គន្តព្យញ្ជនៈ តាមវិធីនិគ្គហិតាទេសសន្ធិ ជាកំណត់ ។

ពួកទិវ-ធាតុចុះបានបច្ច័យ ១ គឺ "យ" ឧ. ទិព្វតិ, សិព្វតិ, ខិយតិ, មុយ្ហតិ, វជ្ជតិ, មុស្សតិ, ពុជ្ឈតិ, យុជ្ឈតិ, វិជ្ឈតិ ។

---

១ អាគមសម្រាប់ចុះក្នុងអាខ្យាតមាន ៥ គឺ អ, ឥ, ស, ហ, និគ្គហិត (ំ) ។ អ-អាគមសម្រាប់ចុះក្នុងខាងដើមធាតុ ចំពោះវិភត្តិ ៣ ពួកគឺ ហីយត្តនី, អជ្ជត្តនី, កាលាតិបត្តិ ឧ. អគមា អគមូ, អវោច, អវោចុំ, អវចំ, អកាសឹ, អគច្ឆិស្សា, អលភិស្ស ។ ឥ-អាគមសម្រាប់ចុះត្រង់ទីបំផុតធាតុ ចំពោះវិភត្តិ ៣ ពួកគឺ អជ្ជត្តនី, ភវិស្សន្តិ, កាលាតិបត្តិ ឧ. អករិម្ហា, វសិម្ហា, ភវិស្សតិ, លភិស្សតិ, អគច្ឆិស្សា, អលភិស្ស, បតិដ្ឋហិស្ស ។ ស-អាគមសម្រាប់ចុះត្រង់ទីបំផុតធាតុចំពោះតែអជ្ជត្តនីវិភត្តិមួយប៉ុណ្ណោះ ឧ. អគមាសិ, អហាសិ, អហោសិ, អហោសុំ ។ ហ-អាគមសម្រាប់ចុះត្រង់ទីបំផុតធាតុតាមគួរដល់ការប្រកប ឧ. បតិដ្ឋហាតិ, បតិដ្ឋហន្តិ, បតិដ្ឋហិ, បតិដ្ឋហឹសុ, បតិដ្ឋហិស្សតិ, បតិដ្ឋហិស្ស ។ និគ្គហិតអាគម (ំ) សម្រាប់ចុះក្នុងពួករុធ-ធាតុ, (ដែលកំពុងនិយាយនេះឯង) ។ ចំពោះតែព្រូ-ធាតុមួយ, បើផ្សំនឹងតិ-វត្តមានា, ឲ្យចុះ ឦ-អាគម : ព្រវីតិ "-ពោល" ។

ពួកសុ-ធាតុចុះបានបច្ច័យ ៣ គឺ ណុ, ណា, ឧណា ។ ណុ : សុណោតិ, វុណោតិ,...។ ណា : សុណាតិ, សុណន្តិ, វុណាតិ,... ។ ឧណា : បាបុណាតិ, បាបុណន្តិ, បាបុណាតុ, បាបុណេយ្យ, បាបុណិ, បាបុណិស្សតិ ។ (ឧណា មិនសូវប្រើទេ) ។

ពួកកី-ធាតុចុះបានបច្ច័យ ១ គឺ "នា" ឧ. កីនាតិ, វិក្កីណាតិ (នា > ណា), ចិនាតិ, ជិនាតិ, ជានាតិ (ញា > ជា), នាយតិ (ញា > នា, នា-បច្ច័យ > យ), ធុនាតិ, ធុនន្តិ, លុនាតិ, លុនន្តិ ។

ពួកគហ-ធាតុចុះបានបច្ច័យ ២ គឺ ប្ប, ណ្ហា ។ ប្ប : ឃេប្បតិ (គហ > ឃេ) ។ ណ្ហា : គណ្ហាតិ, គណ្ហតិ, គណ្ហន្តិ, គណ្ហាតុ, គណ្ហតុ, គណ្ហន្តុ, គណ្ហេយ្យ, គណ្ហេយ្យុំ,... ។

ពួកតន-ធាតុចុះបានបច្ច័យ ២ គឺ ឱ, យិរ ។ ឱ : តនោតិ, ករោតិ, ជាគរោតិ, សក្កោតិ, សក្កោន្តិ ។ យិរ : កយិរតិ, កយិរហិ (យិរ មិនសូវប្រើទេ) ។

ពួកចុរ-ធាតុចុះបានបច្ច័យ ២ គឺ ណេ, ណយ ។ ណេ : ចោរេតិ, ចិន្តេតិ, តក្កេតិ, មន្តេតិ, មន្តេន្តិ, ... ។ ណយ : ចោរយតិ, ចិន្តយតិ, តក្កយតិ, មន្តយតិ, មន្តយន្តិ... ។

ក្នុងកម្មវាចកៈចុះបានបច្ច័យ ១ គឺ "យ" ឧ. បចិយតេ, បច្ចតេ, គមិយតេ, គច្ឆិយតេ, គម្យតេ, ទមិយតេ, ទម្យតេ, លភិយ-តេ, លព្ភតេ, វុច្ចតេ, ភុញ្ជិយតេ, ពោធិយតេ, ពុជ្ឈតេ, សយ្យតេ, កីយតេ, ញាយតេ, គហិយតេ, ករិយតេ ចុរិយតេ ។

ក្នុងភាវវាចកៈចុះបានបច្ច័យ ១ គឺ "យ" ឧ. ភូយតេ, សីយតេ, បចិយតេ, បច្ចតេ, គមិយតេ, គច្ឆិយតេ, គម្យតេ, ទមិយតេ, ទម្យតេ, លព្ភតេ, វុច្ចតេ, ... ។

យ-បច្ច័យ ចុះក្នុងកត្តុវាចកៈ, កម្មវាចកៈ និង ភាវវាចកៈ មានគតិផ្សេងគ្នា ដូច្នេះ ៖

យ-បច្ច័យដែលចុះក្នុងកត្តុវាចកៈក្នុងពួកទិវ-ធាតុ ត្រូវទុកឲ្យគង់រូបនៅជា "យ" ដូចដើមក៏មាន ឧ. ខិយតិ ។ ផ្សំ "យ" និងទីបំផុតធាតុក៏មាន ឧ. មុយ្ហតិ ។ ផ្លាស់ "យ" និងទីបំផុតធាតុជាព្យញ្ជនៈផ្សេង អំពីភាពដើមក៏មាន ឧ. ទិព្វតិ, ពុជ្ឈតិ ។

យ-បច្ច័យចុះក្នុងកម្មវាចកៈ និងភាវវាចកៈ ដែលទុកឲ្យគង់រូបនៅជា "យ" ដូចដើម, ត្រូវចុះ - អាគមផ្សំមកផង

បើទីបំផុតធាតុគ្មានស្រៈ គឺជាមូគព្យញ្ជនៈ ឧ. បចិយតេ[១], គច្ឆិយតេ, ទមិយតេ ។ បើទីបំផុតធាតុមានស្រៈវិញ មិនបាច់ចុះ-អាគមទេ ឧ. ភូយតេ[១], ញាយតេ, កីយតេ[១] ។ តម្រួត "យ" ជា "យ្យ" ក៏មាន ឧ. ភុយ្យតេ[១], សុយ្យតេ ។ ទីបំផុតធាតុគ្មានស្រៈ បើមិនចុះ-អាគមទេ ត្រូវផ្សំ "យ" និងទីបំផុតធាតុជាការស្រេច ឧ. គម្យតេ, ទម្យតេ ។ ផ្លាស់ "យ" និងទីបំផុតធាតុជាព្យញ្ជនៈផ្សេងអំពីភាពដើម គឺធ្វើទីបំផុតធាតុឲ្យជាព្យញ្ជនៈសំយោគក៏បាន ឧ. បច្ចតេ, លព្ភតេ, វុច្ចតេ, ផល្លតេ, ទម្មតេ, ឧច្ចតេ, សក្កតេ, ទិស្សតេ ។ ផ្លាស់ "អា" របស់ធាតុជា "ឦ" ក៏បាន ឧ. ទីយតេ[១], ធីយតេ, មីយតេ, បីយតេ, ហីយតេ, បីយតេ, មហីយតេ, មថីយតេ ។

---

១ តាមសង្កេតឃើញក្នុងបាឡីព្រះត្រៃបិដកនិងគម្ពីរផ្សេងៗ ថា ឥ-អាគមក្តី ទីបំផុតធាតុជា ឥ ឬ ឦក្តី, បើផ្សំជាមួយនឹងយ-បច្ច័យដែលគង់រូប ច្រើនមានរូបជាឦយ ឬ ឥយ្យ គឺទីឃៈ ឥ ជាឦ ឬរស្សៈ ឦ ជា ឥ ហើយតម្រួត យ ជាយ្យ ឧ. បចីយតេ ឬ បចិយ្យតេ, ចីយតេ ឬ ចិយ្យតេ, កីយតេ ឬ កិយ្យតេ, ទីយតេ ឬទិយ្យតេ ។ សូម្បីទីបំផុតធាតុ ជា ឧ ឬ ឩ, បើផ្សំជាមួយនឹង យ-បច្ច័យគង់រូប ច្រើនតែមានរូបជា ឩយ ឬ ឧយ្យ គឺ ទីឃៈ ឧជាឩ ឬ រស្សៈ ឩ ជា ឧ ហើយតម្រួត យ ជា យ្យ ឧ. សូយិត្ថ ឬ សុយ្យិត្ថ, ហូយតេ ឬ ហុយ្យតេ, ភូយតេ ឬ ភុយ្យតេ ។

ក្នុងហេតុកត្តុវាចកៈចុះបានបច្ច័យ ៤ គឺ ណេ, ណយ, ណាបេ, ណាបយ (បច្ច័យទាំង ៤ នេះ ហៅថា ការិតបច្ច័យ ឬ ហៅថា ហេតុបច្ច័យ ក៏បាន) ។ ណេ : បាចេតិ, លាភេតិ, ការេតិ, ... ។ ណយ : បាចយតិ, លាភយតិ, ការយតិ, ... ។ ណាបេ : បាចាបេតិ, លាភាបេតិ, ការាបេតិ,...។ ណាបយ : បាចាបយតិ, លាភាបយតិ, ការាបយតិ,... ។

ក្នុងហេតុកម្មវាចកៈ ចុះបច្ច័យតាមពួកធាតុក៏មាន មិនចុះក៏មានផង ចុះការិតបច្ច័យផង[១] ចុះឥ-អាគមផង ចុះយ-បច្ច័យសម្រាប់កម្មវាចកៈផង ឧ. បាចាបិយតេ (បច > បាច, ណាបេ > អាប, បាច + អាប + ឥ + យ + តេ > បាចាបិយតេ), រុន្ធាបិយតេ (រុធ + និគ្គហិត > រុន្ធ, ណាបេ > អាប, រុន្ធ + អាប + ឥ + យ + តេ > រុន្ធាបិយតេ, ទិព្វាបិយតេ (ទិវ + យ, វ + យ > ព្វ, ណាបេ > អាប, ទិព្វ + អាប + ឥ + យ + តេ > ទិព្វាបិយតេ), បាចាបិយន្តេ, រុន្ធាបិយន្តេ, ទិព្វាបិយន្តេ (...អន្តេ-វិភត្តិ)... ។

១ ការិតបច្ច័យច្រើនចុះ ណាបេ លុបទុកតែត្រឹម អាប ។

ណយ-បច្ច័យ ចុះអំពីមុខនាមសព្ទ ធ្វើឲ្យក្លាយជា កិរិយា-សព្ទ ក៏បានខ្លះ ឧ. អតិហត្ថយតិ "-កន្លងទៅ ឬ ទៅដោយដំរី" (ហត្ថិនា + អតិក្កមតិ > អតិហត្ថយតិ), ឧបវីណាយតិ "-ចូលទៅច្រៀងដោយពិណ" (វីណាយ + ឧបគាយតិ > ឧបវី-ណាយតិ), ទឡ្ហយតិ "-ធ្វើឲ្យមាំ" (ទឡ្ហំ + ករោតិ > ទឡ្ហយតិ) ។

បច្ច័យ ៣ គឺ ខ, ឆ, ស, ចុះក្នុងអញ្ញាសៈ គឺកិរិយាសព្ទដែលមានវិធីបន្ថែមព្យញ្ជនៈខាងដើមធាតុឲ្យជា ២ តួ ដូចមាននិយាយតទៅនេះ ៖

១- អំពីមុខធាតុ ៤ សព្ទគឺ តិជ "អត់ទ្រាំ", គុប "គ្រប់គ្រង, រក្សា", កិត "រក្សា, ថែទាំ", មាន "ពិចារណា, ល្បង", ចុះបច្ច័យទាំង ៣ តាមលំដាប់ ដូច្នេះ ខ : តិតិក្ខតិ "-អត់ទ្រាំ" (តិជ-ធាតុ) ។ ឆ : ជិគុច្ឆតិ "-គ្រប់គ្រង, រក្សា", តែដោយអំណាចអញ្ញាសៈ ឲ្យប្រែថា "-ខ្ពើម, ឆ្អើម" (គុប-ធាតុ), តិកិច្ឆតិ "-រក្សា, ថែទាំ" (កិត-ធាតុ) ។ ស : វិមំសតិ "-ពិចារណា, ល្បង" (មាន-ធាតុ), ទីឃៈជា វីមំសតិ ក៏មាន ។

២- អំពីមុខធាតុទាំងឡាយមានដើមថា : ភុជ "បរិ-ភោគ", យស "ស៊ី", ហរ "នាំទៅ", សុ "ឮ, ស្ដាប់", បា "ផឹក", ចុះបច្ច័យទាំង ៣ ក្នុងសេចក្ដីថា ប្រាថ្នា-" ឬថា "ចង់-" ដូច្នេះ ខ : ពុភុក្ខតិ "-ប្រាថ្នាដើម្បីបរិភោគ, ចង់បរិភោគ" (ភុជ-ធាតុ) ។ ឆ : ជិឃច្ឆតិ "-ប្រាថ្នាដើម្បីស៊ី, ចង់ស៊ី" (យស-ធាតុ) ។ ស : ជិគីសតិ "-ប្រាថ្នាដើម្បីនាំទៅ, ចង់នាំទៅ" (ហរ-ធាតុ), សុសុស្សតិ "-ប្រាថ្នាដើម្បីស្ដាប់, ចង់ស្ដាប់" (សុ-ធាតុ), បិវាសតិ "-ប្រាថ្នាដើម្បីផឹក, ចង់ផឹក" (បា-ធាតុ) ។

អព្ភាសៈនោះ, ទោះចុះបច្ច័យទាំង ៣ គឺ ខ ឆ ស ក្ដី, ទោះចុះបច្ច័យឯទៀតខ្លះក្រៅពីនោះក្ដី, មានវិធីរូបសិទ្ធិដូចរបៀបខាងក្រោយនេះ ៖

*ក)* បើព្យញ្ជនៈអព្ភាសៈគឺព្យញ្ជនៈ ដែលបន្ថែមខាងដើមនោះជា កវគ្គ គឺ ជា ក ខ គ ឃ ង, ត្រូវផ្លាស់ កវគ្គ ជា ចវគ្គ គឺផ្លាស់ជា ច ឆ ជ ឈ ញ, ផ្លាស់តាមលំដាប់ដូច្នេះ ក > ច,

ខ > ឆ, គ > ជ, ឃ > ឈ, (ង > ញ) ។. កម "ឈានទៅ, ដើរ" តាមធម្មតា[១] ជា កមតិ, កមេតិ, អព្ភាសៈជា ក-កម + អ + តិ, ផ្លាស់ "ក" អព្ភាសៈ (ក ខាងដើម) ជា "ច" ហើយចុះនិគ្គហិតអាគម (ំ) ខាងលើ "ច" ជា "ចំ" (តាមដំណើររុធ-ធាតុ) រួចផ្លាស់និគ្គហិតជា "ង" (តាមលំដាប់វគ្គ), ផ្សំជា ចង្កមតិ "-ចង្ក្រម = (ដើរទៅដើរមក)" ។ គម "ទៅ, ដល់" តាមធម្មតាជា គច្ឆតិ, គមេតិ, អព្ភាសៈជា គ-គម + អ+ តិ, ផ្លាស់ "គ" អព្ភាសៈជា "ជ" ហើយចុះនិគ្គហិតអាគមខាងលើ "ជ" ជា "ជំ" (តាមដំណើររុធ-ធាតុ) រួចផ្លាស់និគ្គហិតជា "ង" (តាមលំដាប់វគ្គ), ផ្សំជា ជង្គមតិ "-ដើរទៅ, ទៅ" ។ គុប គ្រប់គ្រង, រក្សា" តាមធម្មតាជា គោបតិ, គោបេតិ, អព្ភាសៈជា គុ-គុប + ឆ + តិ, ផ្លាស់ "គ" អព្ភាសៈជា "ជ" ហើយផ្លាស់ស្រៈ "ុ" របស់អព្ភាសៈ[២]ជា "ិ" រួចផ្លាស់ "ប" ទីបំផុតធាតុជា "ច" (ព្រោះមាន ឆ-បច្ច័យនៅខាងចុង), ផ្សំជា ជិគុច្ឆតិ

---

១ តាមដំណើររបស់ធាតុ គឺតាមដំណើរដែលមិនប្រើជា អព្ភាសៈ ។

២ ហៅឲ្យខ្លីថា "ស្រៈអព្ភាសៈ" ។

‟-ខ្លើម, ឆ្អើម″ ។ ឃស ‟ស៊ី″ តាមធម្មតាជា ឃសិតុំ ឥច្ឆតិ ‟-ប្រាថ្នាដើម្បីស៊ី″ ឬ ‟-ចង់ស៊ី″, អញ្ញាសៈជា ឃ-ឃស + ឆ + តិ, ផ្លាស់ ‟ឃ″ អញ្ញាសៈជា ‟ឈ″ ហើយផ្លាស់ ‟ឈ″ ជា ‟ជ[១]″ រួចផ្លាស់ស្រៈ ‟អ″ របស់អញ្ញាសៈជា ‟ឥ″ ហើយផ្លាស់ ‟ស″ ទីបំផុតធាតុជា ‟ច″ (ព្រោះមាន ឆ-បច្ច័យនៅខាងចុង), ផ្សំជា ជិឃច្ឆតិ[២] ‟-ប្រាថ្នាដើម្បីស៊ី″ ឬ ‟-ចង់ស៊ី″ ។

*ខ*) ធាតុដែលជាតួ ‟ហ″ គឺដែលមាន ‟ហ″ ជាទីបំផុត ត្រូវផ្លាស់ ‟ហ″ អញ្ញាសៈជា ‟ជ″ (ព្រោះ ហ ជា កណ្ឋជៈ. ជា ឃោសៈ ដូច គ ដែរ) ឧ. ហា ‟លះបង់″ តាមធម្មតាជា ហាតិ, ហិយតិ, អញ្ញាសៈជា ហា-ហា + អ + តិ, ផ្លាស់ ‟ហ″ អញ្ញាសៈជា ‟ជ″ ហើយរស្សៈស្រៈ ‟អា″ របស់អញ្ញាសៈជា ‟អ″ រួចលុបអ-បច្ច័យចេញ, ផ្សំជា ជហាតិ ‟-លះបង់″, ឬលុប ‟អា″ របស់ធាតុចេញ ហើយផ្សំ ‟ហ″ និង

១ ន័យផ្សេងពីនេះថាឲ្យផ្លាស់ ‟ឃ″ ជា ‟គ″ ហើយផ្លាស់ ‟គ″ ជា ‟ជ″ក៏បាន។ ២ជិឃច្ឆតិ មានសេចក្ដីដូចគ្នានឹង ‟ឃសិតុំ ឥច្ឆតិ″ ដែរ។

អ-បច្ច័យជា ជហតិ ក៏បាន ។ ហុ[១] "បូជា" តាម ធម្មតាជា ហវតិ, អក្ខរសះជា ហុ-ហុ + អ + តិ, ផ្លាស់ "ហ" អក្ខរសះជា "ជ" ផ្លាស់ស្រះ "ឧ" របស់អក្ខរសះជា "ឱ" ហើយ ផ្លាស់ "ឱ" ជា "អវ[២]", ផ្សំជា ជុហវតិ ឬ ជុហ្វតិ "-បូជា", ឬ លុប "ឧ" របស់ធាតុចេញ ហើយទីឃះ អ-បច្ច័យជា "អា", ផ្សំជា ជុហាតិ, ពុំនោះសោត ផ្លាស់ "ឧ" របស់ធាតុជា "ឱ" ហើយលុប អ-បច្ច័យចេញ, ផ្សំជា ជុហោតិ ក៏បាន ។

គ) ព្យញ្ជនះអក្ខរសះជាវគ្គឯទៀតក្រៅពី កវគ្គ និង ហ, ត្រូវ ផ្លាស់ព្យញ្ជនះអក្ខរសះជាព្យញ្ជនះក្នុងវគ្គជាមួយគ្នា ប៉ុន្តែឲ្យផ្លាស់ ព្យញ្ជនះ ទី ២ ជាព្យញ្ជនះទី ១, ផ្លាស់ព្យញ្ជនះទី ៤ ជាព្យញ្ជនះ ទី ៣

ឧ. ឆិទ "កាត់, ដាច់" តាមធម្មតាជាឆិន្ទតិ, អក្ខរសះជា ឆិ-ឆិទ + អ + តិ, ផ្លាស់ "ឆ" អក្ខរសះជា "ច" លុប "ទ" ទីបំផុតធាតុ ចេញ ហើយផ្លាស់ស្រះ "ឥ" របស់ធាតុជា "អ" តម្រួត "ច" មក

---

១ ហុ មាន ៣ យ៉ាងគឺ ហុ ប្រែថា "កើត, មាន, ជា-", ហុ ប្រែថា "បូជា", ហុ ប្រែថា "ហ៍វ" ឬ "ហាវ" ដែលប្រើក្លាយមកជា "ហៅ" ប៉ុន្តែ មានន័យខ្លះថាឲ្យតាំង"ហវ-ធាតុ" ។ ២ អ័វ ។

ជា "ច្ឆ", ផ្សំជា ចិច្ឆតិ "-កាត់" ។ អក្ខរសៈជា ឆិ-ឆិទ + អ (បច្ច័យ) + អ (បរោក្ខា), ផ្លាស់ "ឆ" អក្ខរសៈជា "ច" ផ្លាស់ស្រៈ "ឥ" របស់អក្ខរសៈជា "អ" ព្រឹទ្ធិ ឥ របស់ ឆិទ ជា ឯ តម្រួត "ច" លើ "ឆ" លុប អ-បច្ច័យចេញ, ផ្សំជា ចច្ឆេទ ។ កុជ "បរិភោគ" តាមធម្មតាជា កុញ្ជិតុំ ឥច្ឆតិ ឬ ភោតុំ ឥច្ឆតិ "-ប្រាថ្នាដើម្បីបរិភោគ" ឬ "-ចង់បរិភោគ", អក្ខរសៈជា កុ-កុជ + ខ + តិ, ផ្លាស់ "ក" អក្ខរសៈជា "ព", (ព្រោះអំណាច ខ-បច្ច័យ នៅខាងចុង) ផ្លាស់ "ជ" ទីបំផុតធាតុជា "គ" ហើយផ្លាស់ "គ" ជា "ក", ផ្សំជា ពុកុក្ខតិ "-ប្រាថ្នាដើម្បីបរិភោគ" ឬ "-ចង់បរិភោគ" ។ ធា "ទ្រទ្រង់" អក្ខរសៈជា ធា-ធា + អ + តិ, ផ្លាស់ "ធ" អក្ខរសៈជា "ទ" ហើយរស្សៈស្រៈ "អា" របស់អក្ខរសៈជា "អ", លុប អ-បច្ច័យចេញ, ផ្សំជា ទធាតិ "-ទទ្រង់" ។

*ឃ)* ព្យញ្ជនៈអក្ខរសៈ ក្រៅពីគតិដែលបាននិយាយមកហើយនោះ, មានដំណើររូបសិទ្ធិតាមសមគួរដល់ការប្រកប ឧ. ទា "ឲ្យ" តាមធម្មតាជា ទេតិ, អក្ខរសៈជា ទា-ទា + អ + តិ, រស្សៈស្រៈ "អា" របស់អក្ខរសៈជា "អ" លុប អ-បច្ច័យចេញ, ផ្សំជា

ទទាតិ "-ឲ្យ" ។ តិជ "អត់ទ្រាំ" តាមធម្មតាជា តេជតិ, អញ្ញាសៈជា តិ-តិជ + ខ + តិ, (ព្រោះមាន ខ-បច្ច័យនៅខាងចុង) ផ្លាស់ "ជ" ទីបំផុតជាតុជា "គ" ហើយផ្លាស់ "គ" ជា "ក", ផ្សំជា តិតិក្ខតិ "-អត់ទ្រាំ" ។ កិត "រក្សា, ថែទាំ" តាមធម្មតាជា កិតេតិ, អញ្ញាសៈជា កិ-កិត + ឆ + តិ, មិនផ្លាស់ "ក" ជា "ច" ដូចន័យមុន (ត្រង់ ចង្កមតិ) នោះទេ, ឲ្យផ្លាស់ "ក" អញ្ញាសៈជា "ត", (ព្រោះអំណាច ឆ-បច្ច័យនៅខាងចុង) ផ្លាស់ "ត" ទីបំផុតជាតុជា "ច", ផ្សំជា តិកិច្ឆតិ "-រក្សា, ថែទាំ" ។ មាន "ពិចារណា, ល្បង" តាមធម្មតាជា មានេតិ, អញ្ញាសៈជា មា-មាន + ស + តិ, ផ្លាស់ "ម" អញ្ញាសៈជា "វ" ហើយផ្លាស់ស្រះ "អា" របស់អញ្ញាសៈជា "ឥ", (ព្រោះអំណាច ស-បច្ច័យនៅខាងចុង) ផ្លាស់ "មាន" ជាតុជា "មំ", ផ្សំជា វិមំសតិ "-ពិ-ចារណា, ល្បង" ។ ហរ "នាំទៅ" តាមធម្មតាជា ហរិតុំ ឥច្ឆតិ "-ប្រាថ្នាដើម្បីនាំទៅ" ឬ "-ចង់នាំទៅ", អញ្ញាសៈជា ហ-ហរ + ស + តិ, ផ្លាស់ "ហ" អញ្ញាសៈជា "ជ" ហើយផ្លាស់ស្រះ "អ" របស់អញ្ញាសៈជា "ឥ", (ព្រោះអំណាច ស-បច្ច័យនៅខាងចុង)

ផ្លាស់ "ហរ" ធាតុជា "គី" ផ្សំជា ជិគីសតិ "-ប្រាថ្នាដើម្បីនាំទៅ" ឬ "-ចង់នាំទៅ" ។ សុ "ឮ, ស្តាប់" តាមធម្មតាជា សុណិតុំ ឬ សោតុំ ឥច្ឆតិ "-ប្រាថ្នាដើម្បីស្តាប់" ឬ "-ចង់ស្តាប់", អព្ភាសៈជា សុ-សុ + ស + តិ, តម្រួត ស-បច្ច័យជា "ស្ស", ផ្សំជាសុសុស្សតិ "-ប្រាថ្នាដើម្បីស្តាប់" ឬ "-ចង់ស្តាប់" ។ បា[១] "ផឹក" តាមធម្មតាជា បាតុំ ឬ បិវិតុំ ឥច្ឆតិ "-ប្រាថ្នាដើម្បីផឹក" ឬ "-ចង់ផឹក", អព្ភាសៈជា បា-បា + ស + តិ, ផ្លាស់ស្រៈ "អា" របស់អព្ភាសៈជា "ឥ", (ព្រោះអំណាច ស-បច្ច័យនៅខាងចុង) ផ្លាស់ "បា" ធាតុជា "វា", ផ្សំជា បិវាសតិ "-ប្រាថ្នាដើម្បីផឹក" ឬ "-ចង់ផឹក" ។ បត "ធ្លាក់ចុះ, ជ្រុះ" តាមធម្មតាជា បតតិ, អព្ភាសៈជា ប-បត + អ + តិ, ផ្សំជា បបតតិ "-ធ្លាក់ចុះ, ជ្រុះ" ។ ចល "កម្រើក, រម្ជួល,..." តាមធម្មតាជា ចលតិ, អព្ភាសៈជា ច-ចល + អ + តិ, ចុះនិគ្គហិតអាគមខាងលើ "ច" ជា "ចំ" (តាមដំណើរ រុធ-ធាតុ) ហើយផ្លាស់និគ្គហិតជា "ញ" (តាមលំដាប់វគ្គ), ផ្សំជា ចញ្ចលតិ "-កម្រើក, រម្ជួល" ។

១ បា-ធាតុ ប្រែបាន ២ យ៉ាងគឺ ប្រែថា "ផឹក", ថា "រក្សា" ។

បច្ច័យ ២ គឺ អាយ, ឞ្យ សម្រាប់ចុះអំពីមុខ នាមសព្ទ ធ្វើឲ្យក្លាយជា កិរិយាសព្ទ, ចុះក្នុងអត្ថ ៣ យ៉ាង គឺ *ក*) ចុះក្នុង "អាចារត្ថៈ" មានសេចក្តីថា "ប្រព្រឹត្ត-", *ខ*) ចុះក្នុង "ឧបមាចារត្ថៈ" មានសេចក្តីថា "ប្រព្រឹត្ត...ថាដូចជា-" ឬ "ប្រព្រឹត្ត... ឲ្យដូចជា-", *គ*) ចុះក្នុង "អត្តិច្ឆត្ថៈ" មានសេចក្តីថា "ប្រាថ្នា... ដើម្បីខ្លួន" ឬថា "ចង់បាន... ដើម្បីខ្លួន" ។ អាយ-បច្ច័យចុះក្នុងអត្ថ ២ យ៉ាងគឺ អាចារត្ថៈ និងឧបមាចារត្ថៈ ។ ឞ្យ-បច្ច័យចុះក្នុងអត្ថ ២ យ៉ាងគឺ "ឧបមាចារត្ថៈ និងអត្តិច្ឆត្ថៈ ។

អាយ-បច្ច័យចុះក្នុងអាចារត្ថៈ ឧ. ចិរាយតិ "-ប្រព្រឹត្តយូរ" (ចិរំ-អាចរតិ > ចិរាយតិ), ឃុរុឃុរាយតិ "-ប្រព្រឹត្តនូវសូរឮឃុរុឃុរុ" (ឃុរុឃុរុំ (សទ្ទំ) - អាចរតិ > ឃុរុឃុរាយតិ), តដតដាយតិ "-ប្រព្រឹត្តនូវសូរឮតដៈតដៈ" (តដតដំ. (សទ្ទំ) - អាចរតិ > តដតដាយតិ) ។

អាយ-បច្ច័យ ចុះក្នុងឧបមាចារត្ថៈ[១] ឧ. បព្វតាយតិ "-ប្រព្រឹត្ត (នូវខ្លួន) ថាដូចជាភ្នំ" (បព្វតំ ឥវ-(អត្តានំ)-អាចរតិ > បព្វតាយតិ), សមុទ្ទាយតិ "-ប្រព្រឹត្ត (នូវខ្លួន) ថាដូចជាសមុទ្ទ" សមុទ្ទំ ឥវ-(អត្តានំ)-អាចរតិ > សមុទ្ទាយតិ), សមណាយតិ "-ប្រព្រឹត្ត (នូវខ្លួន) ថាដូចជាសមណៈ" (សមណំ ឥវ-(អត្តានំ) អាចរតិ > សមណាយតិ) ។

ឦយ-បច្ច័យ ចុះក្នុងឧបមាចារត្ថៈ ឧ. ឆត្តីយតិ "-ប្រព្រឹត្តធ្វើ (នូវវត្ថុមិនមែនឆត្រ) ថាដូចជាឆត្រ" (អឆត្តំ - ឆត្តំ ឥវ-អាចរតិ[២] > ឆត្តីយតិ), បុត្តីយតិ "-ប្រព្រឹត្តធ្វើ (នូវជនមិនមែនកូន) ថាដូចជាកូន" (អបុត្តំ-បុត្តំ ឥវ-អាចរតិ > បុត្តីយតិ) ។

ឦយ-បច្ច័យ ចុះក្នុងអត្តិច្ឆត្ថៈ ឧ. បត្តីយតិ "-ប្រាថ្នានូវបាត្រដើម្បីខ្លួន" ឬថា "-ចង់បាននូវបាត្រដើម្បីខ្លួន" (អត្តនោ-បត្តំ-ឥច្ឆតិ > បត្តីយតិ), វត្ថីយតិ "-ចង់បាននូវសំពត់ដើម្បី

---

១ អាយ-បច្ច័យ បើចុះអំពីមុខគុណនាម ឬអំពីមុខនាមនាមដែលប្រើជាកិរិយាវិសេសនៈឬក៏អំពីមុខឧទានសព្ទ នោះកុលបុត្រគប្បីដឹងថាជា អាចារត្ថៈ, បើចុះអំពីមុខនាមនាមដែលមិនសម្តែងអាការជាកិរិយាវិសេសនៈទេ ត្រូវដឹងថាជា ឧបមាចារត្ថៈ ។ ២ ដោយអំណាច អា-បុព្វបទ ឲ្យប្រែថា "ប្រព្រឹត្តធ្វើ-" ឬថា "ធ្វើ-" ក៏បាន (ខាងអាយ-បច្ច័យក៏ដូចគ្នាដែរ) ។

ខ្លួន″ (អត្តនោ-វត្តំ-ឥច្ឆតិ > វត្តីយតិ), ធនីយតិ ‶-ចង់បាននូវទ្រព្យដើម្បីខ្លួន″ (អត្តនោ-ធនំ-ឥច្ឆតិ > ធនីយតិ[១]) ។

បច្ច័យ ៣ គឺ អល, អារ, អាល ចុះអំពីមុខនាមសព្ទ ធ្វើឲ្យក្លាយជាកិរិយាសព្ទដូច្នេះ អលៈ ជោតលតិ ‶-ធ្វើនូវសេចក្តីរុងរឿង″ (ជោតិ + អល + តិ > ជោតលតិ) ។ អារៈ សន្តាវតិ ‶-ប្រព្រឹត្តស្ងប់″ (សន្ត + អារ + តិ > សន្តារតិ) ។ អាលៈ ឧបក្កមាលតិ ‶-ប្រព្រឹត្តព្យាយាម″ (ឧបក្កម + អាល + តិ > ឧបក្កមាលតិ) ។

បច្ច័យ ៨ គឺ ខ, ឆ, ស, អាយ ឦយ, អល, អារ, អាល នេះ ជាបច្ចេកបច្ច័យ ‶បច្ច័យផ្សេងដោយឡែក″ ក្នុងអាខ្យាតមិនរាប់បញ្ចូលក្នុងពួកជាតុណាមួយឡើយ ។

---

១ ឦយ-បច្ច័យចុះក្នុងអត្ថ ២ យ៉ាងក៏ពិត ប៉ុន្តែចុះបានចំពោះតែអំពីមុខនាមនាមប៉ុណ្ណោះ, ដែលនឹងដឹងថាចុះក្នុងឧបមាចារត្ថៈ ឬ ក្នុងអត្តិច្ឆត្ថៈនោះ ត្រូវសង្កេតមើលតាមលំនាំសេចក្តី ដូចជា ឆត្តីយតិ បើចុះក្នុងអត្តិច្ឆត្ថៈ ប្រែថា ‶-ចង់បាននូវឆត្រដើម្បីខ្លួន″, បត្តីយតិ បើចុះក្នុងឧបមាចារត្ថៈ ប្រែថា ‶-ប្រព្រឹត្តធ្វើនូវភាជន៍មិនមែនបាត្រថាដូចជាបាត្រ″ យ៉ាងនេះវិញក៏បានប្រសិនបើមានដំណួលសេចក្តីគួរប្រែយ៉ាងនុ៎ះ ។

# បែបបំបែកធាតុ

[១៦៧] ធាតុដែលផ្សំនឹងវិភត្តិ, បច្ច័យ ដូចបាននិយាយមកហើយនោះ គ្រាន់តែជាបែបឲ្យឃើញដោយអន្លើៗ មិនគ្រប់វិភត្តិទាំង ៨, នឹងបំបែកធាតុខ្លះផ្សំនឹងវិភត្តិទាំង ៨ ព្រមទាំងបច្ច័យឲ្យឃើញជាបែបធៀប ដូចមានខាងក្រោយនេះ ៖

## កត្តុវាចកៈ

### បំបែក ភូ-ធាតុ ចុះអ-បច្ច័យ ជាបែបធៀប

#### វត្តមានា

| បុរិស | ឯក. | ពហុ. |
|---|---|---|
| ប. | ភវតិ | ភវន្តិ |
| ម. | ភវសិ | ភវថ |
| ឧ. | ភវាមិ | ភវាម |

#### បញ្ចមី

| បុរិស | ឯក. | ពហុ. |
|---|---|---|
| ប. | ភវតុ | ភវន្តុ |
ហោហិស្សតិ "-នឹងមាន, នឹងជា-", ហុ-ធាតុ, អ-បច្ច័យ, ស្សតិ-ភវិស្សន្តិ, ផ្លាស់ ឧ របស់ ហុ ជា ឱហ, ចុះ ឥអាគម, លុប អ-បច្ច័យ ។

ហោហិស្សន្តិ ដូច ហោហិស្សតិ, ខុសគ្នាតែចុះ ស្សន្តិ-
ភវិស្សន្តិ ប៉ុណ្ណោះ ។

បែបបំបែកធាតុអាខ្យាត មិនមែនអស់ហើយត្រឹមតែប៉ុណ្ណោះទេ នៅមានន័យដ៏វិចិត្រផ្សេង ៗ ជាងនេះទៅទៀតច្រើនណាស់ ដែលនិយាយមកហើយនុ៎ះ គ្រាន់តែជាបែបធៀបនាំមុខការសិក្សាប៉ុណ្ណោះ ។ បែបបំបែកធាតុនោះមាន ២ យ៉ាង គឺ ម្យ៉ាងបំបែកចំពោះតែវិភត្តិអាខ្យាតមិនបាច់ដាក់បុរិសសព្វនាមមកផង ដូច្នេះ: វត្តមានា, លភតិ, លភន្តិ, លភសិ, លភថ, លភាមិ, លភាម ។ បេ ។ កាលាតិបត្តិ: អលភិស្ស, អលភិស្សំសុ, អលភិស្សេ, អលភិស្សថ, អលភិស្សំ អលភិស្សម្ហា ។ ម្យ៉ាងបំបែកដាក់បុរិសសព្វនាមដែលជាបទប្រធានមកផង ដូច្នេះ : វត្តមានា : សោ លភតិ, តេ លភន្តិ[១], ត្វំ លភសិ, តុម្ហេ លភថ, អហំ លភាមិ, មយំ លភាម ។ បេ ។ កាលាតិបត្តិ : សោ អលភិស្ស,

១ ត្រង់បឋមបុរិសៈនេះ ដាក់នាមសព្ទជាបទប្រធានបានតាមគួរដល់ការប្រកប លើកលែងតែតុម្ហនិងអម្ហចេញ), ដាក់បានដូច្នេះ : បុរិសោ លភតិ, បុរិសា លភន្តិ, ឥត្ថី លភតិ, ឥត្ថិយោ លភន្តិ, កុលំ លភតិ, កុលានិ លភន្តិ,… … ។

តេ អលភិស្សំសុ, ត្វំ អលភិស្សេ, តុម្ហេ អលភិស្សថ, អហំ អលភិស្សំ, មយំ អលភិស្សម្ហា ។

ម្យ៉ាងទៀត វេយ្យាករណបណ្ឌិតជាអាចារ្យបង្រៀន គប្បីណែនាំសិស្សឲ្យហាត់បំបែកតាមដំណើររបស់ធាតុដូច្នេះ គឺ ធាតុណាដែលមានដំណើរអាចប្រកបបានគ្រប់វិភត្តិអាខ្យាត ឬធាតុណាដែលមានដំណើរប្រកបបានចំពោះតែវិភត្តិមួយ ៗ ត្រូវនាំសិស្សឲ្យហាត់បំបែកធាតុទាំងនោះ តាមគួរដល់ការប្រកប ត្រាតែសិស្សចាំបែបបំបែកធាតុ រត់មាត់ស្ទាត់ជំនាញ ទោះធាតុណាក៏ដោយ តែឃើញហើយអាចបំបែកបានដោយរហ័សមាត់មិនទទាក់ទទាម ។ បើកុលបុត្រណាបានចេះបែបបំបែកធាតុស្ទាត់ហើយ វិធីគ្រប់យ៉ាងក្នុងអាខ្យាត ក៏ឈ្មោះថាគឺកុលបុត្រនោះបានចេះប្រាកដដោយពិត ។

អាខ្យាតនិទ្ទេស ទី ៥ ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

---

# កិតកនិក្ខេស ទី ៦

## កិតកនិទ្ទេសទី ៦

## **កិតកៈ**

[១៦៨] សព្ទដែលផ្សំចូលនឹងបច្ច័យ ធ្វើកិរិយាសព្ទឲ្យក្លាយជានាមសព្ទក៏មាន គង់នៅជាកិរិយាសព្ទដូចដើមប៉ុន្តែមានគតិផ្សេងគ្នាពីអាខ្យាតក៏មាន ហៅថា កិតកៈ (ក្រិត) ។ កិតកៈនោះ មាន ២ យ៉ាងគឺ កិតកៈដែលជានាមសព្ទ ហៅថា នាម-កិតកៈ ឬ កិតនាម ១ ដែលជាកិរិយាសព្ទ ហៅថា កិរិយាកិតកៈ ឬកិតកិរិយា ១ ។ កិតកៈទាំង ២ យ៉ាងនុ៎ះ សុទ្ធតែមាន "ធាតុ" ជាទីតាំង គឺកើតចេញមកអំពីធាតុ ដែលជាឫសគល់នៃពាក្យដូចអាខ្យាតដែរ (មើលក្នុងអាខ្យាតនិទ្ទេស ត្រង់លេខ ១៦៤) ។

## **នាមកិតកៈ**

[១៦៩] កិតកៈដែលជានាមនាមក្តី ជាគុណនាមក្តី ហៅថា នាមកិតកៈ ។ កាលបើដឹងកំណើតសព្ទជាក់ប្រាកដហើយ ដែលនឹងកំណត់សម្គាល់នាមកិតកៈ ឲ្យស្គាល់ដំណើរសេចក្តីផ្សេងគ្នានោះ ត្រូវសម្គាល់ដោយសាធនៈ ដែលមានបច្ច័យជាគ្រឿងចំណាំមិនឲ្យច្រឡំ ទើបអាចនឹងដឹងសេចក្តីជាក់ប្រាកដបាន ។

សព្ទដែលសម្រេចមកអំពីរូបវិគ្គហៈរបស់កិតកៈ គឺដែលលុបបទ ឬលុបអក្ខរៈក្នុងវិគ្គហៈចេញខ្លះ ហើយបំបែរលំនាំឲ្យប្លែកពីវិគ្គហៈ រួមមកជាសព្ទមួយ ៗ មានបច្ច័យ (សម្រាប់កិតកៈ) ជាគ្រឿងសម្គាល់ ហៅថា "សាធនៈ" ។ សាធនៈនោះមាន ៧ យ៉ាង គឺ កត្តុសាធនៈ ១ កម្មសាធនៈ ១ ករណសាធនៈ ១ សម្បទានសាធនៈ ១ អបាទានសាធនៈ ១ អធិករណសាធនៈ ១ ភាវសាធនៈ ១ ។ ដែលចែកជាឈ្មោះសាធនៈ ៧ យ៉ាងដូច្នេះ ដោយអាស្រ័យរូបវិគ្គហៈខាងក្នុង ដែលស្ទុះចេញមក ជាគ្រឿងចំណាំសម្ដែងដំណើរឲ្យស្គាល់ថា ជាសាធនៈនោះ ៗ ពីព្រោះសាធនៈទាំងអស់ សុទ្ធតែមានបែបតាំងវិគ្គហៈផ្សេងគ្នា ។

រូបវិគ្គហៈនៃសាធនៈមាន ៣ យ៉ាង គឺ កត្តុរូប ១ កម្មរូប ១ ភាវរូប ១, រាប់សមាសរូប ១ បញ្ចូលមកផងជា ៤ យ៉ាង ។ រូបវិគ្គហៈនៃសាធនៈណា ដែលជាកត្តុវាចកៈក្ដី ជាហេតុកត្តុវាចកៈក្ដី រូបវិគ្គហៈនៃសាធនៈនោះ ហៅថា កត្តុរូប, ដែលជាកម្មវាចកៈ ហៅ កម្មរូប, ដែលជាភាវវាចកៈ ហៅថា ភាវរូប, រូបវិគ្គហៈម្យ៉ាង (ច្រើនប្រើតុំ-បច្ច័យជាតួប្រធាន) ប្រាប់អាការរបស់កិរិយា

ហើយបទដែលប្រកបឆដ្ឋីវិភត្តិ ស្ទុះចេញមកជាអញ្ញបទនៃសា-ធនៈ មានលំនាំដូចឆដ្ឋីពហុព្វីហិសមាស ហៅថា សមាសរូប ។

កត្តុរូបចែកចេញជា ៧ យ៉ាងគឺ កត្តុរូប-កត្តុសាធនៈ ១ កត្តុ-រូប-តស្សីលសាធនៈ ១ កត្តុរូប-កម្មសាធនៈ ១ កត្តុរូប-ករណសា-ធនៈ ១ កត្តុរូប-សម្បទានសាធនៈ ១ កត្តុរូប-អបាទានសាធនៈ ១ កត្តុរូប-អធិករណសាធនៈ ១ ។ កម្មរូបចែកចេញជា ៤ យ៉ាងគឺ កម្មរូប-កម្មសាធនៈ ១ កម្មរូប-ករណសាធនៈ ១ កម្មរូប-សម្បទាន-សាធនៈ ១ កម្មរូប-អធិករណសាធនៈ ១ ។ ភាវរូបមានតែម្យ៉ាង គឺ ភាវរូប-ភាវសាធនៈ ។ សមាសរូបមានតែម្យ៉ាង គឺ សមាស-រូប-តស្សីលសាធនៈ ។

## កត្តុសាធនៈ

បទជាសយកត្តាក្តី ហេតុកត្តាក្តី ដែលប្រកបបឋមាវិភត្តិ ជាបទប្រធានក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទ, តួកិរិយាសព្ទ របស់បទប្រធាននោះ ក៏សម្រេចរូបផ្សំនឹងបច្ច័យនៃកិតកៈ មកជា សាធនៈនៅជាកត្តាតាមលំនាំដើម, រូបសព្ទដែលសម្រេចមកនុ៎ះ ឯង ហៅថា កត្តុសាធនៈ ។ មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា

"អ្នក[១]-", បើចុះក្នុងតស្សីលៈ ប្រែថា "អ្នក[២]- ដោយប្រក្រតី, -តាមប្រក្រតី" ឬមិនបាច់ប្រែចេញពាក្យថា "អ្នក-" ក៏បានខ្លះ តាមគួរដល់ដំណើរសេចក្តី ។. កុម្ភការោ "(ជន) អ្នកធ្វើនូវឆ្នាំង", កម្មការាបកោ "(ជន) អ្នកញុំាងអ្នកដទៃឲ្យធ្វើនូវអំពើ" ឈ្មោះ កត្តុរូប-កត្តុសាធនៈ ។ ធម្មចារី "(ជន) អ្នកប្រព្រឹត្តនូវធម៌ ដោយប្រក្រតី" ឬ "-តាមប្រក្រតី "ឈ្មោះកត្តុរូប-តស្សីលសា - ធនៈ ។ តាំងវិគ្គហៈថា កុម្ភំ-ករោតី'តិ >កុម្ភការោ (ជនោ), កម្មំ-ករោតី'តិ > កម្មការោ (ជនោ), កម្មំ-ការាបេតី'តិ > កម្មការាបកោ (ជនោ), ធម្មំ-ចរតិ-សីលេនា'តិ> ធម្មចារី (ជនោ) ។ បើតាំងវិគ្គហៈពេញ[២]តាមដំណើរប្រយោគថា(យោ)-កុម្ភំ ករោតិ-ឥតិ-(សោ) > កុម្ភការោ (ជនោ), (យោ)-កម្មំ-ករោតិ-ឥតិ- (សោ) > កម្មការោ (ជនោ),(យោ)-កម្មំ-ការាបេតិ-ឥតិ-(សោ)> កម្មកា-រាបកោ (ជនោ), (យោ)-ធម្មំ-ចរតិ-សីលេន-ឥតិ-

---

១ ត្រង់ពាក្យថា "អ្នក-" នេះ ត្រូវផ្លាស់ដាក់ពាក្យថា "ព្រះអង្គ-, ទ្រង់-, លោក-, គេ-, គាត់-, វា-" វិញក៏បាន តាមដំណើរសេចក្តី ។ ២ វិគ្គហៈពេញ... នេះ តាំងគ្រាន់តែជាបែបឲ្យអ្នករៀនយល់ដំណើរប្រែ, មិនមែនជាបែបសម្រាប់ឲ្យរៀនចងវិគ្គហៈទេ, បែបខាងលើទើបសម្រាប់ឲ្យរៀនចងវិគ្គហៈ, លោកអាចារ្យចូរពន្យល់ឲ្យសិស្សចេះប្រែលោតប្រយោគគ្រប់វិគ្គហៈទាំងអស់ផងចុះ ។

(សោ) > ធម្មចារី (ជនោ) ។ រូបវិគ្គហៈជាកត្តា ដល់ដាក់ចុះប្រមូលសម្រេចមកជាសាធនៈក៏ជាកត្តា ព្រោះហេតុនោះបានជាហៅថា កត្តុរូប-កត្តុសាធនៈ ។ កត្តុរូប-កត្តុសាធនៈហ្នឹងឯង ដោយសារមានពាក្យជាប់មកអំពី "សីល" សព្ទ ដែលប្រែថា "ប្រក្រតី" ចូលមកផង ក៏ត្រឡប់ឲ្យឈ្មោះថា កត្តុរូប-តស្សីលសាធនៈ ទៅវិញ ដើម្បីឲ្យមានឈ្មោះប្លែកគ្នា តាមលំនាំសេចក្តី ។

## កម្មសាធនៈ

សព្ទជាអំពើ ដែលប្រកបទុតិយាវិភត្តិក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទនៃសាធនៈ, ឬដែលប្រកបបឋមាវិភត្តិ ជាបទប្រធាន ជាកម្មវាចកៈក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា កម្មសាធនៈ ។ ដែលជាកត្តុរូប មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "ជាទី-" ឧ "បិយោ" (កូន) ជាទីស្រឡាញ់[១] (នៃបិតា)", តាំងវិគ្គហៈថា បិយេតិ-តន្តិ > បិយោ (បុត្តោ) ។ វិគ្គហៈ

១ ពាក្យថា "កូន" ជាអញ្ញបទដែលស្ទុះចេញមកអំពី តំ (បុត្តំ) ជាបទទុតិយាវិភត្តិ គឺជាតួកម្មក្នុងវិគ្គហៈ, ពាក្យថា "ជាទី" ជាពាក្យប្រាប់សាធនៈ, ពាក្យថា "ស្រឡាញ់" ជាសព្ទដើម ដែលសម្រេចមកអំពី បិយ "ស្រឡាញ់" ជាកិរិយាសព្ទក្នុងវិគ្គហៈ, ពាក្យថា "នៃបិតា" ចេញមកអំពីបិតា-សព្ទដែលជាកត្តុវាចកៈ ជាបទប្រធានក្នុងវិគ្គហៈ ដល់ដាក់ចុះមកជាសាធនៈ ត្រឡប់ប្រែឮសូរជាឆដ្ឋីវិភត្តិថា "នៃ-" ទៅវិញ ជាពាក្យបន្ទាប់បន្សំរបស់សាធនៈ ថាក៏បាន ទេក៏បាន ។

ពេញថា (បិតា)-បិយេតិ-តំ-ឥតិ-(សោ) > (បុត្តោ) ។ ឈ្មោះកត្តុរូប-កម្មសាធនៈ ពីព្រោះរូបវិគ្គហៈជាកត្តុវាចកៈ ហើយបទប្រកបទុតិយាវិភត្តិជាតួកម្ម ស្ទុះចេញមកជាអញ្ញបទរបស់សាធនៈ ។ ដែលជាកម្មរូប មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "គឺ-" ឬ "ដែល-" ឧ. ទានំ "(វត្ថុ) ដែលជនឲ្យ" ឬ "(វត្ថុ) ដែលជនគប្បីឲ្យ", តាំងវិគ្គហៈថា ទិយ្យតេ'តិ > ទានំ (វត្ថុ) ឬ ទាតព្វន្តិ > ទានំ (វត្ថុ) ឬ (យំ-ជនេន) -ទាតព្វំ-ឥតិ-(តំ) > ទានំ (វត្ថុ) ។ ឈ្មោះកម្មរូប-កម្មសាធនៈ ពីព្រោះរូបវិគ្គហៈជាកម្មវាចកៈ ហើយបទដែលជាប្រធាន ក្នុងវិគ្គហៈនោះ ស្ទុះចេញមកជាអញ្ញបទរបស់សាធនៈ ក៏នៅជាកម្មវាចកៈដូចដែល ។

## ករណសាធនៈ

អ្នកធ្វើសម្រេចនូវអំពើដោយសព្ទណា ដែលប្រកបតតិយាវិភត្តិជាករណៈក្នុងវិគ្គហៈ សព្ទនោះឯងស្ទុះចេញពីក្នុងវិគ្គហៈមកជាអញ្ញបទនៃសាធនៈ ហៅថា ករណសាធនៈ ។ ដែលជាកត្តុរូប មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "ជាហេតុ-, ជា

គ្រឿង-, សម្រាប់-" ឧ. ពន្ធនំ "(វត្ថុ) ជាគ្រឿងចង, -សម្រាប់ចង", តាំងវិគ្គហៈថា ពន្ធតិ-តេនា´តិ > ពន្ធនំ (វត្ថុ) ។ វិគ្គហៈពេញថា (ជនោ)-ពន្ធតិ-តេន-ឥតិ-(តំ) > ពន្ធនំ (វត្ថុ) ។ ឈ្មោះកត្តុរូប-ករណសាធនៈ ពីព្រោះរូបវិគ្គហៈ ជាកត្តុវាចកៈ ហើយបទប្រកបតតិយាវិភត្តិជាករណៈ ស្ទុះចេញមកជាអញ្ញបទ របស់សាធនៈ ។ ដែលជាកម្មរូប មានពាក្យជាគ្រឿងសម្គាល់ឲ្យ ប្រែថា "ជាហេតុគឺ-, ឬ ជាហេតុដែល, ជាគ្រឿង-, ឬ ជាគ្រឿង ដែល-" ឧ. ពន្ធនំ "(វត្ថុ) ជាគ្រឿងដែលជនចង (នៃសត្វ)", តាំងវិគ្គហៈថា ពន្ធិយតេ-តេនា´តិ > ពន្ធនំ (វត្ថុ) ។ វិគ្គហៈពេញ ថា (សត្តោ-ជនេន) ពន្ធិយតេ-តេន-ឥតិ-(តំ) > ពន្ធនំ (វត្ថុ) ។ ឈ្មោះកម្មរូប-ករណសាធនៈ ពីព្រោះរូបវិគ្គហៈជាកម្មវាចកៈ ហើយបទប្រកបតតិយាវិភត្តិជាករណៈ ស្ទុះចេញមកជាអញ្ញបទ របស់សាធនៈ ។

## សម្បទានសាធនៈ

សព្ទដែលទទួលនូវអំណោយ គឺសព្ទដែលប្រកបចតុត្ថី-វិភត្តិជាសម្បទានៈក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា សម្បទានសាធនៈ ។ ដែលជាកត្តុរូប មានពាក្យជាគ្រឿង

សម្គាល់ឲ្យប្រែថា "ជាទី-" ១. ធនភូតិ "(ជន) ជាទីចូរកើតនៃទ្រព្យ", តាំងវិគ្គហៈថា ធន-មស្ស-ភវតូ'តិ > ធនភូតិ (ជនោ) ។ វិគ្គហៈពេញថា ធនំ-អស្ស-ភវតុ-ឥតិ-(សោ)>ធនភូតិ (ជនោ) ។ ឈ្មោះកត្តុរូប-សម្បទានសាធនៈ ពីព្រោះរូបវិគ្គហៈជាកត្តុវាចកៈ ហើយបទប្រកបចតុត្ថីវិភត្តិជាសម្បទានៈ ស្នុះចេញមកជាអញ្ញបទ របស់សាធនៈ ។ ដែលជាកម្មរូប មានពាក្យជាគ្រឿងសម្គាល់ ឲ្យប្រែថា "ជាទីគឺ-, ជាទីដែល-," ១. សម្បទានោ "(បដិគ្គាហក) ជាទីគឺទាយកប្រគល់ឲ្យ (នៃវត្ថុ)", តាំងវិគ្គហៈថា សម្បទីយតេ-ឯតស្សា'តិ > សម្បទានោ (បដិគ្គាហកោ) ។ វិគ្គហៈពេញថា (វត្ថុ-ទាយកេន) -សម្បទីយតេ-ឯតស្ស-ឥតិ-(ឯសោ) > សម្បទានោ (បដិគ្គាហកោ) ។ ឈ្មោះកម្មរូប-សម្បទានសាធនៈ ពីព្រោះរូបវិគ្គហៈជាកម្មវាចកៈ ហើយបទប្រកបចតុត្ថីវិភត្តិជាសម្បទានៈ ស្នុះចេញមកជាអញ្ញបទ របស់សាធនៈ ។

## អបាទានសាធនៈ

សព្ទ ដែលប្រាប់ដែនឲ្យដឹងថាអ្វីមួយដែលបានឃ្លាតចេញចាកខ្លួនហើយ គឺសព្ទដែលប្រកបបញ្ចមីវិភត្តិ ជាអបាទានៈក្នុង

វិគ្គហៈ ស្នុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា អបាទាន-សាធនៈ, ប្រើបានតែជាកត្តុរូបម្យ៉ាង, មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "ជាដែន-" ឧ. បភស្សរោ "(សរីរប្បទេស) ជាដែនផ្សាយចេញនៃពន្លឺ", បភវោ "(ប្រទេស) ជាដែនកើតមុន (នៃស្ទឹង)", តាំងវិគ្គហៈថា បភា-សរតិ-តស្មា៍តិ > បភស្សរោ (សរីរប្បទេសោ), បឋមំ-ភវតិ-តស្មា៍តិ > បភវោ[១] (បទេសោ) ។ វិគ្គហៈពេញថា បភា-សរតិ-តស្មា-ឥតិ (សោ) > បភស្សរោ (សរី-រប្បទេសោ), (នទី) -បឋមំ-ភវតិ-តស្មា-ឥតិ-(សោ) > បភវោ (បទេសោ) ។ ឈ្មោះកត្តុរូប-អបាទានសាធនៈ ពីព្រោះរូបវិគ្គហៈជាកត្តុវាចកៈហើយបទប្រកបបញ្ចមីវិភត្តិជាអបាទានៈ ស្នុះចេញមកជាអញ្ញបទរបស់សាធនៈ ។ (អបាទានសាធនៈនេះ ជាសា-ធនៈ សម្តែងសេចក្តីត្រឹមតែឲ្យដឹងថា ខ្លួនគ្រាន់តែជាដែនដែលគេឃ្លាតចាកប៉ុណ្ណោះ មិនមែនសម្តែងដំណើរអ្វីដទៃក្រៅអំពីនេះទេ, ព្រោះហេតុដូច្នោះ សាធនៈនេះនឹងប្រើជាកម្មរូបពុំបានឡើយ) ។

---

១ តាំង ប-បុព្វបទ (ដែលក្នុងទីនេះត្រូវប្រែថា "មុន"), ភូ-ធាតុ, ចង់វិគ្គហៈថា បភវតិ-តស្មា៍តិ > បភវោ (បទេសោ) ដូច្នេះក៏បាន ប្រែថា "(ប្រទេស) ជាដែនកើតមុន (នៃស្ទឹង)" ដូចគ្នា ។

-៥០៨-

## អធិករណសាធនៈ

សព្ទដែលប្រាប់ទី គឺសត្តមីវិភត្តិដែលប្រាប់ទីកន្លែង ក្នុងវិគ្គហៈ ស្ទុះចេញមកជាអញ្ញបទនៃសាធនៈ ហៅថា អធិករណសាធនៈ ។ ដែលជាកត្តុរូប មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "ជាទី-" ឧ. អាវាសោ "(ប្រទេស) ជាទីនៅអាស្រ័យ (នៃបព្វជិត)", តាំងវិគ្គហៈថា អាវសន្តិ-ឯត្ថា'តិ > អាវាសោ (បទេសោ)។ វិគ្គហៈពេញថា (បព្វជិតា)-អាវសន្តិ-ឯត្ថ-ឥតិ-(ឯសោ)>អាវាសោ (បទេសោ) ។ ឈ្មោះកត្តុរូប-អធិករណសាធនៈ ពីព្រោះរូបវិគ្គហៈជាកត្តុវាចកៈ ហើយបទប្រកបសត្តមីវិភត្តិដែលប្រាប់ទី ស្ទុះចេញមកជាអញ្ញបទរបស់សាធនៈ ។ ដែលជាកម្មរូប មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "ជាទីគឺ-, ជាទីដែល-" ឧ. អាតបនំ "(ទី) ជាទីដែលជនហាល (នៃវត្ថុមានសំពត់ជាដើម), តាំងវិគ្គហៈថា អាតបិយតេ-ឯត្ថា'តិ > អាតបនំ (ឋានំ) ។ វិគ្គហៈពេញថា (វត្ថាទិ ជនេហិ) -អាតបិយតេ-ឯត្ថ-ឥតិ-(ឯតំ) > អាតបនំ (ឋានំ) ។ ឈ្មោះកម្មរូប-អធិករណសាធនៈ ពីព្រោះរូបវិគ្គហៈ ជាកម្មវាចកៈ ហើយបទប្រកបសត្តមីវិភត្តិ ដែលប្រាប់ទី ស្ទុះចេញមកជាអញបទរបស់សាធនៈ ។

## ភាវសាធនៈ

សាធនៈដែលគ្រាន់តែប្រាប់អាការរបស់កិរិយាសព្ទ ដែលក្លាយមកជានាមសព្ទ គឺប្រាប់ឲ្យដឹងត្រឹមតែដំណើររបស់កិរិយា-សព្ទនោះប៉ុណ្ណោះ មិនមែនសម្តែងដំណើរជាកត្តា ឬជាកម្មទ្បើយ ហៅថា ភាវសាធនៈ ។ នេះមានតែភាវរូបម្យ៉ាង, មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "កិរិយា-, ការ-, សេចក្តី-, ដំណើរ-, គឺ-" ឧ. និសជ្ជា "កិរិយាអង្គុយ", គមនំ "កិរិយាទៅ, ដំណើរទៅ", ជាននំ "កិរិយាដឹង, សេចក្តីដឹង", លភនំ "កិរិយាបាន, ការបាន", បាកោ "កិរិយាចម្អិន" ។ បែបចងវិគ្គហៈរបស់ភាវសាធនៈនេះមាន ៣ យ៉ាងគឺ *ក*) ចងដោយអាខ្យាតកិរិយាជាភាវវាចកៈ, *ខ*) ចងដោយកិតកិរិយាជាភាវវាចកៈ, *គ*) ចងដោយកិតនាមជាភាវ-សាធនៈ ដែលសម្រេចរូបមកអំពីអាខ្យាតកិរិយា ឬកិតកិរិយាជាភាវវាចកៈរួចហើយ ។ ចងដោយអាខ្យាតកិរិយា : និសីទិយតេ´តិ > និសជ្ជា, គមិយតេ´តិ > គមនំ, ញាយតេ´តិ > ជាននំ,

លព្ភតេ´តិ>លភនំ, បច្ចតេ´តិ[១]>បាកោ ។ ចងដោយកិតកិរិយា : និសីទិតព្វន្តិ > និសជ្ជា, គមិតព្វន្តិ > គមនំ, ញាតព្វន្តិ > ជាននំ, លភិតព្វន្តិ > លភនំ, បចិតព្វន្តិ[២] > បាកោ ។ ចងដោយកិតនាមដែលជាភាវសាធនៈ : និសីទនំ > និសជ្ជា, បចនំ[៣] > បាកោ ។ ឈ្មោះភាវរូប-ភាវសាធនៈ ពីព្រោះរូបវិគ្គហៈ ជាភាវវាចកៈ ស្ទុះចេញមកជាសាធនៈ ក៏ជាភាវវាចកៈដូចដែល ។

## *សាមាសរូប-តស្សីលសាធនៈ*

សាធនៈដែលមានរូបវិគ្គហៈ (ច្រើនតែប្រកបតុំ-បច្ច័យ ជាមួយនឹងធាតុ ប្រើជាបទប្រធាន) ប្រាប់អាការរបស់កិរិយាសព្ទមាន "សីល" សព្ទ ដែលប្រែថា "ប្រក្រតី" ប្រកបបឋមាវិភត្តិ

១ អាខ្យាតកិរិយាសម្រាប់ភាវវាចកៈ ត្រូវប្រើបានតែជាបឋមបុរិសៈ ឯកវចនៈ អត្តនោបទម្យ៉ាង, ឯអនភិហិតកត្តាត្រូវប្រើតាមសេចក្តីត្រូវ ការ ដូចបាននិយាយក្នុងអាខ្យាតនិទ្ទេស ត្រង់លេខ១៦៥រួចហើយ ។ ២ កិតកិរិយា សម្រាប់ភាវវាចកៈ ត្រូវប្រើតព្វ-បច្ច័យ ឬអនីយ-បច្ច័យហើយច្រើនប្រើជានបុំសកលិង្គ ឯកវចនៈ យ៉ាងនេះ, ឯបទដែល សម្រេចជាសាធនៈ ប្រើបានគ្រប់លិង្គទាំង ៣, ចំណែកខាងអនភិហិ- តកត្តា ត្រូវប្រើបានតាមសេចក្តីត្រូវការ ។ ៣ បែបចងវិគ្គហៈដោយ កិតនាមនេះ លុះតែកិតនាមជាភាវសាធនៈ ដែលមានលំនាំផ្សេងពី គ្នានោះ ទើបយកមកតាំងជាវិគ្គហៈបាន (ដើម្បីឲ្យស្រួលស្តាប់) ដូចជា និសីទនំ មានលំនាំផ្សេងអំពី និសជ្ជា, បចនំ ផ្សេងអំពី បាកោ យ៉ាងនេះទើបបាន, កុំចងជា គមនំ > គមនំ, បចនំ > បចនំ, លភនំ > លភនំ ដូច្នេះឡើយ ។ ម្យ៉ាង ទៀត បែបប្រែវិគ្គហៈ ជាកិតនាម មិនមានដាក់អនភិហិតកត្តាទេ ។

ឯកវចនៈ ជាបទវិសេសនៈ ហើយបទប្រកបឆដ្ឋីវិភត្តិស្នុះចេញមកជាអញ្ញបទ មានអាការដូចគ្នានឹងឆដ្ឋីពហុព្វីហិសមាស ហៅថា សមាសរូប-តស្សីលសាធនៈ ។ មានពាក្យជាគ្រឿងសម្គាល់ឲ្យប្រែថា "អ្នកមាន-ជាប្រក្រតី" ឬ "មាន-ជាប្រក្រតី" ឧ. បាបការី "(ជន) អ្នកមានកិរិយាធ្វើនូវបាបជាប្រក្រតី", ធម្មចារី "(ជន) អ្នកមានកិរិយាប្រព្រឹត្តនូវធម៌ជាប្រក្រតី" ។ តាំងវិគ្គហៈថា បាបំ-កាតុំ-[១] សីលំ-យស្ស-សោ > បាបការី (ជនោ), ធម្មំ-ចរិតុំ-សីលំ-យស្ស-សោ > ធម្មចារី (ជនោ), ឬតាំងវិគ្គហៈថា បាបំ-កាតុំ-សីលម៑ស្សា៑តិ > បាបការី (ជនោ) ដូច្នេះក៏បាន ។

## បច្ច័យនៃនាមកិតកៈ

[១៧០] បច្ច័យដែលសម្រាប់ចុះប្រកបនឹងនាមកិតកៈនោះ ចែកជា ៣ ពួក គឺ *ក*) កិត-បច្ច័យ សម្រាប់ចុះក្នុងកត្តុរូប,

---

១ បែបចងវិគ្គហៈនៃសាធនៈនេះ ច្រើនប្រើតុំ-បច្ច័យដូច្នេះ តែបើនឹងចង់ប្រើកិតនាមដែលជាភាវសាធនៈ ជា ករណំ, ចរណំ ដូច្នេះវិញក៏បាន, ប៉ុន្តែបើមានបទកម្មដូចយ៉ាង បាបំ, ធម្មំ នោះ ត្រូវប្រើជាឆដ្ឋីកម្មឲ្យទៅជា បាបស្ស, ធម្មស្ស ដូច្នេះវិញទើបបាន ពីព្រោះ ករណំ, ចរណំ ជាយុ-បច្ច័យ, ត្រូវចងវិគ្គហៈថា បាបស្ស-ករណំ-សីលំ-យស្ស-សោ > បាបការី (ជនោ), ធម្មស្ស-ចរណំ-សីលំ-យស្ស- សោ >ធម្មចារី (ជនោ) ។ បើចង់ដឹងបែបចងវិគ្គហៈដែលប្លែក ៗ ពី បែបនេះទៅទៀតនោះ ចូរមើលក្នុងកច្ចាយនបករណ៍កិតកៈ ឯ ណោះចុះ ។

ខ) កិច្ច-បច្ច័យ សម្រាប់ចុះក្នុងកម្មរូប និងភាវរូប, គ) កិត-កិច្ច-បច្ច័យ សម្រាប់ចុះក្នុងកត្តុរូប, កម្មរូប, ភាវរូប ។

កិត-បច្ច័យ មាន ៩ គឺ ណ្វុ, ណី, ក្វិ, តុ, រូ, អាវី, ណុក, (តុក,[១] ឥក) ។

កិច្ច-បច្ច័យ មាន ៥ គឺ ណ្យ, ខ, តេយ្យ, (រិច្ច, រិរិយ) ។

កិតកិច្ច-បច្ច័យ មាន ១៣ គឺ ណ, អ, ឥ, យុ, តិ, រម្ម, រ, ឥន, តវេ, តុំ, (រត្តុ, រិតុ, រាតុ) ។

[១៧១] ឧទាហរណ៍ក្នុងកិត-បច្ច័យ

ណ្វុៈ បច្ច័យនេះ, លើកលែងតែអំពីមុខ ញា-ធាតុចេញ ត្រូវផ្លាស់ជា "អក" ជាកំណត់, មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- ធាតុដែលជារស្សៈសុទ្ធ ត្រូវព្រឹទ្ធិអក្សរដើមធាតុ ឧ. ករោតី'តិ > ការកោ[២] (ជនោ) "(ជន) អ្នកធ្វើ[៣]" ក. ក. (ទីឃៈ

១ បច្ច័យដែលនៅក្នុងវង់ក្រចក () នេះទាំងប៉ុន្មាន សម្គាល់ថាប្រើបានចំពោះតែធាតុនីមួយ ៗ ប៉ុណ្ណោះ ។ ២ វេយ្យាករណបណ្ឌិតជាអាចារ្យបង្រៀន ត្រូវពន្យល់បែបនាមកិតកៈដែលសម្រេចមកអំពី កិរិយាសព្ទឲ្យសិស្សបានយល់ដោយសព្វគ្រប់ផងចុះ ។ ៣ កិរិយា- សព្ទដែលជាសកម្មធាតុ បើប្រើឲ្យគ្រប់គ្រាន់ ត្រូវប្រែដាក់តួ កម្ម មកផង តាមដំណើរសេចក្ដី, ដូចយ៉ាងឧទាហរណ៍នេះ, ក្នុងវិគ្គហៈ ត្រូវដាក់បញ្ចូលសព្ទថា "កម្មំ" មកផង, ប្រែថា "(ជន) អ្នកធ្វើ (នូវអំពើ)" ។

អ របស់ ក នៃករ-ធាតុជា អា[១], ផ្លាស់ ណ្វុ ជា អក, ផ្សំជា ការកោ, ឥត្ថីលិង្គ : ចុះឥ-អាគម, ចុះអា-បច្ច័យ[២], ផ្សំជា ការិ-កា, នបុំសកលិង្គ : ការកំ[៣] ។ បើអក្សរដើមធាតុជាទីឃៈ ឬ មានព្យញ្ជនៈសំយោគនៅខាងចុង មិនមានវិធីឲ្យព្រឹទ្ធិឡើយ ឧ. ភាសតី´តិ > ភាសកោ (ជនោ) "(ជន) អ្នកនិយាយ" ក. ក. (ភាស-ធាតុ), សិក្ខតី´តិ > សិក្ខកោ (ជនោ) "(ជន) អ្នកសិក្សា" ក. ក. (សិក្ខ-ធាតុ) ។

២- ត្រូវព្រឹទ្ធិស្រៈរបស់ធាតុ ហើយផ្លាស់ជារូបផ្សេងទៅទៀត ឧ. សុណាតី´តិ > សាវកោ (ជនោ) "(ជនោ) អ្នកស្ដាប់" ក. ក. (ព្រឹទ្ធិ ឧ របស់ សុ-ធាតុជា ឱ ហើយផ្លាស់ ឱ ជា អវ រួចទីឃៈ អ របស់ អវ ជា អាវ, ផ្លាស់ ណ្វុ ជា អក, ផ្សំជា សាវកោ, ឥ. សាវិកា, នបុំ. សាវកំ) ។ វិធីនេះ សូម្បីស្រៈជា

១ បែបព្រឹទ្ធិស្រៈឯទៀតក្រៅពី "អ" : ទេសកោ "(ជន) អ្នកសម្ដែង" (វិការៈ ឥ របស់ ទិស-ធាតុជា ឯ), ទុសកោ "(ជន) អ្នកប្រទូស្ត" (ទីឃៈ ឱ របស់ ទុស-ធាតុជា ឱ), ភោជកោ "(ជន) អ្នកបរិភោគ" (វិការៈ ឧ របស់ ភុជ-ធាតុជា ឱ) ។ ២ អា-បច្ច័យសម្រាប់ឥត្ថីលិង្គដែលហៅថា "អា-សាធារណបច្ច័យ" ។ ៣ បែបបំបែកផ្សំនឹងវិភត្តិនាម : បុំ. ដូច បុរិស, ឥ. ដូច កញ្ញា, នបុំ. ដូច កុល ។

ទីឃៈក៏ឲ្យព្រឹទ្ធិបាន ឧ. នេតី´តិ > នាយកោ (ជនោ) "(ជន) អ្នកនាំ" ក. ក. (ព្រឹទ្ធិ ឦ របស់ នី-ធាតុជា ឯ ហើយផ្លាស់ ឯ ជា អយ រួចទីឃៈ អ របស់ អយ ជា អាយ, ផ្លាស់ ណ្វុ ជា អក, ផ្សំជា នាយកោ, ឥ. នាយិកា, នបុំ. នាយកំ) ។ ដែលព្រឹទ្ធិហើយផ្លាស់ជារូបផ្សេងទៅទៀតយ៉ាងនេះ ចំពោះតែ ធាតុទោល[១] គឺធាតុដែលមានតែអក្សរមួយតួ ហើយមាន ស្រៈ ឥ, ឦ, ឧ, ឩ, ជាទីបំផុត នោះទើបព្រឹទ្ធិបាន ដូចជា ភិ ជា ភាយកោ, នី ជា នាយកោ, វិ+នី ជា វិនាយកោ, អនុ+នី ជា អនុនាយកោ, សុ ជា សាវកោ, លុ ជា លាវកោ, ភូ ជា ភាវកោ ។

៣- ត្រូវផ្លាស់ អា របស់ធាតុជា អាយ[២] ឧ. ទេតី´តិ > ទាយកោ (ជនោ)" (ជន) អ្នកឲ្យ" ក.ក. (ផ្លាស់ អា របស់ ទា-ធាតុ

---

១ គួរហៅថា ធាតុឯកព្យាង្គ "ធាតុមានព្យាង្គមួយ", បើធាតុមានអក្សរ ២ តួ ហៅថា ធាតុទ្វេព្យាង្គ "ធាតុមានព្យាង្គពីរ", ធាតុមានអក្សរច្រើនតាំងពី ៣ តួឡើងទៅ ហៅថា ធាតុពហុព្យាង្គ "ធាតុមានព្យាង្គច្រើន" ។ ២ ក្នុងវេយ្យាករណៈខ្លះថា មិនបាច់ផ្លាស់យ៉ាងនេះ ឲ្យចុះ យ-បច្ច័យ (អាខ្យាត) អំពីមុខធាតុដែលមាន អា ជាទីបំផុត ក៏បាន ។

ជា អាយ, ផ្លាស់ ណ្វុ ជា អក, ផ្សំជា ទាយកោ, ឥ. ទាយិកា, នបុំ. ទាយកំ) ។ ដែលផ្លាស់យ៉ាងនេះ ចំពោះតែធាតុទោល ដែលមានស្រះ អា ជាទីបំផុតនោះទើបបាន ដូចជា ទា ជា ទាយកោ, បា ជា បាយកោ, យា ជា យាយកោ ។

៤- ត្រូវផ្លាស់ ហន-ធាតុទាំងមូលជា ឃាត ឬជា វធ ក៏បាន ឧ. គាវោ-ហនតី´តិ > គោឃាតកោ (ជនោ) "(ជន) អ្នកពិឃាតនូវគោ" ក. ក. (គោ-សទ្ទុបបទ[១], ហន-ធាតុ ផ្លាស់ ជា ឃាត, ផ្លាស់ ណ្វុ ជា អក, ផ្សំជា គោឃាតកោ, ឥ. គោ-ឃាតិកា, នបុំ. គោឃាតកំ) ។ ហនតី´តិ > វធកោ (ជនោ) "(ជន) អ្នកសម្លាប់" ក. ក. (ហន-ធាតុ ផ្លាស់ជា វធ ហើយ មិនបាច់ព្រឹទ្ធិ វ របស់ វធ ជា វា ឡើយ, ផ្លាស់ ណ្វុ ជា អក, ផ្សំជា វធកោ, ឥ. វធិកា, នបុំ. វធកំ) ។

---

១ អ្នកសិក្សាកុំច្រឡំ បុព្វបទ និង សទ្ទុបបទ ។ បុព្វបទ ចំពោះឧប-សគ្គឬនិបាតដែលតាំងនៅក្នុងខាងដើមធាតុដូច វិ-បុព្វបទ, នី-ធាតុ ជា វិនាយកោ, ឮសំ-បុព្វបទ, ករ-ធាតុ ជា ឮសក្ករំជាដើម ។ សទ្ទុប-បទ ចំពោះនាមសព្ទណាមួយ ដូច គោ-សព្ទ ក្នុងទីនេះ ជាដើម ។

៥- ចំពោះតែអំពីមុខ ញា-ធាតុមួយ, ផ្លាស់ណ្ហុ-បច្ច័យជា "អក" ក៏បាន ជា "អានក[១]" ក៏បាន ឧ. ជានាតី'តិ > ជានកោ (ជនោ) "(ជន) អ្នកដឹង " ក. ក. (ផ្លាស់ ញា-ធាតុជា "ជា", លុប អា របស់ នា-បច្ច័យ (អាខ្យាត), ផ្លាស់ណ្ហុ ជា អក, ផ្សំជា ជានកោ, ឥ. ជានិកា, នបុំ. ជានកំ) ។ សញ្ជានាតី'តិ > សញ្ជាននកោ (ជនោ) "(ជន) អ្នកដឹងច្បាស់" ក. ក., សញ្ជាបេតី'តិ វា > សញ្ជាននកោ (ជនោ) "ម្យ៉ាងទៀតថា (ជន) អ្នកញ៉ាំងជនដទៃឲ្យដឹងច្បាស់" ក. ក. (ផ្លាស់និគ្គហិតរបស់ សំ-បុព្វបទជា "ញ", ផ្លាស់ ញា-ធាតុជា "ជា", ផ្លាស់ ណ្ហុ ជា អានក, លុប អា របស់ ជា, ផ្សំជា សញ្ជាននកោ, ឥ. សញ្ជាននិកា, នបុំ. សញ្ជាននកំ) ។

សព្ទដែលចុះណ្ហុ-បច្ច័យនេះ, បើជាសកម្មធាតុ, ត្រូវប្រើសព្ទជា កម្មបទរាយ ដែលសម្ពន្ធចូលនឹងខ្លួន ប្រកបឆដ្ឋីវិភត្តិ ឲ្យជាឆដ្ឋីកម្ម ឧ. ទានស្ស ទាយកោ "ជនអ្នកឲ្យ នូវទាន", ខីរស្ស បាយកោ "ក្មេងអ្នកបៅ នូវទឹកដោះ" ។

---

១ វិធីផ្លាស់ ណ្ហុ-បច្ច័យជា អានក នេះ, ក្នុងកច្ចាយនបករណ៍, លោករៀបរៀងទៅក្នុងកច្ចាយនឧណាទិឯណោះទេ, ខ្ញុំនាំយកមករៀបរៀងក្នុងកិតកនិទ្ទេសនេះឲ្យហើយ ដើម្បីឲ្យមានរបៀបហូរហែជាការងាយដល់អ្នកសិក្សា ។

ណី : បច្ច័យនេះ ច្រើនចុះក្នុងតស្សីលសាធនៈ, មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- ធាតុដែលជារស្សៈសុទ្ធ ត្រូវព្រឹទ្ធិអក្សរដើមធាតុ ឧ. ធម្មំ-វទតិ-សីលេនា'តិ > ធម្មវាទី (ជនោ) "(ជន) អ្នកពោលនូវធម៌ដោយប្រក្រតី" ក. ត., ធម្មំ-វត្តុំ-សីលំ-យស្ស-សោ > ធម្មវាទី (ជនោ) " (ជន) អ្នកមានកិរិយាពោលនូវធម៌ជាប្រក្រតី" ស. ត., ធម្មំ-វទតី'តិ > ធម្មវាទី (ជនោ) "(ជន) អ្នកពោលនូវធម៌" ក. ក. (ធម្ម-សទ្ទុបបទ, វទ-ធាតុ) ទីឃៈ អ របស់ វ នៃ វទ-ធាតុជា អា[១], លុប ណ ទុកតែ ណី, ផ្សំជា ធម្មវាទី, ឥត្ថីលិង្គ : ចុះឥនី-បច្ច័យ[២] ហើយលុប ណី របស់ វាទី ចេញ ផ្សំជា ធម្មវាទិនី, នបុំសកលិង្គ : រស្សៈ ណី ជា ឥ ជា ធម្មវាទិ[៣]) ។ បើអក្សរដើមធាតុជាទីឃៈ ឬមានព្យញ្ជនៈសំយោគនៅខាងចុង មិនមានវិធីឲ្យព្រឹទ្ធិឡើយ ឧ. ធម្មេន-ជីវិតុំ-សីលំ-យស្ស-សោ > ធម្មជីវី (ជនោ) "(ជន) អ្នកមានកិរិយារស់នៅតាមធម៌ជាប្រក្រតី" ស. ត. (ធម្ម-សទ្ទុបបទ,

---

១ បែបព្រឹទ្ធិស្រៈឯទៀតក្រៅពី "អ" មានគតិដូចគ្នានឹង ណ្ហុ-បច្ច័យដែរ ។ ២ ឥនី-បច្ច័យសម្រាប់ឥត្ថីលិង្គ ដែលបាននិយាយក្នុងនាមនិទ្ទេសរួចហើយ ។ ៣ បែបបំបែកផ្សំនឹងវិភត្តិនាម : បុំ. ដូចសេដ្ឋី, ឥ. ដូច នារី, នបុំ. ដូច អក្ខិ ។

ជីវ-ធាតុ), មន្តេតិ-សីលេនា´តិ > មន្តី (ជនោ) "(ជន) អ្នកប្រឹក្សាតាមប្រក្រតី″ ក. ត. (មន្ត-ធាតុ) ។

២- ធាតុដែលមាន អា ជាទីបំផុត ត្រូវផ្លាស់ អា ជា អាយ ឧ. ទេតិ-សីលេនា´តិ > ទាយី (ជនោ) "(ជន) អ្នកឲ្យតាមប្រក្រតី″ ក. ត. (ផ្លាស់ អា របស់ ទា-ធាតុជា អាយ, លុប ណ ទុកតែ ឦ, ផ្សំជា ទាយី, ឥ. ទាយិនី, នបុំ. ទាយិ) ។

៣- ត្រូវផ្លាស់ទីបំផុតធាតុជារូបផ្សេង ឧ. យុញ្ជិតុំ-សីល´មស្សា´តិ > យោគី (ជនោ) "(ជន) អ្នកមានកិរិយាប្រកប ជាប្រក្រតី″ ស. ត. (យុជ-ធាតុ, ផ្លាស់ ជ ជា គ, ព្រឹទ្ធិ ឧ របស់ យុ ជា ឱ, លុប ណ ទុកតែ ឦ, ផ្សំជា យោគី[១] ឥ. យោគិនី, នបុំ. យោគិ) ។

៤- ត្រូវផ្លាស់ ហន-ធាតុទាំងមូលជា ឃាត ឧ. បរេ-ឧបហន្តុំ-សីលំ-យស្ស-សោ > បរូបឃាតី (ជនោ) "(ជន) អ្នកមានកិរិយាចូលទៅបៀតបៀននូវសត្តដទៃជាប្រក្រតី″ ស. ត. (បរ-សទ្ទបបទ, ឧប-បុព្វបទ, ហន-ធាតុ, ផ្លាស់ ហន ជា ឃាត, លុប

---

១ តាំង "យោគ″ ចុះឦ-បច្ច័យ ក្នុង តទស្សត្ថិតទ្ធិត សម្រេចរូបជាយោគី ក៏បានប្រែថា "ជន មានការព្យាយាមជាគ្រឿងប្រកប″ ។

ណ ទុកតែ ឰ, ទីឃៈ ឧ របស់ ឧប ជា ឩ[១], ផ្សំជា បរូបឃាតី, ឥ. បរូបឃាតិនី, នបុំ. បរូបឃាតិ) ។

ក្វិ : បច្ច័យនេះ គ្រាន់តែចុះមកជាលំនាំ ហើយត្រូវលុបចេញ ឥតទុកឲ្យមានសល់ឡើយ, មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- សព្ទដែលចុះក្វិ-បច្ច័យនេះ ត្រូវឲ្យមាន នាមនាម, គុណនាម, សព្វនាម ជាសទ្ទុបបទ ឬ ឧបសគ្គ, និបាត ជាបុព្វបទ ជាកំណត់ដោយដាច់ខាត ។ នាមនាម ជាសទ្ទុបបទ ឧ. ឧរេន-គច្ឆតី´តិ > ឧរគោ (សត្តោ) "(សត្វ) ទៅដោយទ្រូង=(ពស់)" ក. ក. (ឧរ-សទ្ទុបបទ, គម-ធាតុ, លុប ក្វិ-បច្ច័យ, លុបទីបំផុតធាតុផ្សំជា ឧរគ, ផ្លាស់សិ-វិភត្តិជា ឱ[២]ជា ឧរគោ) ។

១ ទីឃៈសម្រួលតាមអំណាចសន្ធិ, មិនមែនទីឃៈព្រោះអំណាចណី-បច្ច័យទេ, ណី-បច្ច័យក្នុងឧទាហរណ៍នេះមានអំណាចត្រឹមតែឲ្យផ្លាស់ ហន-ធាតុជា ឃាត ប៉ុណ្ណោះ ។ ២ បែបផ្លាស់សិ-វិភត្តិជា ឱ, ជា ° ឬគ្រាន់តែចុះសិ-វិភត្តិមកជាលំនាំហើយលុបសិ ចេញនោះ មិនបានប្រាប់គ្រប់ឧទាហរណ៍ក្នុងកិតកនិទ្ទេសនេះទេ (មានប្រាប់ខ្លះ ទេខ្លះ), អ្នករៀនចូរដឹងតាមបែបបំបែកសព្ទផ្សំនឹងវិភត្តិក្នុងនាមនិទ្ទេសឯណោះចុះ, ក្នុងទីនេះ, និយាយយ៉ាងខ្លីដោយដាច់ខាតទៅថា "កិតកៈទាំងអស់, លើកលែងតែសព្ទដែលចុះបច្ច័យ ៥ គឺ តវេ, តុំ, ត្វា, ត្វាន, តូន ចេញ, សុទ្ធតែត្រូវប្រកបដោយវិភត្តិនាមទាំង ៧ តាមដំណើរលិង្គទាំងបី" ។

គុណនាម ជាសទ្ទុបបទ ឧ. តុរំ-គច្ឆតី៑តិ > តុរគោ (សត្ថោ) "(សត្វ) ទៅរួសរាន់ = (សេះ)" ក. ក. (តុរ-សទ្ទុបបទ, គម-ធាតុ,...,...) ។ សព្វនាមជាសទ្ទុបបទ ឧ. សព្វំ-វិទតី៑តិ > សព្វវិទូ (ភគវា) "(ព្រះមានជោគ) ទ្រង់ជ្រាបនូវហេតុទាំងអស់= (ទ្រង់ជ្រាបសព្វ)" ក. ក. (សព្វ-សទ្ទុបបទ, វិទ-ធាតុ, លុបក្វិ-បច្ច័យ, មិនលុបទីបំផុតធាតុឡើយ, ចុះឩ-អាគម, ផ្សំជាសព្វវិទូ) ។ ឧបសគ្គ ជាបុព្វបទ ឧ. សំ : សុដ្ឋុ-ខនតី៑តិ > សង្ខោ (សត្ថោ) "(សត្វ) ជីកដោយប្រពៃ=(ស័ង្ខ)" ក. ក. (សំ-បុព្វ-បទ, ខន-ធាតុ, លុបក្វិ-បច្ច័យ, លុបទីបំផុតធាតុ, ផ្លាស់និគ្គហិតជា "ង", ផ្សំជា សង្ខ, ផ្លាស់ សិ-វិភត្តិជា ឱ ជា សង្ខោ) ។ និបាតជាបុព្វបទ ឧ. សយំ-ភវតី៑តិ > សយម្ភូ (ភគវា) "(ព្រះមានជោគ) ទ្រង់កើតឯង=(ទ្រង់ត្រាស់ដឹងចំពោះព្រះអង្គ)" ក. ក. (សយំ-បុព្វបទ, ភូ-ធាតុ, លុបក្វិ-បច្ច័យ, ផ្សំជា សយម្ភូ) ។

២- ធាតុដែលមានអក្សរ ២ តួ, លើកលែងតែ វិទ-ធាតុមួយចេញ, ត្រូវលុបទីបំផុតធាតុជាកំណត់ ដូចជា ឧរគោ, តុរគោ, សង្ខោ ជាដើម ។

៣- ចំពោះតែ វិទ-ធាតុមួយនេះ, មិនត្រូវលុបទីបំផុតធាតុឡើយ តែត្រូវចុះ ឪ-អាគមមកជាកំណត់ ឧ. លោកំ-វិទតី´តិ > លោកវិទូ (ភគវា) "(ព្រះមានជោគ) ទ្រង់ជ្រាបនូវត្រៃលោក" ក. ក. (លោក-សទ្ទបបទ, វិទ-ធាតុ, លុបក្វិ-បច្ច័យ, ចុះ ឪអាគម, ផ្សំជា លោកវិទូ), សព្វវិទូ ដូចបាននិយាយរួចហើយ ។

៤- បើធាតុទោលតែមួយតួ, គ្រាន់តែលុបក្វិ-បច្ច័យចេញ ត្រូវទុកធាតុឲ្យនៅតាមរូបដើម ដូចជា សយម្ភូ ជាដើម[១] ។

តុ : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវទុកឲ្យគង់រូបនៅ, មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- ត្រូវលុបទីបំផុតធាតុ ហើយតម្រួត "ត" លើ តុ-បច្ច័យជា "ត្តុ" ឧ. ករោតី´តិ > កត្តា (ជនោ) "(ជន) អ្នកធ្វើ" ក. ក. (លុបទីបំផុតនៃ ករ-ធាតុ, តម្រួត តុ ជា ត្តុ, ផ្សំជា កត្តុ, ផ្លាស់ ឧ និងសិ-វិភត្តិជា អា សម្រេចរូបជា កត្តា ។ មើលក្នុងនាមនិទ្ទេសត្រង់លេខ ៨៣) ។

---

១ សព្ទដែលចុះក្វិ-បច្ច័យនេះ អាចប្រើបានគ្រប់លិង្គទាំង ៣ ប៉ុន្តែ ឥ. និង នបុំ. មិនសូវមានប្រើ ។ បច្ច័យឯទៀតខ្លះក្រៅពីនេះ ក៏មានគតិដូចគ្នាដែរ ។

២- ផ្លាស់ទីបំផុតធាតុជា "ត" ឬជា "ន" តាមគួរដល់ការប្រកប ឧ. វទតី´តិ > វត្តា (ជនោ) "(ជន) អ្នកពោល" ក. ក. (ផ្លាស់ទីបំផុតនៃ វទ-ធាតុជា "ត", ផ្សំជា វត្តុ,...) ។ កោធំ-សមេតិ-សីលេនា´តិ > កោធសន្តា (ជនោ) "(ជន) អ្នករម្ងាប់នូវកំហឹងតាមប្រក្រតី" ក.ត. (កោធ-សទ្ទុបបទ សម-ធាតុ, ផ្លាស់ទីបំផុតធាតុជា "ន", ផ្សំជា កោធសន្តុ,...) ។ បើធាតុដែលមាន "ន" ជាទីបំផុតស្រាប់, មិនបាច់ផ្លាស់ទេគ្រាន់តែផ្សំ ន និងតុ-បច្ច័យជាការស្រេច ឧ. ហន្តុំ-សីល´មស្សា´តិ > ហន្តា (ជនោ) "(ជន) អ្នកមានកិរិយាបៀតបៀន ជាប្រក្រតី" ស. ត. (ផ្សំ ន ទីបំផុតធាតុ និង តុ-បច្ច័យជា ហន្តុ,...) ។

៣- ធាតុដែលមានអក្សរ ២ តួ, បើមិនលុប ឬផ្លាស់ទីបំផុតធាតុទេ, ត្រូវចុះឥ-អាគមមក ឧ. សរិតុំ-សីលំ-យស្ស-សោ > សរិតា (ជនោ) "(ជន) អ្នកមានកិរិយារឭកជាប្រក្រតី" ស. ត. (សរ-ធាតុ, ចុះឥ-អាគម, ផ្សំជា សរិតុ,...) ។

៤- ព្រឹទ្ធិធាតុក៏បានខ្លះ ឧ. សុណាតី´តិ > សោតា (ជនោ) "(ជន) អ្នកស្តាប់" ក. ក. (ព្រឹទ្ធិ ឧ របស់ សុ-ធាតុជា

ឱ, ផ្សំជា សោតុ,...) ។ សូម្បីធាតុជាទីឃៈក៏ព្រឹទ្ធិបានខ្លះ ឧ. នេតី´តិ > នេតា (ជនោ) "(ជន) អ្នកនាំ" ក. ក. (ព្រឹទ្ធិ ឦ របស់ នី-ធាតុ ជា ឯ, ផ្សំជា នេតុ,...) ។

៥- បើធាតុទោលតែមួយតួហើយជាទីឃៈ, គ្រាន់តែផ្សំជាមួយនឹងតុ-បច្ច័យជាការស្រេច ឧ. ទទាតី´តិ > ទាតា (ជនោ) "(ជន) អ្នកឲ្យ" ក. ក. (ផ្សំតុ-បច្ច័យនិងទា-ធាតុជា ទាតុ,...) ។

សព្ទដែលចុះតុ-បច្ច័យនេះ, បើជាសកម្មធាតុ, ត្រូវប្រើសព្ទជាតួកម្មបទរាយ ដែលសម្ពន្ធចូលនឹងខ្លួន ឲ្យជាឆដ្ឋីកម្ម ដូចណ្ហុ-បច្ច័យដែរ ឧ. ធម្មស្ស សោតារោ "ជនទាំងឡាយអ្នកស្តាប់ នូវធម៌" ។

រូ : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវលុប "រ" ចេញទុកឲ្យសល់នៅតែស្រៈ ឩ[១], មានវិធីរូបសិទ្ធិ ដូចមានរបៀបខាងក្រោយនេះ ៖

---

១ រ-បច្ច័យក្តី បច្ច័យដែលមាន "រ" ដូចជា រូ, រិច្ច, រិរិយ, រម្ម, រត្ថុ,រិតុ, រាតុ ជាដើមក្តី ហៅថា រានុពន្ធ "បច្ច័យជាប់ដោយ រ" ត្រូវលុប រ ចេញជា កំណត់ ដោយដាច់ខាត ។

១- បើធាតុមានអក្សរ ២ តួ, ច្រើនតែលុបទីបំផុតធាតុចេញ ឧ. វេទំ-គច្ឆតី'តិ > វេទគូ (ព្រាហ្មណោ) "(ព្រាហ្មណ៍) អ្នកដល់នូវវេទ" ក. ក. (វេទ-សទ្ទុបបទ, គម-ធាតុ, លុបទីបំផុតធាតុ, លុប រ ទុកតែ ឩ, ផ្សំជាវេទគូ ។ (មិនបាច់លុបទីបំផុតធាតុក៏បានខ្លះ ឧ. វិទតី'តិ > វិទូ[១] (ជនោ) "(ជន) អ្នកដឹង=(អ្នកប្រាជ្ញ)" ក. ក. (វិទ-ធាតុ, លុប រ ទុកតែ ឩ, ផ្សំជា វិទូ) ។

២- ធាតុមានអក្សរ ២ តួ, បើមិនលុបទីបំផុតធាតុទេ, ច្រើនតែរស្សៈ ឩ ជា ឧ ដូច្នេះ : ភិក្ខតិ-សីលេនា'តិ > ភិក្ខុ (សមណោ)" (សមណៈ) អ្នកសូមតាមប្រក្រតី" ក. ត. (ភិក្ខ-ធាតុ[២], លុប រ ទុកតែ ឩ ហើយរស្សៈ ឩ ជា ឧ, ផ្សំជា ភិក្ខុ, ឥ. ចុះឥនី-បច្ច័យជា ភិក្ខុនី) ។

៣- បើធាតុទោលតែមួយតួ, ត្រូវលុបស្រៈរបស់ធាតុហើយផ្សំនឹង ឩ ដូច្នេះ : កាលំ-ជានាតី'តិ > កាលញ្ញូ (ជនោ)

---

១ អ្នករៀនចូរចំណាំ កុំច្រឡំ : សព្វវិទូ, លោកវិទូ ចុះក្វិ-បច្ច័យ, ចុះ ឩ-អាគម, មាន សព្វ, លោកជាសទ្ទុបបទ, ឯវិទូ នេះចុះរូ-បច្ច័យមិនមានសទ្ទុបបទទេ (ចូរមើលសង្កេតខាងក្វិ-បច្ច័យ) ។ ២ តាំង ភយ-សទ្ទុបបទ, ឥក្ខ-ធាតុ, រូ-បច្ច័យ ក៏បាន, លុប យ របស់ ភយ ទុកតែ ភ, សម្រេចរូបជា ភិក្ខុ ដូចគ្នា, ប្រែថា "(សមណៈ) អ្នកមានកិរិយាឃើញនូវភ័យក្នុងវដ្តៈជាប្រក្រតី" ។

"(ជន) អ្នកដឹងនូវកាល" ក. ក. (កាល-សទ្ទុបបទ, ញា-ធាតុ, លុប រ ទុកតែ ឱ, លុប អា របស់ញា-ធាតុ, តម្រួត ញ ជា ញ្ញ ផ្សំជា កាលញ្ញូ) ។

អាវី : បច្ច័យនេះ ច្រើនតែចុះក្នុងតស្សីលសាធនៈ, ប្រើបាន ទាំងកត្តុរូប ទាំងសមាសរូប ឧ. ភយំ-បស្សតិ-សីលេនា'តិ > ភយ-ទស្សាវី (ជនោ) "(ជន) អ្នកឃើញនូវភ័យតាមប្រក្រតី" ក. ត., ភយំ-បស្សិតុំ-សីល'មស្សា'តិ > ភយទស្សាវី (ជនោ) "(ជន) អ្នកមានកិរិយាឃើញនូវភ័យជាប្រក្រតី" ស. ត. (ភយ-សទ្ទុបបទ, ទិស-ធាតុ, ផ្លាស់ ឥ របស់ ទិ នៃ ទិស-ធាតុជា អ តម្រួត ស ទី បំផុតធាតុជា ស្ស, ផ្សំជា ភយទស្សាវី, ឥ. ចុះឥនី-បច្ច័យជា ភយទស្សាវិនី, នបុំ. រស្សៈ ឦ ជា ឥ ជា ភយទស្សាវិ) ។

ណុក : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវលុប ណ ទុកតែ ឧក, ត្រូវព្រឹទ្ធិធាតុជារស្សៈសុទ្ធ[១], ច្រើនតែចុះក្នុងតស្សីល-សាធនៈ ដូច អាវី-បច្ច័យដែរ ឧ. ករោតិ-សីលេនា'តិ > ការុកោ (ជនោ) "(ជន) អ្នកធ្វើតាមប្រក្រតី" ក. ត., កាតុំ សីល'មស្សា'តិ >

១ ព្រឹទ្ធិដោយអំណាចណុក-បច្ច័យនេះ ដែលជាណានុពន្ធបច្ច័យ ។

ការុកោ (ជនោ) "(ជន) អ្នកមានកិរិយាធ្វើជាប្រក្រតី" ស. ត. (ទីឃៈ អ របស់ ក នៃ ករ-ធាតុជា អា, លុប ណ ទុកតែ ឧក, ផ្សំជា ការុកោ, ឥ. ចុះអា-បច្ច័យជា ការុកា, នបុំ, ការុកំ) ។

តុក : បច្ច័យនេះ ចុះបានចំពោះតែអំពីមុខ គម-ធាតុ មួយប៉ុណ្ណោះ ឧ. អាគច្ឆតី'តិ > អាគន្តុកោ (ភិក្ខុ) "(ភិក្ខុ) អ្នកមក=(ភិក្ខុដែលទើបមកដល់ថ្មី)" ក. ក. (អា-បុព្វបទ, គម-ធាតុ, ផ្លាស់ ម ទីបំផុតធាតុជា "ន", ផ្សំជា អាគន្តុកោ, ឥ. ចុះអា-បច្ច័យជា អាគន្តុកា, នបុំ. អាគន្តុកំ) ។

ឥក : បច្ច័យនេះ ចុះបានចំពោះតែអំពីមុខ គម-ធាតុ ក្នុងសេចក្តីថា "គួរ-" តែម្យ៉ាងប៉ុណ្ណោះ ឧ. គន្តុំ-ភព្វោ'តិ > គមិកោ (ភិក្ខុ) "(ភិក្ខុ) អ្នកគួរដើម្បីទៅ=(ភិក្ខុដែលមានដំណើរត្រូវចេញទៅ)" ក. ក.[១] (គ្រាន់តែផ្សំ គម-ធាតុ និង ឥក-បច្ច័យ ជា គមិក, ផ្លាស់សិ-វិភត្តិជា ឱ ជា គមិកោ, ឥ. ចុះ អា-បច្ច័យ ជា គមិកា, នបុំ. គមិកំ) ។

---

១ បើតាមដំណើរវិគ្គហៈ គួរតែរាប់ ឥក-បច្ច័យនេះបញ្ចូលក្នុងពួកតទ្ធិតឯណោះសោត, គួរហៅសព្ទ "គមិក" នេះថា "ភព្វតទ្ធិត", ប៉ុន្តែលោករៀបរៀង ក្នុងពួកកិតបច្ច័យយ៉ាងនេះហើយ, អ្នករៀនចូរកំណត់ដឹងថាជា កត្តុរូប-កត្តុសាធនៈ តាមរបៀបនេះចុះ ។

[១៧២] ឧទាហរណ៍ក្នុងកិច្ច-បច្ច័យ

ណ្យ : បច្ច័យនេះ កាលបើចុះមកហើយ មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- ព្រឹទ្ធិធាតុដែលជារស្សៈសុទ្ធ[១] លុប ណ ទុកតែ យ, ចុះឥ-អាគម ឧ. កាតព្វន្តិ > ការិយំ (កម្មំ) "(អំពើ) ដែលជនគប្បីធ្វើ) កម្ម. កម្ម. (ព្រឹទ្ធិ អ របស់ ក នៃ ករ-ធាតុ ជា អា, លុប ណ ទុកតែ យ, ចុះឥ-អាគម[២], ផ្សំជា ការិយ, ផ្លាស់ សិ-វិភត្តិ ជា៌ ជា ការិយំ, បុំ. ការិយោ, ឥ. ចុះអា-បច្ច័យ ជា ការិយា[៣] ។

២- ព្រឹទ្ធិធាតុ, លុប ណ ទុកតែ យ ហើយតម្រួត យ ឧ. ចិនិតព្វន្តិ > ចេយ្យំ (វត្ថុ) "(វត្ថុ) ដែលជនគួរសន្សំ" កម្ម. កម្ម. (ព្រឹទ្ធិ ឥ របស់ ចិ-ធាតុជា ឯ, លុប ណ ទុកតែ យ ហើយតម្រួត យ ជា យ្យ, ផ្សំ ជា ចេយ្យ,...,...) ។

៣- ធាតុដែលមាន "ម" ជាទីបំផុត, ត្រូវលុប ណ ទុកតែ យ ហើយផ្លាស់ យ និងទីបំផុតធាតុជា "ម្ម" ឧ. គមិតព្វន្តិ >

១ ព្រឹទ្ធិដោយអំណាច ណ្យ-បច្ច័យនេះ ជា ណានុពន្ធបច្ច័យ ។ ២ បានជាចុះ ឥ-អាគម ព្រោះមិនលុប ឬផ្លាស់ទីបំផុតធាតុឡើយ ។ ៣ ត្រូវចងវិគ្គហៈ ប្រកប តព្វ-បច្ច័យតាមលិង្គ : បុំ. កាតព្វោ´តិ > ការិយោ, ឥ. កាតព្វា´តិ > ការិយា ។

គម្មំ (ធម្មជាតំ) "(ធម្មជាត) ដែលជនគប្បីដល់" កម្ម. កម្ម. (គម-ធាតុ) ។

៤- ធាតុដែលមាន "ទ" ជាទីបំផុត, ត្រូវលុប ណ ទុកតែ យ ហើយផ្លាស់ យ និងទីបំផុតធាតុជា "ជ្ជ" ឧ. មទនំ > មជ្ជំ "កិរិយាស្រវឹង" ភ. ភ. (មទ-ធាតុ) ។

៥- ធាតុដែលមាន "ធ" ជាទីបំផុត, ត្រូវលុប ណ ទុកតែ យ ហើយផ្លាស់យ និងទីបំផុតធាតុជា "ជ្ឈ" ឧ. វជ្ឈិតព្វន្តិ > វជ្ឈំ (ធម្មជាតំ) "(ធម្មជាត) ដែលជនគប្បីសម្លាប់" កម្ម. កម្ម. (វធ-ធាតុ) ។

៦- ធាតុដែលមាន "ជ" ជាទីបំផុត, ត្រូវលុប ណ ទុកតែ យ ហើយផ្លាស់ យ និងទីបំផុតធាតុជា "គ្គ" ឧ. យុញ្ជិតព្វោតិ > យោគ្គោ (វាយាមោ) "(ព្យាយាម) ដែលជនគួរប្រកប" កម្ម. កម្ម. (យុជ-ធាតុ, ព្រឹទ្ធិ ឧ របស់ យុ ជា ឱ) ។

៧- ធាតុដែលមាន "ច" ជាទីបំផុត, ត្រូវលុប ណ ទុកតែ យ, ផ្លាស់ទីបំផុតធាតុជា "ក" ឧ. វុច្ចតីតិ > វាក្យំ (សទ្ទជាតំ)

"(សទ្ទជាត) ដែលជនពោល = (ពាក្យ)" កម្ម. កម្ម. (ទីឃៈ អ របស់ វ នៃ វច-ធាតុជា អា, លុប ណ ទុកតែ យ, ផ្លាស់ ច ទីបំផុតធាតុជា ក, ផ្សំជា វាក្យ,...) ។

៨- ធាតុដែលមាន "ជ" ជាទីបំផុត, ត្រូវលុប ណ ទុកតែ យ, មិនផ្លាស់ យ និងទីបំផុតធាតុជា "គ្គ" ដូច "យោគ្គោ" នោះឡើយ, ផ្លាស់ទីបំផុតធាតុជា "គ" វិញ ឧ. ភជិយតេ'តិ > ភាគ្យំ (វត្ថុ) "(វត្ថុ) ដែលជនចែក" កម្ម. កម្ម. (ទីឃៈ អ របស់ ភ នៃ ភជ-ធាតុ ជា អា, លុប ណ ទុកតែ យ, ផ្លាស់ ជ ទីបំផុតធាតុជា គ, ផ្សំជា ភាគ្យ,...) ។

៩- ធាតុដែលមាន "អា" ជាទីបំផុត, ត្រូវផ្លាស់ ណ្យ-បច្ច័យទាំងមូលជា ឯយ្យ, លុប អា របស់ធាតុចេញ ឧ. ទាតព្វន្តិ > ទេយ្យំ (វត្ថុ) "(វត្ថុ) ដែលជនគប្បីឲ្យ" កម្ម. កម្ម. (ទា-ធាតុ) ។

១០- ធាតុដែលមាន "ហ" ជាទីបំផុត, ត្រូវលុប ណ ទុកតែ យ ហើយផ្សំ ហ ទីបំផុតធាតុនឹង យ ជា យ្ហ ឧ. បគ្គណ្ហិតព្វន្តិ > បគ្គយ្ហំ (ចិត្តំ) "(ចិត្ត) ដែលយោគីគួរផ្គង" កម្ម. កម្ម. (ប-បុព្វបទ, គហ-ធាតុ,...តម្រួត គ ជា គ្គ,...) ។

១១- ចំពោះតែ ភូ-ធាតុមួយ, ផ្លាស់ ណ្យ-បច្ច័យទាំងមូល និង ឩ របស់ភូ-ធាតុជា អព្វ ឧ. ភូយតេ៍តិ > ភព្វំ "កិរិយាកើត" ក. ក. ។

ណ្យ-បច្ច័យនេះ ជាកិច្ចបច្ច័យ សម្រាប់ចុះក្នុងនាមកិតកៈក៏ពិត ប៉ុន្តែជួនណាមានអំណាចឲ្យប្រើជា កិតកិរិយា ក៏បាន ឧ. តំ (វត្ថុ) គារយ្ហំ "(វត្ថុ) នោះ (គឺជន)[១] គួរតិះដៀល" (គរហ-ធាតុ[២] ណ្យ-បច្ច័យ, ព្រឹទ្ធិ អ របស់ គ នៃ គរហ-ធាតុជា អា, លុប ណ ទុកតែ យ ហើយផ្សំជាមួយនឹង ហ របស់ គរហ-ធាតុ ជា យ្ហ, សម្រេចរូបជា គារយ្ហ, ផ្លាស់សិ-វិភត្តិជា ំ ជា គារយ្ហំ, បុំ. គារយ្ហោ, ឥ. ចុះអា-បច្ច័យជា គារយ្ហា ។ ឧទាហរណ៍នេះ បើប្រើជានាមកិតកៈ ចងវិគ្គហៈថា គរហិតព្វន្តិ > គារយ្ហំ (កម្មំ) (អំពើ) ដែលបណ្ឌិតគួរតិះដៀល" កម្ម. កម្ម. ។

---

១ ណ្យ-បច្ច័យដែលប្រើជា កិតកិរិយា យ៉ាងនេះ ឲ្យប្រែថា "គប្បី-, គួរ-, ត្រូវ-" ដូច តព្វ និង អនីយ-បច្ច័យដែរ (មើលទៅក្នុងខាងមុខត្រង់លេខ ១៧៦ និង ១៨១) ។ ២ ធាតុពហុព្យាង្គ ។

ខ : លុះតែមាននិបាតសព្ទ គឺ ល្ឿសំ "តិចតួច", មាន ឧបសគ្គសព្ទ គឺ ទុ "អាក្រក់, កម្រ,..." សុ "ល្អ, ងាយ ស្រួល,...", ទាំង ៣ នេះ ទោះសព្ទណាក្តី ជាបុព្វបទរបស់ធាតុ ដែលគួរប្រកប នោះទើបចុះខ-បច្ច័យនេះបាន, ម្យ៉ាងទៀត, មិន ត្រូវលុបអក្សរទីបំផុត, មិនត្រូវព្រឹទ្ធិធាតុឡើយ ឧ. ល្ឿសំ-ករិយតេ៌តិ > ល្ឿសក្ករំ (កម្មំ) "(អំពើ) ដែលជនធ្វើតិចតួច" កម្ម. កម្ម. (លុបនិគ្គហិតរបស់ ល្ឿសំ ឲ្យនៅជា ល្ឿស, តម្រួត ក ជា ក្ក, លុបខ-បច្ច័យ, ផ្សំជា ល្ឿសក្ករ, ផ្លាស់សិ-វិភត្តិជា ំ ជា ល្ឿសក្ករំ) ។ ទុដ្ឋុ-[១] វុច្ចតី៌តិ > ទុព្វចោ (ជនោ) "(ជន) ដែលគេស្តីថាបានដោយកម្រ" កម្ម. កម្ម. (លុប ដ្ឋុ ទុកតែ ទុ ផ្លាស់ វ របស់ វច-ធាតុជា ព ហើយតម្រួតជា ព្វ, លុប ខ-បច្ច័យ, ផ្សំជា ទុព្វច, ផ្លាស់សិ-វិភត្តិជា ឱ ជា ទុព្វចោ) ។ សុដ្ឋុ-[២] លព្ភតេ៌តិ > សុលភំ "កិរិយាបានដោយងាយ" ភ. ភ. ឬ "(វត្ថុ) ដែលជនបានដោយងាយ" កម្ម. កម្ម. (លុប ដ្ឋុ

១ ចងវិគ្គហៈជា ទុក្ខេន-វុច្ចតេ៌តិ > ទុព្វចោ ដូច្នេះក៏បាន (លុប ក្ខ ទុកតែ ទុ) ។ ២ ចងវិគ្គហៈជា សុខេន-លព្ភតី៌តិ > សុលភំ ដូច្នេះក៏ បាន (លុប ខ ទុកតែ សុ) ។

ទុកតែ សុ, លុបខ-បច្ច័យ, ផ្សំជា សុលក, ផ្លាស់សិ-វិភត្តិជា ១ ជា សុលភំ, បុំ. សុលភោ, ឥ. ចុះអា-បច្ច័យជា សុលភា[១]) ។

តេយ្យ : បច្ច័យនេះ កាលបើចុះមកហើយ មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- ផ្លាស់ទីបំផុតធាតុជាព្យញ្ជនៈផ្សេង ឧ. បត្តព្វន្តិ > បត្តេយ្យំ (ឋានំ) "(ទី) ដែលជនគប្បីដល់" កម្ម. កម្ម. (ផ្លាស់ ទ ទីបំផុតនៃ បទ-ធាតុជា ត ហើយតម្រួតជាមួយនឹង ត របស់ តេយ្យ, ផ្សំជា បត្តេយ្យ, ផ្លាស់សិ-វិភត្តិជា ១ ជា បត្តេយ្យំ, បុំ. បត្តេយ្យោ, ឥ. ចុះអា-បច្ច័យជា បត្តេយ្យា) ។

២- ផ្លាស់ ត របស់ តេយ្យ-បច្ច័យជា ព្យញ្ជនៈផ្សេង ហើយលុបទីបំផុតធាតុ ឧ. លទ្ធព្វន្តិ > លទ្ធេយ្យំ (ធនំ) "(ទ្រព្យ) ដែលជនគប្បីបាន" កម្ម. កម្ម. (ផ្លាស់ ត របស់ តេយ្យ-បច្ច័យជា ទ្ធ ហើយលុប ភ ទីបំផុតនៃ លភ-ធាតុ, ផ្សំជា លទ្ធេយ្យ,...) ។ ទដ្ឋព្វន្តិ > ទដ្ឋេយ្យំ (រូបំ) "(រូប) ដែលជន

១ សព្ទដែលចុះ ខ-បច្ច័យនេះ បើជាកម្មសាធនៈប្រើជាគុណនាមបានទាំង ៣ លិង្គ, បើជា ភាវសាធនៈប្រើបានតែជានាមនាម ។ ភាវសាធនៈនេះ ទោះសព្ទដែលចុះបច្ច័យឯទៀតក៏មានគតិដូចគ្នានឹង ខ-បច្ច័យដែរ ។

គប្បីឃើញ″ កម្ម. កម្ម. (ផ្លាស់ ត របស់ តេយ្យ-បច្ច័យជា រដ្ឋ[១] ហើយលុប រ ចេញ ទុកតែ ដ្ឋ, លុប ឥស របស់ ទិស-ធាតុចេញ ទុកតែ ទ, ផ្សំជា ទដ្ឋេយ្យ,... ។

៣- បើធាតុទោលតែមួយតួ, ត្រូវទុកទាំងធាតុទាំងបច្ច័យឲ្យនៅតាមរូបដើម ឧ. ញាតព្វន្តិ > ញាតេយ្យំ (អារម្មណ៍) ‶(អារម្មណ៍) ដែលជនគប្បីដឹង″ កម្ម. កម្ម. (គ្រាន់តែផ្សំ ញា-ធាតុ និង តេយ្យ-បច្ច័យ ជា ញាតេយ្យ,...) ។ ភាវសាធនៈ ក៏មានន័យដូចគ្នា ។

រិច្ច : បច្ច័យនេះ ចុះបានចំពោះតែអំពីមុខ ករ-ធាតុ មួយប៉ុណ្ណោះ, កាលបើចុះមកហើយត្រូវលុប រ ទុកតែ ឥច្ច, ត្រូវលុបទីបំផុតធាតុ ឧ. កត្តព្វន្តិ > កិច្ចំ (កម្មំ) ‶(អំពើ) ដែលជនគប្បីធ្វើ″ កម្ម. កម្ម. ឬថា : ករិយតេ´តិ > កិច្ចំ (កម្មំ) ‶(អំពើ) ដែលជនធ្វើ″ កម្ម. កម្ម, ករិយតេ´តិ > កិច្ចំ ‶កិរិយាធ្វើ″ ភ. ភ. (លុប រ ទុកតែ ឥច្ច, លុប រ ទីបំផុតនៃ ករ-ធាតុ, ផ្សំជា កិច្ច,

---

១ ផ្លាស់ ត របស់ តេយ្យ-បច្ច័យជា ដ្ឋ តែម្តង តាមវិធីផ្សេងអំពីកច្ចាយនបករណ៍ក៏បាន ។

ផ្លាស់សិ-វិភត្តិជា ំ ជា កិច្ចំ) ។ ប្រើបានតែជានបុំសកលិង្គ ម្យ៉ាងប៉ុណ្ណោះ ។

រិយ : បច្ច័យនេះ ក៏ចុះបានចំពោះតែអំពីមុខ ករ-ធាតុមួយ ដូច រិច្ច-បច្ច័យដែរ, កាលបើចុះមកហើយ ត្រូវលុប រ ខាងដើម ទុកតែ ឥរិយ, ត្រូវលុបទីបំផុតធាតុ ឧ. កាតព្វា´តិ > កិរិយា (ធម្មជាតិ) "(ធម្មជាតិ) ដែលជនគប្បីធ្វើ" កម្ម. កម្ម. ករិយតេ´តិ > កិរិយំ "កិរិយាធ្វើ, ដំណើរធ្វើ" ភ. ភ. (លុប រ ខាងដើម ទុកតែ ឥរិយ, លុប រ ទីបំផុតនៃ ករ-ធាតុ, ផ្សំជា កិរិយ, ផ្លាស់ សិ វិភត្តិជា ំ ជា កិរិយំ, ចុះអា-បច្ច័យ ជា កិរិយា, ចុះ សិ-វិភត្តិ ហើយលុប សិ ចេញ) ។ ប្រើបានតែជាឥត្ថីលិង្គ និង នបុំសកលិង្គ ប៉ុណ្ណោះ ។

[២៧៣] ឧទាហរណ៍ក្នុងកិតកិច្ច-បច្ច័យ

ណ : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវលុបចេញ ទុកតែស្រៈ "អ" ដែល ណ អាស្រ័យផង, មានវិធីរូបសិទ្ធិ ផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- ធាតុដែលជារស្សៈសុទ្ធ, ត្រូវព្រឹទ្ធិអក្សរដើមធាតុ ឧ. ធម្មំ-ចរតី´តិ > ធម្មចារោ (ជនោ "(ជន) អ្នកប្រព្រឹត្តនូវធម៌" ក. ក. (ធម្ម-សទ្ទុបបទ, ចរ-ធាតុ), ចរិតព្វោតិ ចារោ (ធម្មោ) "(ធម៌)ដែលជនគួរប្រព្រឹត្ត" ឬ ថា "(ប្រទេស) ដែលជនគប្បីដើរទៅ" កម្ម. កម្ម, ចរណំ > ចារោ "កិរិយាប្រព្រឹត្ត, កិរិយាដើរ" ភ. ភ. (ទីឃៈ អ របស់ ចរ-ធាតុជា អា, លុប ណ ទុកតែ អ, ផ្សំជា ធម្មចារ, ជា ចារ, ផ្លាស់សិ-វិភត្តិជា ឱ ជា ធម្មចារោ, ជា ចារោ, ឥ. ចុះអា-បច្ច័យជា ធម្មចារា, ចារា, នបុំ. ធម្មចារំ, ចារំ) ។

បវិសន្តិ-ឯត្ថា´តិ > បវេសោ (បទេសោ) "(ប្រទេស) ជាទីចូលទៅ (នៃជន)" ក. អធិ., បវិសិតព្វោ´តិ > បវេសោ (បទេសោ) "(ប្រទេស) ដែលជនគប្បីចូលទៅ" កម្ម. កម្ម., បវិសនំ > បវេសោ "កិរិយាចូលទៅ" ភ. ភ. (ប-បុព្វបទ, វិស-ធាតុ, ព្រឹទ្ធិ ឥ របស់ វិ ជា ឯ, លុប ណ ទុកតែ អ, ផ្សំជា បវេស,...) ។

ទុស្សន្តិ-ឯតេនា´តិ > ទោសោ (សភាវោ) "(សភាវៈ) ជាហេតុប្រទូស្ត (នៃសត្វ)" ក. ករ., ទុស្សនំ > ទោសោ "កិរិយាប្រទូស្ត" ភ. ភ. (ព្រឹទ្ធិ ឧ របស់ ទុ នៃ ទុស-ធាតុជា ឱ, លុប ណ ទុកតែ អ, ផ្សំជា ទោស,...) ។

៣- ធាតុដែលជាទីឃៈ ឬដែលមានព្យញ្ជនៈសំយោគនៅខាងចុង, មិនបាច់ព្រឹទ្ធិឡើយ ឧ. ភាសិយតេ´តិ > ភាសា (វាចា) "(វាចា) ដែលជនពោល" កម្ម. កម្ម., ភាសយតេ´តិ > ភាសា ឬ ភាសនំ > ភាសា[១] "កិរិយាពោល" ភ.ភ(លុប ណ ទុកតែអ,ផ្សំនឹងភាស-ធាតុជាភាសចុះអា-បច្ច័យជាភាសា)។ បរិវិតក្កនំ> បរិវិតក្កោ "កិរិយាត្រិះរិះ, សេចក្ដីត្រិះរិះ = តម្រិះ)" ភ. ភ.(បរិ-បុព្វបទ, វិ-បុព្វបទ, តក្ក-ធាតុ, លុបណ ទុកតែ អ, ផ្សំជា បរិវិតក្ក, ផ្លាស់សិ-វិភត្តិជា ឱ ជាបរិវិតក្កោ) ។

ជួនណាធាតុដែលជាទីឃៈស្រាប់ ត្រូវព្រឹទ្ធិជារូបផ្សេងក៏មានខ្លះ ឧ. ភវតី´តិ > ភាវោ (សភាវោ) "(សភាវៈ) កើត

---

១ ធាតុជាទីឃៈដែលសម្រេចរូបជាកិតនាមដោយលំនាំយ៉ាងនេះ បើចុះអ-បច្ច័យវិញក៏បាន ។

ក. ក., ភវនំ > ភាវោ "កិរិយាកើត" ភ. ភ. (ព្រឹទ្ធិ ឱ របស់ ភូ-ធាតុជា ឱ ហើយផ្លាស់ ឱ ជា អវ រួចទីឃៈ អ របស់ អវ ជា អាវ, លុប ណ ទុកតែ អ, ផ្សំជា ភាវ, ផ្លាស់សិ-វិភត្តិ ជា ឱ ជា ភាវោ) ។

៣- ផ្លាស់ទីបំផុតធាតុជាព្យញ្ជនៈផ្សេង ឧ. បចតី´តិ > បាកោ (ជនោ) "(ជន) អ្នកចម្អិន" ក. ក., បចនំ > បាកោ "កិរិយាចម្អិន" ភ. ភ. (ទីឃៈ អ របស់ ប នៃ បច-ធាតុ ជា អា, ផ្លាស់ ច ទីបំផុតធាតុជា ក. លុប ណ ទុកតែ អ, ផ្សំជា បាក, ផ្លាស់សិ-វិភត្តិជា ឱ ជា បាកោ) ។ យុញ្ជតិ-ឯតេនា´តិ > យោគោ (វាយាមោ) "(ព្យាយាម) ជាគ្រឿងប្រ-កប" ក. ករ., យុជនំ >យោគោ "កិរិយាប្រកប" ភ. ភ. (ព្រឹទ្ធិ ឧ របស់ យុជ-ធាតុជា ឱ, ផ្លាស់ ជ ជា គ, លុប ណ ទុកតែ អ, ផ្សំជា យោគ, ផ្លាស់សិ-វិភត្តិជា ឱ ជា យោគោ) ។

៤- ផ្លាស់អក្សរដើមធាតុជាព្យញ្ជនៈផ្សេងក៏បានខ្លះ ឧ. បរិឌហនំ > បរិឡាហោ "កិរិយាក្តៅក្រហាយ,..." ភ. ភ. (បរិ-

បុព្វបទ, ឌហ-ធាតុ[១], ផ្លាស់ ឌ ជា ឡ ហើយទីឃៈ អ របស់ ឡ ជា អា, លុប ណ ទុកតែ អ, ផ្សំជា បរិឡាហ, ផ្លាស់ សិ-វិភត្តិជា ឱ ជា បរិឡាហោ) ។

៥- ចំពោះតែ ករ-ធាតុមួយ, បើមានសព្ទគឺ បុរ, សំ, បរិ ជាបុព្វបទ, ត្រូវផ្លាស់ ករ-ធាតុទាំងមូលជា "ខរ" ឧ. បុរេ-ករិយតេ´តិ > បុរេក្ខារំ "កិរិយាធ្វើក្នុងខាងមុខ" ភ. ភ. (បុរ-បុព្វបទ, ករ-ធាតុ ផ្លាស់ ករ ជា ខរ ហើយទីឃៈ អ របស់ ខ ជា អា ផ្លាស់ អ របស់រ នៃ បុរ-សព្ទជា ឯ[២], តម្រួត ក លើ ខ, លុប ណ ទុកតែ អ ផ្សំជា បុរេក្ខារ, ផ្លាស់សិ-វិភត្តិជា ០ ជា បុរេក្ខារំ) ។ សំ : ឯកតោ-ករិយន្តី´តិ > សង្ខារា (ធម្មា) "(ធម៌ទាំងឡាយ) ដែលបច្ច័យធ្វើក្នុងទីជាមួយគ្នា" កម្ម. កម្ម. (សំ-បុព្វបទ, ករ-ធាតុ, ផ្លាស់ ករ ជា ខរ ហើយទីឃៈ អ របស់ ខ ជា អា, ផ្លាស់និគ្គហិតរបស់ សំ ជា "ង", លុប ណ ទុកតែ អ, ផ្សំជា សង្ខារ,...) ។ បរិករោតិ-តេនា´តិ > បរិក្ខារោ (សម្ភារោ) "(គ្រឿងសម្ភារៈ) សម្រាប់ធ្វើដោយជុំវិញ

---

១ ជា ទហ-ធាតុក៏មាន, ផ្លាស់ ទ ជា ឡ, ប៉ុន្តែបានពិនិត្យឃើញថា "ឌហ" គួរជាង "ទហ" ពីព្រោះសព្ទនេះសំស្រ្កឹតជា "បរិឌាហ" កាលបើសព្ទណាដែលសំស្រ្កឹតប្រើជា "ឌ", សព្ទនោះខាងបាឡីរមែងតែប្រើជា "ឡ" ដរាប ។ ២ មានន័យមួយថា ឲ្យផ្លាស់ស្មឹ-វិភត្តិជា ឯ ក៏បាន ។

(នៃជន)″ ក. ករ. (បរិ-បុព្វបទ, ករ-ធាតុ, ផ្លាស់ ករ ជា ខរ ហើយ ទីឃៈ អ របស់ ខ ជា អា, តម្រួត ក លើ ខ, លុប ណ ទុកតែ អ, ផ្សំជា បរិក្ខារ,...) ។

៦- ចំពោះ គហ-ធាតុ, ផ្លាស់ គហ ទាំងមូលជា ឃរ ហើយមិនបាច់ព្រឹទ្ធិ ស្រៈ អ នៃ ឃ របស់ ឃរ ជា ឃា ឡើយ ឧ. (ទព្វសម្ភារេ)-គណ្ហាតីʹតិ > ឃរំ (សេនាសនំ) "(សេនាសនៈ) កាន់យក (នូវទព្វសម្ភារៈ) = គ្រឿងប្រុង″ ក. ក. (ផ្លាស់គហ-ធាតុជាឃរ, លុប ណ ទុកតែ អ, ផ្លាស់សិ-វិភត្តិជា ° ជា ឃរំ) ។

៧- ចំពោះ ហន-ធាតុ, ផ្លាស់ ហន ទាំងមូលជា ឃាត ឧ. ឧបហនតីʹតិ > ឧបឃាតោ (ជនោ) "(ជន) អ្នកចូលទៅបៀតបៀន″ ក. ក. (ឧបហននំ > ឧបឃាតោ "កិរិយាចូលទៅបៀតបៀន″ ភ. ភ. (ឧប-បុព្វបទ, ហន-ធាតុ, ផ្លាស់ ហន ជា ឃាត, លុប ណ ទុកតែ អ, ផ្សំជា ឧបឃាត,...) ។

៨- ធាតុដែលមាន អា ជាទីបំផុត, ត្រូវផ្លាស់ អា របស់ធាតុ ជា អាយ[១] ឧ. ទាតព្វន្តិ > ទាយំ (វត្ថុ) "(វត្ថុ) ដែលជនគួរឲ្យ″

---

១ ចុះ យ-បច្ច័យ (អាខ្យាត) តាមន័យខ្លះក្រៅពីកច្ចាយនៈក៏បាន ។

កម្ម. កម្ម. (ផ្លាស់ អា របស់ ទា-ធាតុជា អាយ, លុប ណ ទុកតែ អ, ផ្សំជា ទាយ, ផ្លាស់ សិ-វិភត្តិជា ំ ជា ទាយំ, បុំ. ទាយោ, ឥ. ចុះ អា-បច្ច័យជា ទាយា[១] ។

អ : បច្ច័យនេះ កាលបើចុះមកហើយ មិនមានបង្គាប់ឲ្យព្រឹទ្ធិអក្សរដើមធាតុជាវស្សៈសុទ្ធ ដូចណ-បច្ច័យនោះទេ, មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- បើមានបទនាមជាសទ្ទុបបទ ជាតួកម្ម នៅខាងដើមធាតុ, ត្រូវចុះ នុ-អាគម ហើយផ្លាស់នុ-អាគមជានិគ្គហិត រួចផ្លាស់និគ្គហិតជាវគ្គន្តព្យញ្ជនៈ តាមលំដាប់វគ្គ ឧ. សរណំ-ករោតី´តិ > សរណង្ករោ[២] (ជនោ) "(ជន) អ្នកធ្វើនូវទីពឹង" ក. ក. (សរ-សទ្ទុបបទ ករ-ធាតុ, ចុះ នុ-អាគម ត្រង់ខាងចុងបន្ទាប់សរណ ហើយផ្លាស់ នុ ជា ំ ផ្សំជា សរណំ, រួចផ្លាស់និគ្គហិតរបស់ សរណំ ជា "ង", ផ្សំជាមួយនឹងអ-បច្ច័យជា សរណង្ករ,

១ សព្ទដែលចុះណ-បច្ច័យនេះប្រើជានាមនាមចំពោះលិង្គមួយៗក៏ មាន, ប្រើជាគុណនាមបានទាំង ៣ លិង្គក៏មាន, បែបបំបែកគុណ-នាម : បុំ. ដូច បុរិស. ឥ. ដូច កញ្ញា, នបុំ. ដូច កុល ។ ២ សព្ទដែលចុះអ-បច្ច័យនេះក៏មានគតិប្រើជានាមនាម ឬ ជាគុណនាម ដូច ណ-បច្ច័យដែរ ។

ផ្លាស់សិ-វិភត្តិជា ឱ ជា សរណង្គរោ) ។ អរី-ទមេតី´តិ > អរិន្ទ-មោ (រាជា) "(ស្តេច) ទ្រង់ទូន្មាននូវសត្រូវ" ក. ក. (អរិ-សទ្ទុបបទ, ទម-ធាតុ, វិធីទាំងពួងដូច សរណង្គរោ ផ្សេងគ្នាតែផ្លាស់និគ្គហិតជា "ន" ប៉ុណ្ណោះ) ។

២- សព្ទដែលមានសទ្ទុបបទជាតួកម្មនៅខាងដើម, បើមិនចុះ នុ-អាគមទេ, ត្រូវតម្រួតអក្សរដើមធាតុ តាមគួរដល់ការប្រកប ឧ. តំ-ករោតី´តិ > តក្ករោ[១] (ជនោ) "(ជន) អ្នកធ្វើនូវកិច្ចនោះ" ក. ក. (ត-សទ្ទុបបទ, ករ-ធាតុ, តម្រួត ក ជា ក្ក, ផ្សំជាមួយនឹង អ-បច្ច័យជា តក្ករ,...) ។

៣- សព្ទដែលមានបុព្វបទ ឬ សទ្ទុបបទ នៅខាងដើមដែរ តែមិនមែនជាតួកម្ម, ឬសព្ទដែលមិនមានបុព្វបទ, សទ្ទុ-បបទនៅខាងដើមទេ, មិនត្រូវចុះនុ-អាគមឡើយ ឧ. វិនេតិ-តេនា´តិ > វិនយោ (ធម្មោ) "(ធម៌) សម្រាប់ទូន្មាន (នូវសត្វនៃព្រះសាស្តា)" ក. ករ. (វិ-បុព្វបទ, នី-ធាតុ, ព្រឹទ្ធិ ឦ របស់

---

១ បើចុះនុ-អាគម ជា តង្ករោ, ប៉ុន្តែត្រូវប្រើជា តក្ករោ យ៉ាងនេះតាមគួរដល់ការប្រកប ។

នី-ធាតុជា ឯ ហើយផ្លាស់ ឯ ជា អយ, ផ្សំជាមួយអ-បច្ច័យ ជា វិនយ,...) ។ វនេ-ចរតី´តិ > វនចរោ (ជនោ) "(ជន) អ្នកត្រាច់ទៅក្នុងព្រៃ = ឋ្មើរព្រៃ, ព្រានព្រៃ" ក. ក. (វន-សទ្ទុបបទ, ចរ-ធាតុ, ផ្សំជាមួយនឹងអ-បច្ច័យជា វនចរ,...) ។ ជិនាតី´តិ > ជយោ (ជនោ) "(ជន) អ្នកឈ្នះ" ក. ក., ជយនំ > ជយោ "កិរិយាឈ្នះ" ភ. ភ. (ព្រឹទ្ធិ ឥ របស់ ជិ-ធាតុជា ឯ ហើយផ្លាស់ ឯ ជា អយ, ផ្សំជាមួយនឹងអ-បច្ច័យជា ជយ,...) ។ បថន្តិ : គច្ឆន្តិ-ឯត្ថា´តិ > បថោ (បទេសោ) "(ប្រទេស) ជាទីទៅ (នៃជន) = ផ្លូវ" ក. អធិ. (បថ-ធាតុ "ទៅ") ។

៤- ចំពោះទា-ធាតុ ដែលអញ្ញាសៈជា ទា-ទា រស្សៈជា ទ-ទ, បើមាន បុរ-សព្ទ ជាបុព្វបទ, ត្រូវផ្លាស់ អ របស់ រ នៃ បុរ-សព្ទជា ឥំ ហើយផ្លាស់និគ្គហិតរបស់ ឥំ ជា "ន" ឧ. បុរេ-(ទានំ)-ទទាតី´តិ > បុរិន្ទទោ[១] (ទេវរាជា) "(ទេវរាជ) ទ្រង់ឲ្យ (នូវទាន) ក្នុងកាលពីដើម = ព្រះឥន្ទ" ក.ក. ។

---

១ ចងវិគ្គហៈជា បុរេ-(ទានំ)-អទទី´តិ > បុរិន្ទទោ ដូច្នេះក៏គួរណាស់ ព្រោះមានដំណើរសេចក្តីជាអតីតកាល ។

ឥ : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវទុកឲ្យគង់រូបនៅជា ឥ ដូចដើម, ទាំងធាតុក៏ត្រូវទុកឲ្យគង់នៅ មិនមានវិធីឲ្យលុបទីបំផុតធាតុឡើយ, ទោះមានបុព្វបទឬសទ្ទុបបទក្តី មិនមានក្តី អាចចុះបច្ច័យនេះបាន ឱ. អាទិយតេ'តិ > អាទិ (សភាវោ) "(សភាវៈ) ដែលជនកាន់យក = ខាងដើម" កម្ម. កម្ម. (អា-បុព្វបទ, ទា-ធាតុ, លុប អា របស់ ទា, ផ្សំនឹងឥ-បច្ច័យជា អាទិ, សព្ទនេះជាគុណនាម តិលិង្គិកៈ) ។ ឧទកំ-ទធាតី'តិ > ឧទធិ (បទេសោ) "(ប្រទេស) ទ្រទ្រង់នូវទឹក = សមុទ្ទ" ក. ក. (ឧទក-សទ្ទុបបទ, ធា-ធាតុ, លុប ក របស់ ឧទក ទុកតែ ឧទ, លុប អា របស់ ធា, ផ្សំនឹងឥ-បច្ច័យជា ឧទធិ, ជានាមនាម បុំ.) ។ មុនាតី'តិ > មុនិ (ជនោ) "(ជន) អ្នកដឹង = អ្នកប្រាជ្ញ" ក. ក. (ផ្សំ មុន-ធាតុជាមួយនឹងឥ-បច្ច័យជា មុនិ, ជានាមនាម បុំ.) ។ រុចនំ > រុចិ "កិរិយារុងរឿង, សេចក្តីរុងរឿង" ភ. ភ. (ផ្សំ រុច-ធាតុជាមួយនឹង ឥ-បច្ច័យជា រុចិ, ជានាមនាម[១] ឥ.) ។

---

១ សព្ទដែលចុះឥ-បច្ច័យនេះ ទោះបើជានាមនាមក្តី គុណនាមក្តី មានវិធីបំបែកដូច្នេះ : បុំ. ដូច មុនិ, ឥ. ដូច រត្តិ, នបុំ. ដូច អក្ខិ ។

យុ : បច្ច័យនេះ កាលបើចុះមកហើយ នឹងទុកឲ្យគង់នៅតាមរូបដើមពុំបានឡើយ, ត្រូវផ្លាស់បាន ៣ យ៉ាង គឺផ្លាស់ជា អន, អណ, អានន, មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបខាងក្រោយនេះ ៖

១- វៀរលែងតែធាតុដែលមាន "រ" ឬមាន "ហ" ជាទីបំផុត និងញា-ធាតុចេញ, ត្រូវផ្លាស់ យុ ជា អន ឧ. បនុទតី´តិ > បនូទនោ (ជនោ) "(ជន) អ្នកបន្ទោបង់" ក. ក., បនុទិតុំ-សីលំ-យស្ស-សោ > បនូទនោ (ជនោ) "(ជន) អ្នកមានកិរិយាបន្ទោបង់ជាប្រក្រតី" ស. ត., បនុទិយតេ´តិ > បនូទនំ "កិរិយាបន្ទោបង់" ភ. ភ. (ប-បុព្វបទ, នុទ-ធាតុ, ទីឃៈ ឧ របស់ នុទ ជា ឩ, ផ្លាស់ យុ ជា អន, ផ្សំជា បនូទនោ, ឥ. បនូទនា, នបុំ. បនូទនំ) ។ សុណាតិ-តេនា´តិ > សវនំ (សោតាយតនំ) "(អាយតនៈគឺត្រចៀក) សម្រាប់ឮ (នៃជន)" ក. ករ, សុយ្យតេ-តេនា´តិ > សវនំ[1] (សោតាយតនំ) "(អាយតនៈគឺត្រចៀក) ជាគ្រឿងដែលជនឮ (នៃ

១ (សទ្ទោ-ជនេន)-សុយ្យតេ-តេន (សោតាយតនេន)-ឥតិ-(តំ សោតាយតនំ) > សវនំ... ។

សំឡេង)″ កម្ម. ករ., សុយ្យតេ′តិ > សវនំ "កិរិយាឮ, កិរិយាស្តាប់″ ភ. ភ. (ព្រឹទ្ធិ ឧ របស់ សុ-ធាតុ ជា ឱ ហើយផ្លាស់ ឱ ជា អវ, ផ្លាស់យុ ជា អន, ផ្សំជា សវន,...) ។

២- ធាតុដែលមាន "រ″ ឬមាន "ហ″ ជាទីបំផុត, ត្រូវផ្លាស់ យុ ជា អណ[១] ឧ. កាតព្វន្តិ > ករណំ (កិច្ចំ) "(កិច្ច) ដែលជនគប្បីធ្វើ″ កម្ម. កម្ម. ករិយតេ′តិ > ករណំ "កិរិយាធ្វើ″ ភ. ភ. (ផ្លាស់ យុ ជា អណ, ផ្សំនឹង ករ-ធាតុ ជា ករណ,...) ។ គហិ-យតេ′តិ > គហណំ "កិរិយាកាន់, ការចាប់,...″ ភ. ភ. (ផ្លាស់ យុ ជា អណ, ផ្សំនឹង គហ-ធាតុ ជា គហណ,...) ។ គរហិយ-តេ′តិ > គរហណំ "កិរិយាតិះដៀល″ ភ. ភ. (ផ្លាស់ យុ ជា អណ, ផ្សំនឹង គរហ-ធាតុ ជា គរហណ,...) ។

មានធាតុខ្លះមិនមាន "រ″ ឬ "ហ″ ជាទីបំផុតទេ ក៏អាចឲ្យផ្លាស់ យុ ជា អណ បានដែរ (តែក្នុងបាឡីភាសាមានប្រើតិច) ដូចជា : លក្ខណំ "(ហេតុ) ជាគ្រឿងកំណត់″ ក. ករ. ឬ

---

១ ក្នុងកច្ចាយនបករណ៍ថាឲ្យផ្លាស់ យុ ជា អន ហើយផ្លាស់ ន ជា ណ, បែបផ្លាស់ យុ ជា អណ តែម្តងយ៉ាងនេះ, ពោលតាមវិធីក្នុងបករណ៍ផ្សេងពីកច្ចាយនៈ ។

"កិរិយាកំណត់, សេចក្ដីកំណត់" ភ. ភ. (លក្ខ-ធាតុ "កំណត់, សម្គាល់, ចំណាំ", ផ្លាស់ យុ ជា អណ,...) ។ បមាណំ "(ហេតុ) ជាគ្រឿងរាប់" ក. ករ. ឬ "កិរិយារាប់" ភ. ភ. (ប-បុព្វបទ, មា-ធាតុ "រាប់, ត្នេរ", ផ្លាស់ យុ ជា អណ,...) ។ សមណោ "(បព្វជិត) អ្នកស្ងប់រម្ងាប់" ក. ក. (សម-ធាតុ "ស្ងប់, រម្ងាប់, ស្ងប់រម្ងាប់", ផ្លាស់ យុ ជា អណ,...) ។

៣- ចំពោះតែអំពីមុខ ញា-ធាតុមួយ, ត្រូវផ្លាស់ យុ ជា អន ក៏បាន, ជា អណ ក៏បាន, ជា អានន ក៏បាន ឧ. ញាយ-តេ៍តិ > ជានំ "កិរិយាដឹង" ភ. ភ. (ផ្លាស់ ញា-ធាតុ ជា "ជា", ផ្លាស់ យុ ជា អន, លុប អ របស់ អន ទុកតែ ន, ផ្សំជា ជាន[១],...) ។ ញាយតេ៍តិ > ញាណំ "កិរិយាដឹង, សេចក្ដីដឹង" ភ. ភ. (ផ្លាស់ យុ ជា អណ, លុប អ របស់ អណ ទុកតែ ណ, ផ្សំនឹងញា-ធាតុ ជាញាណ,...) ។ វិជានាតី៍តិ > វិញ្ញាណំ (ធម្មជាតំ) "(ធម្មជាត) ដឹងច្បាស់" ក. ក. (វិ-បុព្វបទ, ញា-ធាតុ, ផ្លាស់ យុ ជា អណ,

---

១ មិនសូវប្រើ ច្រើនប្រើជា "ជានន" ដើម្បីឲ្យច្បាស់លាស់ត្រង់ បឋមាឯកវចនៈមិនឲ្យច្រឡំនឹង ជានន្តុ ដែលផ្លាស់ ន្តុ និងសិ-វិភត្តិ ជា ំ ជា "ជានំ" ប្រែថា "កាលដឹង" នោះទេដឹង ។

លុប អ របស់ អណ ទុកតែ ណ, តម្រួត ញា ជា ញ្ញា, ផ្សំជា វិញ្ញាណ,...) ។ ញាយតេ៍តិ > ជានន្ទំ (ដូច ជានំ, ផ្សេងគ្នា តែ ផ្លាស់ យុ ជា អានន, លុប អា របស់ "ជា" ឲ្យជា "ជ" ប៉ុណ្ណោះ) ។ សញ្ញាយតេ៍តិ > សញ្ជាននំ "កិរិយាដឹងច្បាស់,..." ភ. ភ. (សំ-បុព្វបទ, ញា-ធាតុ, ផ្លាស់ ញា ជា "ជា", ផ្លាស់និគ្គហិតរបស់ សំ ជា "ញ", ផ្លាស់ យុ ជា អានន, លុប អា របស់ ជា ឲ្យជា "ជ", ផ្សំជា សញ្ជានន,...) ។

សព្ទដែលចុះយុ-បច្ច័យនេះ, បើជាសកម្មធាតុ, ត្រូវប្រើសព្ទ ជាកម្មបទរាយ ដែលសម្ពន្ធចូលនឹងខ្លួន ប្រកបឆដ្ឋីវិភត្តិឲ្យជា ឆដ្ឋីកម្ម ឧ. បាបស្ស អករណំ "កិរិយាមិនធ្វើ នូវបាប", ធនស្ស លភនំ "កិរិយាបាន នូវទ្រព្យ" ។

តិ : បច្ច័យនេះ កាលបើចុះមកហើយ មានវិធីរូបសិទ្ធិ ផ្សេងៗ[១] ដូចមានរបៀបខាងក្រោយនេះ ៖

---

១ តិ-បច្ច័យនេះ មានវិធីរូបសិទ្ធិច្រើនត្រូវដំណើរគ្នានឹងត-បច្ច័យ ខាងកិរិយាកិតក: (ចូរមើលសង្កេតវិធីរូបសិទ្ធិនៃត-បច្ច័យខាងមុខ ត្រង់លេខ ១៨១) ។

១- ធាតុដែលមាន ន, ម, រ, ជាទីបំផុត ត្រូវលុបព្យញ្ជនៈទីបំផុតធាតុ ដូច្នេះ : ធាតុមាន "ន" ជាទីបំផុត ឧ. ខននំ > ខតិ "កិរិយាជីក" ភ. ភ. ជានាមនាម ឥ. (លុប ន ទីបំផុតនៃ ខន-ធាតុ, ផ្សំនឹង តិ ជា ខតិ) ។ ធាតុមាន "ម" ជាទីបំផុត ឧ. រមន្តិ-ឯតាយា´តិ > រតិ (ធម្មជាតិ) "(ធម្មជាតិ) ជាហេតុរីករាយ (នៃសត្វ)" ក. ករ., រមនំ > រតិ "កិរិយារីករាយ, សេចក្តីត្រេកអរ=តម្រេក" ភ. ភ. ជានាមនាម ឥ. (លុប ម ទីបំផុតនៃ រម-ធាតុ, ផ្សំនឹង តិ ជា រតិ) ។ ធាតុមាន "រ" ជាទីបំផុត ឧ. សរតិ-ឯតាយា´តិ > សតិ (ធម្មជាតិ) "(ធម្មជាតិ) ជាគ្រឿងរឭក" (នៃជន) = ស្មារតី" ក. ករ., សរណំ > សតិ "កិរិយារឭក" ភ. ភ. ជានាមនាម ឥ. (លុប រ ទីបំផុតនៃ សរ-ធាតុ, ផ្សំជា សតិ) ។

២- ធាតុដែលមាន ច, ទ, ប ជាទីបំផុត, ត្រូវផ្លាស់ទីបំផុតធាតុជា "ត" ផ្សំនឹងតិ-បច្ច័យជា "ត្តិ" ដូច្នេះ : ធាតុមាន "ច" ជាទីបំផុត ឧ. វិមោចតិ-ឯតាយា´តិ > វិមុត្តិ (គុណជាតិ) "(គុណជាតិ) ជាគ្រឿងរួចស្រឡះ (នៃជន)" ក. ករ., វិមុច្ចតេ´តិ > វិមុត្តិ "កិរិយារួចស្រឡះ" ភ. ភ. ជានាមនាម ឥ. (វិ-បុព្វបទ, មុច-ធាតុ, ផ្លាស់

ច ទីបំផុតជាតុជា "ត", ផ្សំនឹង តិ ជា វិមុត្តិ) ។ ជាតុមាន "ទ" ជាទីបំផុត ឧ. វិនាសំ-បជ្ជតេ៎តិ > វិបត្តិ "កិរិយាដល់នូវសេចក្ដីខូចបង់" ក. ក. ជានាមនាម ឥ. (វិនាស-សទ្ទបបទ, លុប នាស ទុកតែ វិ ជាបុព្វបទ, បទ-ជាតុ ផ្លាស់ ទ ទីបំផុតជាតុជា "ត", ផ្សំនឹង តិ ជា វិបត្តិ) ។ ជាតុមាន "ប" ជាទីបំផុត : ឧ. តបនំ > តត្តិ "កិរិយាក្ដៅ, សេចក្ដីក្ដៅ" ក. ក. ជានាមនាម ឥ. (ផ្លាស់ ប ទីបំផុតនៃ តប-ជាតុ ជា "ត", ផ្សំនឹង តិ ជា តត្តិ) ។

៣- ត្រូវផ្លាស់ជាតុទាំងមូល ជារូបផ្សេង ឧ. ជននំ > ជាតិ "កិរិយាកើត = កំណើត" ក. ក. ជានាមនាម ឥ. (ផ្លាស់ ជន-ជាតុ ជា "ជា[១]", ផ្សំនឹង តិ ជា ជាតិ) ។

៤- ជាតុទោលតែមួយតួ, ត្រូវទុកទាំងជាតុទាំងបច្ច័យឲ្យនៅដូចដើម ឧ. (កុមារេ) -ទធាតី៎តិ > ធាតិ (ឥត្ថី) (ស្រី) អ្នកទ្រទ្រង់ (នូវកូនក្មេង) = ម៉ែដោះ[២], បងចិញ្ចឹម, បងរក្សា" ក. ក. ជានាមនាម ឥ (គ្រាន់តែផ្សំ ធា-ជាតុ និង តិ ជា

១ បែបផ្លាស់យ៉ាងនេះ ឃើញមានតែ ជាតិ មួយប៉ុណ្ណោះ ។ ២ មេនំ, ភីលៀង ។

ជាតិ) ។ ញាតព្វោ´តិ > ញាតិ (ជនោ) "(ជន) ដែលគេត្រូវស្គាល់" កម្ម. កម្ម. ជានាមនាម បុំ. (គ្រាន់តែផ្សំញា-ធាតុនិង តិ ជា ញាតិ) ។ ធន´មស្ស-ភវតូ´តិ > ធនភូតិ (ជនោ) "(ជន) ជាទីចូរកើតនៃទ្រព្យ" ក. សម្ប. (ធន-សទ្ទុបបទ, ភូ-ធាតុ, ផ្សំនឹង តិ ជា ធនភូតិ) ។ ភវតី´តិ > ភូតិ (ធម្មជាតិ) "(ធម្មជាតិ) កើត" ក. ក., ភូយតេ´តិ > ភូតិ, ឬ ភវនំ > ភូតិ "កិរិយាកើត, ការកើត" ភ. ភ. ជានាមនាម ឥ. (គ្រាន់តែផ្សំ ភូ-ធាតុ និង តិ ជា ភូតិ) ។

៥- ចំពោះ ឋា-ធាតុ និង បា-ធាតុ ពីរនេះ, ត្រូវផ្លាស់ អា របស់ ឋា ជា ឥ, ផ្លាស់ អា របស់ បា ជា ឦ ដូច្នេះ : ឋា-ធាតុ : ឋានំ > ឋិតិ "កិរិយាតម្កល់, កិរិយាតាំងនៅ,..." ភ. ភ. ជានាមនាម ឥ. ។ បា-ធាតុ : បិវនំ > បីតិ "កិរិយាផឹក" ភ. ភ. ជានាមនាម ឥ. ។

---

១ សព្ទដែលចុះ តិ-បច្ច័យ នេះច្រើនប្រើជានាមនាម (ឥ-ការន្ត) ជាងគុណនាម, បើជាគុណនាម ជាឥ-ការន្តទាំង ៣ លិង្គ, បែបបំបែក : បុំ. ដូច មុនិ, ឥ. ដូច រត្តិ, នបុំ. ដូច អក្ខិ ។

៦- ធាតុដែលមាន ធ, ម, ស ជាទីបំផុត, ត្រូវផ្លាស់ តិ-បច្ច័យ ជាព្យញ្ជនៈផ្សេង ហើយលុបទីបំផុតធាតុចេញ, ដូច របៀបខាងក្រោយនេះ : *ក*) ធាតុមាន "ធ" ជាទីបំផុត, ត្រូវ ផ្លាស់តិ-បច្ច័យជា "ទ្ធិ" ឧ. ពុជ្ឈតិ-ឯតាយា´តិ > ពុទ្ធិ (បញ្ញា) "(ប្រាជ្ញា) ជាគ្រឿងដឹង (នៃជន)" ក. ករ. (ផ្លាស់ តិ ជា ទ្ធិ, លុប ធ ទីបំផុតនៃ ពុធ-ធាតុ, ផ្សំជា ពុទ្ធិ) ។ *ខ*) ធាតុ មាន "ម" ជាទីបំផុត, ត្រូវផ្លាស់តិ-បច្ច័យជា "ន្តិ" ឧ. ខមនំ > ខន្តិ "កិរិយាអត់, សេចក្តីអត់ទ្រាំ = អំណត់" ភ. ភ. ជានាម- នាម ត. (ផ្លាស់ តិ ជា ន្តិ, លុប ម ទីបំផុតនៃ ខម-ធាតុ, ផ្សំ ជា ខន្តិ) ។ *គ*) ធាតុមាន "ស" ជាទីបំផុត, ត្រូវផ្លាស់ តិ- បច្ច័យជា "ដ្ឋិ" ឧ. ទស្សនំ > ទិដ្ឋិ "កិរិយាឃើញ" ភ. ភ. ជា នាមនាម ត. (ផ្លាស់ តិ ជា ដ្ឋិ, លុប ស ទីបំផុតនៃ ទិស-ធាតុ, ផ្សំជា ទិដ្ឋិ) ។ តុសនំ > តុដ្ឋិ "កិរិយាត្រេកអរ, សេចក្តីត្រេកអរ = អំណរ" ភ. ភ. ជានាមនាម ត. (ផ្លាស់ តិ ជា ដ្ឋិ, លុប ស ទីបំផុតនៃ តុស-ធាតុ, ផ្សំជា តុដ្ឋិ) ។

រម្ម : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវលុប រ ចេញ ទុកតែត្រឹម ម្ម, ទាំងទីបំផុតធាតុក៏ត្រូវលុបចេញ (ជាកំណត់) ឧ. ធារេតី´តិ > ធម្មោ (សភាវោ) "(សភាវៈ) ទ្រទ្រង់" ក. ក., ធារេតិ-តេនា´តិ-វា > ធម្មោ (សភាវោ) "ម្យ៉ាងទៀតថា (សភាវៈ) ជាហេតុទ្រទ្រង់ (នៃព្រះមានជោគ)" ក. ករ. (លុប រ នៃ រម្ម ទុកតែ ម្ម, លុប រ ទីបំផុតនៃ ធរ-ធាតុ, ផ្សំជា ធម្ម, ផ្លាស់សិ-វិភត្តិជា ឱ ជា ធម្មោ) ។ ករិយតេ´តិ > កម្មំ (កិច្ចំ) "(កិច្ច) ដែលជនធ្វើ" កម្ម. កម្ម., កាតព្វ´ន្តិ-វា > កម្មំ (កិច្ចំ) "ម្យ៉ាងទៀតថា (កិច្ច) ដែលជនត្រូវធ្វើ = អំពើ" កម្ម. កម្ម. (លុប រ នៃ រម្ម ទុកតែ ម្ម, លុប រ ទីបំផុតនៃ ករ-ធាតុ, ផ្សំជា កម្ម, ផ្លាស់សិ-វិភត្តិជា º ជា កម្មំ) ។

រ : បច្ច័យនេះគ្រាន់តែចុះមកជាលំនាំហើយលុបចេញឥតមានទុកឲ្យសល់ឡើយ, ទាំងទីបំផុតធាតុក៏ត្រូវលុបចេញ (ជាកំ-ណត់) ឧ. អន្តំ-ករោតី´តិ > អន្តកោ (សភាវោ) "(សភាវៈ) ធ្វើនូវទីបំផុត" ក. ក., អន្តំ : វិនាសំ-ករោតី´តិ-វា > អន្តកោ (សភាវោ) "ម្យ៉ាងទៀតថា (សភាវៈ) ធ្វើនូវទីបំផុត គឺសេចក្ដីវិនាស = មច្ចុ-

មារ" ក. ក. (អន្ត-សទ្ទុបបទ, ករ-ធាតុ, លុប រ-បច្ច័យ, លុប ទីបំផុតធាតុ, ផ្សំជា អន្តក, ផ្លាស់ សិ-វិភត្តិជា ឱ ជា អន្តកោ) ។ ទុដ្ឋុ-ខមិយតេ៍តិ > ទុក្ខំ (ធម្មជាតំ) "(ធម្មជាត) ដែលជនអត់ទ្រាំបានដោយកម្រ" កម្ម. កម្ម., ម្យ៉ាងទៀតថា "កិរិយាអត់ទ្រាំបានដោយកម្រ = សេចក្តីព្រួយ, សេចក្តីលំបាក" ភ. ភ. (ទុដ្ឋុ-បុព្វបទ, ខម-ធាតុ, លុប រ-បច្ច័យ, លុប ដ្ឋុ ទុកតែ ទុ, លុបទីបំផុតធាតុ, តម្រួត ក លើ ខ ជា ក្ខ[២], ផ្សំជា ទុក្ខ, ផ្លាស់សិ-វិភត្តិជា ំ ជា ទុក្ខំ) ។ បរិ : សមន្តតោ-ខនិយតេ៍តិ > បរិក្ខា (ភូមិ) "(ទី) ដែលជនជីកដោយជុំវិញ = ស្នាមភ្លោះ, គូ" កម្ម. កម្ម. (បរិ-បុព្វបទ, ខន-ធាតុ, លុប រ-បច្ច័យ, លុបទីបំផុត

---

១ អ្នករៀនចូរសង្កេត កុំច្រឡំ ខ-បច្ច័យ និង រ-បច្ច័យ, ចូរចំណាំដូច្នេះ បើមានឧបសគ្គគឺ ទុ នេះជាបុព្វបទ ហើយមិនលុបទីបំផុតធាតុទេ ដូចជា "ទុដ្ឋុ-ខមិយតេ៍តិ > ទុក្ខមំ" យ៉ាងនេះជា ខ-បច្ច័យ, បើលុបទីបំផុតធាតុ ដូចជា "ទុក្ខ" នេះជា រ-បច្ច័យ, ចូរមើលសង្កេតវិធីនៃ ខ-បច្ច័យខាងដើម) ។ ២ មិនមែនតម្រួតដោយអំណាច រ-បច្ច័យទេ តម្រួតតាមដំណើររបស់សន្ធិ, ព្រោះ ទុ ជាអក្សរ ឃោ-សៈត្រូវតម្រួតអក្សរខាងចុងដើម្បីឲ្យស្រួលមាត់ ដូចជាទុគ្គតិ, ទុ-គ្គមំ,ទុច្ចរិតំ,ទុជ្ជនោ,ទុព្ភិក្ខំ ជាដើមនុ៎ះដែរ, តម្រួតយ៉ាងនេះហៅថា "តម្រួតតាមគួរដល់ការប្រកប, បើបុព្វបទ ជា អឃោសៈដូច "សុ" នេះ មិនត្រូវតម្រួតឡើយ ដូចយ៉ាង សុខំ, សុគតិ, សុគមំ, សុចរិតំ, សុជនោ សុភិក្ខំ ជាដើម ។

ធាតុ, តម្រួត ក លើ ខ ជា ក្ខ[១], ផ្សំជា បរិក្ខ, ចុះ អា-បច្ច័យ ជា បរិក្ខា ) ។

ឥន : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវទុកឲ្យគង់រូបនៅដូចដើម ឱ. ជិនាតី៍តិ > ជិនោ (ភគវា) "(ព្រះមានជោគ) ទ្រង់ឈ្នះ" ក. ក. (លុប ឥ របស់ ជិ-ធាតុ ហើយផ្សំនឹងឥន-បច្ច័យជា ជិន, ផ្លាស់សិ-វិភត្តិជា ឱ ជា ជិនោ) ។ សុបិយតេ៍តិ > សុបិនំ[២] "កិរិយាដេកលក់, កិរិយាយល់សប្តិ" ភ. ក. (ផ្សំសុប-ធាតុនិងឥន-បច្ច័យជា សុបិន, ផ្លាស់សិ-វិភត្តិជា ំ ជា សុបិនំ) ។

តវេ : បច្ច័យនេះកាលបើចុះមកហើយ គង់រូបនៅដូចដើម, ជាបច្ច័យរាប់បញ្ចូលក្នុងកិតកិច្ច-បច្ច័យ នៃនាមកិតកៈ ក៏ពិត ប៉ុន្តែបើចុះផ្សំជាមួយនឹងធាតុហើយ ក៏ជាអព្យយសព្ទ ព្រោះ តវេ ជាអព្យយបច្ច័យ ប្រើប្រកបនឹងវិភត្តិនាមពុំបានឡើយ, ជាបច្ច័យសម្រាប់គ្រាន់តែចុះរាំងមុខធាតុ កុំឲ្យធាតុនូវលោតទទេសុទ្ធតាម

១ ក្នុងបករណៈខ្លះប្រាប់ថា ចុះក្ខិ-បច្ច័យ, ចុះអា-បច្ច័យ, មិនបាច់តម្រួត, សម្រេចរូបជាបរិខា ។ ២ ក្នុងកច្ចាយនបករណ៍ប្រាប់ថា ឥន-បច្ច័យនេះ ចុះបានចំពោះតែអំពីមុខធាតុ ២ គឺ ជិ-ធាតុ និង សុប-ធាតុ ហើយប្រើបានតែសាធនៈ ២ យ៉ាងគឺ កត្តុសាធនៈ និង ភាវសាធនៈ ប៉ុណ្ណោះ (មេសូត្រ ជិតោ ឥន សព្វត្ថ និង សុបតោ ច) ។

លំនាំដើមប៉ុណ្ណោះ[១], មិនមានវិធីឲ្យតាំងវិគ្គហៈទេ, មានសណ្ដាប់ឲ្យប្រែចេញសម្ដីអាយតនិបាត ដូចចតុត្ថីវិភត្តិនាមថា "ដើម្បី-" ឬ គ្រាន់តែប្រែចេញសព្ទធាតុតែម្ដង កុំបាច់ថា "ដើម្បី-" ក៏សឹងបាន តាមគួរដល់ដំណើរសេចក្ដី) ។ វិធីរូបសិទ្ធិសម្រាប់តវេ-បច្ច័យ ដូចមានរបៀបខាងក្រោយនេះ ៖

១- ធាតុដែលមាន "ម" ជាទីបំផុត, ត្រូវផ្លាស់ទីបំផុតធាតុជា "ន" ឧ. គន្តវេ "ដើម្បីទៅ, ដើម្បីដល់", សន្តវេ "ដើម្បីរម្ងាប់..." (ផ្លាស់ ម ទីបំផុតនៃ គម-ធាតុ, នៃ សម-ធាតុ ជា "ន", ផ្សំនឹង តវេ ជា គន្តវេ, សន្តវេ) ។

២-ធាតុដែលមាន "ទ" ជាទីបំផុត, ត្រូវផ្លាស់ទីបំផុតធាតុជា "ត" ឧ. បត្តវេ "ដើម្បីដល់" (ផ្លាស់ ទ ទីបំផុតនៃ បទ-ធាតុជា "ត", ផ្សំនឹង តវេ ជា បត្តវេ) ។

---

១ តវេ-បច្ច័យនេះ សមតែរាប់បញ្ចូលក្នុងពួកកិតកិច្ច-បច្ច័យខាងកិរិយាកិតកៈឯនោះសោះទេ (ទាំងតុំ-បច្ច័យក៏ដូចគ្នាដែរ) ព្រោះជាបច្ច័យសម្រាប់គ្រាន់តែចុះរាំងមុខធាតុ មានលំនាំជាកិរិយាសព្ទ, ប៉ុន្តែបានជាយកមករៀបរៀងយ៉ាងនេះ ដើម្បីកុំឲ្យអស់លោកវេយ្យាករណបណ្ឌិតនិន្ទាបន្ទោសថា ខ្ញុំរៀបរៀងបច្ច័យមិនត្រូវតាមសណ្ដាប់ដែលធ្លាប់ចំណាំមកហើយនោះ ប៉ុណ្ណោះឯង (មើលក្នុងនាមនិទ្ទេស លេខ ១២៧ ត្រង់ពួកទី ៤) ។ម្យ៉ាងទៀត បច្ច័យនេះចុះបានចំពោះតែអំពីមុខធាតុដែលគួរប្រកបប៉ុណ្ណោះ, មិនមែនចុះបានរាល់ធាតុដូចតុំ-បច្ច័យទេ ។

៣- ធាតុដែលមាន "ន" ជាទីបំផុត, គ្រាន់តែផ្សំជាមួយនឹង តវេ ជាការស្រេច[១] ឧ. ហន្តវេ "ដើម្បីបៀតបៀន,...", ខន្តវេ "ដើម្បីជីក" ផ្សំ ហន-ធាតុ, ខន-ធាតុ ជាមួយនឹង តវេ ជា ហន្តវេ, ខន្តវេ) ។

៤- ចំពោះតែ ករ-ធាតុ មួយ, ឲ្យផ្លាស់ ករ ទាំងមូលជា "កា" ឧ. កាតវេ "ដើម្បីធ្វើ" ។

៥- ព្រឹទ្ធិធាតុដែលជាទីឃៈស្រាប់ក៏បានខ្លះ ឧ. នេតវេ "ដើម្បីនាំទៅ" (ព្រឹទ្ធិ ឦ របស់ នី-ធាតុ ជា ឯ, ផ្សំនឹង តវេ ជា នេតវេ) ។

៦- ធាតុទោលតែមួយតួ, ជាទីឃៈ គ្រាន់តែផ្សំធាតុជាមួយនឹង តវេ ជាការស្រេច ឧ. ញាតវេ "ដើម្បីដឹង" (ញា-

---

១ ព្រោះ "ន" ជាវគ្គន្តព្យញ្ជនៈរបស់ តវគ្គ ស្រាប់ហើយ មិនបាច់ផ្លាស់ "ន" ជា "ន" ដដែលៗនោះឡើយ, ប៉ុន្តែមានន័យខ្លះថា បើទុកយ៉ាងហ្នឹងក៏ដោយ, ត្រូវតែផ្លាស់ "ន" ទីបំផុតធាតុជា "ន" ឲ្យជាលំនាំនៃរូបសិទ្ធិ, ដូចជាក្នុងពួកសំខ្យាសព្ទ មានបង្គាប់ឲ្យផ្លាស់ "អ" របស់សព្ទមាន បញ្ច ជាដើមធ្វើជា "អ" ដូច្នោះដែរ, ព្រោះហេតុនោះ, បែបទាំង ២ យ៉ាងនេះ អ្នករៀនចូរប្រើតាមពេញចិត្តចុះ ។

ធាតុ), ទាតវេ "ដើម្បីឲ្យ" (ទា-ធាតុ), បាតវេ "ដើម្បីផឹក, ដើម្បីរក្សា" (បា-ធាតុ), បហាតវេ "ដើម្បីលះបង់" (ប-បុព្វបទ, ហា-ធាតុ) ។

តុំ : បច្ច័យនេះ ក៏ជាអព្យយបច្ច័យ, ជាពួកជាមួយគ្នានឹង តវេ, មានអាការប្រហែលគ្នានឹង តវេ ដែរ, ប្លែកគ្នាខ្លះតែ តុំ-បច្ច័យនេះ មានសណ្ដាប់ឲ្យប្រែចេញសម្ដីអាយតនិបាតដូចចតុត្ថី-វិភត្តិនាមថា "ដើម្បី-" ឬគ្រាន់តែប្រែចេញសព្ទធាតុតែម្ដង មិនបាច់ថា "ដើម្បី-" (ដូចតវេ-បច្ច័យដែរ) ក៏បាន, ប្រើជាបទប្រធានដូចនាមសព្ទដែលប្រកបបឋមាវិភត្តិ ប្រែថា "វីកិរិយា, វីគឺ-" ដូច្នេះក៏បាន[១] ។ រូបសិទ្ធិសម្រាប់តុំ-បច្ច័យនេះ មានគតិផ្សេង ៗ ច្រើនយ៉ាងណាស់, របៀបដូចមានខាងក្រោយនេះ ជាសង្ខេបៈ

---

១ តុំ-បច្ច័យនេះ មានគតិម្យ៉ាងទៀតប្លែកអំពី តវេ, ប្លែកដូច្នេះ : កាលបើចុះអំពីមុខធាតុហើយ, អាចប្រើជាសទ្ទុបបទ រួមភ្ជាប់ជាមួយនឹង កាម-សព្ទ "ប្រាថ្នា, ចង់" នេះផងក៏បាន, តែត្រូវលុបនិគ្គហិតរបស់ តុំ ចេញ ឧ. កត្តុកាមោ "អ្នកប្រាថ្នាដើម្បីធ្វើ" ឬ "អ្នកចង់ធ្វើ" ។ សព្ទយ៉ាងនេះ រមែងតែមាននាមសព្ទជាតួកម្ម បទវាយ នៅខាងដើម, ត្រូវប្រែរូប (សម្ពន្ធចូលនឹងសព្ទដែលចុះតុំ-បច្ច័យ) ឧ. នគរំ-បវិសិតុកាមោ "អ្នកប្រាថ្នាដើម្បីចូលទៅ កាន់ក្រុង" ឬ "អ្នកចង់ចូលទៅ កាន់ក្រុង", សត្ថារំ-ទុដ្ឋុកាមោ "អ្នកប្រាថ្នាដើម្បីឃើញ នូវព្រះសាស្ដា" ឬ "អ្នកចង់ឃើញ នូវព្រះសាស្ដា"... ។

១- ធាតុដែលមាន ច, ជ, ទ, ប ជាទីបំផុត, អាចផ្លាស់ទីបំផុតធាតុជា "ត" ក៏បានខ្លះ, របៀបរូបសិទ្ធិដូច្នេះ : ធាតុមាន "ច" ជាទីបំផុត ឧ. សិត្តុំ "ដើម្បីស្រោច, រីកិរិយាស្រោច[១]" (ផ្លាស់ ច ទីបំផុតនៃ សិច-ធាតុ ជា "ត", ផ្សំនឹងតុំជា សិត្តុំ) ។ ធាតុមាន "ជ" ជាទីបំផុត ឧ. ចត្តុំ "ដើម្បីលះ, ដើម្បីលះបង់" (ផ្លាស់ ជ ទីបំផុតនៃ ចជ-ធាតុជា "ត", ផ្សំនឹងតុំ ជា ចត្តុំ) ។ ធាតុមាន "ទ" ជាទីបំផុត ឧ. វត្តុំ "ដើម្បីពោល" (ផ្លាស់ ទ ទីបំផុតនៃ វទ-ធាតុ ជា "ត" ផ្សំនឹង តុំ ជា វត្តុំ) ។ ធាតុមាន "ប" ជាទីបំផុត ឧ. តត្តុំ "ដើម្បីដុត, ដើម្បីអាំង,..." (ផ្លាស់ ប ទីបំផុតនៃ តប-ធាតុ ជា "ត", ផ្សំនឹង តុំ ជា តត្តុំ) ។

២- ចំពោះតែ ករ-ធាតុមួយ, ផ្លាស់ រ ទីបំផុតធាតុជា "ត" ក៏បាន ឧ. កត្តុំ "ដើម្បីធ្វើ", ផ្លាស់ករ-ធាតុទាំងមូលជា "កា" ក៏បាន ឧ. កាតុំ "ដើម្បីធ្វើ" ។

---

១ បែបប្រែថា "រីកិរិយា-" នេះ, ឧទាហរណ៍ដែលចុះតុំ-បច្ច័យទាំងប៉ុន្មាន ក៏មានដំណើរដូចគ្នា ព្រោះហេតុនេះ, ក្នុងឧទាហរណ៍ឯទៀត អ្នករៀនចូរប្រែផងចុះ ។

៣- ធាតុមានអក្សរ ២ តួ, បើមិនផ្លាស់ទីបំផុតធាតុ ឬ មិនផ្លាស់ធាតុទាំងមូល ជាព្យញ្ជនៈផ្សេងទេ, ត្រូវបុះឥ-អាគមមក ឧ. សិញ្ចិតុំ "ដើម្បីស្រោច" (សិច-ធាតុ, បុះនិគ្គហិតអាគមលើ សិ ជា សឹ ហើយផ្លាស់និគ្គហិតជា "ញ" (តាមវិធីរបស់ពួក រុធ-ធាតុ), បុះឥ-អាគម, ផ្សំនឹង តុំ ជា សិញ្ចិតុំ, អវ-បុព្វបទ ផ្លាស់ អវ ជា ឱ. ជា ឱសិញ្ចិតុំ) ។ ចជិតុំ "ដើម្បីលះ, ដើម្បីលះបង់" (ចជ-ធាតុ, បុះឥ-អាគម, ផ្សំនឹង តុំ ជា ចជិតុំ, បរិ-បុព្វបទ ជា បរិច្ចជិតុំ) ។ វទិតុំ "ដើម្បីពោល" (វទ-ធាតុ, បុះឥ-អាគម, ផ្សំនឹងតុំ ជា វទិតុំ, អវ-បុព្វបទ ផ្លាស់ អវ ជា ឱ. ជា ឱវទិតុំ "ដើម្បីទូន្មាន") ។ សរិតុំ "ដើម្បីរឭក" (សរ-ធាតុ, បុះឥ-អាគម, ផ្សំនឹង តុំ ជា សរិតុំ) ។ ធាតុមានអក្សរច្រើន ក៏អាចបុះឥ-អាគម បានដែរ ឧ. គរហិតុំ "ដើម្បីតិះដៀល" (គរហ-ធាតុ, បុះឥ-អាគម, ផ្សំនឹង តុំ ជា គរហិតុំ, វិ-បុព្វបទ, ជា វិគរហិតុំ) ។

៤- សូម្បីធាតុទោលតែមួយតួ, កាលបើព្រឹទ្ធិ ឬ អព្ភាសៈ ឲ្យកើតជា ២ តួហើយ, ក៏ត្រូវបុះ ឥ-អាគមមក ឧ. ភវិតុំ "ដើម្បី កើត,..." ព្រឹទ្ធិ ឩ របស់ ភូ-ធាតុ ជា ឱ ហើយផ្លាស់ ឱ

ជា អវ, ចុះ ឥ-អាគម, ផ្សំនឹង តុំ ជា ភវិតុំ) ។ នយិតុំ "ដើម្បីនាំ" (ព្រឹទ្ធិ ឦ របស់ នី-ធាតុ ជា ឯ ហើយផ្លាស់ ឯ ជា អយ, ចុះ ឥ-អាគម, ផ្សំនឹង តុំ ជា នយិតុំ) ។ បជហិតុំ "ដើម្បីលះ, ដើម្បីលះបង់" (ប-បុព្វបទ, ហា-ធាតុ, អព្ភាសៈជា ប-ហា-ហា, ផ្លាស់ ហ-អព្ភាសៈជា ជ, រស្សៈ អា របស់អព្ភាសៈជា អ, ចុះឥ-អាគម, លុប អា របស់ ហា-ធាតុ, ផ្សំនឹង តុំ ជា បជហិតុំ) ។

៥- ធាតុទោលតែមួយតួ, បើជារស្សៈ, ព្រឹទ្ធិតាមដំណើររបស់ស្រៈក៏បាន ឧ. សោតុំ "ដើម្បីឮ, ដើម្បីស្តាប់" (ព្រឹទ្ធិ ឧ របស់ សុ-ធាតុ ជា ឱ...) ។ ជេតុំ "ដើម្បីឈ្នះ,..." (ព្រឹទ្ធិ ឥ របស់ ជិ-ធាតុ ជា ឯ,...) ។ សូម្បីធាតុជាទីឃៈ ក៏ព្រឹទ្ធិបានខ្លះដែរ ឧ. នេតុំ "ដើម្បីនាំ" ព្រឹទ្ធិ ឦ របស់ នី-ធាតុ ជា ឯ ផ្សំនឹង តុំ ជា នេតុំ) ។

៦- ធាតុទោលតែមួយតួ ជារស្សៈក្តី, ជាទីឃៈក្តី, បើមិនព្រឹទ្ធិទេ, ត្រូវចុះបច្ច័យអាខ្យាត (សម្រាប់ពួកធាតុ) មកផង, ចុះ ឥ-អាគមផង ឧ. សុណិតុំ "ដើម្បីឮ,..." (សុ-ធាតុ ណា-បច្ច័យ (អាខ្យាត), ចុះឥ-អាគម, លុប អា របស់ ណា, ផ្សំនឹង

តុំ ជា សុណិតុំ) ។ ជិនិតុំ "ដើម្បីឈ្នះ,..." (ជិ-ធាតុ, នា-បច្ច័យ (អាខ្យាត), ចុះឥ-អាគម, លុប អា របស់ នា, ផ្សំនឹង តុំ ជា ជិនិ-តុំ) ។ ជានិតុំ "ដើម្បីដឹង" (ញា-ធាតុ, នា-បច្ច័យ (អាខ្យាត), ផ្លាស់ ញា ជា "ជា", ចុះឥ-អាគម, លុប អា របស់ នា, ផ្សំនឹង តុំ ជា ជានិតុំ) ។ ក្រៅពីធាតុទោល ក៏ត្រូវចុះបច្ច័យអាខ្យាតព្រម ទាំងឥ-អាគមមកផងដែរ, ឧ. ពុជ្ឈិតុំ "ដើម្បីដឹង", យុជ្ឈិតុំ "ដើម្បី ច្បាំង" ផ្លាស់ យ-បច្ច័យ និង ធ ទីបំផុតនៃ ពុធ-ធាតុ, នៃ យុធ-ធាតុ ជា ជ្ឈ, ចុះឥ-អាគម, ផ្សំជា ពុជ្ឈិតុំ, យុជ្ឈិតុំ) ។

៧- ចំពោះ គហ-ធាតុ, គ្រាន់តែចុះឥ-អាគមក៏បាន, ចុះ ណ្ហា-បច្ច័យ (អាខ្យាត) មកហើយលុបទីបំផុតធាតុចេញ, ចុះឥ-អាគម, លុប អា របស់ ណ្ហា-បច្ច័យចេញក៏បាន ឧ. គហិតុំ, គណ្ហិតុំ "ដើម្បីកាន់, យក, ទទួល, ចាប់,..." ។

៨- ធាតុដែលមាន ធ, ភ, ម, ស ជាទីបំផុត, អាចផ្លាស់ តុំ-បច្ច័យជាព្យញ្ជនៈផ្សេង ហើយលុបទីបំផុតធាតុចេញក៏បានខ្លះ, ដូចរបៀបតទៅនេះ : *ក)* ធាតុ មាន "ធ" ឬ "ភ" ជាទីបំផុត,

ឲ្យផ្លាស់ តុំ ជា ទ្នុំ ឧ. សុពោទ្នុំ "ដើម្បីដឹងដោយងាយ" (សុ-បុព្វ-បទ, ពុធ-ធាតុ, ផ្លាស់ តុំ ជា ទ្នុំ, លុបទីបំផុតធាតុ, ព្រឹទ្ធិ ឧ របស់ ពុ ជា ឱ[១], ផ្សំជា សុពោទ្នុំ) ។ លទ្នុំ "ដើម្បីបាន" (ផ្លាស់ តុំ ជា ទ្នុំ[២], លុប ភ ទីបំផុតនៃ លភ-ធាតុ, ផ្សំជា លទ្នុំ) ។ ខ) ធាតុមាន "ម" ជាទីបំផុត ឲ្យផ្លាស់ តុំ ជា ន្តុំ[៣] ឧ. គន្តុំ "ដើម្បីទៅ, ដើម្បីដល់", សន្តុំ "ដើម្បីរម្ងាប់..." (ផ្លាស់ តុំ ជា ន្តុំ, លុប ម ទីបំផុតនៃ គម-ធាតុ, នៃ សម-ធាតុ, ផ្សំជា គន្តុំ, ជា សន្តុំ) ។ គ) ធាតុមាន "ស" ជាទីបំផុត, ឲ្យផ្លាស់ តុំ ជា រដ្ឋុំ ឧ. ទដ្ឋុំ "ដើម្បីឃើញ, ដើម្បីជួប" (ផ្លាស់ តុំ ជា រដ្ឋុំ ហើយលុប រ ទុកតែ ដ្ឋុំ[៤], លុប ស ទីបំផុតនៃ ទិស-ធាតុ, ផ្លាស់ ឥ របស់ ទិ ជា អ, ផ្សំជា ទដ្ឋុំ) ។

---

១ មិនបាច់ព្រឹទ្ធិ ប្រើជា សុពុទ្នុំ ក៏បាន ។ ២ វិធីផ្លាស់យ៉ាងនេះ គឺផ្លាស់បានតាមគួរដល់ការប្រកប, នឹងកំណត់ឲ្យទៀងទាត់តែបែបមួយនោះក៏មិនមែនទេ ដូចជា អា-បុព្វបទ, រភ-ធាតុ "ប្រារព្ធ, ផ្ដើម, តាំងផ្ដើម, ចំពោះ" នេះបើផ្លាស់ តុំ ជា ទ្នុំ ឲ្យជា "អារទ្នុំ" ដូច្នេះក៏បាន ប៉ុន្តែមិនសូវប្រើឲ្យប្រើជា "អារភិតុំ" ដូច្នេះវិញ (ចុះឥ-អាគម) ។ ៣ បើមិនផ្លាស់យ៉ាងនេះ, នឹងផ្លាស់ "ម" ជា "ន" ផ្សំនឹង តុំ ជា "ន្តុំ" ក៏សឹងតែបាន ។ ៤ ផ្លាស់ តុំ ជា ដ្ឋុំ តែម្ដង តាមបែបក្រៅពីកច្ចាយនៈ ក៏បាន ។

៩- ធាតុទោលតែមួយតួ, បើជាទីយៈ, ច្រើនតែទុកឲ្យគង់រូបនៅដូចដើម[១] ឧ. ទាតុំ "ដើម្បីឲ្យ", ញាតុំ "ដើម្បីដឹង", បាតុំ "ដើម្បីផឹក, ដើម្បីរក្សា", ឋាតុំ "ដើម្បីឋិតនៅ,..." (គ្រាន់តែផ្សំ ទា-ធាតុ, ញា-ធាតុ, បា-ធាតុ, ឋា-ធាតុ ជាមួយនឹង តុំ ជាការស្រេច) ។

១០- ធាតុដែលមាន "ន" ជាទីបំផុត, បើមិនចុះ ឥ-អាគមទេ, ត្រូវផ្សំទីបំផុតធាតុជាមួយនឹង តុំ ជា "ន្តុំ[២]" ឧ. ហន្តុំ "ដើម្បីបៀតបៀន,..." (ហន-ធាតុ) ។ តន្តុំ "ដើម្បីលាត, លា, -ត្រដាង" (តន-ធាតុ) ។

១១- តុំ-បច្ច័យនេះ បើចុះក្នុងហេតុកត្តុវាចកៈ, ត្រូវចុះការិតបច្ច័យ (អាខ្យាត) ផង ជាកំណត់ ឧ. លាភេតុំ "ដើម្បីឲ្យបាន" (លភ-ធាតុ, ណេ-បច្ច័យ, តុំ-បច្ច័យ) ។ រុន្ធាបេតុំ "ដើម្បីឲ្យ

---

១ បណ្ដាធាតុទោលជាទីយៈនោះ ធាតុខ្លះត្រូវទុកឲ្យគង់រូបនៅដូចដើមជាដាច់ខាត, ដូចជា ទា-ធាតុ ជា ទាតុំ, ឋា-ធាតុជា ឋាតុំ, ធាតុខ្លះអាចផ្លាស់ជារូបផ្សេងក៏បាន, ដូចជា ញា-ធាតុជា "ញាតុំ" ក៏បាន, ផ្លាស់ ញា ជា "ជា", ចុះឥ-អាគម, លុប អា របស់ នា-បច្ច័យ, ផ្សំជា ជានិតុំ ក៏បាន បាធាតុ ជា បាតុំ ក៏បាន ផ្លាស់ បា ជា បិវ ចុះឥ-អាគម ផ្សំជា "បិវិតុំ" ក៏បាន ។ ២ ចូរមើលនយលក្ខណៈរបស់ តវេ-បច្ច័យ (ត្រង់ លេខ ៣) ។

បិទ, -ឲ្យរាំង,...″ (រុធ-ធាតុ, និគ្គហិតអាគម ផ្លាស់ជា "ន″, ណាបេ-បច្ច័យ, តុំ-បច្ច័យ) ។ សិញ្ចាបេតុំ "ដើម្បីឲ្យដេរ″ (សិវ-ធាតុ, យ-បច្ច័យ, ណាបេ-បច្ច័យ, តុំ-បច្ច័យ) ។ សាវេតុំ "ដើម្បីឲ្យឮ, -ឲ្យស្តាប់″ (សុ-ធាតុ, ណេ-បច្ច័យ, តុំ-បច្ច័យ) ។ កីនាបេតុំ "ដើម្បីឲ្យទិញ″ (កី-ធាតុ, នា-បច្ច័យ, ណាបេ-បច្ច័យ, តុំ-បច្ច័យ) ។ គាហាបេតុំ "ដើម្បីឲ្យកាន់, -ឲ្យទទួល,...″ (គហ-ធាតុ, ណាបេ-បច្ច័យ, តុំ-បច្ច័យ), ឧគ្គណ្ហាបេតុំ "ដើម្បីឲ្យរៀន″ (ឧ-បុព្វបទ, គហ-ធាតុ, ណ្ហា-បច្ច័យ, ណាបេ-បច្ច័យ, តុំ-បច្ច័យ) ។ ការេតុំ "ដើម្បីឲ្យធ្វើ″ (ករ-ធាតុ, ណេ-បច្ច័យ, តុំ-បច្ច័យ) ។ ចោរេតុំ "ដើម្បីឲ្យលួច″ (ចុរ-ធាតុ, ណេ-បច្ច័យ[១] តុំ-បច្ច័យ) ។

រត្ថុ : បច្ច័យនេះ កាលបើចុះមកហើយ ត្រូវលុប រ ចេញ ទុកតែ ត្ថុ, ទាំងទីបំផុតធាតុក៏ត្រូវលុបចេញ ឧ. សាសតី´តី > សត្ថា[២] (ជនោ) "(ជន) អ្នកប្រៀនប្រដៅ = គ្រូប្រៀនប្រដៅ″ ក. ក. (លុប ស ទីបំផុតនៃ សាស-ធាតុ ទុកតែ សា ហើយ

១ ឧទាហរណ៍ទាំងនេះ មានរូបសិទ្ធិតាមវិធីក្នុងអាខ្យាតនិទ្ទេស ។

២ សព្ទនេះ, ខាងព្រះពុទ្ធសាសនា, ជាព្រះនាមវិសេសម្យ៉ាងរបស់ព្រះសម្មាសម្ពុទ្ធ, ត្រូវបញ្ចូលសព្ទថា "ភគវា″ ជាអញ្ញបទរបស់ សាធនៈ ។

រស្សៈ អា របស់ សា ជា អ, លុប រ ទុកតែ ត្ថុ, ផ្សំជា សត្ថុ, ផ្លាស់ ឧ និង សិ-វិភត្តិជា អា ជា សត្ថា[១]) ។ (មើលក្នុងនាម-និទ្ទេស ត្រង់លេខ ៨៣) ។

រិតុ : បច្ច័យនេះ ក៏ត្រូវលុប រ ដែរ ទុកតែត្រឹម ឥតុ, ទាំងទីបំផុតធាតុក៏ត្រូវលុបចេញ ឧ. (បុត្តំ) -បាលេតី'តី > បិតា (បុរិសោ) "(បុរស) អ្នករក្សា (នូវកូន)" ក. ក. (លុប ល ទីបំផុតនៃ បាល-ធាតុ ទុកតែ បា[២] ហើយលុប អា របស់ បា, លុប រ ទុកតែ ឥតុ, ផ្សំជា បិតុ, ផ្លាស់ ឧ និង សិ-វិភត្តិជា អា ជា បិតា) ។ មាតាបិតូហិ-ធារិយតេ'តិ > ធីតា (ឥត្ថី) "(ស្ត្រី) ដែលមាតានិង បិតាទ្រទ្រង់ = កូនស្រី" កម្ម. កម្ម. (លុប រ ទីបំផុតនៃ ធរ-ធាតុ, លុប រ របស់ រិតុ ទុកតែត្រឹម ឥតុ ហើយទីឃៈ ឥ ជា ឦ-ផ្សំជា ធីតុ, ផ្លាស់ ឧ និង សិ-វិភត្តិជា អា ជា ធីតា) ។ (មើលក្នុង នាមនិទ្ទេស ត្រង់លេខ ៨៤ និង ៨៥) ។

---

១ រត្ថុ-បច្ច័យនេះ ឃើញមានចុះចំពោះតែអំពីមុខ សាស-ធាតុ មួយប៉ុណ្ណោះ, តែក្នុងកច្ចាយនបករណ៍ ប្រាប់អាទិសព្ទដោយមេសូត្រថា "សាសាទីហិរត្ថុ", អាងឧទាហរណ៍ចំពោះតែសត្ថាមួយប៉ុណ្ណោះ ។ ២ តាំង បា-ធាតុ វិគ្គហៈ ថា : (បុត្តំ)-បាតី'តិ > បិតា ដូច្នេះក៏បាន, បើធាតុទោលយ៉ាងនេះគ្រាន់តែលុប អា របស់ បា, ផ្សំនឹង ឥតុ ជា បិតុ ។

រាតុ : បច្ច័យនេះ ក៏ដែរ, ជារានុពន្ធបច្ច័យ, ត្រូវលុប រ ទុកតែត្រឹម អាតុ, ទាំងទីបំផុតធាតុក៏ត្រូវលុបចេញ ឧ. (បុត្តំ), មានេតី់តិ > មាតា (ឥត្ថី" "(ស្ត្រី) អ្នករាប់អាន (នូវកូន)" ក. ក. (លុប ន ទីបំផុតនៃ មាន-ធាតុ ទុកតែ មា ហើយលុប អា របស់ មា, លុប រ ទុកតែ អាតុ, ផ្សំជា មាតុ, ផ្លាស់ ឧ និងសិ-វិភត្តិជា អា, ផ្សំជា មាតា) ។ (បុព្វេ)-ភាសតី់តិ > ភាតា (បុរិសោ) "(បុរស) អ្នកស្តី (ក្នុងកាលមុន) = ប្រុសដែលចេះស្តីមុនប្អូន គឺបងប្រុស" ក. ក., (បច្ឆា)-ភាសតី់តិ-វា > ភាតា (បុរិសោ) "ម្យ៉ាងទៀតថា (បុរស) អ្នកស្តី (ក្នុងកាលជាខាងក្រោយ)= ប្រុសដែលចេះស្តីក្រោយបង គឺប្អូនប្រុស" ក. ក. (លុប ស ទីបំផុតនៃ ភាស-ធាតុ, លុប រ ទុកតែ អាតុ, ផ្សំជា ភាតុ, ផ្លាស់ ឧ និងសិ-វិភត្តិជា អា ជា ភាតា) ។ (មើលក្នុងនាមនិទ្ទេស ត្រង់លេខ ៨៤ និង ៨៥) ។

## កិរិយាកិតកៈ

[១៧៤] កិតកៈដែលជាកិរិយាសព្ទ ហៅថា កិរិយាកិតកៈ ឬ កិតកិរិយា ឬហៅថា កិតបទ ក៏បាន ។ កិរិយាកិតកៈនេះ

ក៏ត្រូវប្រើប្រកបនឹង វិភត្តិ, វចនៈ, កាល, ធាតុ, វាចកៈ, បច្ច័យ ដូចអាខ្យាតដែរ ផ្សេងគ្នាអំពីអាខ្យាតតែមិនមាន បទ និង បុរិសៈ ប៉ុណ្ណោះ(១) ។

## វិភត្តិ និង វចនៈ

[១៧៥] វិភត្តិនៃកិរិយាកិតកៈនោះ មិនដូចវិភត្តិអាខ្យាតទេ ពីព្រោះប្រើប្រកបនឹងវិភត្តិនាម, បើនាមសព្ទប្រកបនឹងវិភត្តិណា វចនៈណា, កិរិយាតិតកៈក៏ត្រូវប្រកបនឹងវិភត្តិនោះ វចនៈនោះតាម (ទាំងលិង្គក៏ត្រូវប្រកបឲ្យស្មើគ្នា) ឧ. ភិក្ខុ អរញ្ញំ បវិដ្ឋោ "ភិក្ខុ ចូលទៅហើយ កាន់ព្រៃ" (ប. ឯក.), ភិក្ខូ អរញ្ញំ បវិដ្ឋា "ភិក្ខុទាំងឡាយ ចូលទៅហើយ កាន់ព្រៃ" (ប. ពហុ.), អរញ្ញំ បវិដ្ឋេ ភិក្ខូ អទ្ទសំ "(ខ្ញុំ) បានឃើញហើយ នូវភិក្ខុទាំងឡាយ ចូលទៅហើយ កាន់ព្រៃ" (ទុ. ពហុ.),... ... ។ មគ្គេន គច្ឆន្តំ ឯកំ បុរិសំ បស្សាមិ "(ខ្ញុំ) ឃើញ នូវបុរស ម្នាក់ កំពុងដើរ តាមផ្លូវ" (ទុ. ឯក.), មគ្គេន គច្ឆន្តេ បុរិសេ បស្សាមិ "(ខ្ញុំ) ឃើញ នូវបុរសទាំងឡាយ កំពុងដើរ តាមផ្លូវ" (ទុ. ពហុ.,....) ។

---

១ កិរិយាកិតកៈនេះ មិនបាច់តាំងវិគ្គហៈ ដូចនាមកិតកៈទេ (ដូចអាខ្យាតដែរ) ។

## កាល

[១៧៦] កាល ក្នុងកិតកៈមាន ៣ យ៉ាង គឺ បច្ចុប្បន្នកាល ១ អតីតកាល ២ អនាគតកាល[១] ១, រាប់អនុត្តកាល ១ បញ្ចូលមកផង ជា ៤ យ៉ាង (ដូចអាខ្យាតដែរ[២], ប៉ុន្តែអនាគតកាលមិនសូវប្រើ[៣], ព្រោះហេតុនោះ, ក្នុងទីនេះ, មិនបាច់និយាយអំពីអនាគតកាលនោះទេ ។ កាលទាំងនុ៎ះ មានបច្ច័យនៃកិរិយាកិតកៈ ជាគ្រឿងសម្គាល់, បច្ច័យនោះនឹងមាននិយាយទៅក្នុងខាងមុខ តាំងពីត្រង់លេខ ១៧៨ រៀងដល់លេខ ១៨១ ។

បច្ចុប្បន្នកាលចែកចេញជា ២ យ៉ាង គឺ បច្ចុប្បន្នសុទ្ធ ១ បច្ចុប្បន្នជិតអនាគត ១ ។ បច្ចុប្បន្នសុទ្ធ ឲ្យប្រែថា "កំពុង, កំពុងតែ-" ឬមិនប្រែយ៉ាងនេះ, គ្រាន់តែប្រែចេញសព្ទធាតុ

---

១ ខាងនាមកិតកៈ មានបច្ច័យខ្លះប្រព្រឹត្តទៅបានគ្រប់កាលទាំង ៣ នេះ, ដូចយ៉ាងណា-បច្ច័យជាដើម ឧ. កម្មំ-ករោតី'តិ > កម្មការោ, កម្មំ-អករី'តិ > កម្មការោ, កម្មំ-ករិស្សតី'តិ > កម្មការោ (ជនោ), បច្ច័យយ៉ាងនេះ ហៅថា តេកាលិកបច្ច័យ "បច្ច័យប្រព្រឹត្តទៅក្នុងត្រៃកាល គឺ ចុះបានក្នុងកាលទាំង ៣" (ចូរមើលមេសូត្រ ណាទយោ តេកាលិកា) ។ ២ ចូរមើលក្នុងអាខ្យាតនិទ្ទេស ត្រង់លេខ ១៦០ ។ ៣ អនាគតកាលខាងកិរិយាកិតកៈមានប្រើខ្លះ តែសព្ទដែលចុះ ត-បច្ច័យប៉ុណ្ណោះ (យូរៗ មានប្រទះខ្លះ) ។

ប៉ុណ្ណោះក៏បាន (តាមគួរដល់ដំណើរសេចក្ដី) ឧ. ឧបាសកោ ធម្មំ សុណន្តោ សទ្ធំ ជនេតិ "ឧបាសក កំពុងស្ដាប់ នូវធម៌ ញុំាង សទ្ធា ឲ្យកើត" ។ បច្ចុប្បន្នជិតអនាគត ឲ្យប្រែថា "កាល-, កាលនឹង-" ឧ. ពុទ្ធា ច នាម ធម្មំ ទេសេន្តា សត្តានំ ឧបនិស្ស-យំ វោលោកេត្វា ទេសេន្តិ "ធម្មតា ព្រះពុទ្ធទាំងឡាយ កាល សម្ដែង[១] នូវធម៌ (តែងតែ)-ប្រមើលមើល-នូវឧបនិស្ស័យ-នៃ សត្វទាំងឡាយ-រួចហើយ-ទើបសម្ដែង" ។

អតីតកាលចែកចេញជា ២ យ៉ាង គឺ អតីតកាលគ្រាន់តែ ប្រាប់ថាកន្លងហើយ ១ អតីតកាលកន្លងស្រេចហើយ ១ ។ អតីត-កាលគ្រាន់តែប្រាប់ថាកន្លងហើយ ឲ្យប្រែថា "-ហើយ" ឬថា "-រួចហើយ" ក៏បានខ្លះ ឧ. តយោ មាសា អតិក្កន្តា "ខែទាំង ឡាយ បី កន្លងហើយ", សោ ភត្តំ គណ្ហិត្វា ភុញ្ជិ "គាត់ ទទួល-នូវភត្ត-ហើយ បរិភោគហើយ" ។ អតីតកាលកន្លងស្រេចហើយ ឲ្យប្រែថា "លុះ-ហើយ" ឬថា "លុះរួចហើយ" ក៏បានខ្លះ ឧ. អយំ

---

១ ប្រែថា "កាលនឹងសម្ដែង" ក៏សមសេចក្ដីណាស់ ។

កុលបុត្តោ មំ ទិស្វា[១] មម សង្គហំ ករិស្សតិ, កត្វា[២]ច បន[៣] មហាសម្បត្តឹ លភិស្សតិ "កុលបុត្រ នេះ ឃើញ-នូវអញ-ហើយ នឹងធ្វើ នូវសេចក្ដីសង្គ្រោះ ដល់អញ, ក៏ លុះធ្វើរួចហើយ នឹង បាន នូវសម្បត្តិធំ" ។

អនុត្តកាល ក្នុងអាខ្យាតចែកចេញជា ៤ យ៉ាង[៤], ឯក្នុង កិតកៈនេះចែកចេញត្រឹមតែ ២ យ៉ាងគឺ អនុមតិ ១ បរិកប្បៈ ១ ។ អនុមតិ "ប្រាប់សេចក្ដីយល់ឃើញ" ឲ្យប្រែថា "គួរ-, គួរតែ-" ឧ. ន កេនចិ ពាលោ សេវិតព្វោ, បណ្ឌិតោ បន សេវិតព្វោ "បុគ្គលពាល គឺអ្នកណាមួយ មិនគួរសេពគប់ឡើយ, ឯបុគ្គលជា បណ្ឌិត (គឺជន) គួរសេពគប់" ។ បរិកប្បៈ "ប្រាប់សេចក្ដីកំណត់" ឲ្យប្រែថា "គប្បី-" ឬ "ត្រូវ-" ឧ. រាជកិច្ចំ តេ កត្តព្វំ "កិច្ចរបស់

១ ជាអតីតកាលគ្រាន់តែប្រាប់ថាកន្លងហើយ (ហៅថា បុព្វកាល) ។ ២ ជាអតីតកាលកន្លងស្រេចហើយ (ហៅថា បរិយោសានកាល), អតីតកាលនេះ ត្រូវប្រើបានតែធាតុដែលមានរបស់ជាមួយគ្នានឹង អាខ្យាតកិរិយាខាងដើមបន្ទាប់ខ្លួន, ដូចជាឧទាហរណ៍នេះ ករិស្សតិ (ករ-ធាតុ), កត្វា ក៏ជាករ-ធាតុដែរ ហើយត្រូវរៀងបានតែត្រង់កន្លែង បន្ទាប់អាខ្យាតកិរិយាយ៉ាងនេះ, ត្រូវប្រើដូច្នេះជាកំណត់ដោយដាច់ ខាត ។ ៣ ច បន នេះ មានក៏បាន ទេក៏បាន, ដែលដាក់យ៉ាងនេះ គ្រាន់តែជាប្រដាប់ពាក្យឲ្យស្រួលមាត់ប៉ុណ្ណោះ, ដែលមិនបាច់ដាក់ មកក៏បាននោះដូចជា... យេន ភគវា តេនុបសង្កមិ, ឧបសង្កមិត្វា...។ ៤ ចូរមើលក្នុងអាខ្យាតនិទ្ទេស លេខ ១៦០ ត្រង់និយាយពីអនុត្ត- កាល ។

ស្តេច គឺអ្នក គប្បីធ្វើ″,... សិក្ខា ករណីយា "ការសិក្សា (គឺបព្វ-ជិត) ត្រូវធ្វើ..." ។ "ប្រាប់សេចក្តីជញ្ជឹង, សេចក្តីត្រិះរិះ" ឲ្យប្រែថា "គប្បី-" ឬ "ត្រូវ-" ឧ. កិន្នុ ខោ បនេតំ មយា កាតព្វំ "ចុះ (កិច្ច) ហ្នឹង គឺអញ ត្រូវធ្វើ ដូចម្តេច ហ្ន៎?" ។

## ធាតុ និង វាចកៈ

[១៧៧] ធាតុ ដែលប្រើក្នុងកិតកៈនេះ ក៏ដូចគ្នានឹងអាខ្យាតដែរ, ផ្សេងគ្នាតែលំនាំរូបដែលសម្រេចហើយនោះប៉ុណ្ណោះ, បែបធៀបឲ្យឃើញដោយសង្ខេប ដូច្នេះ : លភ "បាន", (បច្ចុប្បន្ន-កាល) : អាខ្យាត : លភតិ, កិតកៈ បុំ. លភន្តោ, ឥ. លភន្តី, នបុំ. លភន្តំ ។ (អតីតកាល) : អាខ្យាត : លភិ ឬ អលភិ, កិតកៈ បុំ. លទ្ធោ, ឥ. លទ្ធា, នបុំ. លទ្ធំ, អព្យយកិរិយា : លភិត្វា, លភិត្វាន, លទ្ធាន ។ (អនុត្តកាល) : អាខ្យាត : លភេយ្យ កិតកៈ បុំ. លភិតព្វោ ឬ លទ្ធព្វោ, ឥ. លភិតព្វា ឬ លទ្ធព្វា, នបុំ. លភិតព្វំ ឬ លទ្ធព្វំ ។ ព្រោះហេតុនោះមិនបាច់និយាយអំពីធាតុក្នុងទីនេះទៀតទេ នឹងនិយាយស្រួតទៅវាចកៈតែម្តង ។

ក្នុងកិតកៈនេះក៏មាន វាចកៈ ៥ យ៉ាង ដូចក្នុងអាខ្យាតដែរ ប្លែកគ្នាតែលំនាំរូប ដូចនិយាយហើយខាងលើនោះប៉ុណ្ណោះ ។ នឹងនិយាយដោយសង្ខេប ដូចមានសេចក្ដីតទៅនេះ ៖

កត្តុវាចកៈ "ភិក្ខុ អរញ្ញំ បវិដ្ឋោ" ភិក្ខុ ចូលទៅហើយ កាន់ព្រៃ" ។ ទេវី បាសាទេ ឋិតា "នាងទេវី ឋិតនៅ ក្នុងប្រាសាទ" ។ អម្ពស្ស ផលានិ បតិតានិ "ផ្លែទាំងឡាយ នៃស្វាយ ជ្រុះហើយ" ។

កម្មវាចកៈ ភគវតា ទេសិតោ អយំ ធម្មោ "ធម៌ នេះដែលព្រះមានជោគ ត្រាស់សម្ដែងហើយ" ។ នេវ តិរច្ឆានកថា បព្វជិតេន វត្តព្វា "តិរច្ឆានកថា គឺបព្វជិត មិនត្រូវនិយាយឡើយ" ។ មយា កតំ បុញ្ញំ "បុណ្យ ដែលខ្ញុំ ធ្វើហើយ" ។

ភាវវាចកៈ ភរិយំ មេ និស្សាយ ភយេន ឧប្បន្នេន ភវិតព្វំ "គឺ ភ័យ កើតឡើង ព្រោះអាស្រ័យ នូវភរិយា នៃអញ គប្បីមាន[១] = ជាក់ជាភ័យ កើតមាន ព្រោះអាស្រ័យ នូវភរិយា របស់អញ" បាតោ វ តយា ឧដ្ឋាតព្វំ "គឺឯង ត្រូវក្រោកអំពីព្រលឹម" ។

---

១ បើត្រូវការប្រែរៀងជាសេចក្ដីឲ្យស្រួលស្ដាប់ មិនបាច់ដាក់ពាក្យ ថា "គប្បីមាន" នេះ មកទេ ត្រូវប្រែរួបភ្ជាប់តាំងពី មេ រហូតដល់ ភវិតព្វ ។

ហេតុកត្តុវាចកៈ អាចរិយោ អន្តេវាសិកេ វិនយំ សិក្ខាបេន្តោ "អាចារ្យ កំពុង - ញុំាងអន្តេវាសិកទាំងឡាយ - ឲ្យរៀននូវវិន័យ" ។ មាតា បុត្តំ នហាបេន្តី "ម្តាយ កំពុង - ញុំាងកូន - ឲ្យងូត" ។

ហេតុកម្មវាចកៈ វិនយោ អាចរិយេន អន្តេវាសិកេហិ[១] សិក្ខាបេតព្វោ "វិន័យ គឺអាចារ្យ គប្បី - ញុំាងអន្តេវាសិកទាំងឡាយ-ឲ្យរៀន" ។

## បច្ច័យនៃកិរិយាកិតកៈ

[១៧៨] បច្ច័យ សម្រាប់ចុះប្រកបនឹងកិរិយាកិតកៈនោះក៏ចែកជា ៣ ពួក[២] ដូចបច្ច័យនៃនាមកិតកៈដែរ ។ កិត-បច្ច័យមាន ៣ គឺ អន្ត, តវន្តុ, តាវី ។ កិច្ច-បច្ច័យមាន ២ គឺ តព្វ, អនីយ ។ កិតកិច្ច-បច្ច័យមាន ៥ គឺ មាន, ត, ត្វា, ត្វាន, តូន ។

---

១ ជា "អន្តេវាសិកេ" តាមធម្មតារបស់ ការិតកម្ម ក៏បាន ។ ២ កិត-បច្ច័យ សម្រាប់ចុះក្នុងកត្តុវាចកៈ និងហេតុកត្តុវាចកៈ, កិច្ច-បច្ច័យ សម្រាប់ចុះក្នុងកម្មវាចកៈ, ភាវវាចកៈ, និងហេតុកម្មវាចកៈ, កិតកិច្ច-បច្ច័យ សម្រាប់ចុះក្នុងវាចកៈបានគ្រប់ទាំង ៥ ។

រួមបច្ច័យទាំង ៣ ពួកជា ១០, បណ្ដាបច្ច័យទាំង ១០ នុ៎ះ, អន្ត, មាន ពីរនេះប្រាប់បច្ចុប្បន្នកាល, តព្វ, អនីយ ពីរនេះប្រាប់អនុត្តកាល, ត មួយនេះច្រើនតែប្រាប់អតីតកាលជាងបច្ចុប្បន្នកាល, ខាងអនាគតកាលក៏ប្រើបាន តែមានតិចណាស់, តវន្តុ, តាវី, ត្វា, ត្វាន, តូន ប្រាំនេះប្រាប់អតីតកាល ដោយច្រើនជាងកាលឯទៀត[១] ។

[១៧៩] ឧទាហរណ៍ក្នុងកិត-បច្ច័យ

អន្ត : បច្ច័យនេះ សម្រាប់ចុះបានតែក្នុងវាចកៈ ២ គឺ កត្តុវាចកៈ និងហេតុកត្តុវាចកៈប៉ុណ្ណោះ, កាលបើចុះមកហើយត្រូវចុះបច្ច័យសម្រាប់ពួកធាតុក្នុងអាខ្យាតមកផងក៏បាន មិនបាច់ចុះបច្ច័យអាខ្យាតក៏បាន, តែបើខាងហេតុកត្តុវាចកៈត្រូវតែចុះការិតបច្ច័យក្នុងអាខ្យាតមកផង ខានពុំបាន ។

កត្តុវាចកៈ កថេន្តោ "កំពុងពោល, កាលពោល" (កថធាតុ, អ-បច្ច័យ (អាខ្យាត), អន្ត-បច្ច័យ, ផ្លាស់ អ-បច្ច័យ

---

១ ចូលមើលទៅក្នុងខាងមុខ ត្រង់លេខ ១៨១ ។

ជា ឯ[១], លុប អ របស់ អន្ត ទុកតែ ន្ត, ផ្សំជា កថេន្ត ផ្លាស់សិ-វិភត្តិជា ឱ ជា កថេន្តោ, ឥ. ចុះ ឦ-បច្ច័យមកផង ជា កថេន្តី, នបុំ. កថេន្តំ[២]) ។ សុណន្តោ "កំពុងស្តាប់, កាលស្តាប់" (សុ-ធាតុ, ណា-បច្ច័យ, អន្ត-បច្ច័យ, លុប អា របស់ ណា-បច្ច័យ, ផ្សំជា សុណន្ត, ផ្លាស់សិ-វិភត្តិជា ឱ ជា សុណន្តោ, ឥ. សុណន្តី, នបុំ. សុណន្តំ) ។ ករោន្តោ "កំពុងធ្វើ, កាលធ្វើ, (ករ-ធាតុ, ឱ-បច្ច័យ (អាខ្យាត), អន្ត-បច្ច័យ, លុប អ របស់ អន្ត ទុកតែ ន្ត, ផ្សំជា ករោន្ត, ផ្លាស់សិ-វិភត្តិជា ឱ ជា ករោន្តោ, ឥ. ករោន្តី, នបុំ. ករោន្តំ) ។

ដែលមិនបាច់ចុះបច្ច័យអាខ្យាតនោះ ដូចជា : លភន្តោ "កំពុងបាន, កាលបាន" (លភ-ធាតុ, អន្ត-បច្ច័យ, គ្រាន់តែផ្សំ

---

១ ក្នុងបករណៈខ្លះថាចុះ ឯ-បច្ច័យ, ថាពួកភូ-ធាតុចុះបានបច្ច័យ ២ គឺ អ, ឯ ។ ២ បែបបំបែកផ្សំនឹងវិភត្តិនាម : បុំ. ដូច បុរិស ឬដូច ភវន្ត ក៏បាន ខ្លះ ឥ. ដូច នារី, នបុំ. ដូច កុល ឬដូច ភវន្ត ក៏បានខ្លះ ។

លក ជាមួយនឹង អន្ត ជា លកន្ត[១], ផ្លាស់សិ-វិភត្តិជា ឱ ជា លកន្តោ, ឥ. លកន្តី, នបុំ. លកន្តំ) ។

ហេតុកត្តុវាចកៈ កថាបេន្តោ "កំពុងឲ្យពោល, កាលឲ្យពោល" (កថ-ធាតុ, ណាបេ-បច្ច័យ (អាខ្យាត), អន្ត-បច្ច័យ, លុប ណ ទុកតែ អាបេ, លុប អ របស់ អន្ត ទុកតែ ន្ត, ផ្សំជា កថាបេន្ត[២], ផ្លាស់សិ-វិភត្តិជា ឱ ជា កថាបេន្តោ, ឥ. ចុះឦ-បច្ច័យមកផងជា កថាបេន្តី, នបុំ. កថាបេន្តំ) ។ សាវេន្តោ "កំពុងឲ្យស្តាប់, កាលឲ្យឮ" (សុ-ធាតុ, ណេ-បច្ច័យ (អាខ្យាត), អន្ត-បច្ច័យ, ព្រឹទ្ធិ ឧ របស់ សុ ជា ឱ ហើយផ្លាស់ ឱ ជា អវ រួចទីឃៈ អ របស់ អវ ជា អាវ, លុប ណ ទុកតែ ឯ, លុប អ របស់

---

១ បានជាមិនបាច់ចុះបច្ច័យអាខ្យាត ពីព្រោះហេតុយ៉ាងនេះមានទំនងល្មមផ្សំតែត្រឹមអន្ត-បច្ច័យប៉ុណ្ណោះបានហើយ, អន្ត ក៏ជាកិតបច្ច័យតាមទំនើងខ្លួនឯងស្រាប់តែមានន័យមួយទៀតថា បើទុកជាធាតុដែលមានទំនងយ៉ាងនេះក៏ត្រូវតែចុះបច្ច័យអាខ្យាតសម្រាប់ពួកធាតុមកផងដូចឧទាហរណ៍នេះ ត្រូវចុះ អ-បច្ច័យ, អន្ត-បច្ច័យ, អន្ត-បច្ច័យ, ហើយលុប អ-បច្ច័យអាខ្យាត ចេញ, ផ្សំជាលភន្ត ។ ន័យទាំង ២ យ៉ាងនេះ អ្នករៀនគួរកាន់យកតាមសេចក្តីពេញចិត្តចុះ ។

២ បើតាមអំណាចការិតបច្ច័យ (ដែលជា ណានុពន្ធៈ) ត្រូវព្រឹទ្ធិ ស្រៈ អ នៃ ក ជា កា, តែមានមិនបាច់ព្រឹទ្ធិ យ៉ាងនេះក៏បានខ្លះ (តាមទម្លាប់ប្រើ) ប៉ុន្តែដែលមិនព្រឹទ្ធិយ៉ាងនេះ មានតិចណាស់ ។

អន្ត ទុកតែ ន្ត, ផ្សំជា សាវេន្ត..., ឥ. សាវេន្តី, នបុំ, សាវេន្តំ) ។ ការេន្តោ "កំពុងឲ្យធ្វើ, កាលឲ្យធ្វើ" (ករ+ណេ+អន្ត, ករ > ការ, ណេ > ឯ. អន្ត > ន្ត ផ្សំជា ការេន្ត, សិ > ឱ ជា ការេន្តោ, ឥ. ការេន្តី, នបុំ. ការេន្តំ) ។ លាភាបេន្តោ[១] "កំពុងឲ្យបាន, កាលឲ្យបាន" (លភ+ណាបេ+អន្ត, លភ > លាភ, ណាបេ > អាបេ, អន្ត > ន្ត ផ្សំជា លាភាបេន្ត, សិ > ឱ ជា លាភាបេន្តោ, ឥ. លាភាបេន្តី, នបុំ. លាភាបេន្តំ) ។

តវន្តុ : បច្ច័យនេះ ក៏សម្រាប់ចុះបានតែក្នុងវាចកៈ ២ គឺ កត្តុវាចកៈ និង ហេតុកត្តុវាចកៈ ដូចអន្ត-បច្ច័យដែរ ប៉ុន្តែមាន វិធីរូបសិទ្ធិផ្សេងគ្នាអំពីអន្ត-បច្ច័យ, ដូចមានរបៀបតទៅនេះ ៖

---

១ ការិតបច្ច័យ (អាខ្យាត) ទាំង ៤ គឺ ណេ, ណយ, ណាបេ, ណាបយ នេះ ត្រូវចុះបានតាមលំនាំរបស់ធាតុដែលគួរប្រកប, ដូច ជា កថ-ធាតុ នឹងចុះ ណេ-បច្ច័យពុំបានឡើយ ព្រោះខាងកត្តុវាចកៈ ជា កថេន្ត ទៅហើយ បើចុះ ណេ នឹងច្រឡំគ្នា, ត្រូវចុះបានតែ ណយ ជា កថយន្ត, ណាបេ ជា កថាបេន្ត, ណាបយ ជា កថាបយន្ត, ឯ សុ-ធាតុ ត្រូវចុះបាន គ្រប់បច្ច័យទាំង ៤ : ណេ ជា សាវេន្ត, ណយ ជា សាវយន្ត, ណាបេ ជា សាវបេន្ត, ណាបយ ជា សាវាបយន្ត, ករ-ធាតុ ត្រូវចុះបានគ្រប់បច្ច័យទាំង ៤, ណេ ជា ការេន្ត, ណយ ជា ការយន្ត, ណាបេ ជា ការាបេន្ត, ណាបយ ជា ការាបយន្ត, លភ-ធាតុ ត្រូវចុះបានគ្រប់បច្ច័យទាំង ៤ : ណេ ជា លាភេន្ត, ណយ ជា លាភយន្ត, ណាបេ ជា លាភាបេន្ត, ណាបយ ជា លាភាបយន្ត, ទោះធាតុឯទៀតក្រៅពីនេះ ក៏មានន័យប្រើតាមគួរដល់ការ ប្រកបដូចគ្នា ។

## កត្តុវាចកៈ

ធាតុទោលតែមួយតួ, ត្រូវទុកធាតុឲ្យគង់រូបនៅដូចដើម ឧ. សុតវា "ឮហើយ,[១] ស្តាប់ហើយ", ជិតវា "ឈ្នះហើយ" (គ្រាន់តែផ្សំ សុ-ធាតុ, ជិ-ធាតុ ជាមួយនឹង តវន្តុ-បច្ច័យ ជា សុតវន្តុ-ជិតវន្តុ, ផ្លាស់ ន្តុ និងសិ-វិភត្តិជា អា ជា សុតវា, ជិតវា, ឥ. ចុះ ឦ-បច្ច័យមកផង ហើយផ្លាស់ ន្តុ ជា "ត" ជា សុតវតី, ជិតវតី, លុប ឧ របស់ ន្តុ ឬផ្លាស់ ន្តុ ជា ន្ត ផ្សំជា សុតវន្តី, ជិតវន្តី ក៏បាន, នបុំ. លុប ឧ របស់ ន្តុ ឬផ្លាស់ ន្តុ ជា ន្ត, ជា សុតវន្តំ[២], ជិតវន្តំ) ។

ធាតុមានអក្សរ ២ តួ ដែលមាន ច, ជ, ប ជាទីបំផុត, ផ្លាស់ទីបំផុតធាតុជា "ត" ក៏បាន ឧ. សិត្តវា "ស្រោចហើយ", ភុត្តវា "បរិភោគហើយ", ចត្តវា "លះហើយ, លះបង់ហើយ", គុត្តវា "គ្រប់គ្រងហើយ, រក្សាហើយ" (ផ្លាស់ទីបំផុតនៃ សិច-ធាតុ, ភុជ-ធាតុ, ចជ-ធាតុ, គុប-ធាតុ ជា "ត", ផ្សំជា សិត្តវន្តុ, ភុត្តវន្តុ, ចត្តវន្តុ, គុត្តវន្តុ,...) ។

---

១ ប្រែថា "លុះ-ហើយ, លុះ-រួចហើយ" ក៏បាន ។ ២ បែបបំបែកផ្សំនឹងវិភត្តិនាម : បុំ. និង នបុំ. ដូច ភគវន្តុ, ឥ. ដូច នារី ។

បើមិនផ្លាស់ទីបំផុតជាតុទេ, ត្រូវទុកជាតុ ឲ្យគង់រូបដូចដើម, ប៉ុន្តែត្រូវចុះត-អាគមមកផង ឧ. ចជិតវា "លះហើយ, លះបង់ហើយ" (ចជ-ធាតុ) ។ ចំពោះតែ វស-ធាតុ មួយ, ត្រូវផ្លាស់ អ របស់ វ នៃ វស ជា ឧ ត្រូវចុះត-អាគមមកផង ឧ. វុសិតវា "នៅហើយ" ។

## ហេតុកត្តុវាចកៈ

ក្នុងហេតុកត្តុវាចកៈ ត្រូវចុះការិតបច្ច័យមកផង (ចំពោះតែធាតុខ្លះដែលប្រើបានតាមគួរដល់ការប្រកប) ឧ. ភោជេតវា, ភោជយិតវា, ភោជាបេតវា, ភោជាបយិតវា, "ឲ្យបរិភោគហើយ" (ភុជ-ធាតុ, ណេ, ណយ, ណាបេ, ណាបយ, ព្រឹទ្ធិ ឧ របស់ ភុ នៃ ភុជ ជា ឱ, ត្រង់ ណយ និង ណាបយ ត្រូវចុះត-អាគមមកផង..., ត. ភោជេតវតី,..., នបុំ. ភោជេតវន្តំ,...) ។

តាវី : បច្ច័យនេះ មានគតិដូចគ្នានឹងតវន្តុ, ខុសគ្នាតែស្រៈទីបំផុត : មួយជា ឧ, មួយជា ឦ ប៉ុណ្ណោះ ។ កត្តុវាចកៈ សុតាវី "ឮហើយ, ស្តាប់ហើយ", ជិតាវី "ឈ្នះហើយ", សិត្តាវី "ស្រោចហើយ", ភុត្តាវី "បរិភោគហើយ", ចត្តាវី "លះហើយ, លះបង់

ហើយ״, គុត្តាវី ‶គ្រប់គ្រងហើយ, រក្សាហើយ״, ចជិតាវី ‶លះហើយ, លះបង់ហើយ״, វុសិតាវី ‶នៅហើយ״ ។ ឥ. ចុះឥនី-បច្ច័យមកផង, លុប ឦ របស់ វី, ផ្សំជា សុតាវិនី, ជិតាវិនី, សិត្តាវិនី,..., នបុំ. រស្សៈ ឦ ជា ឥ, ជា សុតាវិ, ជិតាវិ, សិត្តាវិ,... ។ ហេតុកត្តុវាចកៈ ភោជេតាវី, ភោជយិតាវី, ភោជាបេតាវី, ភោ-ជាបយិតាវី ‶ឲ្យបរិភោគហើយ״..., ឥ. ភោជេតាវិនី,..., នបុំ. ភោជេតាវិ,[១]... ។

[១៨០] ឧទាហរណ៍ក្នុងកិច្ច-បច្ច័យ

តព្វ : បច្ច័យនេះ កាលបើចុះមកហើយ មានវិធីរូបសិទ្ធិផ្សេង ៗ ដូចមានរបៀបជាសង្ខេបតទៅនេះ ៖

១- ធាតុដែលមានអក្សរ ២ តួ, ផ្លាស់ទីបំផុតធាតុជា ‶ត״ ក៏បានខ្លះ ឧ. កត្តព្វំ ‶(គឺជន) គប្បីធ្វើ, គួរធ្វើ, ត្រូវធ្វើ״, វត្តព្វំ ‶(ដែលជន) គប្បីពោល,...״, បត្តព្វំ ‶(ដែលជន) គប្បីដល់״ (ផ្លាស់ទីបំផុតនៃ ករ-ធាតុ, វទ-ធាតុ, បទ-ធាតុ ជា ‶ត״, ផ្សំជា

---

១ បែបបំបែកផ្សំនឹងវិភត្តិនាម :បុំ. ដូច សេដ្ឋី, ឥ. ដូច នារី, នបុំ. ដូច អក្ខិ ។ តវន្តុ និង តាវី ទាំង ២ នេះ មិនសូវប្រើទេ, ជាបច្ច័យចុះមិនបានទូទៅគ្រប់ធាតុទាំងអស់ឡើយ, សម្រាប់ អតីតកាល ច្រើនប្រើ ត-បច្ច័យ ឬ ត្វា-បច្ច័យ ទូទៅគ្រប់ធាតុទាំងអស់ ។

កត្តព្វ, វត្តព្វ, បត្តព្វ, ផ្លាស់សិ-វិភត្តិជា ១ ជា កត្តព្វំ,វត្តព្វំ,បត្តព្វំ, បុំ.កត្តព្វោ, វត្តព្វោ, បត្តព្វោ, ឥ. ចុះអា-បច្ច័យមកផងជា កត្តព្វា, វត្តព្វា,[១] បត្តព្វា ) ។

២- ធាតុដែលមាន "ម" ជាទីបំផុត, ផ្លាស់ទីបំផុតធាតុ ជា "ន" ក៏បានខ្លះ ឧ. គន្តព្វំ "(គឺជន) គប្បីទៅ, គប្បីដល់", សន្តព្វំ "(គឺជន) គប្បីរម្ងាប់" (ផ្លាស់ ម ទីបំផុតនៃ គម-ធាតុ, សម-ធាតុ ជា "ន", ផ្សំជា គន្តព្វ, សន្តព្វ,...) ។

៣- ធាតុដែលមាន "ន" ជាទីបំផុត, ផ្លាស់ទីបំផុតធាតុ ជា "ន" ដដែល, ឬគ្រាន់តែផ្សំជាមួយនឹងបច្ច័យតែម្តងក៏បាន ឧ. ហន្តព្វំ "(គឺជន) គប្បីបៀតបៀន,..." (ហន-ធាតុ), ខន្តព្វំ "(ដែលជន) គប្បីជីក" (ខន-ធាតុ), តន្តព្វំ "(ដែលជន) គប្បីលាត, -លា, -ត្រដាង, -សន្ធឹង" (តន-ធាតុ) ។

៤- ធាតុដែលមាន "ភ" ជាទីបំផុត, ផ្លាស់ "ត" របស់ តព្វ និងទីបំផុតធាតុជា "ទ្ធ" ក៏បានខ្លះ ឧ. លទ្ធព្វំ (ដែលជន) គប្បីបាន" (លភ-ធាតុ) ។

---

១ បែបបំបែកផ្សំនឹងវិភត្តិនាម : បុំ. ដូច បុរិសៈ ឥ. ដូច កញ្ញា, នបុំ. ដូច កុល ។

៥- ធាតុដែលមាន "ស" ជាទីបំផុត, ផ្លាស់ "ត" របស់ តព្វ និងទីបំផុតធាតុជា "ដ្ឋ" ក៏បានខ្លះ ឧ. ទដ្ឋព្វំ (គឺជន) គប្បីឃើញ" (ផ្លាស់ ត និង ស ទីបំផុតនៃ ទិស-ធាតុ ជា "ដ្ឋ", ផ្លាស់ ឥ របស់ ទិ ជា អ, ផ្សំជា ទដ្ឋព្វ,...), បម្មុដ្ឋព្វំ "(គឺជន) គប្បីភ្លេច, គប្បីភាន់" (ប-បុព្វបទ, មុស-ធាតុ, តម្រួត ម, ឬមិនបាច់តម្រួត : ប្រើជា បមុដ្ឋព្វំ ក៏បាន) ។

៦- ចំពោះតែ ករ-ធាតុ មួយ, លុបទីបំផុតធាតុ ហើយ ទីឃៈ អ របស់ ក ជា អា ក៏បាន, ផ្លាស់ ករ-ធាតុទាំងមូល ជា កា ក៏បាន ឧ. កាតព្វំ "(ដែលជន) គប្បីធ្វើ" ។

៧- ធាតុទោលតែមួយតួ, ត្រូវទុកធាតុឲ្យនៅតាមរូបដើម, ឬផ្លាស់ធាតុជារូបផ្សេងក៏បានខ្លះ ឧ. ទាតព្វំ "(ដែលជន)គប្បីឲ្យ" (ទា-ធាតុ), ឋាតព្វំ "(គឺជន) គប្បីឈរ,..." (ឋា-ធាតុ), បហាតព្វំ "(គឺជន) គប្បីលះ, គប្បីលះបង់" (ប-បុព្វបទ, ហា-ធាតុ), នហាតព្វំ "(គឺជន) គប្បីងូត" (នហា-ធាតុ), បាតព្វំ, បិវិតព្វំ "(គឺជន) គប្បីផឹក" (បា-ធាតុ, ផ្លាស់ បា ជា បិវ, ចុះឥ-អាគម) ។

៨- ធាតុដែលមានអក្សរ ២ តួ ឬ ៣ តួ, បើមិនផ្លាស់ ឬមិនលុបទីបំផុតធាតុទេ, ត្រូវចុះឥ-អាគមមក ជាកំណត់ដោយដាច់ខាត ឧ.ករ-ធាតុ : ករិតព្វំ, អវ-បុព្វបទ ផ្លាស់ជា ឱ, វទ-ធាតុ : ឱវទិតព្វំ "(ដែលជន) គប្បីទូន្មាន", អា-បុព្វបទ, បទ-ធាតុ, ផ្លាស់ ទ ទីបំផុតធាតុជា "ជ" ហើយតម្រួតជា ជ្ជ : អាបជ្ជិតព្វំ, គម-ធាតុ : គមិតព្វំ, ខម-ធាតុ : ខមិតព្វំ, លភ-ធាតុ : លភិតព្វំ, អា-បុព្វបទ,រភ-ធាតុ:អារភិតព្វំ ,ឧ-បុព្វបទ,ទិស-ធាតុ តម្រួតទ:ឧទ្ទិសិតព្វំ,គរហ-ធាតុ : គរហិតព្វំ,... ...។ សូម្បីធាតុទោលតែមួយតួ ដែលព្រឹទ្ធិ ឬផ្លាស់រូបឲ្យជាពីរតួ ក៏ត្រូវចុះឥ-អាគមដែរ ឧ. ភូ-ធាតុ : ភវិតព្វំ, បុ-ធាតុ : បវិតព្វំ, សី-ធាតុ : សយិតព្វំ, ភី-ធាតុ : ភាយិតព្វំ, បា-ធាតុ : បាយិតព្វំ, បិវិតព្វំ, យា-ធាតុ : យាយិតព្វំ,... ... ។

៩- ធាតុទោលតែមួយតួ, ត្រូវព្រឹទ្ធិធាតុ តាមគួរដល់ការប្រកប ឧ. ភូ-ធាតុ : ភវិតព្វំ (ព្រឹទ្ធិ ឩ របស់ ភូ ជា ឱ ហើយផ្លាស់ ឱ ជា អវ, ចុះ ឥ-អាគម), សុ-ធាតុ : សោតព្វំ (ព្រឹទ្ធិ ឧ របស់ សុ ជា ឱ), បុ-ធាតុ : បវិតព្វំ (ព្រឹទ្ធិ ឧ របស់ បុ ជា

ឱ ហើយផ្លាស់ ឱ ជា អវ, ចុះឥ-អាគម), សី-ធាតុ : សយិតព្វំ (ព្រឹទ្ធិ ឦ របស់ សី ជា ឯ ហើយផ្លាស់ ឯ ជា អយ, ចុះ ឥ អាគម, គ្រាន់តែព្រឹទ្ធិ ឦ ជា ឯ, ជា សេតព្វំ ក៏បាន), នី-ធាតុ : នេតព្វំ (ព្រឹទ្ធិ ឦ របស់ នី ជា ឯ), ភី-ធាតុ : ភាយិតព្វំ (ព្រឹទ្ធិ ឦ របស់ ភី ជា ឯ ហើយផ្លាស់ ឯ ជា អយ, ទីឃៈ អ នៃ អយ ជា អាយ, ចុះ ឥ-អាគម), ... ... ។

១០- ធាតុដែលមាន អា ជាទីបំផុត, ផ្លាស់ អា ជា អាយ បើចុះឥ-អាគម ក៏បានខ្លះ ឧ. យា-ធាតុ : យាយិតព្វំ, បា-ធាតុ:បាយិតព្វំ, នហា-ធាតុ "ជម្រះ, កក់, ងូត" : នហាយិតព្វំ,...។

១១- ធាតុខ្លះ ត្រូវចុះបច្ច័យសម្រាប់ពួកធាតុក្នុងអាខ្យាតមកផងក៏មាន ឧ. ពុជ្ឈិតព្វំ "(គឺជន) គប្បីដឹង,..." (ផ្លាស់យ-បច្ច័យនិង ធ ទីបំផុតនៃពុធ-ធាតុជា ជ្ឈ, ចុះឥ-អាគម, ផ្សំជា ពុជ្ឈិតព្វ,...) សុណិតព្វំ "(ដែលជន) គប្បីឮ,..." (សុ-ធាតុ, លុប អា របស់ណា-បច្ច័យ, ចុះឥ-អាគម, ផ្សំជា សុណិតព្វ,...), ជានិតព្វំ "(ដែលជន) គប្បីដឹង" (ផ្លាស់ញា-ធាតុជា "ជា", លុប អា របស់ នា-បច្ច័យ, ចុះឥ-អាគម ផ្សំជា ជានិតព្វ,...),

គណ្ហិតព្វំ "(ដែលជន) គប្បីកាន់,..." (លុប ហ ទីបំផុតនៃ គហ-ធាតុ, លុប អា របស់ណ្ហា-បច្ច័យ, ចុះឥ-អាគម, ផ្សំជា គណ្ហិតព្វ,...), ចិន្តេតព្វំ "(គឺជន) គប្បីគិត" (ចិន្ត-ធាតុ, ណេ-បច្ច័យ, លុប ណ ទុកតែ ឯ, ផ្សំជា ចិន្តេតព្វ,...) ។

ខាងហេតុកម្មវាចកៈ ត្រូវចុះការិតបច្ច័យមកផង, ត្រង់ ណយ និង ណាបយ ត្រូវចុះឥ-អាគមផង[១] ឧ. ករ-ធាតុ : បុំ. ការេតព្វោ, ការយិតព្វោ, ការាបេតព្វោ, ការាបយិតព្វោ, ឥ. ការេតព្វា, ការយិតព្វា, ការាបេតព្វា, ការាបយិតព្វា, នបុំ. ការេតព្វំ, ការយិតព្វំ, ការាបេតព្វំ, ការាបយិតព្វំ "(ដែលជន) គប្បីឲ្យធ្វើ, ត្រូវឲ្យធ្វើ, គួរឲ្យធ្វើ",... ... ។

អនីយ : បច្ច័យនេះ មានគតិដូច តព្វ-បច្ច័យដែរ, ខុស គ្នាតែវិធីរូបសិទ្ធិនិងភាពសណ្ឋានប៉ុណ្ណោះ, ដូចមានឧទាហរណ៍ សង្ខេបតទៅនេះ ៖

---

១ មិនបាច់ចុះ យ-បច្ច័យទេ ព្រោះ តព្វ ជាកិច្ចបច្ច័យស្រាប់ហើយ អាចញ៉ាំងសព្ទឲ្យជាហេតុកម្មវាចកៈ ដោយត្រឹមតែអំណាចខ្លួននឹង ការិតបច្ច័យប៉ុណ្ណោះ ។

ធាតុដែលមានអក្សរ ២ តួ, ផ្លាស់ឲ្យខុសចាកភាពដើមខ្លះក៏មាន ឱ. ទស្សនីយំ "(គឺជន) គប្បីឃើញ, គួរមើល" (ផ្លាស់ ឥ របស់ ទិស-ធាតុ ជា អ, តម្រួត ស ទីបំផុតធាតុជា ស្ស ផ្សំជា ទស្សនីយ,..., បុំ. ទស្សនីយោ, ឥ. ចុះអា-បច្ច័យមកផងជា ទស្សនីយា[១]) ។

ធាតុទោលតែមួយតួ, ត្រូវព្រឹទ្ធិធាតុខ្លះ, មិនបាច់ព្រឹទ្ធិខ្លះ ឱ. ដែលត្រូវព្រឹទ្ធិ : ភវនីយំ "(គឺសត្វ) គប្បីកើត", សវនីយំ "(ដែលជន) គួរស្ដាប់" (ព្រឹទ្ធ ឱ របស់ ភូ-ធាតុ, ឱ របស់ សុ-ធាតុ ជា ឱ ហើយផ្លាស់ ឱ ជា អវ, ផ្សំជា ភវនីយ, សវនីយ) ។ ជយនីយំ "(ដែលជន) គប្បីឈ្នះ" (ព្រឹទ្ធិ ឥ របស់ ជិ-ធាតុ ជា ឯ ហើយផ្លាស់ ឯ ជាអយ, ផ្សំជា ជយនីយ,...) ។ ដែលមិនបាច់ព្រឹទ្ធិ : បានីយំ "(ដែលជន) គួរផឹក", ឋានីយំ

១ បែបបំបែកផ្សំនឹងវិភត្តិនាម : បុំ. ដូច បុរិស, ឥ. ដូច កញ្ញា, នបុំ. ដូច កុល ។ អនីយ-បច្ច័យនេះ មានលំនាំគួរឲ្យច្រឡំនឹង ណ្យ-បច្ច័យក្នុងតទ្ធិតខ្លះ ដូចជា: "...បូជនីយោ, ទស្សនីយោ, សវនីយោ" នេះ ចុះអនីយ-បច្ច័យក៏បាន ចុះណ្យ-បច្ច័យក៏បាន, អ្នករៀនចូរដឹងថា : ប្រើបានទាំង ២ យ៉ាង តាមដំណើរសេចក្ដី, បើឃើញថាខាងបច្ច័យណាសមសេចក្ដីជាង, ចូរប្រែខាងបច្ច័យនោះចុះ ។

(ដែលជន) គប្បីឋិតនៅ″ (លុប អ របស់ អនីយ ទុកតែ នីយ[១], ផ្សំនឹង បា-ធាតុ, ឋា-ធាតុ ជា បានីយ, ឋានីយ,...) ។

សូម្បីធាតុដែលមានអក្សរ ២ តួ ក៏ត្រូវព្រឹទ្ធិបានខ្លះដែរ ឧ- ភោជនីយំ ‷(ដែលជន) គួរបរិភោគ″ (ព្រឹទ្ធិ ឧ របស់ ភុ នៃ ភុជ-ធាតុ ជា ឱ) ។ សារណីយំ ‷(គឺជន) គួររឭក″ (ទីឃៈ អ របស់ ស នៃ សរ-ធាតុ ជា អា (ព្រោះធាតុមាន រ ជាទីបំផុត) ផ្លាស់ ន របស់ អនីយ ជា ណ, ទីឃៈ អ របស់ អនីយ ជា អា) ។ សម្មោទនីយំ ‷(គឺជន) គួររីករាយព្រម = គួរ ស្មោះសរ, -រួសរាយ, -រាក់ទាក់)″ (ព្រឹទ្ធិ ឧ របស់ មុ នៃ មុទ- ធាតុ ជា ឱ, ផ្លាស់និគ្គហិតរបស់ សំ-បុព្វបទ ជា ‷ម″, ផ្សំជា សម្មោទនីយ,...) ។

ធាតុដែលមាន ‷រ″ ឬ ‷ហ″ ជាទីបំផុត, ត្រូវផ្លាស់ ‷ន″ របស់ អនីយ ជា ‷ណ″ គឺធ្វើអនីយ ឲ្យជា អណីយ ឧ. ករ- ណីយំ ‷(គឺជន) គប្បីធ្វើ″ (ករ-ធាតុ), សរណីយំ ‷(ដែលជន)

---

១ បានជាលុប អ ព្រោះ បា, ឋា ជាទីឃៈស្រាប់ហើយ ត្រូវទុកឲ្យ នៅតាមរូបដើម ។

គួរឮក" (សរ-ធាតុ, ទីឃៈ ឲ្យជា សារាណីយំ ក៏បាន), គហ-ណីយំ "(ដែលជន) គប្បីកាន់,..." (គហ-ធាតុ), គរហណីយំ "(ដែលជន) គួរតិះដៀល" (គរហ-ធាតុ) ។ សូម្បីធាតុក្រៅពីនេះ ក៏អាចឲ្យផ្លាស់ "ន" ជា "ណ" បានខ្លះដែរ (តែមានតិច) ឧ. រមណីយំ "(ដែលជន) គួរ[១] ត្រេកអរ" (រម-ធាតុ) ។

តាមធម្មតារបស់បច្ច័យនេះ, ច្រើនតែទុកទាំងធាតុទាំងបច្ច័យឲ្យនៅដូចដើម (មិនផ្លាស់ប្រែ) ឧ. បច-ធាតុ : បចនីយំ, វច-ធាតុ : វចនីយំ, គម-ធាតុ : គមនីយំ, ខម-ធាតុ : ខមនីយំ, វទ-ធាតុ : វទនីយំ, ខន-ធាតុ : ខននីយំ, លភ-ធាតុ : លភនីយំ តុស-ធាតុ : តុសនីយំ,... ... ។

---

១ កាលបើមានលំនាំសេចក្តីថា "គួរ-, គួរតែ-, សមតែ-" ដូចជា : ឯសោ គរហណីយោ "(មនុស្ស)ហ្នឹង សមតែអ្នកផងតិះដៀល", ឥទំ ឧទកំ បានីយំ "ទឹក នេះ គួរគេផឹកបាន", តែបើគេមិនតិះដៀល, មិនផឹក, ក៏មិនជាអ្វី, យ៉ាងនេះ ត្រូវប្រែថា "គួរ" ឬ "គួរតែ-សមតែ-" (អនុត្តកាល ជា អនុមតិ) ។ កាលបើលំនាំសេចក្តី សម្តែង អាការមានកំណត់មានកំហិត (នឹងខានពុំបាន) ដូចជា : រាជកិច្ចំ តេ ករណីយំ ឬ កត្តព្វំ "កិច្ចរបស់ស្តេចគឺអ្នក ត្រូវធ្វើ", ន ភិក្ខវេ មូគវត្តំ តិត្ថិយសមាទានំ សមាទិតព្វំ, យោ សមាទិយេយ្យ, អាបត្តិ ទុក្កដស្ស "ម្នាកភិក្ខុទាំងឡាយ វត្ត គ (តមមិនស្តី) ជាតិត្ថិយសមាទាន (គឺអ្នក រាល់គ្នា) មិនត្រូវកាន់ទេ, ភិក្ខុណា កាន់, អាបត្តិទុក្កដ មាន (ដល់ភិក្ខុ នោះ) = ភិក្ខុនោះត្រូវអាបត្តិទុក្កដ", យ៉ាងនេះ ត្រូវប្រែថា "គប្បី" ឬ "ត្រូវ-" (អនុត្តកាល ជា បរិកប្បៈ) ។

ខាងហេតុកម្មវាចកៈ, គ្រាន់តែចុះណាបេ-បច្ច័យមកផងមិនបាច់ចុះបច្ច័យសម្រាប់ពួកធាតុ (អាខ្យាត) ក៏មាន, ត្រូវចុះណាបេ-បច្ច័យ ព្រមទាំងបច្ច័យសម្រាប់ពួកធាតុផង ក៏មាន ឧ. ដែលគ្រាន់តែចុះណាបេ- បច្ច័យមកផង : ករ-ធាតុ : បុំ. ការាបនីយោ, ឥ. ការាបនីយា, នបុំ. ការាបនីយំ,[១] "(ដែលជន) គប្បីឲ្យធ្វើ, ត្រូវឲ្យធ្វើ, គួរឲ្យធ្វើ" (លុប ណ និង ឯ ទុកតែត្រឹម អាប)... ... ។ ដែលត្រូវចុះណាបេ-បច្ច័យព្រមទាំងបច្ច័យសម្រាប់ពួកធាតុផង : សិរ-ធាតុ : បុំ. សិញ្ញាបនីយោ, ឥ. សិញ្ញាបនីយា, នបុំ. សិញ្ញាប-នីយំ "(ដែលជន) គប្បីឲ្យដេរ, ត្រូវឲ្យដេរ, គួរឲ្យដេរ,..." ។

អនីយ-បច្ច័យនេះជាកិច្ចបច្ច័យខាងកិរិយាកិតកៈក៏ពិតមែន ប៉ុន្តែជួនណាប្រើជានាមនាមក៏បានខ្លះ ឧ. សេដ្ឋី បណីតេន ខាទ-នីយេន ភោជនីយេន ភិក្ខុសង្ឃំ បរិវិសិ "សេដ្ឋី អង្គាសហើយនូវភិក្ខុសង្ឃ ដោយវត្ថុដែលជនគួរទំពាស៊ី (បង្អែម) ដោយវត្ថុដែលជនគួរបរិភោគ (ចម្អាប) ដ៏ថ្លៃថ្លា" ។

---

១ ធាតុដែលមាន "រ" ឬ "ហ" ជាទីបំផុត, បើមានការិត-បច្ច័យរាំងត្រង់ចន្លោះកណ្ដាលយ៉ាងនេះ មិនបាច់ផ្លាស់ "ន" ជា "ណ" ឡើយ ។

[១៨១] ឧទាហរណ៍ក្នុងកិតកិច្ច-បច្ច័យ

មាន : បច្ច័យនេះ, បើមិនចុះយ-បច្ច័យ (អាខ្យាត) ផ្សំមកផងទេ ក៏ជាកត្តុវាចកៈ ដូចអន្ត-បច្ច័យដែរ, តែបើប្រើជាកត្តុវាចកៈ ត្រូវចុះបច្ច័យសម្រាប់ពួកជាតុ (អាខ្យាត) មកផង[១], បើប្រើជាកម្មវាចកៈ និងភាវវាចកៈ ត្រូវចុះយ-បច្ច័យនិងបច្ច័យសម្រាប់ពួកជាតុ (អាខ្យាត) និងឥ-អាគមផ្សំមកផង ជួនណាមិនបាច់ចុះឥ-អាគមក៏បាន (តាមដំណើររបស់ជាតុ) ។

កត្តុវាចកៈ បចមានោ "កំពុងចម្អិន, កាលចម្អិន[២]" (បច+អ (អាខ្យាត) + មាន > បចមាន, សិ > ឱ, ជា បចមានោ, ឥ. បច-មាន + អា > បចមានា, នបុំ. បចមានំ[៣]) ។ លភមានោ "កំពុងបាន,..." (លភ + អ (អាខ្យាត) + មាន > លភមាន,...) ។

---

១ ដើម្បីឲ្យទីបំផុតធាតុមានស្រៈ ដូចជា : ប័ច+អ+មាន > បចមាន, ល័ភ+អ+មាន >លភមាន, ច័រ+អ+មាន > ចរមាន, ក័រ+ឱ+មាន > កុរុមាន (ក > កុ, ឱ > ឧ)... ... ។ ២ គ្រាន់តែប្រែចេញសព្ទធាតុថា "ចម្អិន" ប៉ុណ្ណោះក៏បាន ព្រោះមាន-បច្ច័យនេះប្រាប់បច្ចុប្បន្នកាល ដូចវត្តមានាវិភត្តិអាខ្យាតដែរ (ខាងអន្ត-បច្ច័យក៏ដូចគ្នា) ។ ៣ បែបបំបែកផ្សំនឹងវិភត្តិនាម បុំ. ដូច បុរិស, ឥ. ដូច កញ្ញា,នបុំ. ដូច កុល ។

កម្មវាចកៈ ករិយមានោ "(គឺជន) កំពុងធ្វើ, កាលធ្វើ" (ករ+ឥ (អាគម) + យ (អាខ្យាត) + មាន > ករិយមាន,...)។ បច្ចមានោ "(គឺជន) កំពុងចម្អិន,..." (បច + យ (អាខ្យាត) + មាន > បច្ចមាន[១], យ > ច, ឬ ច + យ > ច្ច ក៏បាន, មិនបាច់ចុះឥ-អាគមឡើយ)។

ភាវវាចកៈ ករិយមានំ "(គឺជន) កំពុងធ្វើ, កាលធ្វើ" (ករ+ឥ (អាគម) + យ (អាខ្យាត) + មាន > ករិយមាន,...)។ លព្ភមានំ "(គឺជន) កំពុងបាន, កាលបាន" (លភ+យ (អាខ្យាត) + មាន > លព្ភមាន, ភ + យ > ព្ភ)។

ខាងហេតុកត្តុវាចកៈ ត្រូវចុះ ណយ ឬ ណាបយ មកផង ឧ. ករ-ធាតុ : ការយមានោ ការាបយមានោ "កំពុងឲ្យធ្វើ, កាលឲ្យធ្វើ", ញា-ធាតុ : ញាបយមានោ "កំពុងឲ្យដឹង,...") ទា-ធាតុ : ទាបយមានោ[២] "កំពុងឲ្យឲ្យ,...", សុ-ធាតុ : សា-

---

១ បើទុក យ ឲ្យគង់រូបនៅដូចដើម ត្រូវចុះឥ-អាគមមកផងជា បចិយមាន ។ ២ ធាតុដែលមាន អា ជាទីបំផុតយ៉ាងនេះ, ខាងហេតុ-កត្តុវាចកៈ ត្រូវចុះការិតបច្ច័យបាន តែ ណាបយ មួយប៉ុណ្ណោះ ខាងហេតុកម្មវាចកៈ, និងភាវវាចកៈ, ត្រូវចុះ ណាបេ (លុបទុកតែត្រឹមអាប), ចុះយ-បច្ច័យ ឥ-អាគម, ជា ទាបិយមាន។

វយមានោ, សាវាបយមានោ "កំពុងឲ្យឮ, កាលឲ្យឮ, កាលឲ្យស្តាប់" ។ ត្រូវចុះបច្ច័យសម្រាប់ពួកធាតុ (អាខ្យាត) មកផងក៏មាន ឧ. ទិព្វាបយមានោ "កំពុងឲ្យលេង, កាលឲ្យលេង"( ទិវ + យ + ណាបយ + មាន > ទិព្វាបយមាន, វ + យ > ព្វ ) ។ យុជ្ឈាបយមានោ "កំពុងឲ្យច្បាំង, កាលឲ្យច្បាំង" ( យុធ + យ + ណាបយ + មាន > យុជ្ឈាបយមាន ) ធ + យ > ជ្ឈ ) ។ កីនាបយមានោ "កំពុងឲ្យទិញ, កាលឲ្យទិញ" ( កី + នា + ណាបយ + មាន > កីនាបយមាន,... ) ។

ខាងហេតុកម្មវាចកៈ ត្រូវចុះណាបេ-បច្ច័យ, យ-បច្ច័យ, ឥ-អាគម មកផង ឧ. ការាបិយមានោ "( គឺជន ) កំពុងឲ្យធ្វើ, កាលឲ្យធ្វើ" ( ករ + ណាបេ + យ + ឥ + មាន > ការាបិយមាន, ណាបេ > អាប) ។ ត្រូវចុះបច្ច័យសម្រាប់ពួកធាតុ (អាខ្យាត) មកផងក៏មាន ឧ. ទិព្វាបិយមានោ "( គឺជន ) កំពុងឲ្យលេង, កាលឲ្យលេង" ( ទិវ + យ[១] + ណាបេ + ឥ + យ[២] + មាន >

១ យ-បច្ច័យសម្រាប់ពួកទិវ-ធាតុ ។ ២ យ-បច្ច័យសម្រាប់ចុះក្នុងកម្មវាចកៈ និងភាវវាចកៈ ។

ទិព្វាបិយមាន[១], វ៌+យ > ព្វ, ណាបេ > អាប) ។ វិក្កីណាបិ-យមានោ "(គឺជន) កំពុងឲ្យលក់, កាលឲ្យលក់" (វិ+កី+នា+ណាបេ+ឥ+យ+មាន > វិក្កីណាបិយមាន, (ព្រោះមាន វិ-បុព្វបទ) ត្រូវតម្រួត ក ហើយផ្លាស់ នា-បច្ច័យ ជា ណា, លុប ណ និង ឯ ទុកតែត្រឹម អាប) ។

ត : បច្ច័យនេះ កាលបើចុះមកហើយ មានអំណាចឲ្យប្រើបានគ្រប់វាចកៈទាំង ៥, តែខាងហេតុកត្តុវាចកៈមិនសូវមានប្រើ, មានវិធីរូបសិទ្ធិច្រើនយ៉ាង ដូចរបៀបជាសង្ខេបតទៅនេះ ៖

ធាតុដែលមាន "រ" ជាទីបំផុត, ត្រូវលុបទីបំផុតធាតុចេញក៏មាន ឧ. កតោ "(គឺជន) ធ្វើហើយ" (ករ-ធាតុ), ឥ. ចុះអា-បច្ច័យមកផងជា កតា, នបុំ. កតំ[២] ។ មតោ "ស្លាប់ហើយ" (មរ-ធាតុ) ។ ផ្លាស់ត-បច្ច័យជា "អណ្ណ" ហើយលុបទីបំផុត

---

១ អ្នករៀនចូរសង្កេត, កុំច្រឡំ : "ទិព្វាបយមាន" ដែលសម្រេចមកអំពី ទិវ+យ+ណាបយ+មាន (ជាហេតុកត្តុវាចកៈ) និង "ទិព្វាបិយ-មាន" នេះ ដែលសម្រេចមកអំពី ទិវ+យ+ណាបេ+យ+ឥ+មាន (ជា ហេតុកម្មវាចកៈ និងភាវវាចកៈ) ។ ២ បែបបំបែកផ្សំនឹងវិភត្តិនាម, បុំ. ដូច បុរិស ឥ. ដូច កញ្ញា, នបុំ. ដូច កុល ។

ធាតុចេញក៏មាន ឧ. បុណ្ណោ "ពេញហើយ" (បុរ-ធាតុ) ។ ផ្លាស់ត-បច្ច័យជា "ឥណ្ណ" ហើយលុបទីបំផុតធាតុចេញក៏មាន ឧ. តិណ្ណោ "ឆ្លងហើយ" (តរ-ធាតុ), ជិណ្ណោ "ចាស់ហើយ, គ្រាំគ្រាហើយ,..." (ជរ-ធាតុ) ។ គ្រាន់តែចុះឥ-អាគម ផ្សំនឹងត-បច្ច័យ ក៏មាន ឧ. សរិតោ "រឭកហើយ" (សរ-ធាតុ), ធារិតោ "(ដែលជន) ទ្រទ្រង់ហើយ,..." (ធរ-ធាតុ), ទីឃៈ[១] អ ជា អា) ។

ធាតុដែលមាន "ទ" ជាទីបំផុត ត្រូវផ្លាស់ ត-បច្ច័យជា "អន្ន" ហើយលុបទីបំផុតធាតុចេញក៏មាន ឧ. រុន្នោ "យំហើយ" (រុទ-ធាតុ), សន្នោ "លិចចុះហើយ" (សទ-ធាតុ) ។ ផ្លាស់ ត-បច្ច័យជា "ឥន្ន" ហើយលុបទីបំផុតធាតុចេញក៏មាន ឧ. ឆិន្នោ "កាត់ហើយ, ដាច់ហើយ" (ឆិទ-ធាតុ), ភិន្នោ "បែកហើយ ធ្លាយហើយ" (ភិទ-ធាតុ), និសិន្នោ "អង្គុយហើយ" (និ-បុព្វ-បទ, សទ-ធាតុ) ។ គ្រាន់តែចុះឥ-អាគមមកក៏មាន ឧ. មទ្ទិតោ "(គឺជន) ញាំញីហើយ, ប្របាច់ហើយ..." (មទ-ធាតុ, តម្រួតទ) ។

---

១ ទីឃៈតាមគួរដល់ការប្រកប ដើម្បីឲ្យស្រួលមាត់ មិនមែនទីឃៈព្រោះអំណាចត-បច្ច័យទេ ។

ធាតុដែលមាន "ឥ" ជាទីបំផុត, ត្រូវផ្លាស់ត-បច្ច័យជា "ឥណ្ណ" ក៏មាន ឧ. សុចិណ្ណោ "(ដែលជន) សន្សំដោយប្រពៃហើយ" (សុ-បុព្វបទ, ចិ-ធាតុ) ។ ផ្លាស់ ត-បច្ច័យជា "ណ្ណ" ក៏មាន ឧ. ខីណំ "អស់ហើយ" (ខិ-ធាតុ) ។

ចំពោះ ឥ-ធាតុ, ត្រូវទុកធាតុឲ្យគង់រូបនៅជា "ឥ" ដូចដើមក៏បាន, ផ្លាស់ឥ-ធាតុជា "ឯ" ក៏បាន ឧ. ឥតោ, ឯតោ[១] "ទៅហើយ, ដល់ហើយ", បេតោ[២] "ទៅបាត់ទៅហើយ = ទៅកាន់បរលោកហើយ" (ប-បុព្វបទ, ឥ-ធាតុ)។

ធាតុដែលមាន "ឦ, ឧ, ឩ" ជាទីបំផុត, ត្រូវទុកឲ្យនៅតាមរូបដើម ឧ. ភីតោ "ខ្លាចហើយ" (ភី-ធាតុ), នីតោ "(គឺជន) នាំទៅហើយ" (នី-ធាតុ), សុតំ "(គឺជន) ឮហើយ,..." (សុ-ធាតុ), ធុតោ "(គឺជន) កម្ចាត់ហើយ,..." (ធុ-ធាតុ) ។ ភូតំ "កើតហើយ" (ភូ-ធាតុ) ។

---

១ មិនស្រូវប្រើ ព្រោះក្រែងច្រឡំនឹង ឥម, ឯត (វិសេសនសព្វនាម) ដែលចុះតោ-បច្ច័យជា ឥតោ ឯតោ ដែរនោះទេដឹង (?) ។ ២ ប្រើជានាមនាមក៏បាន,វិគ្គហៈថាៈបរលោកំ អយិ : អគច្ឆី´តិ> បេតោ (ជនោ) អ្នកទៅហើយកាន់បរលោក" (បរលោកសទ្ទបទ + ឥ + ត, លុប "រលោក" ទុកតែ "ប" ជា បុព្វបទ ។

ធាតុដែលមាន "ម" ជាទីបំផុតត្រូវលុបទីបំផុតធាតុចេញក៏មាន ឧ. គតោ "ទៅហើយ,..." (គម-ធាតុ), រតោ "រីករាយហើយ,..." (រម-ធាតុ) ។ ផ្លាស់ត-បច្ច័យជា "ន្ត" ហើយលុបទីបំផុតធាតុចេញក៏មាន ឧ. បក្កន្តោ "ចៀសចេញទៅហើយ,..." (ប-បុព្វបទ, កម-ធាតុ), ទន្តោ "(គឺជន) ទូន្មានហើយ,..." (ទម-ធាតុ), សន្តោ "រម្ងាប់ហើយ,..." (សម-ធាតុ) ។

ធាតុដែលមាន "ន" ជាទីបំផុត, លុបទីបំផុតធាតុចេញក៏បាន ឧ. ខតោ "(ដែលជន) ជីកហើយ" (ខន-ធាតុ), ហតោ "(ដែលជន) បៀតបៀនហើយ,..." (ហន-ធាតុ) ។ ប៉ុន្តែ ជន-ធាតុ, ត្រូវផ្លាស់ ជន ជា "ជា" ឧ. ជាតោ "កើតហើយ" ។

ធាតុដែលមាន "ច, ជ, ប"ជាទីបំផុត, ផ្លាស់ទីបំផុតធាតុជា "ត[១]" ហើយតម្រួតជាមួយនឹងត-បច្ច័យជា "ត្ត" ក៏បាន ឧ. សិត្តោ "(គឺជន) ស្រោចហើយ" (សិច-ធាតុ) ។ ភុត្តោ "(ដែលជន) បរិភោគហើយ" (ភុជ-ធាតុ) ។ គុត្តោ "(គឺជន)

---

១ មានន័យខ្លះថា ធាតុដែលមាន "ជ" ជាទីបំផុត, ត្រូវផ្លាស់ត-បច្ច័យជា "ទ" សិនហើយសឹមផ្លាស់ ទ ជា "ត" រួចតម្រួតជាមួយនឹងត-បច្ច័យជា "ត្ត" ។

គ្រប់គ្រងហើយ,...″ (គុប-ធាតុ) ។ ប៉ុន្តែ បច-ធាតុ, ត្រូវផ្លាស់ ត-បច្ច័យជា "ក្ក″ ហើយលុបទីបំផុតធាតុចេញ ឧ. បក្កំ "(ដែលជន) ចម្អិនហើយ, ឆេះហើយ″ ។ សុច-ធាតុ, បែរជាត្រូវព្រឹទ្ធិអក្សរដើមធាតុ, ចុះឥ-អាគម ទៅវិញ ឧ. សោចិតោ "សោកហើយ, ស្តាយហើយ″ ។

ធាតុដែលមាន "ធ, ភ″ ជាទីបំផុត, ផ្លាស់ត-បច្ច័យជា "ទ្ធ″ ហើយលុបទីបំផុតធាតុចេញក៏បាន ឧ. កុទ្ធោ "ខឹងហើយ″ (កុធ-ធាតុ) ។ អារទ្ធោ "(គឺជន) ប្រារព្ធហើយ,...″ (អា-បុព្វបទ, រភ-ធាតុ), លទ្ធោ "(ដែលជន) បានហើយ″ (លភ-ធាតុ) ។

ធាតុដែលមាន "ស″ ជាទីបំផុត, ត្រូវផ្លាស់ត-បច្ច័យជា "ដ្ឋ″ ហើយលុបទីបំផុតធាតុចេញ ឧ. តុដ្ឋោ "ត្រេកអរហើយ″ (តុស-ធាតុ), នដ្ឋោ "វិនាសហើយ, ខូចហើយ, បាត់ហើយ,...″ (នស-ធាតុ), ហដ្ឋោ "រីករាយហើយ,...″ (ហស-ធាតុ) ។ ប៉ុន្តែ សុស-ធាតុ, ត្រូវផ្លាស់ ត-បច្ច័យជា "ក្ខ″ ហើយលុបទីបំផុតធាតុចេញ ឧ. សុក្ខ "ស្ងួតហើយ,... ។ ភាស-ធាតុ, បែរជាគ្រាន់តែចុះឥ-អាគមទៅវិញ ឧ. ភាសិតោ "(ដែលជន) ពោលហើយ,...″ ។

ធាតុដែលមាន "ហ" ជាទីបំផុត, ត្រូវផ្លាស់ត-បច្ច័យជា "ឍ" ហើយលុបទីបំផុតធាតុចេញក៏មាន ឧ. ឧឍោ "(ដែលភ្លើង) ឆេះហើយ,..." (ឧហ-ធាតុ) ។ ផ្លាស់ ត-បច្ច័យជា "ហ" ហើយផ្លាស់ "ហ" ទីបំផុតធាតុជា "ឡ" ផ្សំជា "ឡ្ហ[១] ក៏មាន ឧ. មុឡ្ហោ "វង្វេងហើយ,..." (មុហ-ធាតុ) ។ ផ្លាស់ត-បច្ច័យជា "ទ្ធ" ហើយលុបទីបំផុតធាតុចេញក៏មាន ឧ. សន្នទ្ធោ "(ដែលជន) ចងហើយ, សៀតហើយ" (សំ-បុព្វបទ, នហ-ធាតុ, ផ្លាស់និគ្គហិតរបស់ សំ ជា "ន") ។

ចំពោះធាតុខ្លះដោយឡែក ឧ. បុដ្ឋោ "(គឺជន) សួរហើយ" (បុច្ឆ-ធាតុ, ផ្លាស់ត-បច្ច័យជា "ដ្ឋ" ហើយលុបទីបំផុតធាតុ) ។ ភដ្ឋោ, ភគ្គោ "(ដែលជន) បំបាក់ហើយ" (ភញ្ជ-ធាតុ, ផ្លាស់ត-បច្ច័យជា "ដ្ឋ", ជា "គ្គ" ហើយលុបទីបំផុតធាតុ) ។ សក្កា "អាចហើយ,..." (សក-ធាតុ, ផ្លាស់ត-បច្ច័យជា "ក" ហើយលុបទីបំផុតធាតុ) ។ អនុសិដ្ឋោ "(គឺអាចារ្យ) ប្រៀនប្រដៅរឿយៗ ហើយ" (អនុ-បុព្វបទ, សាស-ធាតុ, ផ្លាស់ត-បច្ច័យជា "រិដ្ឋ", លុប "រ"

---

១ តាមបែបខ្លះថាឲ្យផ្លាស់ត-បច្ច័យជា "ឡ្ហ" ហើយលុបទីបំផុតធាតុចេញក៏បាន ។

ចេញ ទុកតែ "ឥដ្ឋ" ហើយលុបទីបំផុតធាតុចេញ រួចលុប អា របស់ សា) ។ ឋិតោ "ឋិតនៅហើយ,..." (ផ្លាស់ អា របស់ ឋា-ធាតុ ជា ឥ) ។ បីតោ "(គឺជន) ផឹកហើយ" (ផ្លាស់ អា របស់ បា-ធាតុ ជា ឦ) ។ ទិន្នោ "(គឺជន) ឲ្យហើយ" (ផ្លាស់ ត-បច្ច័យ ជា ឥន្ន ហើយលុប អា របស់ ទា-ធាតុ) ។ ញាតោ "(គឺជន) ដឹងហើយ" (ញា-ធាតុ) ។ អភិជ្ឈិតោ "(គឺជន) សម្លឹងរំពៃហើយ,..." (អភិ-បុព្វបទ, ឈា-ធាតុ[១], លុប អា របស់ ឈា ហើយតម្រួត ជ, ចុះឥ-អាគម) ។ ឥច្ឆិតំ "(ដែលជន) ប្រាថ្នាហើយ, ចង់បានហើយ",... ... (ឥស-ធាតុ, ផ្លាស់ទីបំផុតធាតុ ជា "ច្ឆ" ចុះឥ-អាគម),... ... ។

ករ-ធាតុ បើមានឧបសគ្គ ៣ តួ គឺ "សំ, ឧប, បរិ" ជា បុព្វបទ, ត្រូវផ្លាស់ "ករ" ជា "ខ" ខ្លះ[២] ជា "ខរ" ខ្លះ តាម

១ មានន័យមួយទៀតថា : អភិ-បុព្វបទ, ឈេ-ធាតុ "គិត, ជញ្ជឹង, កួចកាន់", លុប ឯ របស់ ឈេ ហើយតម្រួត ជ, ចុះ ឥ-អាគម, ត-បច្ច័យ ។ ២ កាលបើមានសព្ទទាំងនេះជាបុព្វបទហើយ ទោះប្រកប បច្ច័យខ្លះទៀត, ក៏ត្រូវផ្លាស់ ករ ជា "ខ" ឬជា "ខរ" ដែរ ឧ. បដិសង្ខរណំ "កិរិយាជួសជុល" (បដិ+សំ+ករ+យុ), សំខាតុំ "ដើម្បីរាប់,..." (សំ+ករ+តុំ), អភិសំខរិត្វា តាក់តែងហើយ, និម្មិតហើយ..." (អភិ+សំ+ករ+ឥ+ត្វា)... ... ។

គួរដល់ការប្រកប ឧ. សំខតោ[១] "(គឺបច្ច័យ) ធ្វើព្រមហើយ, តាក់តែងហើយ,...", ឧបក្ខតោ "ចូលទៅធ្វើហើយ, តាំងធ្វើហើយ,...", បរិក្ខតោ "(គឺជន) ធ្វើជុំវិញហើយ, ហែហមហើយ, ព័ទ្ធហើយ,..." ។ ទោះមាននិបាតសព្ទគឺ "បុរ" នេះជាបុព្វបទក៏អាចផ្លាស់ "ករ" ជា "ខ" បានដែរ ឧ. បុរក្ខតោ "(គឺជន) ធ្វើក្នុងខាងមុខហើយ, ចោមរោមហើយ,..." ។

បែបផ្សំ-បច្ច័យ ជាមួយនឹងធាតុ ដូចបាននិយាយមកហើយនោះក្តី ជាមួយនឹងធាតុឯទៀត ៗ ក្រៅពីនោះក្តី, ជួនណាមិនបាច់លុបឬផ្លាស់អ្វីឡើយ គ្រាន់តែផ្សំជាមួយនឹងធាតុ ជាការស្រេចប៉ុណ្ណោះក៏មាន, ត្រូវចុះឥ-អាគមផ្សំមកផងក៏មាន ត្រូវចុះបច្ច័យសម្រាប់ពួកធាតុ (អាខ្យាត) ចុះនិគ្គហិតអាគម ចុះឥ-អាគមមកផងក៏មាន, ត្រូវប្រើវិធីផ្លាស់ ឬព្រឹទ្ធិ ឬតម្រួត ក៏មាន តាមគួរដល់ការប្រកប, អ្នកសិក្សា បើបានប្រទះបែបប្រើ ត-បច្ច័យមានគតិប្លែកអំពីវិធីដែលបាននិយាយមកហើយនោះ, ចូរសង្កេតចំណាំឲ្យជាក់ ត្រាតែបានយល់ដោយទូលាយជាងនេះទៅទៀត

---

១ ផ្លាស់និគ្គហិតជា "ង" ជា សង្ខតោ ក៏បាន ។

ចុះ ព្រោះនៅមានវិធីប្លែកជាងនេះទៅទៀតច្រើន ។ ឧទាហរណ៍ខាងមុខនេះ ជារបៀបរាយរង គ្រាន់តែជាគ្រឿងចំណាំដោយសង្ខេប ៖

មរ-ធាតុ : មតោ, មរិតោ, មារិតោ, តរ-ធាតុ : តិណ្ណោ, តរិតោ, បុរ-ធាតុ : បុណ្ណោ, បូរិតោ, ភិទ-ធាតុ : ភិន្នោ, ភិន្ទិតោ, ភូ-ធាតុ : ភូតោ, ភាវិតោ, រម-ធាតុ : រតោ, រមិតោ, ទម-ធាតុ : ទន្តោ, ទមិតោ, ហន-ធាតុ : ហតោ, ហនិតោ, ឃាតិតោ, សិច-ធាតុ : សិត្តោ, សិញ្ចិតោ, ភុជ-ធាតុ : ភុត្តោ, ភុញ្ជិតោ, គុប-ធាតុ : គុត្តោ, គោបិតោ, កុធ-ធាតុ : កុទ្ធោ កុជ្ឈិតោ, លភ-ធាតុ : លទ្ធោ, លភិតោ, ហស-ធាតុ : ហដ្ឋោ, ហសិតោ, សំ-បុព្វបទ, នហ-ធាតុ : សន្នទ្ធោ, សន្នយ្ហិតោ, គហ-ធាតុ : គហិតោ, គណ្ហិតោ, វហ-ធាតុ : វហិតោ, បុច្ឆ-ធាតុ : បុដ្ឋោ, បុច្ឆិតោ, ភញ្ជ-ធាតុ : ភដ្ឋោ, ភគ្គោ, ភញ្ជិតោ, អនុ-បុព្វបទ, សាស-ធាតុ : អនុសិដ្ឋោ, អនុសាសិតោ, អភិ-បុព្វបទ, ឈា-ធាតុ : អភិជ្ឈិតោ, អភិជ្ឈាយិតោ, ញា-ធាតុ : ញាតោ, ជានិតោ, ភី-ធាតុ : ភីតោ, ភាយិតោ, សី-ធាតុ : សយិតោ, និ-បុព្វបទ, វា-ធាតុ : និព្វុតោ, បរិ-បុព្វបទ,

វា-ធាតុ : បរិនិព្វុតោ[១], និ-បុព្វបទ, បទ-ធាតុ : និព្វុតោ[២], អា-បុព្វបទ, បទ-ធាតុ : អាបន្នោ, ឧ-បុព្វបទ, បទ-ធាតុ : ឧប្បន្នោ, ឧប-បុព្វបទ, បទ-ធាតុ : ឧបបន្នោ, ប-បុព្វបទ, ហា-ធាតុ : បហីនោ[៣], ចិរ-សព្ទ : ចិរាយិតោ[៤], ប-បុព្វបទ, ហិ-ធាតុ : បហិតោ, បហិតា, បហិតំ,... ... ។

ឧទាហរណ៍ដែលចុះត-បច្ច័យ ដូចបាននិយាយមកហើយទាំងប៉ុន្មាននោះប្រើបានចំពោះវាចកៈ ៣ យ៉ាងគឺ កត្តុវាចកៈ, កម្មវាចកៈ, ភាវវាចកៈមានរូបសិទ្ធិដូចគ្នាតែបែបមួយ, ដែលនឹងអាចដឹងថាជាវាចកៈណានោះ ត្រូវស្ទង់មើលដំណើរប្រយោគនិងលំនាំសេចក្ដី, បើឃើញថា, បណ្ដាវាចកៈទាំង ៣ យ៉ាងនោះ, មានសេចក្ដីជាក់នៅខាងវាចកៈណា ចូរប្រែតាមដំណើររបស់វាចកៈនោះចុះ, ប៉ុន្តែបើជាអកម្មធាតុត្រូវប្រើបានខាងកត្តុវាចកៈ និងភាវវាចកៈតែពីរយ៉ាងប៉ុណ្ណោះ បើជាសកម្មធាតុ ត្រូវប្រើបានចំពោះវាចកៈទាំង ៣ យ៉ាង ។

---

១ ផ្លាស់ វ ជា ព, ផ្លាស់ អា ជា ឧ. តម្រួត ព ជាពីរតួ ។ ២ លុប ទ ទីបំផុតនៃបទធាតុ ហើយផ្លាស់ ប ជា ព រួចតម្រួត ព ជាពីរតួ ។ ៣ ផ្លាស់ ត-បច្ច័យជា ឦន, លុប អា របស់ ហា-ធាតុ ។ ៤ ចិរ-សព្ទ, អាយ-បច្ច័យ (អាខ្យាត) ឥ-អាគម, ត-បច្ច័យ ។

ចំណែកខាងហេតុកម្មវាចកៈ, ត្រូវចុះណាបេ-បច្ច័យ លុប ណ និង ឯ ទុកតែត្រឹម អាប ព្រមទាំងឥ-អាគមមកផង, មិនបាច់ចុះបច្ច័យសម្រាប់ពួកធាតុ (អាខ្យាត) ក៏មាន, ត្រូវចុះបច្ច័យសម្រាប់ពួកធាតុមកផង ក៏មាន ។ ដែលមិនបាច់ចុះបច្ច័យសម្រាប់ពួកធាតុ : មារាបិតោ "(គឺជន) ឲ្យស្លាប់ហើយ" (មរ+ណាបេ + ឥ + ត), ឃាតាបិតោ "(ដែលជន) ឲ្យសម្លាប់ហើយ,..." (ហន + ណាបេ + ឥ + ត, ហន > ឃាត), ភោជាបិតោ "(ដែលជន) ឲ្យបរិភោគហើយ" (ភុជ + ណាបេ + ឥ + ត),... ។ ដែលត្រូវចុះបច្ច័យ សម្រាប់ពួកធាតុមកផង : ជានាបិតោ "(គឺជន) ឲ្យដឹងហើយ" (ញា + នា + ណាបេ + ឥ + ត, ញា > ជា), រជ្ជាបិតំ "(ដែលជន) ឲ្យជ្រលក់ហើយ" (រជ + យ[១] + ណាបេ + ឥ + ត), ... ... ។ ធាតុឯទៀត ៗ ក្រៅពីនេះ ត្រូវសម្រេចតាមគួរដល់ការប្រកប ដូចបាននិយាយក្នុងខាងដើមរួចមកហើយ ។

---

១ យ-បច្ច័យសម្រាប់ពួកទិវ-ធាតុ : ជ + យ > ជ្ជ ។

ត-បច្ច័យនេះ សម្រាប់ប្រើ ខាងប៉ែកកិរិយាកិតកៈក៏ពិត ប៉ុន្តែជួនណាប្រើជានាមកិតកៈក៏បាន ឧ. ពុជ្ឈតី´តិ > ពុទ្ធោ (ភគវា) "(ព្រះមានព្រះភាគ) ទ្រង់ត្រាស់ដឹង" ក. ក. (ផ្លាស់ ត-បច្ច័យជា "ទ្ធ" ហើយលុប ធ ទីបំផុតនៃ ពុធ-ធាតុ) ។ តថា-អាគមី´តិ > តថាគតោ (ភគវា) " (ព្រះមានជោគ) ទ្រង់មក ហើយដោយប្រការដូច្នោះ" ក. ក. (តថា-បុព្វបទ, អា-បុព្វបទ, គម-ធាតុ, ត-បច្ច័យ), តថា-អគមី´តិ-វា > តថាគតោ (ភគវា) "ម្យ៉ាងទៀត (ព្រះមានជោគ) ទ្រង់បានទៅហើយ ដោយប្រការ ដូច្នោះ" ក. ក. (តថា-បុព្វបទ, គម-ធាតុ, ត-បច្ច័យ) ។ ធម្មេ-រមតី´តិ > ធម្មរតោ (ជនោ) "(ជន) អ្នករីករាយក្នុងធម៌" ក. ក. (ធម្ម-សទ្ទបបទ, រម-ធាតុ, ត-បច្ច័យ) ។ ធម្មំ-រក្ខតី´តិ > ធម្មរក្ខិ-តោ (ភិក្ខុ) "(ភិក្ខុ) អ្នករក្សានូវធម៌" ក. ក. (ធម្ម-សទ្ទបបទ, រក្ខ-ធាតុ, ឥ-អាគម, ត-បច្ច័យ) ។ សរតី´តិ > សរតោ (ជនោ) "(ជន) អ្នករឭក, អ្នកនឹកឃើញ" ក. ក. (សរ-ធាតុ, ត-បច្ច័យ) ។ (រូបាទីសុ) - សញ្ជតី´តិ > សត្តោ (ជនោ) "(ជន) អ្នកចំពាក់

(ក្នុងអារម្មណ៍មានរូបារម្មណ៍ជាដើម)″ ក. ក. (សជ-ធាតុ, ត-បច្ច័យ, ផ្លាស់ទីបំផុតធាតុជា ‶ត[១]″ តម្រួតជាមួយនឹងត-បច្ច័យជា ‶ត្ត″) ។ (អត្តនោ-មាតាបិតូនំ-ហទយំ) - បូរេតី´តិ > បុត្តោ (ជនោ) ‶(ជន) អ្នក (ញុំាំងហឫទ័យ នៃមាតានិងបិតា របស់ខ្លួន) ឲ្យពេញ = កូនប្រុស″ ក. ក. (បុរ-ធាតុ, ត-បច្ច័យ, ផ្លាស់ទីបំផុតធាតុជា ‶ត″ ហើយតម្រួតជាមួយនឹងត-បច្ច័យជា ‶ត្ត″ ឬលុបទីបំផុតធាតុហើយតម្រួតបច្ច័យក៏បាន), (អត្តនោ-កុលំ) បុនាតី´តិ-វា > បុត្តោ (បុរិសោ) ‶ម្យ៉ាងទៀត (បុរស) អ្នកសម្អាត (នូវត្រកូល របស់ខ្លួន) ក. ក. (បុ-ធាតុ, ត-បច្ច័យតម្រួតជា ‶ត្ត″) ។ (ទារុអាទីនិ) - លាតិ : អាទទាតិ - ឯតាយា´តិ > លតា (ភូតគាមជាតិ) ‶(ភូតគាមជាតិ) សម្រាប់កាន់យក[២] (នូវវត្ថុមានឧសជាដើម នៃជន) = វល្លិ″ ក. ករ.(លា-ធាតុ, ត-បច្ច័យ, អា-បច្ច័យ រស្សៈ អា របស់ លា ជា អ),... ... ។

---

១ មានន័យខ្លះថា ឲ្យផ្លាស់ ត-បច្ច័យជា ‶ទ″ សិនហើយសឹមផ្លាស់ ទ ជា ‶ត″ រួចតម្រួតជាមួយនឹងត-បច្ច័យជា ‶ត្ត″ ។ ២ ពាក្យថា ‶កាន់យក″ ក្នុងទីនេះ សំដៅដំណើរប្រើការផ្សេងៗមាន ‶ចងឧស″ ជាដើម ។

សព្ទដែលចុះត-បច្ច័យនេះ, បើជាកិរិយាកិតកៈ មិនបាច់តាំងវិគ្គហៈឡើយ គ្រាន់តែសម្រេចរូបហើយជាការស្រេច, បើជានាមកិតកៈ ត្រូវតាំងវិគ្គហៈតាមគួរដល់ការប្រកប ។

ត្វា, ត្វាន, តូន[១]: បច្ច័យទាំង ៣ នេះ ជាអព្យយបច្ច័យ, កាលបើចុះផ្សំជាមួយនឹងធាតុហើយ, សព្ទដែលសម្រេចហើយនោះមានរូបយ៉ាងណា ក៏នៅយ៉ាងនោះ, មិនមានវិធីឲ្យចុះវិភត្តិនាម ឬឲ្យផ្លាស់ប្រែទៅទៀតឡើយ[២], កាលបើចុះមកហើយមានវិធីរូបសិទ្ធិផ្សេង ៗ ដូចរបៀបជាសង្ខេបតទៅនេះ ៖

---

១ អព្យយបច្ច័យទាំង ៣ នេះ, ក្នុងបករណៈទាំងពួង ច្រើនហៅថា តូនាទិបច្ច័យ "បច្ច័យមានតូនជាដើម", បើតាមពាក្យនេះគួររៀបរៀងជា "តូន, ត្វាន, ត្វា" ឬ "តូន, ត្វា, ត្វាន", ប៉ុន្តែបានសង្កេតឃើញរបៀបឧទាហរណ៍ដែលលោករៀងនោះមិនទៀងៈ ជួនណារៀង តូន មុន, ជួនណារៀង ត្វា មុន, ព្រោះហេតុនោះបានជា ក្នុងទីនេះ ខ្ញុំរៀង ត្វា ឲ្យនៅមុន ដ្បិត ត្វា មានប្រើច្រើនជាង បន្ទាប់មក ត្វាន, ឯ តូន រៀងក្រោយបង្អស់ព្រោះប្រើតិចណាស់ យូរៗ មានប្រទះឃើញខ្លះ, ខ្ញុំរៀបរៀងយ៉ាងនេះ ដើម្បីនឹងសម្តែង ឧទាហរណ៍យក ត្វា ចេញមុខជាមេរបៀប តាមដំណើរដែលប្រើច្រើនជាងគេ, បើទុកជារៀង ត្វា ឲ្យនៅមុនបង្អស់ដូច្នេះ ក៏គង់មានអំណាចឲ្យហៅថា "តូនាទិ-បច្ច័យ" បាន, ឬបើនឹងហៅតាមរបៀបក្នុងទីនេះថា ត្វាទិបច្ច័យ "បច្ច័យមានត្វាជាដើម" ដូច្នេះក៏សឹងតែបាន ព្រោះបច្ច័យទាំង ៣ នេះមានអំណាចស្មើគ្នា ចង់រៀងណា មុន, ហៅចេញឈ្មោះណាមុន ក៏ឥតមានទាស់ឡើយ ។ ២ ចូរមើល ក្នុងនាមនិទ្ទេសលេខ ១២៧ ត្រង់ពួកទី ៤ ។

បើមានឧបសគ្គៈណាមួយ ជាបុព្វបទនៃធាតុខ្លះដែលគួរប្រកប, ត្រូវផ្លាស់បច្ច័យទាំង ៣ នោះណាមួយជា "យ" ហើយទុកឲ្យនៅជា "យ" ប៉ុណ្ណោះក៏មាន, ផ្លាស់ "យ" នោះនិងទីបំផុតធាតុជាព្យញ្ជនៈផ្សេងទៅទៀតក៏មាន, ដូចរបៀបខាងមុខនេះ ៖

ធាតុដែលមាន "អា" ជាទីបំផុត, ត្រូវទុក "យ" ឲ្យគង់រូប ឧ. អាទាយ "កាន់យកហើយ, នាំទៅហើយ,..." (អា-បុព្វបទ, ទា-ធាតុ), ឧដ្ឋាយ "តាំងឡើងហើយ, ក្រោកឡើងហើយ,..." (ឧ-បុព្វបទ, ឋា-ធាតុ), អភិញ្ញាយ[១] "ដឹងចំពោះហើយ,..." (អភិ-បុព្វបទ, ញា-ធាតុ), អភិវន្ទិយ "ថ្វាយបង្គំចំពោះហើយ,..." (អភិ-បុព្វបទ, វន្ទ-ធាតុ, ឥ-អាគម),... ... ។

ធាតុដែលមាន "ទ" ជាទីបំផុត, ផ្លាស់ "យ" នោះនិងទីបំផុតធាតុជា "ជ្ជ" ក៏បាន ឧ. អច្ឆិជ្ជ "ដណ្ដើមយកហើយ,..." (អា-បុព្វបទ រស្សៈ ជា អ, ឆិទ-ធាតុ), ឧបបជ្ជ "ចូលទៅដល់ហើយ,..." (ឧប-បុព្វបទ, បទ-ធាតុ),... ... ។

---

១ ជួនណាលុប "យ" ចេញក៏មានខ្លះ អភិញ្ញាយ > អភិញ្ញា, បដិសង្ខាយ > បដិសង្ខា (បដិ+សំ+ខា+យ)... ។

ធាតុដែលមាន "ម" ជាទីបំផុត, ផ្លាស់ "យ" នោះនិងទីបំផុតធាតុជា "ម្ម" ក៏បាន ឧ. និក្ខម្ម "ចេញហើយ,..." (និ-បុព្វ-បទ, ខម-ធាតុ), ឧបគម្ម ចូលទៅដល់ហើយ,..." (ឧប-បុព្វ-បទ, គម-ធាតុ), អាគម្ម "មកហើយ,..." (អា-បុព្វបទ, គម-ធាតុ), អបកម្ម "គេចចេញហើយ,..." (អប-បុព្វបទ, កម-ធាតុ)... ។

ធាតុដែលមាន "ភ" ជាទីបំផុត, ផ្លាស់ "យ" នោះនិងទីបំផុតធាតុជា "ព្ភ" ក៏បាន ឧ. អារព្ភ "ប្រារព្ធហើយ,..." (អា-បុព្វបទ, រភ-ធាតុ) ។

ធាតុដែលមាន "ធ" ឬ "ភ" ជាទីបំផុត, បើទុកជាមិនមានឧបសគ្គជាបុព្វបទ, ផ្លាស់ "យ" នោះនិងទីបំផុតធាតុជា "ទ្ធា" ឬ "ទ្ធាន[១]" ក៏បាន ឧ. វិទ្ធា "បាញ់ហើយ, ចាក់ហើយ,..." (វិធ-ធាតុ), លទ្ធា, លទ្ធាន, "បានហើយ,..." (លភ-ធាតុ),... ... ។

ធាតុដែលមាន "ហ" ជាទីបំផុត, ផ្លាស់ "យ" នោះនិងទីបំផុតធាតុជា "យ្ហ" ក៏បាន ឧ. បគ្គយ្ហ "ផ្គងហើយ,..."

---

១ ត្រូវផ្លាស់ ត្វាន ឬ តូន ជា "យ" ហើយផ្លាស់ "យ" ជា "ទ្ធាន" ឲ្យសមតាមរូបដើមដែលមាន "ន" ។

(ប-បុព្វបទ, គហ-ធាតុ), សន្នយ្ហ "ចងមាំហើយ, សៀត ហើយ,..." (សំ-បុព្វបទ, នហ-ធាតុ), អារុយ្ហ "ឡើងហើយ" (អា-បុព្វបទ, រុហ-ធាតុ),... ។

ធាតុដែលមានឧបសគ្គជាបុព្វបទ, មិនបាច់ផ្លាស់បច្ច័យ ទាំង ៣ ណាមួយជា "យ" (ត្រូវទុកឲ្យគង់រូបនៅតាមដើម) ក៏មាន ដោយច្រើនណាស់ ឧ. វិគរហិត្វា "តិះដៀលហើយ ផ្សេងៗ,..."(វិ-បុព្វបទ,គរហ ធាតុ, ឥអាគម), និក្ខមិត្វា "ចេញហើយ,..." (និ-បុព្វបទ, ខម-ធាតុ,ឥអាគម, និសីទិត្វា "អង្គុយហើយ"(និ-បុព្វបទ,សទ-ធាតុផ្លាស់ជាសីទ,ឥអាគម),ឧប-សង្កមិត្វា "ចូលទៅជិតហើយ, ចូលទៅរកហើយ,..." (ឧប-បុព្វ-បទ, សំ-បុព្វបទ, កម-ធាតុ, ឥ-អាគម), អនុភវិត្វា"សោយហើយ, រងហើយ,..."(អនុ-បុព្វបទ, ភូ-ធាតុ ផ្លាស់ឩ ជា ឱ ហើយផ្លាស់ ឱ ជា អវ, ឥ-អាគម),... ... ។

ធាតុដែលមាន "ច" ឬ "ន" ជាទីបំផុត, ផ្លាស់បច្ច័យ ទាំង ៣ ណាមួយជា "រច្ច" រួចលុប "រ" ទុកតែ "ច្ច" ហើយ លុបទីបំផុតធាតុក៏បាន ឧ. វិវិច្ច "ស្ងាត់វិសេសហើយ,..." ( វិ-បុព្វ-

បទ, វិច-ធាតុ), អាហច្ច "ចុច, ទើស, ទល់, កល់, កើល, ទង្គិច ហើយ,..." (អា-បុព្វបទ, ហន-ធាតុ)... ... ។ ចំពោះឥ-ធាតុ, បើមានឧបសគ្គជាបុព្វបទ, ក៏ត្រូវផ្លាស់យ៉ាងនុ៎ះបានដែរ ឧ. អតិច្ច "កន្លងហើយ,..." (អតិ-បុព្វបទ, ឥ-ធាតុ), បដិច្ច "អាស្រ័យហើយ,..." (បដិ-បុព្វបទ, ឥ-ធាតុ), បេច្ច "ទៅបាត់ទៅហើយ, ទៅកាន់បរលោកហើយ..." (ប-បុព្វបទ, ឥ-ធាតុ) ។

ចំពោះតែ ទិស-ធាតុ មួយ, ផ្លាស់ ត្វា ជា ស្វា, ផ្លាស់ ត្វាន ជា ស្វាន ក៏បាន ឧ. ទិស្វា "ឃើញហើយ", ទិស្វាន "លុះឃើញហើយ" ។ បើមានឧបសគ្គជាបុព្វបទ, ត្រូវផ្លាស់បច្ច័យទាំង ៣ ណាមួយ នឹង ស ទីបំផុតនៃទិស-ធាតុជា "ស្ស" ក៏បាន ឧ. ឧទ្ទិស្ស "សម្តែងហើយ,..." (តម្រួត ទ) ។ គ្រាន់តែផ្លាស់បច្ច័យជា "យ" ហើយចុះឥ-អាគមមកក៏បានខ្លះ ឧ. ឧទ្ទិសិយ ។ មិនបាច់ផ្លាស់អ្វីឡើយ, គ្រាន់តែចុះឥ-អាគមមកក៏បាន ឧ. ឧទ្ទិសិត្វា (ឧ-បុព្វបទ, ទិស-ធាតុ) ។ ទោះមិនមានឧបសគ្គជាបុព្វបទក៏ដោយ, ផ្លាស់ "ទិស" ជា "បស្ស" ក៏បាន ឧ. បស្សិយ, បស្សិត្វា, បស្សិត្វាន (ចុះឥ-អាគមទាំង ៣ បទ) ។

វិធីប្លែកជាងនេះ នៅមានទៅទៀតច្រើនណាស់, អ្នករៀនចូរសង្កេតឧទាហរណ៍ទាំងឡាយខាងមុខនេះ ជាបែបធៀប ហើយនឹកទៅរកវិធីរូបសិទ្ធិខាងអាខ្យាត និងរូបសិទ្ធិនៃតុំ-បច្ច័យ, ត-បច្ច័យខាងដើមផង ក៏គង់នឹងអាចយល់បានដោយងាយ :

ទា : ទត្វា, ទទិត្វា(១), អា+ទា(២): អាទាយ, អាទិយិត្វា(១), សំ+អា+ទា : សមាទាយ, សមាទិយិត្វា ។ ហា : ហិត្វា, ជហិត្វា(៤), ប + ហា : បហាយ, បជហិត្វា, វិ + ហា : វិជហិត្វា, បរិ+ហា : បរិ-ហាយិត្វា(៥), អវ > ឱ + ហា(៦):ឱហាយិត្វា ។ ឈា : ឈាយិត្វា, ឧ + ឈា : ឧជ្ឈាយិត្វា ។ ឋា : ឋត្វា, ឧ + ឋា : ឧដ្ឋាយ, ឧដ្ឋហិត្វា(៧): ឧប + ឋា : ឧបដ្ឋហិត្វា(៨) ។ ញា : ញត្វា, ជានិត្វា(៩), សំ + ញា :

---

១ អព្ភាសៈ ជា ទាទា, រស្សៈ អា របស់អព្ភាសៈ ជា អ, ចុះឥ-អាគម, លុប អា របស់ធាតុ (ប៉ុន្តែទទិត្វា មិនសូវប្រើ, ច្រើប្រើតែ ទត្វា) ។ ២ មើលថា អា-បុព្វបទ និងទា-ធាតុ, ឬថា អា-បុព្វបទ, ទា-ធាតុ ។ ៣ ផ្លាស់ អា របស់ ទា ជា ឥ, ចុះយ-បច្ច័យ (សម្រាប់ពួក ទិវ-ធាតុ), ចុះ ឥ-អាគម ។ ៤ អព្ភាសៈ ជា ហា-ហា, ផ្លាស់ ហា-អព្ភាសៈជា "ជ", រស្សៈ អា-អព្ភាសៈជា អ, ចុះឥ-អាគម, លុប អា របស់ ហា-ធាតុ ។ ៥ ផ្លាស់ អា របស់ហា-ធាតុជា អាយ, ចុះឥ-អាគម ។ ៦ មើលថា អវ-បុព្វបទ ផ្លាស់ជា ឱ, ហា-ធាតុ ។ ៧-៨ រស្សៈ អា របស់ ឋា ជា អ ហើយ តម្រួតដ លើ ឋ ជា ដ្ឋ ចុះ ហ-អាគមនិងឥ-អាគម ។ ៩ ផ្លាស់ ញា ជា "ជា", លុប អា របស់នា-បច្ច័យ (សម្រាប់ពួកកី-ធាតុ), ចុះឥ-អាគម ។

សញ្ជានិត្វា, បរិ+ញា : បរិញ្ញាយ, បរិជានិត្វា ។ បា : បិវិត្វា, បិត្វា ។ ជិ : ជិត្វា, ជេត្វា, ជិនិត្វា, វិ+ជិ : វិជិត្វា, វិជេត្វា, វិជិនិត្វា ។ ភី : ភាយិត្វា[១], ន > អ+ភី : អភាយិត្វា ។ សី : សយិត្វា, អធិ + សី : អធិសយិត្វា ។ នី : នេត្វា, ឧប+នី : ឧបនីយ, ឧបនេត្វា, វិ+នី : វិនេត្វា ។ ហុ : ហុត្វា ។ បុ : បវិត្វា ។ សុ : សុត្វា, សុណិត្វា, បដិ+សុ : បដិសុណិត្វា ។ ភូ : ភវិត្វា, អភិ+ភូ : អភិភុយ្យ, អភិភវិត្វា, អនុ+ភូ : អនុភុយ្យ, អនុភវិត្វា ។ វន្ទ : វន្ទិត្វា, អភិ+វន្ទ : អភិវន្ទិយ, អភិវន្ទិត្វា ។ ឆិទ : ឆិន្ទិត្វា, ឆេត្វា, អា > អ+ឆិទ : អច្ឆិជ្ជ, អច្ឆិន្ទិត្វា ។ កុជ : កុត្វា, កុញ្ជិត្វា, បរិ+កុជ : បរិកុញ្ជិត្វា ។ វិធ : វិទ្ធា, វិទ្ធាន, វិជ្ឈិត្វា[២], ប+វិធ : បវិទ្ធា, បវិជ្ឈិត្វា ។ លភ : លទ្ធា, លទ្ធាន, លភិត្វា ។ សំ+នហ : សន្នយ្ហ, សន្នយ្ហិត្វា[៣] ។ គហ : គហេត្វា, គណ្ហិត្វា, ឧ+គហ : ឧគ្គហេត្វា, ឧគ្គណ្ហិត្វា, ប+គហ : បគ្គយ្ហ, បគ្គហេត្វា ។ ប+អាប : បាបុណិត្វា[៤] ។ មទ : មទិត្វា,

១ ព្រឹទ្ធិ ឦ របស់ ភ ជា ឯ ហើយផ្លាស់ ឯ ជា អយ រួចទីឃៈ អយ ជា អាយ ចុះឥ-អាគម ។ ២ ផ្លាស់ យ-បច្ច័យ (សម្រាប់ពួកទិវ-ធាតុ) និងទីបំផុតធាតុជា ជ្ឈ, ចុះឥ-អាគម ។ ៣ ចុះ យ-បច្ច័យ (សម្រាប់ ពួកទិវ-ធាតុ) ហើយផ្សំ យ និងទីបំផុតធាតុជាយ្ហ, ចុះឥ-អាគម ។ ៤ លុប អា របស់ ឧណា-បច្ច័យ (សម្រាប់ ពួកសុ-ធាតុ) ចុះឥ-អាគម ។

ប+មទ : បមជ្ជ, បមជ្ជិត្វា ។ រុទ : រោទិត្វា, ប+រុទ : បរោទិត្វា ។ បទ : បត្វា, អា+បទ : អាបជ្ជិត្វា[១], ឧ+បទ : ឧប្បជ្ជិត្វា, ឧប+បទ: ឧបបជ្ជ, និ+បទ : និព្វត្តិត្វា[២] ។ ជន : ជនិត្វា, វិ+ជន : វិជាយ, វិជាយិត្វា[៣] ។ វា : វាយិត្វា, ប+វា : បវាយ, បវាយិត្វា, បរិ+និ+វា : បរិនិព្វាយិត្វា[៤] ។ គម : គន្ត្វា, អា+គម : អាគម្ម, អាគន្ត្វា, ឧប+គម : ឧបគម្ម, ឧបគន្ត្វា ។ មន្ត : មន្តេត្វា, មន្តយិត្វា[៥], អា+មន្ត : អាមន្តេត្វា, អាមន្តយិត្វា, និ+មន្ដ : និមន្តេត្វា, និមន្តយិត្វា ។ ចិរ-សព្ទ : ចិរាយិត្វា[៦] ។ និទ្ទ-សព្ទ : និទ្ទាយិត្វា[៧] ។ ហន : ហន្ត្វា, ហន្ត្វាន, ហន្តូន ។ ករ : ករិត្វា, កត្វា, កត្វាន, កត្តូន, កាតូន,... ... ។

បច្ច័យទាំង ៣ នេះ មានអំណាចឲ្យចុះបានគ្រប់វាចកៈទាំង ៥ (ព្រោះជាកិតកិច្ច-បច្ច័យ), ប៉ុន្តែច្រើនប្រើតែខាងកត្តុវាចកៈនិង

---

១ ផ្លាស់យ-បច្ច័យ (សម្រាប់ពួកទិវ-ធាតុ) និងទីបំផុតធាតុជា ជ្ជ, ចុះឥ-អាគម ។ ២ ផ្លាស់ "ប" (អក្សរដើមធាតុ) ជា "ព ហើយតម្រួត ជា "ព្វ", ផ្លាស់ "ទ" ទីបំផុតធាតុជា "ត" ហើយតម្រួត "ត្ត", ចុះឥ-អាគម ។ ៣ ផ្លាស់ "ជន" ជា "ជា" ហើយផ្លាស់ អា របស់ "ជា" ជា អាយ, ចុះឥ-អាគម ។ ៤ ផ្លាស់ អា របស់ "វា" ជា អាយ, ផ្លាស់ "វ" ជា "ព" ហើយតម្រួតជា "ព្វ", ចុះឥ-អាគម ។ ៥ ចុះ ណេ, ណយសម្រាប់ ពួកចុរ-ធាតុ (ជាកត្តុវាចកៈ) ។ ៦ ចិរ-សព្ទ, អាយ-បច្ច័យ (អាខ្យាត), ឥ-អាគម ។ ៧ និទ្ទ-សព្ទ, អាយ-បច្ច័យ (អាខ្យាត), ឥ-អាគម ។

ហេតុកត្តុវាចកៈ ។ ឧទាហរណ៍ទាំងប៉ុន្មានដែលនិយាយមកហើយនោះ សម្រាប់ប្រើខាងកត្តុវាចកៈ, ឯខាងហេតុកត្តុវាចកៈ ត្រូវចុះការិត-បច្ច័យមកផង, ត្រូវចុះបច្ច័យសម្រាប់ពួកធាតុផ្សំមកផងក៏មាន, ត្រង់ ណយ និង ណាបយ ត្រូវចុះឥ-អាគមមកផង, ដូចឧទាហរណ៍ជាសង្ខេបតទៅនេះ ៖

បច-ធាតុ : បាចេត្វា, បាចយិត្វា, បាចាបេត្វា, បាចាបយិត្វា "ឲ្យចម្អិនហើយ,..." ។ ភុជ-ធាតុ : ភោជេត្វា, ភោជយិត្វា, ភោជាបេត្វា, ភោជាបយិត្វា, ភុញ្ជេត្វា, ភុញ្ជយិត្វា, ភុញ្ជាបេត្វា, ភុញ្ជាបយិត្វា "ឲ្យបរិភោគហើយ" ។ សិវ-ធាតុ : សិព្វេត្វា, សិព្វយិត្វា, សិព្វាបេត្វា, សិព្វាបយិត្វា "ឲ្យដេរហើយ,..." ។ សុ-ធាតុ : សាវេត្វា, សាវយិត្វា, (សាវាបេត្វា,[១] សាវាបយិត្វា) "ឲ្យឮហើយ, ឲ្យស្តាប់ហើយ", ញា-ធាតុ : ញាបេត្វា, ញាបយិត្វា, ជានាបេត្វា, ជានាបយិត្វា "ឲ្យដឹងហើយ" ។ គហ-ធាតុ : គាហាបេត្វា, គាហាបយិត្វា, គណ្ហាបេត្វា, គណ្ហាបយិត្វា "ឲ្យកាន់យកហើយ, ឲ្យចាប់ហើយ,..." ។

---

១ ឧទាហរណ៍ទាំង ២ នេះ ពិតជាប្រកបជាមួយនឹងបច្ច័យបានមែន ប៉ុន្តែមិនសូវប្រើទេ ។

ករ-ធាតុ : ការេត្វា, ការយិត្វា, ការាបេត្វា, ការាបយិត្វា, "ឲ្យធ្វើហើយ" ។ ចុរ-ធាតុ : ចោរេត្វា, ចោរយិត្វា[១], ចោរាបេត្វា, ចោរាបយិត្វា "ឲ្យលួចហើយ" ។ ទា-ធាតុ : ទាបេត្វា, ទាបយិត្វា "ឲ្យឲ្យហើយ" ។ បា-ធាតុ : បាយេត្វា "ឲ្យផឹកហើយ",... ។ ហា-ធាតុ : ហាបេត្វា, ហាបយិត្វា, "ឲ្យបាត់ហើយ",... ។ ភូ-ធាតុ : ភាវេត្វា, ភាវយិត្វា "ឲ្យកើតហើយ",... ។ ភី-ធាតុ : ភាយិត្វា "ឲ្យខ្លាចហើយ" ។ ចិរ-សព្ទ : ចិរាយេត្វា "ឲ្យប្រព្រឹត្តយូរហើយ = នាំឲ្យយូរ",... ... ... ។

បច្ច័យទាំង ៣ នេះប្រាប់អតីតកាលច្រើនជាងកាលឯទៀត, ឯ "កាល" ដែលបច្ច័យទាំង ៣ ត្រូវប្រព្រឹត្តទៅបាននោះ, បើនិយាយដោយសព្វគ្រប់, មាន ៧ យ៉ាងគឺ បុព្វកាល, បរិយោសានកាល, សមានកាល, អបរកាល, ហេតុកាល, នាមវិសេសន, កិរិយាវិសេសន[២] ។

---

១ ណេ និង ណយ នេះ, បើសម្រាប់ពួកចុរ-ធាតុ ប្រើជាកត្តុវាចកៈ, បើសម្រាប់ ខាងពួកការិត-បច្ច័យ ប្រើជាហេតុកត្តុវាចកៈ (ក្នុងទីនេះ ជាហេតុកត្តុវាចកៈ) ។ ២ រាប់យកត្រឹមតែ ៦ យ៉ាងក៏បាន, គឺរាប់នាមវិសេសនៈនិង កិរិយាវិសេសនៈ រួមឲ្យនៅតែមួយហៅត្រឹមតែ វិសេសនៈ ប៉ុណ្ណោះ ហើយសឹមចែកវិសេសនៈចេញជា ២ យ៉ាងគឺនាមវិសេសនៈ១ កិរិយាវិសេសនៈ ១, ដែល រាប់ជា ៧ យ៉ាងដូច្នេះ គឺចែកឲ្យស្រេចតែម្តង ដើម្បីឲ្យងាយ កុំចាំបាច់ចែកទៀត ។

បុព្វកាល : អតីតកាលដែលគ្រាន់តែប្រាប់ថាកន្លងហើយ ហៅថា "បុព្វកាល" ឲ្យប្រែថា "-ហើយ" ឬថា "-រួចហើយ" ក៏បានខ្លះ ត្រូវប្រែមុនកិរិយារបស់ប្រធាន ឧ. សោ ភត្តំ គណ្ហិ-ត្វា ភុញ្ជិ (ចូរមើលក្នុងខាងដើម ត្រង់លេខ ១៧៦) ។

បរិយោសានកាល : អតីតកាលដែលកន្លងស្រេចហើយ ហៅថា "បរិយោសានកាល" ឲ្យប្រែថា "លុះ-ហើយ" ឬថា "លុះ-រួចហើយ" ក៏បានខ្លះ, ត្រូវប្រែក្រោយបន្ទាប់អាខ្យាតកិរិយា ដែលមានរូបធាតុត្រូវនឹងខ្លួនដែរ ឧ. អយំ កុលបុត្តោ មំ ទិស្វា មម សង្គហំ ករិស្សតិ, កត្វា ច បន មហាសម្បត្តឹ លភិស្សតិ (មើលក្នុងខាងដើម ត្រង់លេខ ១៧៧) ។

សមានកាល : កាលដែលប្រាប់សេចក្តី មានលំនាំជាបច្ចុប្បន្នថា "កំពុងតែ-" ឬ "ដែលកំពុង-" ហៅថា "សមា-នកាល", ត្រូវប្រែមុនកិរិយារបស់ប្រធាន, តែមិនចេញពាក្យថា "-ហើយ" ទេ គ្រាន់តែប្រែចេញសព្ទរបស់ធាតុប៉ុណ្ណោះ ឧ. សេដ្ឋី ឧបាហនំ អារុយ្ហ ឆត្តំ ធារេត្វា មគ្គេន គច្ឆតិ "សេដ្ឋី ពាក់ នូវស្បែកជើង បាំង នូវឆត្រ ដើរ-តាមផ្លូវ-ទៅ" ។

អបរកាល : កាលប្រាប់ដំណើរ របស់កិរិយាសព្ទ ដែលតួប្រធានត្រូវសម្រេច តបន្ទាប់អំពីកិរិយារបស់ប្រធាន ហៅថា "អបរកាល", ត្រូវប្រែក្រោយកិរិយារបស់ប្រធាន ប្រែថា "-ហើយ" ក៏បាន, មិនថា "-ហើយ" ក៏បាន (តាមគួរដល់ដំណើរសេចក្តី) ឧ. ធម្មកថិកោ ធម្មាសនេ និសីទិ តត្ថេវ ឋបិតំ ចិត្តវីជនឹ គហេត្វា "ធម្មកថិក អង្គុយ-លើធម្មាសនៈ-ហើយ ចាប់ នូវផ្លិតដ៏វិចិត្រ ដែលគេដាក់ នាធម្មាសនៈនោះស្រាប់" ។

ហេតុកាល : កាល ដែលប្រាប់ដំណើរសេចក្តីថា "ព្រោះ-" ឬ "ព្រោះតែ-" ហៅថា "ហេតុកាល" ត្រូវប្រែ ក្រោយកិរិយារបស់ប្រធាន ប្រែថា "ហេតុ-, ព្រោះ-" ឬ "ព្រោះតែ-" ក៏បានខ្លះ ឧ. ឥទំ មេ ទុក្ខំ តុម្ហេ និស្សាយ ជាតំ "សេចក្តីព្រួយ នេះ កើតហើយ ដល់ខ្ញុំ ព្រោះអាស្រ័យ នូវអ្នកទាំងឡាយ" ។ ភរិយំ មេ និស្សាយ ភយេន ឧប្បន្នេន ភវិតព្វំ (ចូរមើលខាងដើមត្រង់លេខ ១៧៧) ។

នាមវិសេសនៈ : កាល ដែលប្រើជាវិសេសនៈរបស់នាមសព្ទ ហៅថា "នាមវិសេសនៈ", ត្រូវប្រែមុនកិរិយារបស់ប្រធាន,

មិនប្រែថា "-ហើយ" ទេ ឧ. ឋបេត្វា ទ្វេ អគ្គសាវកេ អវ-សេសា អរហត្តំ បាបុណឹសុ "ភិក្ខុដ៏សេសទាំងឡាយ, លើកទុក នូវអគ្គសាវ័កទាំងឡាយ ពីរ, ដល់ហើយ នូវអរហត្ត" ។ (ឋបេត្វា ជានាមវិសេសនៈ របស់ អវសេសា) ។

កិរិយាវិសេសនៈ : កាល ដែលប្រើជាវិសេសនៈរបស់កិរិយា-សព្ទ គឺនាំកិរិយាសព្ទឲ្យមានសេចក្ដីប្លែក ជាងប្រក្រតី (ដូចកិរិយាវិសេសនៈទាំងពួងដែរ) ហៅថា "កិរិយាវិសេសនៈ", ត្រូវប្រែក្រោយកិរិយារបស់ប្រធាន, មិនប្រែថា "-ហើយ" ទេ ឧ. តីណិ រតនានិ ឋបេត្វា អញ្ញំ មេ បដិសរណំ នត្ថិ "ទីពឹងឯទៀត របស់ខ្ញុំ មិនមានទេ វៀរលែង នូវព្រះរតនៈទាំងឡាយបី" ។ (ឋបេត្វា ជាកិរិយាវិសេសនៈ ក្នុង នត្ថិ) ។

គតិរបស់បច្ច័យក្នុងកិតកនិទ្ទេសនេះ មិនមែនអស់ហើយត្រឹមតែប៉ុណ្ណោះទេ នៅមានវិធីនៃរូបសិទ្ធិប្លែកៗ ទៅទៀតជាច្រើន, វេយ្យាករណបណ្ឌិត ជាអាចារ្យបង្រៀន ចូរអធិប្បាយពន្យល់សិស្ស ឲ្យបានទូលាយវិសេសជាងនេះទៅទៀតផងចុះ ។

កិតកនិទ្ទេស ទី ៦ ចប់ ដោយសង្ខេបតែប៉ុណ្ណោះ ។

# ឧណាទិនិខ្មែស ទី ៧

## ឧណាទិនិទ្ទេសទី ៧

### ឧណាទិ

[១៨២] ឧណាទិនិទ្ទេសនេះ មានគតិដូចគ្នានឹងកិតក-និទ្ទេសដែរ, បើនិយាយដោយរួបរួមទៅ ក៏គឺកិតកៈនុ៎ះឯង, ប៉ុន្តែមានបច្ច័យប្លែកគ្នា អំពីកិតកនិទ្ទេសជាច្រើន, ទាំងបច្ច័យដែលបាននិយាយហើយក្នុងកិតកនិទ្ទេសនោះ លោកក៏យកមកប្រើក្នុងឧណាទិនិទ្ទេសនេះខ្លះទៀត គ្រាន់តែសម្ដែងវិធីមានអាទេស (ផ្លាស់) ជាដើម ផ្សេងគ្នាខ្លះអំពីវិធីក្នុងកិតកនិទ្ទេសប៉ុណ្ណោះ, ឯសាធនៈមានដំណើរដូចគ្នានឹងកិតកៈ ។

នឹងនិយាយក្នុងនិទ្ទេសនេះ ចំពោះតែបច្ច័យខ្លះដែលប្លែកគ្នាអំពីបច្ច័យក្នុងកិតកនិទ្ទេស ព្រមទាំងឧទាហរណ៍ជាសង្ខេបឲ្យសមល្មមដល់កម្លាំងនៃកុលបុត្រអ្នកសិក្សាថ្មី ។

### បច្ចេក-បច្ច័យ

[១៨៣] បច្ច័យក្នុងឧណាទិដែលប្លែកគ្នាអំពីបច្ច័យក្នុងកិតកៈ ហៅថា បច្ចេក-បច្ច័យ ″បច្ច័យផ្សេងដោយឡែក″, ក្នុងទី

នេះ និយាយដោយសង្ខេបត្រឹមតែ ២៥ គឺ ថ, ម, ល, យ, យាណ, លាន, ថុ, ត្តិម, ណិម, ណុ, ត្រណ, ធ, ទ, តទ្វ, ក, តវ, អល, ទុ, ព្វីវ, ឝរ, នុ, ណុ, ឧស្ស, នុស, តស ។

បណ្តាបច្ច័យទាំង ២៥ នេះ បច្ច័យណាជាកិត-បច្ច័យ ឬ ជាកិច្ច-បច្ច័យ ឬក៏ជាកិតកិច្ច-បច្ច័យនោះ, អ្នកសិក្សាចូរសង្កេត ហើយកំណត់ដឹង តាមដំណើរវិគ្គហៈ ព្រមទាំងរូបសព្ទ ដែល សម្រេចហើយនោះចុះ ។

## ឧទាហរណ៍ដោយសង្ខេប

[១៨៤] ឧទាហរណ៍ដែលប្រកបដោយបច្ច័យទាំង ២៥ នោះ មានពិស្តារនៅក្នុងកច្ចាយនបករណ៍ឧណាទិឯណោះ, ក្នុង ទីនេះ និយាយដោយសង្ខេប គ្រាន់តែជាគ្រឿងចំណាំ ដូច មានរបៀបតទៅនេះ ៖

ថ : រូបសិទ្ធិសម្រាប់បច្ច័យនេះ ដូច្នេះ ៖

១- មិនបាច់ព្រឹទ្ធិធាតុក៏បាន ឧ. បច្ចនីកធម្មេ - សមត្ថេ - តី´តិ > សមថោ (ធម្មោ) "(ធម៌) រម្ងាប់នូវធម៌ជាសត្រូវ" ក. ក. (សម-ធាតុ) ។

២- ផ្លាស់ទីបំផុតធាតុជាព្យញ្ជនៈផ្សេងក៏បាន ឧ. ទហនំ > ទរថោ "កិរិយាក្ដៅក្រហាយ, សេចក្ដីក្រវល់ក្រវាយ" ភ. ភ. (ផ្លាស់ ហ[១] ទីបំផុតនៃ ទហ-ធាតុជា "រ") ។

៣- លុបទីបំផុតធាតុក៏បាន ឧ. រហិតព្វោ : គណ្ហិតព្វោ′តិ > រថោ (យានវិសេសោ) "(យានវិសេស) ដែលជនគួរកាន់យក = ដែលគេគួរជិះ" កម្ម. កម្ម. (លុប ហ ទីបំផុតនៃ រហ-ធាតុ), រមន្តិ : កីឡន្តិ - អនេនា′តិ-វា > រថោ (យានវិសេសោ) "ម្យ៉ាងទៀតថា (យានវិសេស) ជាគ្រឿងលេងសប្បាយ (នៃជន)" ក. ករ. (លុប ម ទីបំផុតនៃ រម-ធាតុ) ។

៤- ចំពោះធាតុ ៣ តួគឺ សុ, វុ, អស នេះ ឲ្យផ្លាស់ ឧ. របស់ សុ, វុ ជា អត, ផ្លាស់ អស ជា អត ឧ. សវន្តិ : សត្តេ-ហឹសន្តិ-ឯតេនា′តិ > សត្ថំ (បហរណវត្ថុ) "(វត្ថុសម្រាប់ប្រហារ) ជាគ្រឿងបៀតបៀននូវសត្វ (នៃជន) = សស្ត្រា" ក. ករ. (ផ្លាស់ ឧ របស់ សុ-ធាតុជា អត) ។ វុណោតិ : ហិរោត្ត-

១ ក្នុងបករណៈឯទៀតខ្លះថា ឲ្យតាំង ទរ-ធាតុ,ចុះថ-បច្ច័យ, មិនបាច់ផ្លាស់ទីបំផុតធាតុឡើយ ឧ. ទរន្តិ : ទហន្តិ-ឯតេហីតិ > ទរថា (កិលេសា) "(កិលេសទាំងឡាយ) ជាហេតុរោលរាល (នៃសត្វ)" ក. ករ., ទរណំ : ទហនំ វា > ទរថោ ភ. ភ. ។

ប្បំ-សំវរតិ-ឯតេនា´តិ > វត្ថំ (វត្ថុ) "(វត្ថុ) សម្រាប់បិទបាំងនូវហិរិ និងឱត្តប្បៈ (នៃជន) = សំពត់" ក. ករ. (ផ្លាស់ ឱ របស់ វុ-ធាតុ ជា អត) ។ សទ្ធានុរូបំ[១] បសតិ : ភវតី´តិ > អត្ថោ (សភាវោ) "(សភាវៈ) កើតតាមសមគួរដល់សព្ទ=សេចក្តី" ក. ក. (ផ្លាស់ អស-ធាតុទាំងមូលជា "អត") ។

៥- ផ្លាស់ទីបំផុតធាតុជា "ត" ក៏បាន ឱ. សសន្តិ : សត្តេ-ហឹសន្តិ-ឯតេនា´តិ > សត្ថំ (បហរណវត្ថុ) "(វត្ថុសម្រាប់ប្រហារ) ជាគ្រឿងបៀតបៀននូវសត្វ (នៃជន) = សស្ត្រា" ក. ករ. (ស-សុ-ធាតុ ឬ សស-ធាតុ, ផ្លាស់ទីបំផុតធាតុជា "ត") ។ សាសតិ : អត្ថេ-អាចិក្ខតិ-ឯតេនា´តិ > សត្ថំ (បករណំ) (គម្ពីរ) សម្រាប់ប្រាប់នូវអត្ថ (នៃអ្នកប្រាជ្ញ) = សាស្ត្រា" ក. ករ. (សាស-ធាតុ, ផ្លាស់ទីបំផុតធាតុជា "ត", រស្សៈ អា របស់ សា ជា អ) ។ សរន្តិ : បវត្តន្តិ-ឯត្ថា´តិ > សត្ថោ (សមូហោ) "(ប្រជុំ) ជាទីប្រព្រឹត្តទៅ (នៃជន) = ពួក" ក. អធិ. (ផ្លាស់ រ ទីបំផុតនៃ សរ-ធាតុ ជា "ត") ។ វសតិ : ហិរោត្តប្បំ-អច្ឆាទេតិ-ឯតេនា´តិ > វត្ថំ (វត្ថុ)

១ សទ្ធានុរូបំ ជាកិរិយាវិសេសនៈ ក្នុង ភវតិ ។

"(វត្ថុ) ជាគ្រឿងបិទបាំងនូវហិរិនិងឱត្តប្បៈ (នៃជន)=(សំពត់)" ក. កវ. (ផ្លាស់ ស ទីបំផុតនៃវស-ធាតុជា "ត") ។ អវន្តិ : បវត្តន្តិ-អនេនា'តិ > អត្ថោ[១] (សភាវោ) "(សភាវៈ) សម្រាប់ប្រព្រឹត្តទៅ (នៃជន)" = (ទ្រព្យ, សម្បត្តិ)" ក. កវ. (ផ្លាស់ វ ទីបំផុតនៃអវ-ធាតុជា "ត") ។

ម : រូបសិទ្ធិសម្រាប់បច្ច័យនេះ ដូច្នេះ

១- មិនបាច់ព្រឹទ្ធិធាតុក៏បាន ឧ. អត្តនោ-សីតលភាវេន-សត្តេ-ហិនោតិ : ហឹសតី'តិ > ហិមំ (ធម្មជាតំ) "(ធម្មជាត) បៀតបៀននូវសត្វដោយភាវៈនៃខ្លួនជាធាតុត្រជាក់ = (សន្សើម)" ក. ក. (ហិ-ធាតុ) ។ ភាយិតព្វោ'តិ > ភីមោ (យក្ខោ) "(យក្ស) ដែលជនគួរខ្លាច" កម្ម. កម្ម., ភាយន្តិ-ឯតស្មា'តិ > ភីមំ (ឋានំ) "(ទី) ជាដែនខ្លាច "នៃជន)" ក. អបា. (ភី-ធាតុ) ។

២- ព្រឹទ្ធិធាតុក៏បាន ឧ. សិយតេ : សមគ្គេន-សង្ឃេន-កម្មវាចាយ-ពន្ធិយតេ'តិ > សីមា (ភូមិ) "(ទី) ដែលសង្ឃព្រម

---

១ អត្ថ-សព្ទនេះ មានន័យច្រើនយ៉ាង គឺឲ្យប្រែថា: ការសម្តែងនូវសព្ទ (សេចក្តី): ទ្រព្យសម្បត្តិ, ប្រយោជន៍, សេចក្តីចម្រើន, វត្ថុ, ហេតុ ។ល។ អ្នករៀន, កាលបើបានប្រទះសព្ទនេះ, ចូរសង្កេតឲ្យជាក់ ហើយប្រែតាមសមគួរដល់ដំណើរសេចក្តីចុះ ។

ព្រៀងគ្នាចងដោយកម្មវាចា" កម្ម. កម្ម, (ទីឃៈ ត របស់ សិ-ធាតុ ជា ឦ ផ្សំនឹងម-បច្ច័យជា សីម ចុះអា-បច្ច័យមកផងជា សីមា) ។

ល និង យ : បច្ច័យទាំង ២ នេះចុះបានចំពោះតែអំពីមុខ ធាតុគឺ អល, កល, សល តែ ៣ ប៉ុណ្ណោះ ឧ. អលតិ : សជ្ជតី´តិ > អល្លំ, អល្យំ (ធម្មជាតំ) "(ធម្មជាត) ជាប់នៅ" ក. ក. (អល-ធាតុ) ។ កលិតព្វំ : សំខ្យាតព្វន្តិ > កល្លំ, កល្យំ (ធម្មជាតំ) "(ធម្មជាត) ដែលជនគប្បីរាប់" កម្ម. កម្ម. (កល-ធាតុ) ។ សត្តានំ-សរីរេ-សលតិ : គច្ឆតិ : បវិសតី´តិ > សល្លំ, សល្យំ[១] (បហរណវត្ថុ) "(វត្ថុជាគ្រឿងប្រហារ) ចូលទៅក្នុងសរីរនៃសត្វ=(សរ-កូនសរ)" ក. ក., សត្តានំ-ជីវិតំ-សលតិ : វិធំសេតិ-ឯតេនា´តិ-វា > សល្លំ, សល្យំ[១] (បហរណវត្ថុ) "ម្យ៉ាងទៀតថា (វត្ថុជាគ្រឿងប្រហារ) សម្រាប់កម្ចាត់បង់នូវជីវិតនៃសត្វ (នៃជន)" ក. ករ. (សល-ធាតុ) ។

យាណៈ បច្ច័យនេះ ចុះបានចំពោះតែអំពីមុខ កល-ធាតុមួយប៉ុណ្ណោះ ឧ. កលិតព្វំៈ សំខ្យាតព្វន្តិ > កល្យាណំ[១]

---

១ អល្យ, កល្យ, សល្យ ទាំង ៣ សព្ទនេះ ពិតជាចុះយ-បច្ច័យយ៉ាងនេះបានមែន ប៉ុន្តែមិនសូវប្រើទេ ច្រើនប្រើតែ អល្ល, កល្ល, សល្ល ។

២ កល្យាណ-សព្ទនេះប្រើជាគុណនាមប្រែថា "ល្អ, ពីរោះ, ជាទីពេញចិត្ត" ។

(គុណជាតំ) "(គុណជាត) ដែលជនគួររាប់ = លម្អ" កម្ម. កម្ម, បដិវឹសំ - កលិតព្វំ : សំខ្យាតព្វន្តិ > បដិកល្យាណំ (វត្ថុ) "(វត្ថុ) ដែលជនគប្បីរាប់ឲ្យជាចំណែក" កម្ម. កម្ម. (បដិវឹស-សទ្ទបបទ, លុប វឹស ចេញ ទុកតែ បដិ ជា បុព្វបទ) ។

លាន : បច្ច័យនេះ ចុះបានចំពោះតែអំពីមុខសល-ធាតុមួយប៉ុណ្ណោះ ឧ. គណតោ - បដិក្កមិត្វា - សលតិ-ឯត្ថា'តិ > បដិ-សល្លានោ (បទេសោ) "(ប្រទេស) ជាទីគេចចេញអំពីពួកហើយសម្ងំនៅ (នៃយោគី)" ក. អធិ. (លុប ក្កមិត្វា ចេញ ទុកតែ បដិ ជា បុព្វបទ) ។

ថុ : វេបេនេ-និព្វតោ > វេបុថុ (រោគោ) "(រោគ) កើតហើយព្រោះកិរិយាញាប់ញ័រ" ក. ក. (ព្រឹទ្ធិ ឥ របស់ វិ នៃវិបុ-ធាតុជា ឯ) ។ សយេន-និព្វតោ > សយថុ (រោគោ) "(រោគ) កើតហើយព្រោះកិរិយាដេក" ក. ក. (ព្រឹទ្ធិ ឦ របស់ សី-ធាតុជា អយ) ។ ទវេន-និព្វតោ > ទវថុ (រោគោ) "(រោគ) កើតហើយព្រោះកិរិយាក្តៅក្រហាយ" ក. ក. (ទវ[១]-ធាតុ) ។ វមេន-

---

១ ក្នុងបករណៈខ្លះថាឲ្យតាំង ទុ-ធាតុ "ក្តៅក្រហាយ, អន្ទះអន្ទែង", ព្រឹទ្ធិ ឧ របស់ ទុ ជា អវ ។

និព្វតោ > វមថុ (រោគោ) "(រោគ) កើតហើយព្រោះកិរិយាចង្អោរ" ក. ក. (វម-ធាតុ) ។

ត្តិម : ទានេន-និព្វត្តំ > ទត្តិមំ (ធនំ) "(ទ្រព្យ) កើតហើយព្រោះអំណោយ" ក. ក. (វស្សៈ អា របស់ទា-ធាតុជា អ) ។

ណិម : បច្ច័យនេះជាណានុពន្ធៈ, ត្រូវលុប ណ ទុកតែ ឥម, ត្រូវព្រឹទ្ធិធាតុដែលជាវស្សៈសុទ្ធ ឧ. អវហនេន-និព្វត្តំ > ឱហារិមំ (ធនំ) "(ទ្រព្យ) កើតហើយព្រោះកិរិយាបូជា" ក.[១] ក. (អវ-បុព្វបទ, ហុ-ធាតុ "បូជា", ផ្លាស់អវ-បុព្វបទជា ឱ, ព្រឹទ្ធិ ឧ របស់ ហុ ជា អវ ហើយទីឃៈ អវ ជា អាវ, លុប ណ ទុកតែ ឥម) ។

ណុ : បច្ច័យនេះជាណានុពន្ធៈ, ត្រូវលុប ណ ទុកតែ ឧ, ត្រូវព្រឹទ្ធិធាតុ ដែលជាវស្សៈសុទ្ធ, ចុះបានតែក្នុងកាល ២ គឺ

---

១ បច្ច័យទាំង ៣ គឺ "ថុ, ត្តិម, ណិម" នេះ, បើតាមដំណើរវិគ្គហៈ គួរតែរាប់បញ្ចូលក្នុងតទ្ធិតឯណោះសោះទេ, គួរហៅថា "និព្វតតទ្ធិត" ប៉ុន្តែដោយសារលោកយកមករៀបរៀងក្នុងឧណាទិ, ហើយតាំងជាតួធាតុប្រកបនឹងបច្ច័យដូច្នេះ, ក៏គួរឲ្យឈ្មោះឧទាហរណ៍ទាំងនេះជា "កត្តុរូបកត្តុសាធនៈ" តាមន័យនេះចុះ, ព្រោះវិគ្គហៈរបស់កត្តុសាធនៈ មានអំណាចឲ្យប្រើអាខ្យាតកិរិយា ឬកិតកិរិយា ដែលជាកត្តុវាចកៈ បានដូចគ្នា ។

បច្ចុប្បន្នកាល និង អតីតកាល ឧ. ករោតី'តិ > ការុ (ជនោ) "(ជន) អ្នកធ្វើ" ក. ក., អកាសី'តិ > ការុ (ជនោ) "(ជន) អ្នកបានធ្វើហើយ" ក. ក. (ទីឃៈ អ របស់ ក នៃ ករ-ធាតុ ជា អា, លុប ណ ទុកតែ ឧ) ។

ត្រណ[១] : បច្ច័យនេះជាណានុពន្ធៈ, ត្រូវលុប ណ ទុកតែ ត្រ, ប៉ុន្តែត្រូវព្រឹទ្ធិធាតុក៏បាន មិនបាច់ព្រឹទ្ធិក៏បាន ព្រោះ ត្រ ជាព្យញ្ជនៈ ទ្វេភាពស្រាប់ ឧ. អាតបំ-ឆាទេតី'តិ > ឆត្រំ (វត្ថុ) "(វត្ថុ) បាំងនូវកម្ដៅថ្ងៃ" ក. ក., អាតបំ-ឆាទេតិ-ឯតេនា'តិ-វា > ឆត្រំ (វត្ថុ) "ម្យ៉ាងទៀតថា (វត្ថុ) សម្រាប់បាំងនូវកម្ដៅថ្ងៃ (នៃជន) = ឆត្រ-តាំងយូ" ក. ករ. (លុប ទ ទីបំផុតនៃ ឆទ-ធាតុ, លុប ណ ទុកតែ ត្រ) ។ យុញ្ជន្តិ : សត្តេ-ពន្ធន្តិ-ឯតេនា'តិ > យោត្រំ[២]

---

១ ក្នុងកច្ចាយនបករណ៍អក្សរសីហឡៈ (អក្សរអ្នកលង្កាទ្វីប) និង អក្សរមរម្មៈ (ភូមា) ជា"ត្រណ", សូម្បីកច្ចាយនបករណ៍ស្លឹករឹតរបស់ យើងក៏មានចារជា "ត្រណ" ខ្លះដែរ, ឲ្យមើលថា "ត្រ័ណ" ឬថា "ត្រណ៍" ក៏បាន ។
២ ត្រណ-បច្ច័យនេះ ពិតជាចុះយ៉ាងនេះបានមែន ប៉ុន្តែក្នុងបាឡីភាសា មិនសូវប្រើទេ ច្រើនប្រើត-បច្ច័យជាជំនួស បច្ច័យនេះ, ក្នុងកច្ចាយន-បករណ៍ឧណាទិ មានសម្ដែងឧទាហរណ៍ ជាគូគ្នានឹងត-បច្ច័យ, ដូចជា ឧទាហរណ៍ទាំង ២ នេះលោកតាំង វិគ្គហៈជាមួយគ្នាតែម្ដងថា អាតបំ-ឆាទេតី'តិ > ឆត្តំ, ឆត្រំ : យុញ្ជន្តិៈ សត្តេ-ពន្ធន្តិឯតេនា'តិ > យោត្តំ, យោត្រំ ។ ឆត្តំ, យោត្តំ ចុះត-បច្ច័យ ផ្លាស់ទីបំផុតធាតុជា "ត" ។ បើចង់ដឹង ឧទាហរណ៍ពិស្ដារ, ចូរមើល ក្នុងកច្ចាយនបករណ៍ឧណាទិ ។

(វត្ថុ) "(វត្ថុ) សម្រាប់ប្រកប គឺថា សម្រាប់ចងនូវសត្វ (នៃជន) = ខ្សែ" ក. ករ. (លុប ជ ទីបំផុតនៃ យុជ-ធាតុ ហើយព្រឹទ្ធិ ឧ របស់ យុ ជា ឱ, លុប ណ ទុកតែ ត្រ) ។

ធ : បច្ច័យនេះ ច្រើនចុះតែអំពីមុខធាតុដែលមានអក្សរ ២ តួ ឧ. (សប្បាទយោ)-រមន្តិ-ឯត្ថា´តិ > រន្ធំ (ឋានំ) "(ទី) ជាទីរីករាយ (នៃសត្វមានពស់ជាដើម) = រន្ធ, រូង, ប្រហោង, ព្រង់" ក. អធិ. (ផ្លាស់ ម ទីបំផុតនៃ រម-ធាតុជា "ន", ផ្សំជា រន្ធ), រណិតព្វំ :ទូសេតព្វន្តិ-វា > រន្ធំ (ធម្មជាតំ) "ម្យ៉ាងទៀតថា (ធម្ម-ជាត) ដែលជនគួរប្រទូស្ត = ទោស, កំហុស សេចក្តីពិរុធ)" កម្ម. កម្ម. ផ្លាស់ ណ ទីបំផុតនៃ រណ-ធាតុជា "ន", ផ្សំជា រន្ធ) ។ រោគំ-ឱសាបេតី´តិ > ឱសធំ[១] (ភេសជ្ជំ) "(ភេសជ្ជៈ) ញុំាងរោគឲ្យក្តៅ=ថ្នាំរម្ងាប់រោគ" ក. ក. (ព្រឹទ្ធិ ឧ នៃ ឧស-ធាតុ ជា ឱ, ផ្សំជា ឱសធ) ។

---

១ ក្នុងបករណៈខ្លះថាឲ្យតាំង ឧស-ធាតុ, ចុះថ-បច្ច័យ, សម្រេចរូបជា ឱសថ (ជានបុំ.), ប្រែដូចគ្នានឹង ឱសធ នេះដែរ ។

ទ : បច្ច័យនេះ ច្រើនចុះតែអំពីមុខធាតុដែលមាន "ទ" ជាទីបំផុត, ត្រូវផ្លាស់ទីបំផុតធាតុជា "ន" ក៏មាន, ផ្សំ "ទ" ទីបំផុតធាតុជាមួយនឹងបច្ច័យជា "ទ្ទ" ក៏មាន (តាមគួរដល់ការប្រកប) ឧ. ចទិតព្វោ : ឥច្ឆិតព្វោ'តិ > ចន្ទោ (ទេវបុត្តោ) "(ទេវបុត្ត) ដែលជនគួរចង់បាន = ព្រះចន្ទ" កម្ម. កម្ម. (ផ្លាស់ ទ ទីបំផុតនៃ ចទ-ធាតុជា "ន") ។ សំ : សុដ្ឋុ-ឧទន្តិ : បសវន្តិ - (វារិវាហា) - ឯត្ថា'តិ > សមុទ្ទោ (បទេសោ) "(ប្រទេស) ជាទីហូរទៅដោយប្រពៃ (នៃផ្លូវទឹក) = សមុទ្ទ" ក. អធិ. (សំ-បុព្វបទ, ឧទ-ធាតុ ផ្លាស់និគ្គហិត របស់ សំ ជា "ម", ផ្សំទីបំផុតធាតុជាមួយនឹងបច្ច័យជា ទ្ទ) ។

ឥទ្ទ : ទលតិ : ទុគ្គតភាវំ-គច្ឆតី'តិ > ទលិទ្ទោ (ជនោ) "(ជន) អ្នកទ័ល គឺថា អ្នកដល់នូវភាពនៃខ្លួនជាបុគ្គលទុគ៌ត = អ្នកកម្សត់" ក. ក. (ទល-ធាតុ[១]) ។

---

១ ក្នុងបករណៈខ្លះថាឲ្យតាំង ទល-ធាតុ ផ្លាស់ ល ជា ឡ, ខ្លះថាឲ្យតាំង ទឡ-ធាតុ ចុះឥទ្ទ-បច្ច័យ, សម្រេចរូបជា "ទឡិទ្ទ" ប្រែចេញសព្វដូចគ្នានឹង ទលិទ្ទ នេះដែរ ។

ក : រូបសិទ្ធិសម្រាប់បច្ច័យនេះ ដូច្នេះ ៖

១- ឲ្យផ្លាស់ទីបំផុតធាតុជា "ក" ឧ. វចិតព្វំ : បរិភាសិតព្វន្តិ > វក្កំ (អាការជាតំ) "(អាការ[១]) ដែលជនគួរតិះដៀល = ទាច" កម្ម. កម្ម. (ផ្លាស់ ច ទីបំផុតនៃ វច-ធាតុជា "ក" ផ្សំជាមួយនឹងបច្ច័យជា "ក្ក") ។

២- គ្រាន់តែចុះក-បច្ច័យមកជាលំនាំ ហើយលុបចេញ ក៏បាន ឧ. ភឱិតព្វំ : ភាជិតព្វន្តិ > ភណ្ឌំ (វត្ថុ) "(វត្ថុ) ដែលជនគួរបែក" កម្ម. កម្ម. ភឱិតព្វំ : ពន្ធិតព្វន្តិ-វា > ភណ្ឌំ (វត្ថុ) "ម្យ៉ាងទៀតថា (វត្ថុ) ដែលជនគប្បីវេច = ទ្រព្យ, អីវ៉ាន់" កម្ម. កម្ម. (ភឱិ-ធាតុ ឬ ភឌ-ធាតុ ក៏បាន, ចុះនិគ្គហិតអាគម ហើយផ្លាស់និគ្គហិតជា "ណ", លុប ក-បច្ច័យចេញ) ។

៣- សព្ទដែលចុះបច្ច័យឯទៀតស្រេចហើយ, ចុះ ក-បច្ច័យក្នុង សកត្ថ ផ្សំមកទៀតក៏បាន ដូចជា "មញ្ច, គាម, ខន្ធ, អន្ធ, គន្ធ" នេះ ចុះ ក-បច្ច័យថែមមកជា "មញ្ចក, គាមក, ខន្ធក, អន្ធក, គន្ធក",... ... ។

---

១ អាការជាតំ ប្រែត្រឹមតែ "អាការ" ប៉ុណ្ណោះក៏បាន ព្រោះ "ជាត" ចុះក្នុង សកត្ថ "អត្ថរបស់ខ្លួន" ចុះមកគ្រាន់តែសម្រួលលិង្គប៉ុណ្ណោះ ។

ឥរ : វជតិ : អប្បដិហតភាវំ - គច្ឆតី'តិ > វជិរំ (រតនវត្ថុ) "(រតនវត្ថុ) ដល់នូវភាវៈនៃខ្លួនជារបស់ដែលវត្ថុឯទៀតកម្ចាត់បង់ពុំបាន = ពេជ្រ" ក. ក. វជ-ធាតុ ។

អល : កុសេ : បាបស្សច្ឆទនេ - អលន្តិ > កុសលំ (គុណ-ជាតំ) "(គុណជាត) គួរក្នុងកិរិយាផ្តាច់នូវបាប" ក. ក., កុសតិ : បាបកេ : អកុសលេ ធម្មេ - ឆិន្ទតី'តិ - វា > កុសលំ (គុណជាតំ) "មា្យ៉ាងទៀតថា (គុណជាត) ផ្តាច់នូវធម៌ដ៏អាក្រក់ គឺធម៌ជាអកុសល" (កុស-[១]ធាតុ) ។ ចណ្ឌេ-អលន្តិ > ចណ្ឌាលោ (ជនោ) "(ជន) គួរក្នុងដំណើរកាច" ក. ក., ចណ្ឌេតិ : អញ្ញេ-បីឡេ-តី'តិ-វា > ចណ្ឌាលោ (ជនោ) "មា្យ៉ាងទៀតថា (ជន) អ្នកបៀតបៀននូវជនឯទៀត" ក. ក. (ចណ្ឌ-ធាតុ, ទីឃៈ អ របស់ អល-បច្ច័យជា អា) ។

---

១ កុសល-សព្ទនេះ មានន័យច្រើនយ៉ាងទៀត, ដូចន័យមានដើមថា កុសេ-រាគាទយោ លុនាតិ : ឆិន្ទតី'តិ > កុសលំ (គុណជាតំ) "(គុណជាត) កាត់នូវកិលេសមានរាគៈជាដើមដេកនៅក្នុងសន្តានដោយអាការដែលបណ្ឌិតគួរខ្ពើម" ក. ក. (កុល-សទ្ទុបបទ, លុ-ធាតុ អ-បច្ច័យ, លុប ឧ របស់ លុ)... ... ។

ទុ : ទុក្ខំ - អទតិ : អនុភវតិ - ឯតេនា´តិ > អទ្ទុ[១] (ពន្ធវត្ថុ) "(វត្ថុសម្រាប់ចង) ជាគ្រឿងស៊ីនូវទុក្ខ គឺថា ជាគ្រឿងរងនូវទុក្ខ (នៃជន) = ខ្នោះ" ក. ករ. (អទ-ធាតុ, ផ្សំទីបំផុតធាតុជាមួយនឹងបច្ច័យជា ទ្ទុ) ។ ទុក្ខវេទនំ-ទទាតី´តិ > ទទ្ទុ (រោគោ) "(រោគ) ឲ្យនូវទុក្ខវេទនា = អុតធំ[២]" ក. ក. (ទា-ធាតុ, អក្ខរសៈជា ទា-ទា, រស្សៈ ជា ទ-ទ, ផ្សំ ទ ខាងចុងជាមួយនឹងបច្ច័យជា ទ្ទុ) ។

ល្លិវរ : ចយិតព្វន្តិ > ចីវរំ (វត្ថំ) "(សំពត់) ដែលបព្វជិតគួរសន្សំ" កម្ម. កម្ម. (ចិ-ធាតុ, លុប ឥ របស់ធាតុចេញ) ។ បាតព្វន្តិ > បីវរំ (ឧទកំ) "(ទឹក) ដែលជនគួរផឹក" កម្ម. កម្ម. បា-ធាតុ[៣], លុប អា របស់ធាតុចេញ) ។ ជាលកុមិនាទីនិ-ទធាតី´តិ > ធីវរោ (ជនោ) អ្នកទ្រទ្រង់នូវនេសាទុបករណ៍[៤] មានសំណាញ់និងទ្រូជាដើម = នេសាទមច្ឆជាតិ" ក. ក. (ធា-ធាតុ, លុប អា របស់ធាតុចេញ) ។

---

១ ក្នុងបរកណៈខ្លះថា "អន្ទុ" (ជាឥត្ថីលិង្គ) ប្រែថា "ខ្នោះ" ដែរ ។ " ទទ្ទុ លោកអាចារ្យខ្លះ ប្រែថា "កមរលាយ", ខ្លះប្រែ "កញ្ច្រិល" ។ ៣ ក្នុងបករណៈខ្លះក្រៅពីកច្ចាយនៈ ថាឲ្យតាំង បី-ធាតុ "ពេញ" ចុះល្លិវរ-បច្ច័យ, សម្រេចរូបជា "បីវរ" ដូច្នេះដែរប្រើជាគុណនាម ឲ្យប្រែថា "ពេញ, ធាត់, ថ្លោស" ដូចគ្នានឹង "បិន, ថុល្ល" ។ ៤ គ្រឿងប្រដាប់របស់នេសាទ ។

ឝរ : អត្តនោ-គន្ធេន-អញ្ញំ-គន្ធំ-កប្បតិ : ហនតិ : ហឹសតី´តិ > កប្បូរោ (វត្ថុវិសេសោ) "(វត្ថុវិសេស) បៀតបៀននូវក្លិនឯ-ទៀតដោយក្លិននៃខ្លួន" ក. ក., កប្បតិ : រោគវិធំសនេ-សមត្ថេតី´តិ វា > កប្បូរោ[១] (ភេសជ្ជវិសេសោ) "ម្យ៉ាងទៀតថា (ភេសជ្ជវិសេស) អាចក្នុងកិរិយាកម្ចាត់នូវរោគ = កប៉ូរ" ក. ក. (កប្ប-ធាតុ) ។ វល្លិតព្វោ : ពន្ធិតព្វោ´តិ > វល្លូរោ (មំសវិសេសោ) "(សាច់ដ៏វិសេស) ដែលជនគប្បីចង = សាច់ងៀត" កម្ម. កម្ម. (វល្ល-ធាតុ) ។

នុ : វច្ឆំ-ធាយេតិ : បាយេតី´តិ > ធេនុ (គាវី) "(មេគោ) កំពុងញ៉ាំងកូនគោឲ្យបៅ" ក. ក. (ធេ-ធាតុ), ខីរំ-ទធាតី´តិ-វា > ធេនុ (គាវី) "ម្យ៉ាងទៀតថា (មេគោ) កំពុងទ្រទ្រង់នូវទឹកដោះ = មេគោមានទឹកដោះ[២]" ក. ក. (ធា-ធាតុ, ផ្លាស់ អា របស់ ធា ជា ឥ ហើយផ្លាស់ ឥ ជា ឯ) ។ ភោជនំ-ហនតិ : ហឹសតិ-ឯតាយា´តិ>ហនុ (សរីរាវយវជាតិ) "(សរីរាវយវជាតិ[៣])

---

១ កប្បូរ-សព្ទនេះ, ក្នុងកច្ចាយនបករណ៍ឧណាទិ ប្រើជាបុំលិង្គយ៉ាងនេះ, តែក្នុងបករណ៍ឯទៀត មានអភិធានប្បទីបិកាជាដើម ឃើញប្រើជានបុំសកលិង្គ ។ ២ មេគោដែលមានកូនតូចកំពុងបៅដោះនៅឡើយ ។ ៣ ជាតិ ចុះក្នុងសកត្ថ ។

សម្រាប់បៀតបៀននូវភោជន (នៃសត្វ) = ចង្កា″ ក. ករ. (ហន-ធាតុ, លុបទីបំផុតជាតុចេញ) ។

ណុ : បច្ច័យនេះ មានរូបដូចគ្នានឹង ណុ-បច្ច័យ ខាងដើម[១], ប៉ុន្តែមិនមែនជា ណានុពន្ធ ដូច្នោះទេ, ត្រូវទុកឲ្យគង់រូបនៅជា "ណុ″ ដូចដើម ។ ទុកជាតុឲ្យនៅតាមរូបដើមក៏បាន, លុបទីបំផុតជាតុក៏បាន, ព្រឹទ្ធិជាតុក៏បាន ឧ. ភាតិ : ទិប្បតី′តិ > ភាណុ[២] (ទេវបុត្តោ) "(ទេវបុត្ត) អ្នកភ្លឺ = ព្រះអាទិត្យ″ ក. ក. (ភា-ធាតុ) ។ ខនិតព្វោ′តិ > ខាណុ[៣] (ឆិន្នតរុក្ខន្ធោ) "(ដើមនៃឈើដាច់) ដែលជនគួរជីកចេញ = ដង្គត់″ កម្ម. កម្ម. (ខន-ធាតុ, លុបទីបំផុតជាតុ ហើយទីឃៈ អ របស់ ខ ជា អា) ។ វេតិ : ភមតិ, តត្ថ តត្ថ-បរិវត្តតី′តិ > វេណុ[៤] (ចុណ្ណោ) "(លម្អិត) វិលទៅក្នុងទីនោះៗ = លម្អង, ផង់″ ក. ក. (វិ-ធាតុ, ព្រឹទ្ធិ ឥ របស់ វិ ជា ឯ) ។

---

១ ណុ-បច្ច័យ ដែលបាននិយាយរួចមកហើយ ត្រង់ ការុ ។ ២ ក្នុងបករណៈខ្លះថា ចុះនុ-បច្ច័យ ជា ភានុ ក៏បាន ។ ៣ ខាណុ-សព្ទនេះ ជានាមនាម ទ្វិលិង្គិកៈ គឺ បុំ. និង នបុំ. ។ ៤ សព្ទនេះ ជានាមនាម ទ្វិលិង្គិកៈ គឺ បុំ. និង ឥ. ។

ឧស្ស : ការណាការណំ-មនតិ : ជានាតី៍តិ > មនុស្សោ[១] (សត្តវិសេសោ) (សត្តវិសេស) អ្នកដឹងនូវហេតុនិងមិនមែនហេតុ = មនុស្ស" ក. ក. (មន-ធាតុ) ។

នុស : អត្ថានត្ថំ-មនតិ : ជានាតី៍តិ > មានុសោ[២] (សត្ត-វិសេសោ) (សត្តវិសេស) អ្នកដឹងនូវអំពើជាប្រយោជន៍និងអំពើមិនមែនជាប្រយោជន៍ = មនុស្ស" ក. ក. (មន-ធាតុ, លុបទីបំផុតធាតុ ហើយទីឃៈ អ របស់ ម ជា អា) ។

ឥស : មាតាបិតូនំ-ហទយំ-បូរេតី៍តិ > បុរិសោ (ជនោ) "(ជន) អ្នកញុំាងហ្ឫទ័យនៃមាតានិងបិតាឲ្យពេញ" ក. ក., អត្តនោ-មនោរថំ-បុរេតី៍តិ > បុរិសោ (ជនោ) "ម្យ៉ាងទៀតថា

---

១ មនុស្ស-សព្ទនេះ, ក្នុងបករណ៍ខ្លះ ក្រៅពីកច្ចាយនៈ, លោក សម្តែងវិគ្គហៈផ្សេងៗគ្នាៈ ជួនណាលោកតាំងវិគ្គហៈជាបទសមាស ឧ. មនោ-ឧស្សោយស្ស-សោ > មនុស្សោ (សត្តវិសេសោ) "(សត្តវិសេស) មានចិត្តខ្ពស់" ឆដ្ឋីពហុព្វីហិសមាស, មនោ-ឧស្សោ : ឧស្សន្នោ-អស្សា៍តិ-វា > មនុស្សោ (សត្តវិសេសោ) "ម្យ៉ាងទៀតថា (សត្តវិសេស) មានចិត្តលូតលាស់" ឆដ្ឋីពហុព្វីហិសមាស, ជួនណា លោកតាំងវិគ្គហៈជាបទតទ្ធិត ឧ. មនុនោ-អបច្ចំ > មនុស្សោ (សត្ត- វិសេសោ) "(សត្តវិសេស) ជាពូជវង្សនៃប្រថមក្សត្រិយ៍ទ្រង់ព្រះនាម មនុ" គោត្តតទ្ធិត ចុះឧស្ស-បច្ច័យ ។ ន័យផ្សេងពីនេះក៏នៅមានទៅទៀត ។ ២ សព្ទនេះក្នុងបករណ៍ខ្លះតាំងវិគ្គហៈ ជាគោត្តតទ្ធិតចុះ ឧស-បច្ច័យ ឧ.មនុនោ-អបច្ចំ>មានុសោ (ទីឃៈ អ របស់ ម ជា អា)។

(ជន) អ្នកញ៉ាំងសេចក្ដីប្រាថ្នារបស់ខ្លួនឲ្យពេញ = ប្រុស" ក. ក. (បុរ-[១]ធាតុ) ។ សស្សុរសសុរេហិ-សុណិតញ្ញៈហឹសិតញ្ញា´តិ > សុ-ណិសា (ឥត្ថី) "(ស្រ្តី) ដែលម្ដាយក្មេកនិងឪពុកក្មេកគួរបៀតបៀនបាន = កូនប្រសាស្រី" កម្ម. កម្ម. (សុណ-ធាតុ[២], ផ្សំនឹងឥស-បច្ច័យជា សុណិស, ចុះអា-បច្ច័យមកផងជា សុណិសា)។

## បែបចង់វិគ្គហៈ

[១៨៥] កុលបុត្រអ្នកសិក្សា កាលបើបានរៀនគម្ពីរសម្ដែងនូវធាតុ តាំងពីអាខ្យាត, កិតកៈ, រៀងមកដល់ឧណាទិនេះហើយ គួរស្គាល់បែបចងវិគ្គហៈ សម្រាប់សម្ដែងនូវសាធនៈឲ្យជាក់ប្រាកដទើបនឹងអាចកម្ចាត់នូវសេចក្ដីសង្ស័យ ក្នុងដំណើរប្រែបាឡីបានដោយងាយ ហើយនឹងបានជាអ្នកឈ្លាសវៃក្នុងវិធីចងវិគ្គហៈផង កាលដែលប្រទះបទបាឡីនីមួយ ៗ បើបានស្គាល់

---

១ ក្នុងបករណៈខ្លះថាតាំង បុ-បុព្វបទ, វិស-ធាតុ "បៀតបៀន", ចុះអ-បច្ច័យ ឧ. បុំ. : និរយំ-វិសតិ : ហឹសតី´តិ > បុរិសោ (ជនោ) "(ជន) អ្នកបៀតបៀននូវនរក=ប្រុស" ក. ក. ។ ២ ក្នុងបករណៈខ្លះថាតាំងសុ-ធាតុ, ចុះ ណិស-បច្ច័យ និង អា-បច្ច័យ (សម្រាប់ឥត្ថីលិង្គ) មកផង ឧ. សស្សុរសសុរានំ-ឱវាទំ-សុណាតី´តិ > សុណិសា (ឥត្ថី) "(ស្រ្តី) អ្នកស្ដាប់នូវឱវាទនៃម្ដាយក្មេកនិងឪពុកក្មេក=កូនប្រសាស្រី" ក.ក.។

ធាតុនិងបច្ច័យដាក់ហើយ ក៏អាចនឹងចងវិគ្គហៈបាន (តាមដំណើរសេចក្តី) មិនញញើតញញើមទទាក់ទទាមឡើយ ។

បែបចងវិគ្គហៈសម្រាប់សម្តែងនូវសាធនៈនោះមាន ៤ យ៉ាងៈ

១- វិគ្គហៈដែលចងតាមលំនាំតួធាតុហៅថា "ធាតុវិគ្គហៈ" ឧ. សាសតី´តិ > សត្ថា ជាដើម ។

២- វិគ្គហៈដែលចងតាមសេចក្តី របស់ធាតុ ហៅថា "ធាត្វត្ថវិគ្គហៈ" ឧ. អនុសាសតី´តិ > សត្ថា ជាដើម ។

៣- វិគ្គហៈដែលចងអាស្រ័យអត្ថនៃធាតុ អនុលោមតាមតួធាតុ គឺខែជម្រាលពីធាតុខាងដើមផ្តួលពាក្យទៅរកធាតុខាងចុង ហើយកំណត់យកសេចក្តីតាមសព្ទធាតុខាងចុង, ប៉ុន្តែយកតួធាតុខាងដើមសម្រេចរូបជាបទនាមកិតកៈ, យ៉ាងនេះហៅថា "ធាតុធាត្វត្ថវិគ្គហៈ" ឧ. សាសតិ : សទេវកេ-លោកេ-អនុ-សាសតី´តិ > សត្ថា ជាដើម ។

៤- វិគ្គហៈ ដែលចងអធិប្បាយសេចក្តី ចេញផ្សេងពីតួធាតុ ហៅថា "អធិប្បាយត្ថវិគ្គហៈ" ឧ. ទេសេតី´តិ > សត្ថា ជាដើម ។

## សេចក្តីពន្យល់ដោយឡែក

[១៨៦] កច្ចាយនសូបត្ថម្ភកៈ តាំងពីនិទ្ទេសទី ១ រៀងមកដល់និទ្ទេសទី ៧ នេះ, មានសេចក្តីខ្លះសម្រាប់ទន្ទេញ, សេចក្តីខ្លះសម្រាប់គ្រាន់តែមើលឲ្យយល់, កាលបើកុលបុត្រអ្នកទើបរៀនដំបូង រៀបនឹងតាំងផ្តើមទន្ទេញឲ្យចាំមាត់នោះ, លុះតែសួរលោកអាចារ្យឲ្យដឹងថា "ត្រូវទន្ទេញពីត្រឹមណា ទៅដល់ត្រឹមណា?", ឬក៏ លុះតែលោកអាចារ្យស្រង់យកតែត្រង់សេចក្តីដែលត្រូវទន្ទេញឲ្យចាំមាត់នោះ សរសេរនឹងក្តារឈ្នួនធំ (តាប្លូ) ឲ្យអ្នករៀនចម្លង, យ៉ាងនេះទើបទន្ទេញបាន, បើមិនដូច្នោះទេ, អ្នករៀនចេះតែទន្ទេញទៅ តាមទំនើងចិត្តរបស់ខ្លួន ឬក៏តាមព្យាយាមមាំខំប្រឹងពុះពារទន្ទេញទាំងអស់ មិនឲ្យមានសល់, យ៉ាងនេះពុំប្រពៃឡើយ, ពីព្រោះត្រង់កន្លែងខ្លះ មានសេចក្តីសម្រាប់ទន្ទេញឲ្យចាំមាត់, កន្លែងខ្លះមិនបាច់ទន្ទេញ សម្រាប់គ្រាន់តែមើលសង្កេត ឲ្យមានផ្លូវយល់ប៉ុណ្ណោះ, បើអ្នករៀនដែលមានព្យាយាមដ៏មុតមាំ អាចខំប្រឹងជម្នះទន្ទេញឲ្យចាំមាត់ទាំងអស់មិនមានសល់ ក៏សឹងតែបាន, ប៉ុន្តែសេចក្តីព្យាយាមយ៉ាងនេះ

ជាហេតុនាំឲ្យនឿយពេក ហួសប្រមាណផង, នាំឲ្យខាតវេលា យឺតដំណើរការសិក្សាផង, ពុំនោះនឹងនាំឲ្យអោចិត្ត កើតសេចក្តីធុញទ្រាន់រវាតគំនិត រហូតដល់រសាយព្យាយាម ឈប់លែងរៀនតទៅទៀតផងក៏មាន ។

ព្រោះហេតុនោះ, បើអ្នករៀន បានប្រព្រឹត្តតាមសេចក្តីពន្យល់ខាងលើនេះ, មិនយូរប៉ុន្មានឡើយ, នឹងមានប្រាជ្ញាភ្លឺរុងរឿង អាចយល់ដំណើរភាសាបាឡីបណ្តើរៗ ឡើងតាមលំដាប់ ហើយនឹងរឹតតែមានសទ្ធាជ្រះថ្លា លូតលាស់ចម្រើន ជាប់ចិត្តស្រឡាញ់ការរៀនសូត្រ ខំប្រឹងស្រូតរូតទៅខាងមុខ មិនរួញរាថយក្រោយ, មុខជានឹងអាចឆ្លងបានដល់ត្រើយ គឺចំណេះខាងភាសាបាឡីជាប្រាកដពុំខាន ។

ឧណាទិនិទ្ទេស ទី ៧ ចប់ ដោយសង្ខេប ។

កច្ចាយនូបត្ថម្ភកៈ ចប់តែប៉ុណ្ណេះ ។

# រូបសិទ្ធិវិធាន

## រូបសិទ្ធិវិធាន

សណ្ដាប់ការរៀនបាឡីភាសា តាមគតិក្នុងកច្ចាយនបករណ៍, តែងមានរបៀប "រូបសិទ្ធិវិធាន" ឬ "រូបសិទ្ធិវិធី" គឺបែបសម្រេចរូបសព្ទបាឡី ដែលហៅថា "បែបតាំងតួ" តាមពាក្យមេសូត្រ ដែលត្រូវសូត្រហៅដល់, របៀបនេះមានជាយូរអង្វែងមកហើយរៀងដរាបមកដល់សព្វថ្ងៃនេះ ។ ព្រោះហេតុនោះ បានជាខ្ញុំរៀបរៀងបែបនេះ ទុកក្នុងប៉ែកខាងចុងនៃកច្ចាយនូបត្ថម្ភកៈនេះ ដោយគំនិតយល់ឃើញថា គង់នឹងមានប្រយោជន៍ដល់កុលបុត្រ ដែលមានសេចក្ដីត្រូវការខ្លះមិនខាន, ព្រមទាំងមានប្រយោជន៍នឹងរក្សាបែបនេះទុក ឲ្យបានឋិតថេរ ចីរកាលតទៅមុខផង ។ ប៉ុន្តែរូបសិទ្ធិវិធាននេះមិនរាប់បញ្ចូលជានិទ្ទេសក្នុងកច្ចាយនូបត្ថម្ភកៈទេ, ទុកជាបែបមួយដោយឡែក ផ្សេងអំពីនិទ្ទេសទាំង ៧ ខាងដើម ។

ក្នុងកាលដែលនឹងរៀបរៀងរូបសិទ្ធិវិធាននេះ ខ្ញុំបានយកបែបតាំងតួច្រើនច្បាប់ ព្រមទាំងយោជនាកច្ចាយនៈ មកពិនិត្យហើយជ្រើសរើស ផ្សំសម្រួលឲ្យមានរបៀបហូរហែ សមគួរដល់

ការប្រកប តាមសេចក្តីពេញចិត្តរបស់ខ្ញុំជាអ្នករៀបរៀង, ព្រោះបែបតាំងតួទាំងប៉ុន្មាន ដែលអស់លោកវេយ្យាករណបណ្ឌិតអំពីដើម បានរៀបរៀងមកហើយនោះ មានច្រើនយ៉ាង ផ្សេងៗ គ្នា (ខ្លះដូច្នេះ ខ្លះដូច្នោះ), ដោយហេតុលោករៀបរៀងតាមសេចក្តីពេញចិត្តរបស់លោក, ប៉ុន្តែបើទុកជាដូច្នោះ ក៏គង់តាំងតួកើតដូចគ្នា ។ ខ្ញុំរៀបរៀងសម្រួលឲ្យមានជា ២ បែប គឺ បែបមួយមានមេសូត្រ, បែបមួយឥតមេសូត្រ, បែបមានមេសូត្រ សម្រាប់កុលបុត្រអ្នករៀនកច្ចាយនបករណ៍ មានមេសូត្រជាគោល, បែបឥតមេសូត្រ សម្រាប់អ្នករៀនតាមរបៀបកច្ចាយនូបត្ថម្ភកៈ មានមេទន្ទេញជាគោល ។ រូបសិទ្ធិទាំង ២ បែបនោះ ដូចមានរបៀបតទៅនេះ ៖

## រូបសិទ្ធិក្នុងសន្ធិ

### បែបមានមេសូត្រ

(តត្រាយមាទិ), ជិនវចនយុត្តំ ហិ សូត្រនេះឈ្មោះអធិការសូត្រ, លិង្គញ្ច និបច្ចតេ ដោយ ច-សព្ទ អាចារ្យឲ្យតាំងបទ-

ច្ឆេទសន្ធិ, តត្រាយមាទិ ឲ្យតាំង តត្រ អយំ អាទិ[១], បទច្ឆេទោ រីកិរិយាកាត់នូវបទ ឥតិ ដូច្នេះ : តត្រ ជាបទ ១, អយំ ជាបទ ១, អាទិ ជាបទ ១ (លុះកាត់បទយ៉ាងនេះរួចហើយ ត្រូវប្រែ រួច សម្ពន្ធ) ។ សន្ធិវិធានំ វិធីនៃសន្ធិ មយា គឺខ្ញុំ កាតព្វំ ត្រូវធ្វើ ឯវំ យ៉ាងនេះ : (ដល់មកត្រង់នេះ, បើតាំងតួតាមបែបខ្លី, ត្រូវសូត្រហៅមេសូត្រសម្រេចរូបឲ្យបានជា តត្រាយមាទិ ទៅ, បើតាំងតួតាមបែបវែង ដើម្បីឲ្យអ្នករៀនស្គាល់អក្ខរវិធីតាមលំដាប់មេសូត្រនោះ, ត្រូវសូត្រមេសូត្រឲ្យឈ្មោះអក្ខរៈតាមរបៀបហូរហែ ដូច្នេះថា): អក្ខរាបាទយោ ឯកចត្តាឡីសំ..., តត្ថោទន្តា សរា អដ្ឋ..., លហុមត្តា តយោ រស្សា..., អញ្ញេ ទីឃា..., សេសា ព្យញ្ជនា..., វគ្គា បញ្ចបញ្ចសោ មន្តា..., អំ ឥតិ និគ្គហិតំ[២] បរសមញ្ញា បយោគេ[៣]... ។ រូបំ រីរូប "តត្រ អយំ អាទិ" ឥតិ

១ ដែលតាំងជាស្រៈពេញតួយ៉ាងនេះ ដើម្បីឲ្យច្បាស់លាស់ជាបែបសម្រាប់ទន្ទេញទេ, ឯសណ្ដាប់ដែលឲ្យអ្នករៀនតាំងនឹងក្តារឈ្នួននោះ ត្រូវតាំងជាស្រៈនិស្ស័យដូច្នេះ តត្រ យំ ា ទិ ។ ២ ក្នុងអភិធានប្បទីបិកាថា និគ្គហិតំ ។ ៣ ត្រូវឲ្យឈ្មោះអក្ខរៈតាមលំដាប់គ្រប់សូត្រ ។ បែបសូត្រមេសូត្រឲ្យឈ្មោះអក្ខរៈយ៉ាងនេះ ចំពោះតែអ្នករៀនដែលមិនទាន់ចេះអក្ខរវិធីនោះទេ, បើចេះស្ទាត់ហើយ កុំសូត្រនាំឲ្យយឺត ខាតវេលាឡើយ ។

ដូច្នេះ វត្តិតព្យញ្ជនំ ហៅថា វត្តិតព្យញ្ជនៈ[១] ។ (ដល់មកត្រង់នេះ ត្រូវសូត្រហៅមេសូត្រសម្រេចរូបថា) : បុព្វមជោ ។ល។ វិយោជយេ..., សរា សរេ លោបំ..., ទីឃំ..., នយេ បរំ យុត្តេ..., មទា សរេ..., បុព្វ ។ល។ នយេ បរំ យុត្តេ... (កើតបានជា តត្រាយមាទិ ហើយឲ្យឈ្មោះសន្ធិថា) : តត្រាយមាទិ ឈ្មោះ បរទីឃសន្ធិ និង និគ្គហិតាទេសសន្ធិ, រូបំ វិរូប "តត្រាយមាទិ" ឥតិ ដូច្នេះ សម្ពន្ធព្យញ្ជនំ ហៅថា សម្ពន្ធព្យញ្ជនៈ ។

បែបឥតមេសូត្រ

តត្រាយមាទិ កាត់បទជា តត្រ + អយំ + អាទិ, លុប អ របស់ ត្រ ហើយទីឃៈ អ របស់ អយំ ជា អា, ផ្លាស់និគ្គហិត របស់ យ ជា ម, តភ្ជាប់ជា តត្រាយមាទិ[២] "ឈ្មោះបរទីឃសន្ធិ

---

១ ជា វឌ្ឍិតព្យញ្ជនៈ ក៏បាន ។ ២ សរសេរយ៉ាងខ្លីក៏បាន, សរសេរកាត់បទ ដូច្នេះ: តត្រាយមាទិ < តត្រ + អយំ + អាទិ (មើលថា "តត្រាយមាទិ មកពី តត្រ + អយំ + អាទិ", ឬថា "តត្រាយមាទិ កាត់បទជា តត្រ + អយំ + អាទិ" ដូច្នេះក៏បាន) សរសេរតបទ ដូច្នេះ : តត្រ + អយំ + អាទិ > តត្រាយមាទិ (មើលថា "តត្រ + អយំ + អាទិ ទៅជា តត្រាយមាទិ", ឬថា "តត្រ + អយំ + អាទិ តភ្ជាប់ជា តត្រាយមាទិ" ដូច្នេះក៏បាន ។

(ព្រោះទីឃៈស្រៈខាងចុង) និង និគ្គហិតាទេសសន្ធិ (ព្រោះផ្លាស់និគ្គហិតជា ម)” ។

## រូបសិទ្ធិក្នុងនាម

### បែបមានមេសូត្រ

(ឯសោ នោ សត្ថា): ជិនវចនយុត្តំ ហិ សូត្រនេះឈ្មោះអធិការសូត្រ, លិង្គញ្ច និបច្ចតេ ដោយច-សព្ទ អាចារ្យឲ្យតាំងសទ្ទរូប, ឯសោ នោ សត្ថា ឲ្យតាំង ឯត អម្ហ សត្ថុ, សទ្ទរូបេនាកាលសទ្ទរូប មយា គឺខ្ញុំ ឋបិតេ តាំងរួចហើយ, វិភត្តិ វីភត្តិហោតិ ចុះ ឯវំ យ៉ាងនេះ : ឯត ចុះសិ-បឋមា, អម្ហ ចុះនំ-ឆដ្ឋី, សត្ថុ ចុះសិ-បឋមា (ជា : ឯត សិ អម្ហ នំ សត្ថុ សិ), ឯតតេ-សន្តោ..., បុព្វ ។ ល ។ វិយោជយេ..., សោ..., សរលោបោ ។ល។ តុ បកតិ..., ឬ សរា សរេ លោបំ..., បទតោ ទុតិយា-ចតុត្ថីសុ វោនោ..., សត្ថុបិតាទីនមា សិស្មឹ សិលោបោ ច... ... (កើតបានជា ឯសោ នោ សត្ថា, ត្រូវប្រែរួចសម្ពន្ធ ៗ រួចហើយកំណត់ឈ្មោះនាមសព្ទ, លិង្គ, វចនៈថា): ឯសោ ជាវិសេសន-

សព្វនាម, បុំលិង្គ, បឋមាឯកវចនៈ, នោ ជាបុរិសសព្វនាម ទ្វិលិង្គិកៈ គឺបុំលិង្គនិងឥត្ថីលិង្គ, ចតុត្ថី ឬ ឆដ្ឋីពហុវចនៈ, តែក្នុងទីនេះប្រើជាឆដ្ឋីពហុវចនៈ, សត្ថា ជាសាធារណនាមនាម, បុំលិង្គ, បឋមាឯកវចនៈ ។

រូបសិទ្ធិក្នុងនាមនេះ នៅមានវិធីប្លែកទៅទៀត ដូច្នេះ :

១- សិ-វិភត្តិ, បើចុះក្នុងអាលបនៈ, ត្រូវឲ្យឈ្មោះ "គ" ដោយមេសូត្រ អាលបនេ សិ គសញ្ញោ ។

២- បើនាមសព្ទជា អា-ការន្ត (ឥត្ថីលិង្គ) ដូចយ៉ាង កញ្ញា ជាដើម ត្រូវតាំងជា កញ្ញ ហើយចុះអា-បច្ច័យមក ដោយមេសូត្រ ឥត្ថិយមតោ អា-បច្ចយោ[១], អា-បច្ច័យនោះត្រូវឲ្យឈ្មោះ "ឃ" ដោយមេសូត្រ អាឃោ (ចូរមើលរូបសិទ្ធិក្នុងនាមនិទ្ទេស ត្រង់ អា-ការន្ត) ។

៣- បើនាមសព្ទជាឥ-ការន្ត, ឧ-ការន្ត បុំ. នបុំ. ឬជាឦ-ការន្ត, ឩ-ការន្ត បុំ. ត្រូវឲ្យ ឥ, ឦ ឈ្មោះ "ឈ", ឧ, ឩ ឈ្មោះ

---

១ មានបែបម្យ៉ាងថា គ្រប់បច្ច័យទាំងអស់, កាលដែលរៀបនឹងសូត្រមេសូត្រចុះមកនោះ, ត្រូវសូត្រមេសូត្រ ធាតុលិង្គេហិ បរា បច្ចយា (មេសូត្រអាខ្យាត) មុនសិនជាដរាប ។

"ល" ដោយមេសូត្រ ឥវណ្ណុវណ្ណា ឈលា, ត្រង់វិភត្តិ ទុ. ឯក., ត្រូវសូត្រនាំនិគ្គហិតទៅកាន់ "ឈ" ថា "និគ្គហិត ឈការំ នេតព្វំ", បើនាំទៅកាន់ "ល" ត្រូវសូត្រថា "និគ្គហិតំ លការំ នេតព្វំ" (ចូរមើលរូបសិទ្ធិក្នុងនាមនិទ្ទេស ត្រង់ ឥ, ឧ-ការន្ត បុំ. នបុំ. នឹង ឦ, ឩ-ការន្ត បុំ.) ។

៤-បើនាមសព្ទជា ឥ, ឦ, ឧ, ឩ-ការន្ត ឥត្ថីលិង្គ, ត្រូវឲ្យ ឥ, ឦ, ឧ, ឩ ឈ្មោះ "ប" ដោយមេសូត្រ តេ ឥត្ថីខ្យា បោ, ត្រង់វិភត្តិ ទុ ឯក., ត្រូវសូត្រនាំនិគ្គហិតទៅកាន់ "ប" ថា "និគ្គហិតំ បការំ នេតព្វំ" (ចូរមើលរូបសិទ្ធិក្នុងនាមនិទ្ទេសត្រង់ ឥ, ឦ, ឧ, ឩ-ការន្ត ឥត្ថីលិង្គ) ។

បែបឥតមេសូត្រ

ឯសោ ជោ សត្ថា តាំងជា ឯត អម្ហ សត្ថុ, ឯត ចុះ សិ-បឋមា, អម្ហ ចុះ នំ-ឆដ្ឋី, សត្ថា ចុះសិ-បឋមា (ជា: ឯត សិ អម្ហ នំ សត្ថុ សិ), ផ្លាស់ ត របស់ ឯត ជា ស, ផ្លាស់ សិ ជា ឱ ហើយលុប អ របស់ ស ចេញ, ផ្សំជា ឯសោ, ផ្លាស់ អម្ហ

និង នំ ជា នោ, ផ្លាស់ ឧ របស់ ត្ថុ ជា អា ហើយលុប សិ ចេញ ឬផ្លាស់ ឧ ព្រមទាំង សិ ជា អា ក៏បាន, ផ្សំជា សត្ថា[១] ។ (ដល់កើតបានជា ឯសោ នោ សត្ថា យ៉ាងនេះហើយ ត្រូវប្រែរួបសម្ពន្ធ ៗ រួចហើយត្រូវឲ្យឈ្មោះ នាមសព្ទ, លិង្គ, វចនៈ ដូចខាងបែបរូបសិទ្ធិមានមេសូត្រដែរ) ។

## រូបសិទ្ធិក្នុងសមាស

### បែបមានមេសូត្រ

[កឋិនទុស្សំ]ៈ ជិនវចនយុត្តំ ហិ សូត្រនេះឈ្មោះអធិការ-សូត្រ, លិង្គញ្ច និបច្ចតេ ដោយច-សព្ទ អាចារ្យឲ្យតាំងសទ្ទរូប, កឋិនទុស្សំ ឲ្យតាំង កឋិន ទុស្ស, សទ្ទរូបេ នាកាលសទ្ទរូបមយា គឺ ខ្ញុំ ឋបិតេ តាំងរួចហើយ, វិភត្តិ វិភត្តិ ហោតិ ចុះ ឯវំ យ៉ាងនេះ កឋិន ចុះ ស-ចតុត្ថី, ទុស្ស ចុះ សិ-បឋមា (ជាៈ កឋិន ស ទុស្ស សិ), សាគមោសេ..., បុព្វ ។ល។ វិយោជយេ...,

១ សរសេរយ៉ាងខ្លីក៏បាន, សរសេរដូច្នេះ : ឯសោ < ឯត + សិ:ឯត> ឯស, សិ > ឱ, នោ < អម្ហ + នំ: អម្ហ + នំ > នោ, សត្ថា < សត្ថុ + សិ: ឧ + សិ > អា (មើលថា "ឯសោ មកពី ឯត និង សិ, គឺ ឯត ទៅជា ឯស, សិ ទៅជា ឱ, នោ មកពី អម្ហ និង នំ, គឺ អម្ហ និងនំ ទៅជានោ, សត្ថា មកពី សត្ថុនិងសិ, គឺ ឧ និង សិ ទៅជា អា") ។

សឹ..., សរលោបោ ។ ល ។ តុ បកតិ..., ឬ សរា សរេ លោបំ... (កើតបានជា កឋិនស្ស ទុស្សំ, ត្រូវប្រែតាមដំណើរវិគ្គហៈរបស់សមាស : "កឋិនស្ស-ទុស្សំ > កឋិនទុស្សំ" នេះ រួចសម្ពន្ធ ។ រួចហើយត្រូវសូត្រវិធីតាំងតួតទៅទៀតថា) : តេសំ វិភត្តិយោ លោបា ច... (ត្រូវលុប ស្ស ទុកតែ កឋិន, លុប ំ ទុកតែ ទុស្ស) បកតិ ចស្ស សរន្តស្ស... "កឋិន ទុស្ស បកតិ ឲ្យនៅដូចដើមវិញ[១]", នាមានំ សមាសោ យុត្តត្ថោ... "កឋិន ទុស្ស ឈ្មោះសមាស", សមាសបទំ មយា សមាសិតព្វំ ខ្ញុំត្រូវបំប្រួញបទសមាសឲ្យរួមចូលជិតគ្នា (សូត្រយ៉ាងនេះរួចហើយ ត្រូវសរសេរបទទាំង ២ ឲ្យរួមចូលជិតគ្នាជា កឋិនទុស្ស), តទ្ធិតសមាសកិតកា នាមំ វា តវេតូនាទីសុ ច... "កឋិនទុស្ស ដាក់ចុះជា

---

១ តពីត្រង់នេះទៅ, បើមានសព្ទលើសដែលត្រូវលុបចេញ, ត្រូវសូត្រលុបសព្ទនោះថា "អតិរេកសទ្ទោ មយា លុត្តព្វោ ខ្ញុំត្រូវលុប សព្ទដែលលើសចេញ", បើមានសព្ទច្រើន ដូចយ៉ាងច-សព្ទក្នុង វិគ្គហៈ នៃ ទ្វន្ទសមាសជាដើម, ត្រូវសូត្រថា "អតិរេកសទ្ទា មយា លុត្តព្វា ខ្ញុំត្រូវលុបសព្ទដែលលើសទាំងឡាយចេញ" ឬសូត្រតាម បែបម្យ៉ាងទៀតថា "វុត្តត្ថានមប្បយោគោ សព្ទដែលមិនគួរប្រកប ត្រូវលុបចេញ" ដូច្នេះវិញក៏បាន, សូត្រយ៉ាងនេះរួចហើយ ត្រូវលុបសព្ទ ដែលលើស គឺសព្ទដែលមិនត្រូវនាំទៅប្រកបក្នុងបទសមាសនោះចេញ ។

សមាសនាម", នាមវិធានំ វិធីនៃនាម មយា គឺខ្ញុំ កាតព្វំ ត្រូវធ្វើ ឯវំ យ៉ាងនេះ : (ត្រូវចុះសិ-បឋមាមកឲ្យជា : កឋិនទុស្សសិ), បុព្វ ។ល។ វិយោជយេ..., សឹ..., សរលោបោ ។ល។ តុ បកតិ..., ឬ សរា សរេ លោបំ... (កើតបានជា កឋិនទុស្សំ) អមាទយោ បរបទេភិ... "កឋិនទុស្សំ ឈ្មោះចតុត្ថីតប្បុរិស-លុត្តសមាស", ឧត្តរបទប្បធានោ អយំ សមាសោ សមាសនេះ មានបទខាងចុងជាប្រធាន គឺមានប្រធាននៅខាងចុង ។

បែបផតមេសូត្រ

កាឋិនទុស្សំ តាំងជា កឋិន ទុស្ស, កឋិន ចុះស-ចតុត្ថី, ទុស្ស ចុះសិ-បឋមា (ជា : កឋិន ស ទុស្ស សិ), ចុះស-អាគមផ្សំនឹងស-វិភត្តិ ជា កឋិនស្ស, ផ្លាស់សិជា ំ ហើយលុប អ របស់ ស្ស នៃ ទុស្ស ចេញ ជា ទុស្សំ ។ លុបវិភត្តិគឺ ស្ស និង ំ ចេញធ្វើឲ្យទៅជា កឋិន ទុស្ស ដូចដើម គឺ ដូចកាលដែលតាំងនោះវិញ, បំប្រួញបទទាំង ២ ឲ្យរួមចូលជិតគ្នាជា កឋិនទុស្ស, ចុះសិ-បឋមា (ជា : កឋិនទុស្ស សិ) ហើយផ្លាស់ សិ ជា ំ រួចលុប

អ របស់ ស្ស នៃ ទុស្ស ចេញ ជា កឋិនទុស្ស[១] "ឈ្មោះ ចតុត្ថីតប្បុរិស-លុត្តសមាស" មានបទខាងចុងជាប្រធាន គឺ មានប្រធាននៅខាងចុង ។

## រូបសិទ្ធិក្នុងតទ្ធិត

បែបមានមេសូត្រ

[វាសិដ្ឋោ] : ជិនវចនយុត្តំ ហិ សូត្រនេះឈ្មោះអធិការសូត្រ លិង្គញ្ច និបច្ចតេ ដោយច-សព្ទ អាចារ្យឲ្យតាំងសទ្ទរូប, វាសិដ្ឋោ ឲ្យតាំងជា វសិដ្ឋ អបច្ច, សទ្ទរូបេ នាកាលសព្ទរូប, មយា គឺខ្ញុំ ឋបិតេ-តាំងរួចហើយ, វិភត្តិ វិភត្តិ ហោតិ ចុះ ឯវំ យ៉ាងនេះ : វសិដ្ឋ ចុះស-ឆដ្ឋី, អបច្ច ចុះសិ-បឋមា (ជា : វសិដ្ឋ ស អបច្ច សិ), សាគមោ សេ..., បុព្វ ។ល។ វិយោជយេ..., សឹ..., សរលោបោ ។ល។ តុ បកតិ..., ឬ សរា សរេ លោបំ... (កើត

១ សរសេរឲ្យខ្លីក៏បាន, សរសេរដូច្នេះ : កថិនទុស្សំ < កថិនស្ស + ទុស្សំ (មើលថា "កថិនទុស្សំ មកពី កថិនស្ស និង ទុស្សំ"), ឬថា : កថិនស្ស + ទុស្សំ > កថិនទុស្សំ (មើលថា "កថិនស្ស និង ទុស្សំ ទៅជា កថិនទុស្សំ" ដូច្នេះក៏បាន, ឬសរសេរថា : កថិនទុស្សំ = កថិន-ស្ស-ទុស្សំ (មើលថា "កថិនទុស្សំ ស្មើគ្នា ឬត្រូវគ្នានឹង កថិនស្ស-ទុស្សំ ដែរ ព្រោះប្រែដូចគ្នា មានសេចក្ដីប៉ុនគ្នា ផ្សេងគ្នាតែមួយជានាមសព្ទបទវាយ, មួយជាបទសមាសប៉ុណ្ណោះ) ដូច្នេះវិញក៏បាន ។

បានជា វសិដ្ឋស្ស អបច្ចំ, ត្រូវប្រែតាមដំណើរវិគ្គហៈរបស់តទ្ធិត : "វសិដ្ឋស្ស-អបច្ចំ > វាសិដ្ឋោ" នេះ រួចសម្ពន្ធ ៗ រួចហើយត្រូវសូត្រវិធីតាំងតួតទៅទៀតថា) : ជាតុលិង្គេហិ បរា បច្ចយា(១)..., វា ណបច្ចេ(២)... (ត្រូវចុះ ណ-បច្ច័យ ត្រង់ចន្លោះកណ្តាល ឲ្យជា : វសិដ្ឋស្ស ណ អបច្ចំ), តេសំ វិភត្តិយោ លោបា ច... (ត្រូវលុប ស្ស ទុកតែ វសិដ្ឋ, លុប ំ ទុកតែ អបច្ច), បកតិចស្ស សរន្តស្ស... "វសិដ្ឋ អបច្ច បកតិឲ្យនៅដូចដើមវិញ", អតិរេកសទ្ទោ មយា លុត្តព្វោ(៣) ខ្ញុំត្រូវលុបសព្ទដែលលើសចេញ (ត្រូវលុប "អបច្ច" ចេញ ទុកឲ្យសល់នៅតែ វសិដ្ឋ ណ), បុព្វ ។ល។ វិយោជយេ... (បុព្វ(៤)វ របស់ វសិដ្ឋ), រុទ្ធាទិសរស្ស វា អសំយោគន្តស្ស(៥) សណេ ច..., អាយុវណ្ណនញ្ញាយោវុទ្ធិ..., ឬ តេសុ

១ មិនបាច់សូត្រមេសូត្រនេះក៏បាន ។ ២ ក្នុងកច្ចាយនបករណ៍អក្សរមរម្មៈ (អក្សរភូមា) ថា "វា ណាបច្ចេ", ណាបច្ចេ និង ណាបច្ចេកាត់បទសន្ធិ ជា "ណា អបច្ចេ" បានដូចគ្នា, ប៉ុន្តែបែបតសន្ធិជា "ណាបច្ចេ" ល្អជាង ។ ៣ សូត្រថា "វត្តគ្គានមប្បយោគោ" ដូច្នេះវិញក៏បាន ។ ៤ ពាក្យមេសូត្រថា "បុព្វមធោ-បិតកមសរំ សរេន វិយោជយេ" ដកយកតែពាក្យថា "បុព្វ" មួយម៉ាត់នេះមកហៅ (តាមទម្លាប់) គឺលុបព្យញ្ជនៈបម្រាសចេញពីស្រៈ, ដូចក្នុងទីនេះ ត្រូវលុបតួ "វ" យកមកសរសេរខាងក្រោម ហើយសរសេរស្រៈ "ុ" ខាងលើ ត្រង់កន្លែងដែល "វ" នៅពីដើមនោះ ។ ៥ ក្នុងកច្ចាយនបករណ៍អក្សរមរម្មៈថា... វាសំយោគន្តស្ស... ។

វុទ្ធិលោបាគមវិការវិបរិតាទេសា ច... (ត្រូវព្រឹទ្ធិគឺទីឃៈ អ របស់ វ ជា អា), តេសំ ណោ លោបំ... (ត្រូវលុប ណ ទុកតែស្រៈ អ, ហើយលុប អ របស់ ដ្ឋ ចេញ, ផ្សំជា វាសិដ្ឋ), តទ្ធិតសមាស ។ល។ តវេត្តូនាទីសុ ច... "វាសិដ្ឋ ដាក់ចុះជា តទ្ធិតនាម", នាមវិធានំ វិធីនៃនាម មយា គឺខ្ញុំ កាតព្វំ ត្រូវធ្វើ ឯវំ យ៉ាងនេះ (ត្រូវចុះសិ-បឋមាមកឲ្យជា : វាសិដ្ឋ សិ), បុព្វ ។ល។ វិយោ-ជយេ..., សោ...., សរលោបោ ។ល។ តុ បកតិ..., ឬ សរា សរេ លោបំ... (កើតបានជា វាសិដ្ឋោ[១], រួចត្រូវឲ្យឈ្មោះតទ្ធិតថា "វាសិដ្ឋោ ឈ្មោះគោត្តតទ្ធិត[២]") ។

បែបឥតមេសូត្រ

វាសិដ្ឋោ តាំងជា វសិដ្ឋ អបច្ច, វសិដ្ឋ ចុះស-ឆដ្ឋី, អបច្ច ចុះសិ-បឋមា (ជា : វសិដ្ឋ ស អបច្ច សិ), ចុះស-អាគម ផ្សំនឹងស-វិភត្តិ ជា វសិដ្ឋស្ស, ផ្លាស់សិជា ំ ហើយលុប អ របស់ ច្ច នៃ អបច្ច ចេញ ជា អបច្ចំ, ចុះណ-បច្ច័យត្រង់ចន្លោះកណ្ដាល

---

១ បើឥត្ថីលិង្គ, ត្រូវចុះឦ-បច្ច័យមកផងជា "វាសិដ្ឋី" (ដោយមេសូត្រ នទាទតោ វា ឦ) រួចចុះ សិ-បឋមា មកហើយលុប សិ ចេញ, នបុំ-សកលិង្គ, ផ្លាស់ជា ំ ដោយមេសូត្រ "សឹ" ជា "វាសិដ្ឋំ" ។ ២ ឲ្យ ឈ្មោះថា "អបច្ចតទ្ធិត" តាមពាក្យក្នុងវិគ្គហៈក៏បាន ។

ឲ្យជា : វសិដ្ឋស្ស ណ អបច្ចំ, រួចលុបវិភត្តិគឺ ស្ស និង ំ ចេញ ធ្វើឲ្យទៅជា វសិដ្ឋ អបច្ច ដូចដើម គឺដូចកាលដែលតាំងនោះវិញ[១] ហើយលុប "អបច្ច" ចេញ ទុកឲ្យសល់នៅតែ វសិដ្ឋ និង ណ, ទីឃៈ អ របស់ វ នៃ វសិដ្ឋ ជា អា គឺធ្វើ "វ" ឲ្យជា "វា" ហើយលុប ណ ទុកតែស្រះ អ, រួចលុប អ របស់ ដ្ឋ ចេញ, ផ្សំជា វាសិដ្ឋ, ចុះសិ-បឋមា មក (ជា : វាសិដ្ឋ សិ), ផ្លាស់សិ ជា ឱ ហើយលុប អ របស់ ដ្ឋ ចេញ, ផ្សំជា វាសិដ្ឋោ[២] "ឈ្មោះគោត្តតទ្ធិត" ។

## រូបសិទ្ធិក្នុងអាខ្យាត

### បែបមានមេសូត្រ

[បឋតិ] : ជិនវចនយុត្តំ ហិ សូត្រនេះឈ្មោះអធិការសូត្រ លិង្គញ្ច និបច្ចតេ ដោយច-សព្ទ អាចារ្យឲ្យតាំងធាតុ, បឋតិ ឲ្យ

១ ទាំង ណ-បច្ច័យ ដែលចុះមកនោះផងជា វសិដ្ឋ ណ អបច្ច ។ ២ សរសេរបែបរូបសិទ្ធិយ៉ាងខ្លីក៏បាន, សរសេរដូច្នេះ : វាសិដ្ឋ < វសិដ្ឋ + ណ + អបច្ច (មើលថា "វាសិដ្ឋ មកពី វសិដ្ឋ + ណ + អបច្ច") ឬថា: វសិដ្ឋស្ស + (ណ) + អបច្ចំ > វាសិដ្ឋោ មើលថា "វសិដ្ឋស្ស + (ណ) + អបច្ចំ ទៅជា វាសិដ្ឋោ") ដូច្នេះក៏បាន, ឬសរសេរថា : វាសិដ្ឋោ = វសិដ្ឋស្ស-អបច្ចំ (មើលថា "វាសិដ្ឋោ ស្មើគ្នា ឬត្រូវគ្នា នឹង វសិដ្ឋស្ស អបច្ចំ ដែរ ព្រោះប្រែដូចគ្នា មានសេចក្តីប៉ុនគ្នា ផ្សេងគ្នាតែមួយជានាមសព្ទបទវាយ មួយជាបទតទ្ធិត ប៉ុណ្ណោះ") ដូច្នេះក៏បាន ។

តាំង បឋ[១]. ភូវាទយោ ធាតវោ... "បឋ ឈ្មោះធាតុ", អយំ ធាតុ រីធាតុនេះ "បឋ" ឥតិ គឺ បឋ វត្តតិ ប្រព្រឹត្តទៅ វាចាយំ ក្នុងសេចក្ដីថា "ពោល, និយាយ, ស្ដី" ។ ធាតុលិង្គេហិ បរា បច្ចយា..., ភូវាទិតោ អ... (ត្រូវចុះអ-បច្ច័យអំពីមុខ បឋ ជា : បឋ|), ធាតុបច្ចយេហិ វិភត្តិយោ..., វត្តមានា បច្ចុប្បន្នេ (ត្រូវចុះតិ-វត្តមានាវិភត្តិ ត្រង់ទីបំផុតបន្ទាប់អ-បច្ច័យ ជា : បឋ|តិ), វត្តមានា តិ អន្តិ ។ល។ ឯ ម្ហេ..., "តិ ឈ្មោះវត្តមានា-វិភត្តិ", អថ បុព្វានិ វិភត្តីនំ ឆ បរស្សបទានិ... "តិ ឈ្មោះបរស្សបទ", កត្តរិ បរស្សបទំ... "តិ-បរស្សបទចុះក្នុងកត្តុ", ទ្វេទ្វេបឋមមជ្ឈិ-មុត្តមបុរិសា... "តិឈ្មោះបឋមបុរិសៈ ឯកវចនៈ" ។ បុព្វ ។ល។ វិយោជយេ... (បុព្វ "ឋ"), ធាតុស្សន្តោ លោបោនេកសរស្ស..., នយេ បរំ យុត្តេ... (លុប អ របស់ ឋ[២] ហើយនាំ ឋ ទៅផ្សំនឹងអ-បច្ច័យ, កើតបានជា បឋតិ) ។

---

១ មើលថា "បឋ-ធាតុ" ដូច្នេះក៏បាន ។ ២ បើកំណត់រូបធាតុថា "ប័ឋ" ដូច្នេះ មិនមានវិធីឲ្យលុបស្រៈឡើយ, គ្រាន់តែផ្សំ ឋ ជាមួយ នឹង អ-បច្ច័យតែម្ដង ជាការស្រេច ។

បែបឥតមេសូត្រ

បថតិ តាំងជា បថ ប្រែថា "ពោល, ស្តី, និយាយ", (ជាពួកភូ-ធាតុ), ចុះអ-បច្ច័យ, តិ-វត្តមានាវិភត្តិ (គឺតាំងជាៈ បថ| តិ), សម្រេចរូប ជា បថតិ(១) ។ (បថតិ អាខ្យាតកិរិយា(២), បថ-ធាតុ, អ-បច្ច័យ, តិ-វត្តមានាវិភត្តិ, បរស្សបទ, បឋមបុរិសៈ, ឯក-វចនៈ, ជាពួកភូ-ធាតុ, ប្រាប់បច្ចុប្បន្នកាល, កត្តុវាចកៈ, ជាកិរិយារបស់នាមសព្ទដែលជា បឋមបុរិសៈ ឯកវចនៈ ដូចគ្នា, ដូចជា "សោ បថតិ, បុរិសោ បថតិ, ឥត្ថី បថតិ" ជាដើម) ។

បែបអញ្ញាសៈមានមេសូត្រ

[ពកូវ] : ជិនវចនយុត្តំ ហិ សូត្រនេះឈ្មោះអធិការសូត្រ, លិង្គញ្ច និបច្ចតេ ដោយច-សព្ទ អាចារ្យឲ្យតាំងធាតុ, ពកូវ ឲ្យតាំង ភូ, ភូវាទយោ ធាតវោ..." ភូ ឈ្មោះធាតុ", អយំ ធាតុ រី ធាតុនេះ "ភូ" ឥតិ គឺ ភូ វត្តតិ ប្រព្រឹត្តទៅ សត្តាយំ(៣) ក្នុងសេចក្តី

១ សរសេរ បែបរូបសិទ្ធិយ៉ាងខ្លីក៏បាន, សរសេរដូច្នេះ បថតិ < បថ + អ + តិ (មើលថា "បថតិ មកពី បថ-ធាតុ និងអ-បច្ច័យ និង តិ-វត្តមានាវិភត្តិ") ឬសរសេរថា : បថ + អ + តិ) បថតិ (មើលថា "បថ-ធាតុ + អ-បច្ច័យ + តិ-វត្តមានាវិភត្តិ ទៅជា បថតិ") ដូច្នេះក៏បាន ។ ២ ហៅថា "អាខ្យាតបទ" ក៏បាន ។ ៣ សត្តាយំ = វិជ្ជមានតាយំ (សត្តា ក្នុងទីនេះជាឥត្ថីលិង្គ, ប្រែថា "កើត, មាន, ជា" ដូចគ្នានឹង វិជ្ជមានតា) ។

"កើត, មាន, ជា" ។ ធាតុលិង្គេហិ បរា បច្ចយា.., ភូវាទិតោ អ... (ត្រូវចុះអ-បច្ច័យអំពីមុខភូ ជា: ភូ|), ធាតុបច្ចយេហិ វិភត្តិយោ..., អបច្ចក្ខេ បរោក្ខាតីតេ...(ត្រូវចុះអ-បរោក្ខាវិភត្តិត្រង់ទីបំផុតបន្ទាប់អ-បច្ច័យជា: ភូ||), បរោក្ខា អ ឧ ។ ល ។ តំ ម្ហេ..."អ ឈ្មោះបរោក្ខាវិភត្តិ", អថ បុព្វានិ ។ ល ។ បរស្សបទានិ.."អ ឈ្មោះបរស្សបទ", កត្តរិបរស្សបទំ..."អ បរស្សបទចុះក្នុងកត្តុ", ទ្វេទ្វេ ។ ល ។ បុរិសា "អឈ្មោះបឋមបុរិសៈឯកវចនៈ" ។ ក្វចាទិវណ្ណានមេកសរានំ ទ្វេភាវោ...(សរសេភូ មួយតួមកទៀតត្រង់ខាងដើមឲ្យជា: ភូ-ភូ||), បុព្វោព្ភាសោ..."ភូ ខាងដើមឈ្មោះអព្ភាសៈ, ទុតិយចតុត្ថានំ បឋមតតិយា...(ផ្លាស់ភ-អព្ភាសៈជា "ព"), បុព្វ ។ ល ។ វិយោជយេ..., អន្តស្សិវណ្ណាការោ វា... (ផ្លាស់ ឩរបស់ អព្ភាសៈជាអ) , ព្រូភូនមាហភូវា បរោក្ខាយំ... (ផ្លាស់ ភូ-ធាតុទាំងមូលជាភូវ), លោបញ្ចេត្តមការោ...(លុបអ-បច្ច័យចេញ), បុព្វ ។ ល ។ វិយោជយេ..., នយេ បរំ យុត្តេ...(លុបអ របស់ វ ហើយនាំ វ ទៅផ្សំនឹងអ បរោក្ខាវិភត្តិ, (កើតបានជា ពភូវ) ។

បែបអញ្ញាសៈឥតមេសូត្រ

ពភូវ តាំងជា ភូ ប្រែថា "កើត, មាន, ជា-", ចុះអ-បច្ច័យ, អ-បរោក្ខាវិភត្តិ, អញ្ញាសៈជា ភូ-ភូ+អ+អ, (ភូ ខាងដើមឈ្មោះអញ្ញាសៈ), ផ្លាស់ភ-អញ្ញាសៈជា "ព", ផ្លាស់ ឱ របស់អញ្ញាសៈ ជា អ ផ្លាស់ ភូ-ធាតុទាំងមូលជា ភូវ, លុបអ-បច្ច័យចេញ, ផ្សំជា ពភូវ[១]... ... ។

## រូបសិទ្ធិក្នុងកិតកៈ

បែបមានមេសូត្រ

[កម្មការោ] : ជិនវចនយុត្តំ ហិ សូត្រនេះឈ្មោះអធិការ-សូត្រ, លិង្គញ្ច និបច្ចតេ ដោយច-សព្ទ អាចារ្យឲ្យតាំងធាតុ, កម្មការោ ឲ្យតាំង កម្ម ករ ឥតិ[២], ភូវាទយោ ធាតវោ... "ករ ឈ្មោះធាតុ", អយំ ធាតុ រីធាតុនេះ "ករ" ឥតិ គឺ ករ កម្ម-សទ្ទុ-បបទោ មាន កម្ម ជាសទ្ទុបបទ វត្តតិ ប្រព្រឹត្តទៅ ករណោ ក្នុង

---

១ បែបរូបសិទ្ធិយ៉ាងខ្លី សរសេរដូច្នេះ : ពភូវ > ភូ-ភូ + អ+អ, ភ-អញ្ញាសៈ > ព, ឱ អញ្ញាសៈ > អ, ភូ-ធាតុ > ភូវ, លុបអ-បច្ច័យ ។ ២ មើលថា កម្ម-សទ្ទុបបទ, ករ-ធាតុ, ឥតិ-និបាតសព្ទ ។

សេចក្តីថា "ធ្វើ" ។ (ដល់មកត្រង់នេះត្រូវសម្រេចរូបតាមវិធីរូបសិទ្ធិនៃនាមនិងអាខ្យាត ឲ្យកើតបានជា "កម្មំ-ករោតិ-ឥតិ[១]" ហើយត្រូវសូត្រមេសូត្រលុបវិភត្តិ, បច្ច័យ និងសព្ទដែលលើសចេញដូចវិធីក្នុងសមាស តទ្ធិត, រួច បកតិ ទុកឲ្យនៅត្រឹម "កម្ម ករ" ដូចដើមវិញ, ហើយសូត្រទៅទៀតថា) ធាតុលិង្គេហិ បរា បច្ចយា..., ធាតុយា កម្មាទិម្ហិណោ... (ចុះណ-បច្ច័យអំពីមុខ ករ ឲ្យជា : កម្ម ករ ណ), បុព្វ ។ល។ វិយោជយេ... (បុព្វ) "ក" របស់ ករ, រួចសូត្រមេសូត្រព្រឹទ្ធិ គឺទីឃៈ អ របស់ ក ជា អា, ហើយសូត្រមេសូត្រលុប ណ-បច្ច័យទុកតែស្រៈ អ, កើតបានជា "កម្មការ អ", លុប អ របស់ រ ហើយនាំ រ ទៅផ្សំនឹងស្រៈរបស់បច្ច័យជា "កម្មការ", រួចសូត្រមេសូត្រដាក់ចុះជាកិតនាម, ចុះ សិ (វិភត្តិ), ផ្លាស់ សិ ជា ឱ, សម្រេចរូបជា កម្មការោ "ឈ្មោះកត្តុរូប-កត្តុសាធនៈ" ។

១ កម្មចុះ º វិភត្តិ,ករ ចុះឱ-បច្ច័យ តិ-វត្តមានាវិភត្តិ,ឥតិនិបាតសព្ទ ,ជាហេតុវាចកៈជាអព្យយសព្ទមិនត្រូវចុះវិភត្តិឡើយ, សម្រេច រូបតាមវិធីរូបសិទ្ធិនៃនាមនិងអាខ្យាត ឲ្យកើតបានជា "កម្មំ ករោតិ ឥតិ", ប៉ុន្តែបើសរសេរជាវិគ្គហៈសម្រេច, ត្រូវប្រើវិធីសន្ធិជា "កម្មំ ករោតី' តិ > កម្មការោ" ។

-៩-

## បែបឥតមេសូត្រ

កម្មការោ តាំងជា កម្ម-សទ្ទុបបទ, ករ-ធាតុ ឥតិ និបាតសព្ទ (កម្ម ករ ឥតិ), កម្ម ចុះ ំ វិភត្តិ, ករ ចុះឱ-បច្ច័យ (អាខ្យាត) តិ-វត្តមានាវិភត្តិ, ឥតិ មិនចុះវិភត្តិទេ ព្រោះជាអព្យយសព្ទ, សម្រេចរូបជា “កម្មំ ករោតិ ឥតិ”, ប្រើតាមវិធីសន្ធិជា “កម្មំ-ករោតី´តិ”, លុបទុកត្រឹមតែ “កម្ម ករ”, ចុះណ-បច្ច័យ (ក្នុងកិតកៈ) អំពីមុខ ករ ជា “កម្មករ ណ”, (ព្រោះអំណាចណ-បច្ច័យជាណានុពន្ធៈ) ត្រូវទីឃៈ អ របស់ ក នៃ ករ ជា អា, លុបណ-បច្ច័យទុកតែស្រៈ អ, ផ្សំជា កម្មការ, ចុះ សិ (វិភត្តិនាម) ហើយផ្លាស់ សិ ជា ឱ, សម្រេចរូបជា កម្មការោ “ឈ្មោះកត្តុរូប-កត្តុសាធនៈ” ។

រូបសិទ្ធិវិធាន ចប់ តែប៉ុណ្ណោះ ។

ចប់

# រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

# គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅធម៌ដែលជាស្នាដៃចាស់ៗ របស់អ្នកនិពន្ធជំនាន់មុនគឺអាស្រ័យ ដោយការមើលឃើញ នូវកត្តាចាំបាច់មួយចំនួន ដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ
ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន
សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៨៨៧ ៩៦១ ៩២៩
អ៊ីមែល: maha.panna@gmail.com
គេហទំព័រ: http://www.mahapanna.org

## Taking Refuge with a mind of Bodhichitta

**In the Buddha, the Dharma and the Sangha,**
**I shall always take refuge**
**Until the attainment of full awakening.**

**Through the merit of practicing generosity**
**and other perfections,**
**May I swiftly accomplish Buddhahood,**
**And benefit of all sentient beings.**

## The Prayers of the Bodhisattvas

**With a wish to awaken all beings,**
**I shall always go for refuge**
**To the Buddha, Dharma, and Sangha,**
**Until I attain full enlightenment.**

**Possessing compassion and wisdom,**
**Today, in the Buddha's presence,**
**I sincerely generate**
**the supreme mind of Bodhichitta**
**For the benefit of all sentient beings.**

"As long as space endures,
As long as sentient beings dwell,
Until then, may I too remain
To dispel the miseries of all sentient beings."

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**＊ The Vows of Samantabhadra ＊**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**＊ The Vows of Samantabhadra Avatamsaka Sutra ＊**

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

# NAME OF SPONSOR
## 助 印 功 德 芳 名

**Book's Title: Tool to support Kaccāyana Vol. 2**

**書 名：柬埔寨巴利文：Tool to support Kaccāyana Vol. 2，**

**巴利文文法工具書 第二冊**

**Book Serial No., 書 號：CA045**

N.T. Dollars：

**119,852：AMITABHA BUDDHIST SOCIETY OF USA**

美國淨宗學會

**Amount： N.T. Dollars 119,852；Print 5,000 copies**

**以上合計：新台幣 119,852 元；恭印伍千冊。**

**Dedication of Merits:**

Wherever the Buddha's teachings have flourished, either in cities or countrysides,
People would gain inconceivable benefits.
The land and people would be enveloped in peace.
The sun and moon will shine clear and bright.
Wind and rain would appear accordingly, and there will be no disasters.
Nations would be prosperous and there would be no use for soldiers or weapons.
People would abide by morality and accord with laws.
They would be courteous and humble, and everyone would be content without injustices.
There would be no thefts or violence.
The strong would not dominate the weak and everyone would get their fair share.

**回向：**天下和順，日月清明，風雨以時，災厲不起，國豐民安，兵戈無用，
崇德興仁，務修禮讓，國無盜賊，無有怨枉，強不凌弱，各得其所。
法界一切有情，所有六道四生，宿世冤親，現世業債，咸憑法力，悉得解脫。
現世者增福延壽，發菩提心，常隨佛學，勤修精進，利濟群生。
已故者往生淨土，同出苦輪，共登覺岸，直證阿鞞跋致，圓滿無上菩提。

**附記：**本會接受善信發心印贈經書，其必要之費用，皆經本會審慎評估；
若有結餘，均續作本會之印(購)經書及運費使用，為施主廣積陰德。

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《東埔寨巴利文：Tool to support Kaccāyana Vol. 2，
巴利文文法工具書 第二冊》

財團法人佛陀教育基金會 印贈
台北市杭州南路一段五十五號十一樓
Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

Printed in Taiwan
5,000 copies; March 2015
CA045 - 13026